ក្រសួងអប់រំ យុវជន និងកីឡា

# របាយការណ៍ស្រាវជ្រាវ ស្តីពី
# ការសិក្សាលើអត្រាបញ្ចប់ការសិក្សាទាបនៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ

"The Study on the Low Completion Rate in Primary and Lower Secondary Education"



ហំ គន្ធា
កង សុផាន់ណា

នាយកដ្ឋានគោលនយោបាយ
មិថុនា ២០១៩

ក្រសួងអប់រំ យុវជន និងកីឡា

# របាយការណ៍ស្រាវជ្រាវ

## ស្តីពី

# ការសិក្សាលើអត្រាបញ្ចប់ការសិក្សាទាបនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ

"The Study on the Low Completion Rate in Primary and Lower Secondary Education"

ហាំ គន្ធា
កង សុផាន់ណា

នាយកដ្ឋានគោលនយោបាយ
មិថុនា ២០១៩

# មាតិកា


ជំពូក ១៖ សេចក្តីផ្តើម ..................................................... 1

១.១ សាវតារ ..................................................... 1

១.២ ហេតុផលនៃការសិក្សា ..................................................... 2

១.៣ គោលបំណងនៃការសិក្សា ..................................................... 3

១.៤ សំណួរស្រាវជ្រាវ ..................................................... 4

១.៥ សារសំខាន់នៃការសិក្សា ..................................................... 4

ជំពូក ២៖ ការរំលឹកទ្រឹស្តី ..................................................... 5

២.១ ការប្រើប្រាស់សូចនាករអប់រំ ..................................................... 5

២.២ ការកំណត់និយមន័យ និងការប្រើប្រាស់អត្រាបញ្ចប់ការសិក្សា ..................................................... 6

២.៣ សន្ទស្សន៍យុគភាពយេនឌ័រ ..................................................... 8

២.៤ មូលហេតុដែលធ្វើឱ្យអត្រាបញ្ចប់ការសិក្សាមានកម្រិតទាប ..................................................... 9

២.៥ យុទ្ធសាស្រ្តបង្កើនអត្រាបញ្ចប់ការសិក្សា ..................................................... 12

ជំពូក ៣៖ ការរចនានិងវិធីសាស្រ្តនៃការសិក្សា ..................................................... 14

៣.១ វិសាលភាពនិងដែនកំណត់នៃការសិក្សា ..................................................... 14

៣.២ ប្រភេទអ្នកចូលរួមនៃការសិក្សា ..................................................... 14

៣.៣ ឧបករណ៍នៃការស្រាវជ្រាវ ..................................................... 14

៣.៤ ការប្រមូល ការបញ្ចូល និងការវិភាគទិន្នន័យ ..................................................... 15

៣.៥ ក្របខណ្ឌនៃការស្រាវជ្រាវ ..................................................... 15

៣.៦ ការរៀបចំឧបករណ៍ស្រាវជ្រាវ ..................................................... 16

ជំពូក ៤៖ របកគំហើញ ..................................................... 17

៤.១ របកគំហើញនៃការសិក្សា ..................................................... 17

៤.១.១ បម្រែបម្រួលចំនួនប្រជាជន ..................................................... 17

៤.១.២ របៀបគណនាអត្រាបញ្ចប់ការសិក្សា ..................................................... 25

៤.១.៣ សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សា ........ 32
៤.១.៤ វិធានការបង្កើនការចូលរៀន ........ 37
៤.២ ទស្សនៈទូទៅនិងបញ្ហាប្រឈមនៃអត្រាបញ្ចប់ការសិក្សា ........ 53
៤.២.១ ការពេញចិត្តលើអត្រាបញ្ចប់ការសិក្សា ........ 53
៤.២.២ បញ្ហាប្រឈមលើការបំពេញភារកិច្ច ........ 54
៤.២.៣ សំណូមពររបស់អ្នកចូលរួមពីអត្រាបញ្ចប់ការសិក្សា ........ 56

**ជំពូក ៥៖ ការពិភាក្សា** ........ 59
៥.១ ការពិភាក្សារបកគំហើញនៃការសិក្សា ........ 59
៥.១.១ បម្រែបម្រួលប្រជាជន ........ 59
៥.១.២ ការគណនាអត្រាបញ្ចប់ការសិក្សា ........ 61
៥.១.៣ ការប្រៀបធៀបអត្រាបញ្ចប់ការសិក្សា ........ 61
៥.១.៤ បញ្ហាប្រឈមនៃការប្រមូលទិន្នន័យ ........ 63
៥.១.៥ បុព្វហេតុនាំឱ្យអត្រាបញ្ចប់ការសិក្សាទាប ........ 64
៥.១.៦ អត្រាបញ្ចប់ការសិក្សារវាងសិស្សស្រីនិងសិស្សប្រុស ........ 68
៥.១.៧ វិធានការបង្កើនអត្រាបញ្ចប់ការសិក្សា ........ 69
៥.១.៨ បញ្ហាប្រឈមនៃអត្រាបញ្ចប់ការសិក្សា ........ 69
៥.១.៩ ការពេញចិត្តនឹងអត្រាបញ្ចប់ការសិក្សា ........ 71

**ជំពូក ៦៖ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍** ........ 72
៦.១ សេចក្ដីសន្និដ្ឋាន ........ 72
៦.១.១ បម្រែបម្រួលកុមារដល់វ័យសិក្សា (ប្រជាជន) ........ 72
៦.២.១ បម្រែបម្រួលប្រជាជន ........ 75
៦.២.២ បម្រែបម្រួលសិស្ស ........ 76
៦.២.៣ សន្ទស្សន៍យុគភាពយេនឌ័រក្នុងអត្រាបញ្ចប់ការសិក្សា ........ 76
៦.២.៤ អន្តរាគមន៍លើអត្រាបញ្ចប់ការសិក្សា ........ 76

**ឯកសារយោង** ........ 78

# មូលន័យសង្ខេប

អត្រាសិស្សបញ្ចប់ការសិក្សានៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិមានសារសំខាន់បំផុតនៅក្នុងវិស័យអប់រំ ដើម្បីឆ្លើយតបទៅនឹងច្បាប់ស្តីពីការអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា "សិស្សគ្រប់រូបត្រូវបញ្ចប់ការសិក្សាថ្នាក់មូលដ្ឋាន" ប៉ុន្តែលទ្ធផលនៃការបញ្ចប់ការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ នៅតាមតំបន់មួយចំនួនមិនទាន់សម្រេចតាមសូចនាករគោលដៅនៅឡើយដោយសារបញ្ហាចំណាកស្រុក ការបោះបង់ការសិក្សា ការរៀបអាពាហ៍ពិពាហ៍ ភាពក្រីក្រ ការបួសជាសង្ឃ ការផ្លាស់ប្តូរទីលំនៅ ការធ្វើចំណាកស្រុកទាំងក្នុងនិងក្រៅប្រទេសរបស់មាតាបិតា ការមិនយកចិត្តទុកដាក់លើការអប់រំជាដើម។ល។

ការសិក្សានេះ គឺដើម្បីឈ្វេងយល់ពីការប្រែប្រួលនៃចំនួនប្រជាជននិងសិស្សក្នុងតំបន់គោលដៅ យុគភាពយេនឌ័រក្នុងអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ និងកំណត់អន្តរាគមន៍ជាក់លាក់ដើម្បីដោះស្រាយបញ្ហាបញ្ចប់ការសិក្សាទាប។ ការសិក្សាស្រាវជ្រាវនេះ គ្របដណ្តប់១២ខេត្ត ៣៦ក្រុងស្រុក និង១៩៩សាលាដែលមានអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិទាបជាង៥០% និងបឋមសិក្សាទាបជាង៨០% ហើយមានអ្នកចូលរួមសរុប១២០០នាក់ រួមមានមន្ទីរអយក. ការិយាល័យអយក. អាជ្ញាធរស្រុក ឃុំសង្កាត់ នាយកសាលា លោកគ្រូអ្នកគ្រូ ឪពុកម្តាយសិស្សមានកូនរៀនថ្នាក់ទី៦និង៩ និងឪពុកម្តាយសិស្សដែលមានកូនអាយុ១៣-២០ឆ្នាំ។ យោងតាមរបកគំហើញនិងការវិភាគស៊ីជម្រៅនៃការសិក្សា ក្រុមសិក្សាជ្រាវជ្រាវ ធ្វើការសន្និដ្ឋានពីកត្តានាំឱ្យអត្រាបញ្ចប់ការសិក្សាទាបនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិដូចខាងក្រោម៖

កត្តាសិស្សក្រីក្រ ចំណាកស្រុក សិស្សបោះបង់ការសិក្សាច្រើន ការត្រួតថ្នាក់ និងចូលរៀនលើសអាយុ សិស្សជនជាតិភាគតិច សិស្សពិការភាពគឺជាបុព្វហេតុនាំឱ្យមានអត្រាបញ្ចប់ការសិក្សាទាប ដែលក្នុងនោះក៏អាចមកពីកត្តាផ្សេងៗ ដូចជាកត្តាសិស្សឬខ្លួនឯង ស្ថិតិ រចនាសម្ព័ន្ធគ្រូ ឪពុកម្តាយជាដើម។ល។

កត្តាទីតាំងភូមិសាស្រ្ត គឺសាលាមួយចំនួនស្ថិតនៅក្នុងតំបន់ជួបការលំបាក ដូចជាតំបន់ភ្នំ តំបន់កោះ គ្មានផ្លូវគមនាគមន៍ (ភក់ បឹងបួ)ដែលជាហេតុធ្វើឱ្យសិស្សពិបាកធ្វើដំណើរទៅមកសាលានាំឱ្យអវត្តមានញឹកញាប់ ឬបោះបង់ការសិក្សា ហើយកង្វះមធ្យោបាយធ្វើដំណើររឹតតែជាបញ្ហាប្រឈមទៅនឹងការបោះបង់ការសិក្សា។

កត្តាវប្បធម៌ ជាបញ្ហាមួយក្នុងចំណោមបញ្ហាប្រឈមនានាដែលនាំឱ្យអត្រាបញ្ចប់ការសិក្សាទាប ផងដែរ ដូចជាជនជាតិភាគតិចនៅតែយកបញ្ហាវប្បធម៌ជាធំ ឆាប់ឱ្យកូនរៀបការនៅវ័យក្មេង ឱ្យតែកូនស្រីឬកូនប្រុសរៀនសូត្រ ឱ្យតម្លៃនៃការសិក្សាទាបសម្រាប់កូនស្រីជាដើម ហើយដោយសារតែឱ្យតម្លៃនៃការសិក្សាទាបនេះហើយ ជាហេតុធ្វើឱ្យគាត់កៀរគរកម្លាំងកូនជួយការងារផ្ទះដើម្បីដោះស្រាយបញ្ហាជីវភាព។

កត្តាស្ថិតិ រវាងទិន្នន័យចំណោលរបស់វិទ្យាស្ថានជាតិស្ថិតិ (NIS) ធៀបនឹងទិន្នន័យចំណោល គឺទិន្នន័យចំណោលខ្ពស់ជាងទិន្នន័យប្រជាជនជាក់ស្តែងស្ទើរតែគ្រប់ស្រុកទាំងអស់ ជាពិសេស ខ្ពស់ជាងទិន្នន័យនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) ដែលស្រុកខ្លះមានភាពខុសគ្នាខ្លាំង។

កត្តាបម្រែបម្រួលសិស្ស អត្រាបញ្ចប់ការសិក្សាជាក់ស្តែងនៅថ្នាក់ការិយាល័យអយក. ភាគច្រើនលើសលុបមានអត្រាបញ្ចប់ការសិក្សាច្រើនជាងអត្រាបញ្ចប់ការសិក្សា នៃទិន្នន័យផ្តល់ដោយ EMIS ដែលក្នុងនោះមានតែស្រុកមួយចំនួនតូចតែប៉ុណ្ណោះ ដែលអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាទាបជាងទិន្នន័យពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ។

កត្តាគ្រួសារ មកពីគ្រួសារមួយចំនួនមិនសូវជួយជំរុញកូន ឬជំរុញតែកូនស្រីឬតែកូនប្រុស ឬគាត់មិនសូវយល់ដឹងពីតម្លៃនៃការអប់រំ ហើយគ្រួសារខ្លះទៀតមិនចង់ឱ្យកូននៅឆ្ងាយពីផ្ទះ ព្រោះកូនគាត់មិនមានសុវត្ថិភាព ជាពិសេសកូនស្រី។ ឪពុកម្តាយខ្លះមិនចេះអក្សរ មិនបានគិតវែងឆ្ងាយ មានជីវភាពក្រីក្រលំបាក ដែលគាត់មិនបានគិតឬចេះគិតគូរឱ្យបានវែងឆ្ងាយអំពីអនាគតរបស់កូនដែលជាហេតុនាំឱ្យគាត់ឱ្យកូនឈប់រៀនឬបោះបង់ការសិក្សា។

កត្តាទំនៀមទម្លាប់ប្រពៃណី គ្រួសារខ្លះយកប្រពៃណីជាធំដោយគាត់គិតថាកូនស្រី ត្រូវរៀបការនៅវ័យក្មេងជាងកូនប្រុស កូនស្រីមិនចាំបាច់រៀនខ្ពស់ ហើយឱ្យតម្លៃនៃការសិក្សាតែទៅលើកូនប្រុស ដោយកូនប្រុសអាចរៀនឬធ្វើការនៅឆ្ងាយពីផ្ទះ ចំណែកកូនស្រីត្រូវនៅជួយកិច្ចការផ្ទះ ជួយថែទាំឪពុកម្តាយដែលកូនស្រីទទួលបន្ទុកការងារផ្ទះច្រើនជាងកូនប្រុស។

កត្តាសង្គម ការអូសទាញពីបរិយាកាសខាងក្នុងនិងខាងក្រៅសាលាដែលធ្វើឱ្យសិស្សមួយចំនួនបោះបង់ការសិក្សាទាំងវ័យក្មេង ជាពិសេសសិស្សប្រុស ដូចជា ការសេពគ្រឿងញៀន ការសេពគប់មិត្តភក្តិ សម្ភារនិយមជាដើម។

អត្រាស្ថិតិ អត្រាបញ្ចប់ការសិក្សានៅពេលបច្ចុប្បន្នគឺគណនាតែលើស្ថិតិសិស្សដែលរៀន

នៅសាលារដ្ឋ មិនបានបូកបញ្ចូលសិស្សរៀននៅសាលាឯកជនទេ។ ចំពោះសិស្ស គាត់ផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយ ឬពីសាលាមួយទៅសាលាមួយ។ លើសពីនេះទៀតសាលាមិនគ្រប់កម្រិតនៅបឋមសិក្សានៅតែមានច្រើននៅឡើយ។

ដើម្បីបង្កើនអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធក្នុងវិស័យអប់រំគួរបង្កើននិងពង្រឹងអាហារូបករណ៍ដល់សិស្សឱ្យបានច្រើននិងទាន់ពេលវេលា ព្រមទាំង បំប៉នសមត្ថភាពដល់មន្ត្រីបច្ចេកទេសនៅថ្នាក់មន្ទីរ អយក. ការិយាល័យអយក. និងសាលារៀនលើការងារគ្រប់គ្រងទិន្នន័យ និងបណ្តុះបណ្តាលនាយកសាលាអំពីការប្រើប្រាស់កុំព្យូទ័រមូលដ្ឋាននិងភាពជាអ្នកគ្រប់គ្រង ដឹកនាំ និងការធ្វើផែនការសាលារៀន(នាយកថ្មី)។ លើសពីនេះទៀត ក្រសួងអយក.និងមន្ទីរអយក.គួរបង្កើនការចុះពិនិត្យតាមដាននិងវាយតម្លៃនៅថ្នាក់ការិយាល័យអយក. និងសាលារៀន ព្រមទាំងរៀបចំហេដ្ឋារចនាសម្ព័ន្ធ សុខភាព អនាម័យនិងបរិស្ថានសាលារៀនឱ្យបានសមស្របនិងគ្រប់សាលា និងបង្កើនសាងសង់អន្តេវាសិកដ្ឋានសម្រាប់គ្រូនិងសិស្ស (ជាពិសេសសិស្សស្រី) នៅតំបន់ជួបការលំបាក ក្រៅពីនេះគួរផ្តល់ថវិកាសម្រាប់ចុះស្រង់ទិន្នន័យសម្រាប់ថ្នាក់មន្ទីរអយក. ការិយាល័យអយក. និងសាលារៀន ហើយគួរពង្រឹងសមត្ថភាពគ្រូនិងបំប៉នពីវិធីសាស្ត្របង្រៀនថ្មីៗ ដើម្បីឱ្យលោកគ្រូអ្នកគ្រូមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀនសិស្ស ជាងនេះទៀត គួរផ្តល់គ្រូឯកទេសឱ្យបានគ្រប់ជំនាញឯកទេសនិងគ្រប់សាលា។ ដើម្បីឱ្យការងារស្ថិតិកាន់តែប្រសើរ គួរសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ (NIS) ដើម្បីធ្វើចំណោលប្រជាជនក្រោយពីជំរឿនឆ្នាំ២០១៩ និងគ្រប់លំដាប់ថ្នាក់ ហើយតួលេខប្រជាជនត្រូវបែងចែកទៅតាមភេទ ជនជាតិភាគតិច បរិយាបន្ន (ពិការភាព) អាយុជាក់លាក់ និងតាមភូមិសាស្ត្រឱ្យបានច្បាស់លាស់។ ក្រសួងអយក.ក៏គួរសាងសង់អគារនៅតាមសាលាដែលខ្វះអគារសិក្សា ព្រមទាំងបំពាក់គ្រឿងបរិក្ខារបង្រៀន និងរៀនឱ្យបានសមស្រប និងផ្តល់សៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់ដល់សិស្សនិងទាន់ពេលវេលា ព្រមទាំងបង្កើតបណ្ណាល័យគំរូ និងពង្រឹងសហប្រតិបត្តិការក្នុងការប្រមូលទិន្នន័យ និងធ្វើបច្ចុប្បន្នភាពជាក់ស្តែងនៅមូលដ្ឋាន៕

# គុណូបការគុណ

ការស្រាវជ្រាវនេះមិនអាចដំណើរការបានឡើយ ប្រសិនបើគ្មានការផ្តួចផ្តើមគំនិត និងជ្រោម ជ្រែងពីថ្នាក់ដឹកនាំនៃក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ និងសហការីដែលជាក្រុមការងារនៃនាយកដ្ឋានគោលនយោបាយ នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងនាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃ ដែលបានផ្តល់នូវធាតុចូល ឯកសារពាក់ព័ន្ធ ក៏ដូចជាជួយចុះប្រមូលទិន្នន័យ ជំនួយការបច្ចេកទេស ចូលរួមវិភាគ និងផ្តល់ជាមតិយោបល់ ព្រមទាំងជួយកែតម្រូវនូវលទ្ធផលនៃការសិក្សាតាំងពីចាប់ផ្តើមរហូតដល់ចប់នៃការស្រាវជ្រាវ។

អរគុណជាពិសេសដល់ឯកឧត្តមបណ្ឌិត ឌី ខាំបូលី ប្រធាននាយកដ្ឋានគោលនយោបាយ ដែលបានចំណាយកម្លាំងកាយចិត្ត និងប្រាជ្ញាក្នុងការដឹកនាំ ចាត់ចែង និងសម្របសម្រួលគ្រប់បែបយ៉ាង ព្រមទាំងជំនះរាល់ឧបសគ្គនានាក្នុងការជំរុញឱ្យការសិក្សាស្រាវជ្រាវនេះចេញជាលទ្ធផល។

ការសិក្សាស្រាវជ្រាវមិនអាចចេញជាលទ្ធផលបានឡើយ ប្រសិនមិនមានការសហការ និងជួយជ្រោមជ្រែងក្នុងការបង្កើតឧបករណ៍ស្រាវជ្រាវប្រមូល បញ្ចូល និងវិភាគទិន្នន័យពីសហការីទាំងអស់និងបុគ្គលិកស្ម័គ្រចិត្តនៃនាយកដ្ឋានគោលនយោបាយនិងអ្នកពាក់ព័ន្ធ។

# បញ្ជីអក្សរកាត់

| អក្សរកាត់ | អង់គ្លេស | ខ្មែរ |
|---|---|---|
| CR | Completion Rate | អត្រាបញ្ចប់ការសិក្សា |
| DoPo | Department of Policy | នាយកដ្ឋានគោលនយោបាយ |
| DTMT | District Training Monitoring Team | ក្រុមពិនិត្យតាមដានបណ្តុះបណ្តាលថ្នាក់ស្រុក |
| DLI | Direct Link Indicator | សូចនាករភ្ជាប់ដោយផ្ទាល់ |
| EMIS | Education Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| GPI | Gender Parity Index | សន្ទស្សន៍យុគភាពយេនឌ័រ |
| IT | Information Technology | បច្ចេកវិទ្យាព័ត៌មាន |
| JMI | Join Monitoring Indicator | សូចនាករពិនិត្យឡើងវិញរួមគ្នា |
| LSCR | Low Secondary Completion Rate | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិទាប |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា (អយក) |
| NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| PCR | Primary Completion Rate | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា |
| SDGs | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |

# ជំពូក ១៖ សេចក្តីផ្តើម

## ១.១ សាវតារ

តាមនិយមន័យជាលក្ខណៈសាកលអត្រាបញ្ចប់ការសិក្សា គឺជាភាគរយនៃក្រុមអាយុកុមារ ឬក្មេងជំទង់ដែលមានអាយុ៣ទៅ៥ឆ្នាំ លើសពីអាយុកំណត់មួយដែលគេរំពឹងថា កុមារកំពុងរៀន នៅថ្នាក់ចុងក្រោយនៃកម្រិតអប់រំ (ភូមិសិក្សា) ណាមួយ[1]។ ជាក់ស្តែងនៅប្រទេសកម្ពុជា ការអប់រំ នៅបឋមសិក្សាមាន៦កម្រិតថ្នាក់ ចំណែកឯអាយុដែលរំពឹងថាកុមារកំពុងរៀនថ្នាក់ចុងក្រោយ (ថ្នាក់ទី៦) គឺអាយុ១១ឆ្នាំ ដោយសារតែអាយុដែលកំណត់ជាផ្លូវការសម្រាប់ការចូលរៀនថ្នាក់ទី១ នៅកម្ពុជាគឺអាយុ៦ឆ្នាំ។ ដូច្នេះអាយុចន្លោះពី១៤ទៅ១៦ឆ្នាំ (មានន័យថា១១+៣និង១១+៥) ជាក្រុមអាយុគោល សម្រាប់ការគណនាអត្រាបញ្ចប់ការសិក្សាកម្រិតបឋមសិក្សា។ អត្រាបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិជាភាគរយនៃក្រុមអាយុ៣ ទៅ៥ ឆ្នាំច្រើនជាងអាយុកំណត់ទូទៅ ដែលរំពឹងថាកំពុងសិក្សានៅថ្នាក់ចុងក្រោយនៃកម្រិតមធ្យមសិក្សាបឋមភូមិ។ មធ្យមសិក្សាបឋមភូមិមានបីកម្រិតថ្នាក់ពីថ្នាក់ទី៧ដល់ទី៩ ហេតុនេះ អាយុសិក្សាថ្នាក់ចុងក្រោយ (ថ្នាក់ទី៩) គឺអាយុ១៤ឆ្នាំ ហើយអាយុ១៧ដល់១៩ឆ្នាំ (មានន័យថា១៤+៣និង១៤+៥) ជាក្រុមអាយុគោលសម្រាប់ការគណនាអត្រាបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ។

ទិន្នន័យអប់រំកម្រិតពិភពលោកឆ្នាំ២០០៨-២០១៤បង្ហាញថា ការអប់រំកម្រិតបឋមសិក្សាអត្រាបញ្ចប់ការសិក្សាមាន ៥១%សម្រាប់បណ្តាប្រទេសដែលមានចំណូលទាប ៨៤%សម្រាប់បណ្តាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនិង៩២%សម្រាប់បណ្តាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ ដោយឡែក អត្រាបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិមាន ២៧% សម្រាប់ បណ្តាប្រទេសមានចំណូលទាប ៦៨%សម្រាប់ប្រទេសមានចំណូលមធ្យមកម្រិតទាប និង ៧៩%សម្រាប់ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់[2]។ សូចនាករដែលបញ្ជាក់ពីអត្រាបញ្ចប់ការសិក្សាទាបបណ្តាលមកពីការចូលរៀនមានកម្រិតទាប ឬការចូលរៀនលើសអាយុនៅក្នុងការអប់រំកម្រិតណាមួយ អត្រាបោះបង់ការសិក្សាខ្ពស់ អត្រាត្រួតថ្នាក់ខ្ពស់ ការបញ្ចប់ការសិក្សាយឺត អត្រាមិនចូលថ្នាក់រៀនខ្ពស់ អត្រាកុមារលើសអាយុខ្ពស់ អត្រាផលធៀបនៃការ

[1] វិទ្យាស្ថានស្ថិតិនៃអង្គការយូណេស្កូ វេបសាយ http://uis.unesco.org/en/glossary-term/completion-rate ចូលមើលនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨

[2] របាយការណ៍តាមដានវិស័យអប់រំពិភពលោក៖ ការអប់រំសម្រាប់ប្រជាជន និងពិភពលោក ការបង្កើតអនាគតប្រកបដោយចីរភាពសម្រាប់ទាំងអស់គ្នា យូណេស្កូ, ២០១៦ ទំព័រ ១៨៤-១៨៥

ចូលរៀនថ្នាក់ចុងក្រោយនៃកម្រិតសិក្សា ឬជាបន្ទំនៃបណ្តាកត្តាទាំងអស់ខាងលើ[3]។ គោលបំណងនៃសូចនាករទាំងនេះគឺដើម្បីបង្ហាញអំពីអត្រានៃកុមារដែលមានអាយុលើស៣ - ៥ ឆ្នាំទៅលើអាយុ១១ឆ្នាំ ដែលបញ្ចប់ការសិក្សាកម្រិតបឋមសិក្សានិងសិស្សអាយុ១៨ឆ្នាំសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ។ អត្រាបញ្ចប់ការសិក្សាក្នុងកម្រិត១០០% ឬក្បែរនេះជាសូចនាករបញ្ជាក់ថា កុមារឬក្មេងជំទង់ទាំងអស់ ឬស្ទើរតែទាំងអស់បានបញ្ចប់ការសិក្សាកម្រិតបឋមសិក្សា (កុមារអាយុលើស១១ឆ្នាំពី៣-៥ឆ្នាំ) និងបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ (ក្មេងអាយុលើ១៨ឆ្នាំពី៣-៥ឆ្នាំ)។ និយមន័យនៃអត្រាបញ្ចប់ការសិក្សានៅប្រទេសកម្ពុជា ត្រូវបានគណនាដោយយកចំនួនសិស្សទាំងអស់ ដែលបានរៀនដល់ថ្នាក់ចុងក្រោយនៃកម្រិតភូមិសិក្សាណាមួយ ដកចំនួនសិស្ស ដែលរៀនត្រួតថ្នាក់នៅថ្នាក់ចុងក្រោយនោះ (ដោយមិនរាប់បញ្ចូលសិស្សរៀនត្រួតថ្នាក់) រួចទើបយកលទ្ធផលមកចែកនឹងចំនួនកុមារសរុបដែលមានអាយុត្រូវរៀននៅថ្នាក់ចុងក្រោយនៃកម្រិតភូមិសិក្សានោះ(អាយុ១១ឆ្នាំសម្រាប់កម្រិតបឋមសិក្សានិង១៨ឆ្នាំសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ)។

## ១.២ ហេតុផលនៃការសិក្សា

អត្រាបញ្ចប់ការសិក្សាកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ គឺជាសូចនាករដ៏សំខាន់ ដែលបញ្ជាក់អំពីការឆ្លើយតបនៃវិស័យអប់រំទៅនឹងច្បាប់អប់រំ។ មាត្រា៦៨នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា "រដ្ឋនឹងផ្តល់ការអប់រំក្នុងកម្រិតបឋមសិក្សា និងមធ្យមសិក្សាដោយមិនគិតកម្រៃនៅតាមគ្រឹះស្ថានអប់រំសាធារណៈដល់ប្រជាជនគ្រប់រូប។ គ្រប់ប្រជាពលរដ្ឋនឹងទទួលបានការអប់រំយ៉ាងតិច៩ឆ្នាំ"[4]។ អត្រាបញ្ចប់ការសិក្សានៅគ្រប់កម្រិតអប់រំនៅកម្ពុជានៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ ទោះបីជាក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវវិធានការរយៈពេលមធ្យមនិងរយៈពេលវែង ដើម្បីដោះស្រាយបញ្ហានានាតាំងពីឆ្នាំ២០១០មកក៏ដោយ។ អត្រាបញ្ចប់ការសិក្សាកម្រិតបឋមសិក្សា ជាសូចនាករសម្រាប់ប្រៀបធៀបរវាងដំណើរការជាក់ស្តែងនៃវិស័យអប់រំ ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ អត្រាបញ្ចប់ការសិក្សាទាំងនៅកម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិនៅតាមបណ្តាស្រុកមួយចំនួននៅតែមានកម្រិតទាប ហើយមិនទាន់បានឆ្លើយតបទៅនឹងចំណុចដៅកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៩-២០១៨) ក៏ដូចជាមិនទាន់ឆ្លើយតបទៅ

[3] វិទ្យាស្ថានស្ថិតិនៃអង្គការយូណេស្កូ http://uis.unesco.org/en/glossary-term/completion-rate បើកមើលនាថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

នឹងសូចនាករពិនិត្យឡើងវិញរួមគ្នា (JMI) សហគមន៍អឺរ៉ុបដែលតម្រូវឱ្យមានការបង្កើនចំនួនស្រុក (១១៥ស្រុកក្នុងឆ្នាំ២០១៩ និង១៣២ស្រុកក្នុងឆ្នាំ២០២១) ដោយទាមទារសម្រេចឱ្យបាននូវអត្រាបញ្ចប់ការសិក្សាកម្រិតបឋមសិក្សាយ៉ាងតិចបំផុត៨០%។ តែផ្ទុយទៅវិញ[5]មានតែស្រុកចំនួន៨៧ប៉ុណ្ណោះ(មិនរាប់បញ្ចូលខណ្ឌក្នុងរាជធានីភ្នំពេញ) ដែលសម្រេចបានអត្រាបញ្ចប់ការសិក្សាបឋមសិក្សាយ៉ាងតិច៨០% (EMIS, ២០១៨)។

អត្រាបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ ជាទូទៅគណនានិងវាស់ស្ទង់នៅកម្រិតថ្នាក់ខេត្តពីព្រោះមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ជាអង្គភាពដែលមានទំនួលខុសត្រូវធំជាងគេលើប្រព័ន្ធអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ។ ឈរលើគោលការណ៍នេះ ផែនការយុទ្ធសាស្ត្រ វិស័យអប់រំថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡាក៏ដូចជាសូចនាករភ្ជាប់ដោយផ្ទាល់ (Direct Link Indicator--DLI) របស់សហគមន៍អឺរ៉ុបបានកំណត់នូវសូចនាករ ដែលក្នុងនោះបានដាក់លក្ខខណ្ឌឱ្យខេត្តឬក្រុងមួយចំនួន ត្រូវសម្រេចឱ្យបាននូវអត្រាបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ យ៉ាងតិច៥០% ចាប់ពីឆ្នាំសិក្សា២០១៧-២០១៨តទៅ[6]។

ក្នុងឆ្នាំ២០១៨ មានខេត្តចំនួន១៣ បានសម្រេចនូវអត្រាបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ៥០% ហើយគោលដៅសម្រាប់ឆ្នាំ២០១៩-២០២០ គឺត្រូវមានខេត្តសម្រេចអត្រាបញ្ចប់ការសិក្សានេះចំនួន១៤ខេត្ត។ គោលដៅនេះនៅមានបញ្ហាប្រឈមជាច្រើនដែលរារាំងដល់ការសម្រេចអត្រាបញ្ចប់ការសិក្សានេះ ដែលក្នុងនោះ រួមមានបញ្ហាចំណាកស្រុក ការបោះបង់ការសិក្សា ការរៀបការ ភាពក្រីក្រ ការបួសជាសង្ឃ ការផ្លាស់ទីលំនៅតាមឪពុកម្ដាយឬអាណាព្យាបាល ត្រូវទៅធ្វើការនៅក្រៅប្រទេស ការមិនឱ្យតម្លៃការអប់រំ។ល។

## ១.៣ គោលបំណងនៃការសិក្សា

ការសិក្សានេះមានគោលបំណងរួម គឺដើម្បីស្វែងរកឱ្យឃើញនូវមូលហេតុនានាដែលនាំឱ្យអត្រាបញ្ចប់ការសិក្សាទាបនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមបណ្ដាខេត្ត និងស្រុកមួយចំនួនពោលគឺ (១) ឈ្វេងយល់ពីការប្រែប្រួលនៃចំនួនប្រជាជននិងសិស្សក្នុងតំបន់គោលដៅ (២) ឈ្វេងយល់ពីយុគភាពយេនឌ័រក្នុងអត្រាបញ្ចប់ការសិក្សាទាំងនៅបឋម

[5] ស្ថិតិ និងសូចនាករឆ្នាំ២០១៧-២០១៨ របស់នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

[6] សហគមន៍អឺរ៉ុបបានស្នើឱ្យផ្លាស់ប្ដូរសូចនាករចម្បងពីអត្រាបញ្ចប់ការសិក្សាមកជាអត្រាបោះបង់ការសិក្សាវិញ (សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិដូចគ្នា)។ សហគមន៍អឺរ៉ុបយល់ឃើញថាការប្រើអត្រាបោះបង់ការសិក្សាជាសូចនាករគឺមានលក្ខណៈជាក់ស្ដែងជាងក្នុងការវាយតម្លៃ។

សិក្សា និងមធ្យមសិក្សាបឋមភូមិ និង (៣) កំណត់អន្តរាគមន៍ជាក់លាក់ដើម្បីដោះស្រាយអត្រាបញ្ចប់ការសិក្សាទាបនៅតាមសាលាបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងដែលបានកំណត់នៅផ្នែក១.៣ខាងលើ ការសិក្សាស្រាវជ្រាវនេះគឺផ្អែកទាំងស្រុងទៅនឹងសំណួរសំខាន់ៗដូចខាងក្រោម៖

១. តើចំនួនប្រជាជន និងសិស្សនៅក្នុងតំបន់គោលដៅមានការប្រែប្រួលយ៉ាងដូចម្ដេចទាក់ទងទៅនឹងអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ?

២. តើមានភាពខុសគ្នាយ៉ាងដូចម្ដេចលើសន្ទស្សន៍យុគភាពយេនឌ័រ លើអត្រាបញ្ចប់ការសិក្សាទាំងនៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ?

៣. តើត្រូវកំណត់អន្តរាគមន៍ជាក់លាក់យ៉ាងដូចម្ដេច ដើម្បីដោះស្រាយអត្រាបញ្ចប់ការសិក្សាទាបនៅតាមសាលាបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ?

## ១.៥ សារសំខាន់នៃការសិក្សា

របកគំហើញនៃការសិក្សានេះនឹងផ្ដល់ជាភស្តុតាងបែបវិទ្យាសាស្ត្រ ដែលអាចឆ្លុះបញ្ចាំងអំពីបញ្ហាប្រជាសាស្ត្រនិងទិន្នន័យនៃការចូលរៀន កត្តាដែលនាំឱ្យអត្រាបញ្ចប់ការសិក្សាទាបនៅតាមបណ្ដាស្រុក និងខេត្តក្រុងមួយចំនួនដែលដំណើរការនៃវិស័យអប់រំ មិនទាន់ទទួលបានលទ្ធផលល្អប្រសើរនៅឡើយ ថែមទាំងអាចឆ្លើយតបទៅនឹងសំណួរថា តើហេតុអ្វីបានជាសិស្សស្រីរៀនសូត្របានពូកែជាងសិស្សប្រុសទាំងកម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិ។ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា រួមទាំងប្រតិបត្តិករវិស័យអប់រំអាចនឹងប្រើប្រាស់លទ្ធផលនៃរបក គំហើញនៃការស្រាវជ្រាវនេះ ដើម្បីកំណត់និងបង្កើតបទអន្តរាគមន៍បែបយុទ្ធសាស្ត្របង្កើនអត្រាបញ្ចប់ការសិក្សាទាំងក្នុងកម្រិតបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ ព្រមទាំងសម្រេចឱ្យបាននូវគោលដៅនានា ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ក៏ដូចជាគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs)។ ក្នុងន័យនេះ ការសិក្សាស្រាវជ្រាវនេះក៏នឹងរួមចំណែកផងដែរក្នុងការលើកកម្ពស់កំណែទម្រង់ជារួមនៃប្រព័ន្ធអប់រំ ដែលនេះជាយន្តការធានាថា កុមារគ្រប់រូបទទួលបានការអប់រំដោយមិនបង់ថ្លៃប្រកបដោយសមធម៌ សមភាព បរិយាបន្ន និង គុណភាព ថែមទាំងអាចបញ្ចប់ការអប់រំកម្រិតមូលដ្ឋានបានទៀតផង។

# ជំពូក ២៖ ការរំលឹកទ្រឹស្តី

## ២.១ ការប្រើប្រាស់សូចនាករអប់រំ

យោងតាមការគ្រប់គ្រង វិភាគ និងការប្រើប្រាស់ទិន្នន័យរបស់នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) នៃក្រសួងអប់រំ យុវជន និងកីឡាបានឱ្យនិយមន័យ សូចនាករថាជាសញ្ញាចង្អុលប្រាប់ឱ្យយើងដឹងពីស្ថានភាព ឬពីព្រឹត្តិការណ៍ក្នុងជីវភាពជាក់ស្តែង។ រីឯ សូចនាករអប់រំជាសញ្ញាចង្អុលប្រាប់ជាពិសេសមន្ត្រី និងអ្នកពាក់ព័ន្ធអំពីការវិវត្តនៃស្ថានភាពណាមួយដែលបានអនុវត្តរួចហើយឬកំពុងអនុវត្ត ឬនឹងត្រូវអនុវត្តក្នុងវិស័យអប់រំ ដើម្បីឱ្យអ្នកទាំងនោះយកមកធ្វើជាមូលដ្ឋានបង្អែកសម្រាប់វាស់ស្ទង់ ប្រៀបធៀបទៅនឹងវត្ថុបំណងដែលចង់បាន (EMIS, 2018, p.5)។ សូចនាករអប់រំ មានសារសំខាន់ណាស់សម្រាប់វាស់ពីការរីកចម្រើននៃសេវាកម្មអប់រំ ដែលផ្តល់ជាធនធានបញ្ចូល ដំណើរការ លទ្ធផល និងផលសម្រេច។ សូចនាករអប់រំសំខាន់ៗរួមមាន សូចនាករលទ្ធភាពចូលរៀន សូចនាករប្រសិទ្ធភាព សូចនាករគុណភាព និងសូចនាករសមធម៌ (EMIS, 2018, p.5) ក្នុងនោះរង្វាស់សូចនាករត្រូវបានកំណត់ជាលេខភាគរយ អត្រា និងផលធៀប។

ការប្រើប្រព័ន្ធសូចនាករអប់រំ មានគោលបំណងចង្អុលបង្ហាញ តាមដានប្រព័ន្ធសេដ្ឋកិច្ចយុត្តិធម៌ ព្រហ្មទណ្ឌ ឬប្រព័ន្ធសង្គមផ្សេងៗ។ ក្នុងន័យនេះ សូចនាករស្ថិតិត្រូវបានប្រើដើម្បីតាមដានលក្ខខណ្ឌស្មុគស្មាញ ដែលមានការពិបាកវិនិច្ឆ័យឱ្យបានទៀងទាត់ ឬខកខានក្នុងការសង្កេតប្រចាំថ្ងៃ។ គោលបំណងសំខាន់នៃសូចនាករ គឺដើម្បីបង្ហាញពីប្រព័ន្ធមួយដែលព័ត៌មាននោះអាចត្រូវបានប្រើដើម្បីវិនិច្ឆ័យពីវឌ្ឍនភាពឆ្ពោះទៅរកគោលដៅមួយចំនួនឬបទដ្ឋាន (ស្តង់ដារ) ទៅនឹងបទដ្ឋានកន្លងមក (Shavelson, et al., 1991)។ សូចនាករអប់រំ (Shavelson, et al., 1991) ជាស្ថិតិដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពសំខាន់ៗនៃប្រព័ន្ធអប់រំ ហើយប្រាប់ពីប្រព័ន្ធទាំងមូលដោយរៀបរាប់ពីស្ថានភាពនិងលក្ខណៈសំខាន់ៗ ឧទាហរណ៍ចំនួនសិស្សដែលបានចុះឈ្មោះចូលរៀននៅក្នុងសាលាជាដើម។

សូចនាករអប់រំអាចផ្តល់ជាតម្រុយអំពីកម្មវិធីអប់រំដែលយើងចង់បាន។ ឧទាហរណ៍ ការប្រើសូចនាករដើម្បីពិពណ៌នាអំពីស្ថានភាពនៃសង្គម និងសក្តានុពលរបស់ខ្លួន ដូច្នេះ វាធ្វើឱ្យសមត្ថភាពរបស់យើងកាន់តែប្រសើរឡើងក្នុងការដោះស្រាយបញ្ហារបស់ប្រទេស ឬក្រសួងក្នុងការខិតខំប្រឹងប្រែងស្វែងរកដំណោះស្រាយ។ ផ្នែកនេះក៏នឹងផ្តល់ជាវិភាគទានដោយផ្ទាល់បន្ថែមទៀតដល់អ្នកបង្កើតគោលនយោបាយ អ្នកធ្វើការសម្រេចចិត្តជាដើម ដែលកត្តាទាំងនេះ

ជាធាតុចូលដ៏សំខាន់ដើម្បីជួយដល់អ្នកគ្រប់គ្រងក្នុងការធ្វើការសម្រេចចិត្ត (Sheldon និងParke, 1975, p. 698 as cited in Shavelson, et al., 1991)។ ស្រដៀងគ្នានេះដែរ Shavelson, et al. (1991, p.2) បានលើកឡើងថា សូចនាករអាចជួយដល់អ្នកបង្កើតគោលនយោបាយក្នុងការបកស្រាយឬបំលែងគោលដៅទាំងនោះទៅជាសកម្មភាព។

ប្រព័ន្ធសូចនាករអប់រំល្អនឹងផ្តល់នូវព័ត៌មានសុក្រឹតនិងច្បាស់លាស់ ដើម្បីបំភ្លឺ ឬបង្ហាញពីស្ថានភាពអប់រំ និងចូលរួមចំណែកលើកកម្ពស់ព័ត៌មានអប់រំ។ ព័ត៌មានដែលបង្កើតឡើងធម្មតាៗមិនអាចយកទៅប្រើផ្លូវការបានទេ ពោលគឺត្រូវមានការខិតខំប្រឹងប្រែងផ្សេងៗដើម្បីវិភាគ និងចងក្រងជារបាយការណ៍អំពីការសិក្សានានាដែលអាចជឿទុកចិត្តបាន ទើបអាចយកទៅប្រើប្រាស់ផ្លូវការបាន (Shavelson, et al., 1991, p.2)។

Shavelson, et al. (1991, p.2) ក៏បានលើកឡើងផងដែរថា ដើម្បីឱ្យសូចនាករកាន់តែមានភាពជឿជាក់ ជាពិសេសសូចនាករថ្នាក់ជាតិគួរត្រូវបានគិតគូរឱ្យបានទូលំទូលាយទៅលើលទ្ធផលអប់រំ ឧទាហរណ៍ សមិទ្ធផល ការចូលរួមជាដើម។ លទ្ធផលនៃការពិនិត្យតាមដានធម្មតាមិនផ្តល់ការពន្យល់សម្រាប់និន្នាការដែលបានសង្កេតទេ។ និន្នាការ អាចត្រូវបានពន្យល់តាមរយៈការផ្លាស់ប្តូរប្រជាសាស្ត្រ ការកែលម្អអប់រំឬការបន្សាំផ្សេងៗមួយចំនួនទៀត។ គោលនយោបាយអប់រំ ជះឥទ្ធិពលដោយប្រយោលទៅលើលទ្ធផលតាមរយៈសកម្មភាពមួយចំនួនដូចជា ការបង្កើនបទដ្ឋានគ្រូ គុណភាពនៃវិញ្ញាបនបត្រ ឬសម្រាប់ការបញ្ចប់វិទ្យាល័យជាដើម។ ផលប៉ះពាល់ដោយផ្ទាល់ នៃគោលនយោបាយទាំងនេះ នឹងឆ្លុះបញ្ចាំងតាមរយៈការផ្លាស់ប្តូររបៀបនៃការបង្រៀនរបស់គ្រូ។ ឧទាហរណ៍គុណវុឌ្ឍិរបស់គ្រូ ពោលគឺការបង្កើនគ្រូកម្រិតបរិញ្ញាបត្រលើមុខវិជ្ជាដែលពួកគេបង្រៀន មិនមែនមានតែសញ្ញាបត្រអប់រំទេ ដែលក្នុងនោះ វាទាមទារឱ្យមានការបណ្តុះបណ្តាលពីវិធីសាស្ត្របង្រៀន (គរុកោសល្យ) ការចាត់ចែងរៀបចំអំពីរបៀបបង្រៀនរបស់គ្រូនិងកម្មវិធីសិក្សា។ លើសពីនេះទៀត សូចនាករជាតិត្រូវតែបង្ហាញយ៉ាងហោចណាស់ពីសមាសធាតុសំខាន់ៗនៃប្រព័ន្ធអប់រំ។ លទ្ធផលនៃការត្រួតពិនិត្យ សូចនាករគួរឆ្លុះបញ្ចាំងពីលក្ខណៈរបស់សិស្ស និងសហគមន៍ ដែលសាលារៀនជាអ្នកផ្តល់ហិរញ្ញវត្ថុនិងធនធានមនុស្ស ជាពិសេសគ្រូបង្រៀន។ សាលារៀនត្រូវផ្តល់ពីភាពគ្រប់គ្រាន់នៃកម្មវិធីសិក្សា និងការបង្រៀន ដើម្បីជាឧត្តមភាពលើវិស័យអប់រំប្រកបដោយសមធម៌ ជាពិសេសសម្រាប់ដំណើរការអប់រំផ្សេងៗទៀត។ សូចនាករត្រូវទាក់ទងគ្នាទៅវិញទៅមកដើម្បីអាចមើលឃើញ ឬវាស់វែងពីលទ្ធផលបាន។

## ២.២ ការកំណត់និយមន័យ និងការប្រើប្រាស់អត្រាបញ្ចប់ការសិក្សា

យោងទៅតាម (Boissiere, 2004) បានឱ្យនិយមន័យអត្រាបញ្ចប់ការសិក្សាថាជាសមាមាត្រនៃសិស្សដែលបញ្ចប់ការសិក្សានៅកម្រិតបឋមក្នុងឆ្នាំសិក្សាមួយ ធៀបទៅនឹងចំនួនសរុបនៃកុមារដែលមានអាយុបញ្ចប់ការសិក្សាផ្លូវការ។ ស្រដៀងគ្នាទៅនឹង (Ayub, 2018) បានឱ្យនិយមន័យអត្រាបញ្ចប់ការសិក្សាថា ជាសមាមាត្រនៃចំនួនសិស្សដែលបានចូលរៀនក្នុងឆ្នាំសិក្សាមួយធៀបទៅនឹងចំនួនសរុបនៃសិស្សទាំងនោះ (ក្រុមនោះ) ដែលបានអង្គុយប្រឡងជាប់ដោយជោគជ័យនៅក្នុងសាលាបឋមសិក្សា។ ក្នុងនោះដែរ (Muli, 2014) អត្រាបញ្ចប់ការសិក្សាសំដៅទៅលើភាគរយនៃសិស្ស និស្សិតដែលបញ្ចប់វគ្គសិក្សាឬកម្រិតសិក្សាជាក់លាក់នៃការអប់រំ។ លើសពីនេះទៀត អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាសំដៅទៅលើភាគរយនៃសិស្សដែលបញ្ចប់ឆ្នាំសិក្សាចុងក្រោយនៅសាលាបឋមសិក្សា (Wambua, 2014)។

អត្រាបញ្ចប់ការសិក្សា ជាផលធៀបនៃចំនួនសិស្សថ្មីនៅថ្នាក់ចុងក្រោយនៅភូមិសិក្សាណាមួយ (មិនរាប់សិស្សត្រួតថ្នាក់) ក្នុងឆ្នាំសិក្សា (T) និងចំនួនប្រជាជនដែលមានអាយុឆ្លើយតបទៅនឹងអាយុនៃថ្នាក់ចុងក្រោយរបស់ភូមិសិក្សានោះ ក្នុងឆ្នាំសិក្សា (T) ដូចគ្នា ហើយគិតជាភាគរយ (EMIS, 2018, p.20)។ ក្នុងនោះមានរបៀបគណនាដូចបង្ហាញក្នុងរូបមន្តខាងក្រោម៖

$$CR = \frac{\text{ចំនួនសិស្សថ្មីរៀននៅថ្នាក់ចុងក្រោយនៅភូមិសិក្សាមួយ (មិនរាប់សិស្សត្រួតថ្នាក់) ក្នុងឆ្នាំសិក្សា (T)}}{\text{ចំនួនប្រជាជនដែលមានអាយុឆ្លើយតបទៅនឹងអាយុនៃថ្នាក់ចុងក្រោយ}} \text{x100}$$

ដើម្បីគណនារូបមន្តដូចបង្ហាញខាងលើគឺតម្រូវឱ្យមានទិន្នន័យ ដូចជា (១) ចំនួនសិស្សថ្មីរៀន នៅថ្នាក់ចុងក្រោយនៅភូមិសិក្សាមួយ (មិនរាប់សិស្សត្រួតថ្នាក់) ក្នុងឆ្នាំសិក្សា (T) និង (២) ចំនួនប្រជាជនដែលមានអាយុឆ្លើយតបទៅនឹងអាយុនៃថ្នាក់ចុងក្រោយរបស់ភូមិសិក្សានោះ ក្នុងឆ្នាំសិក្សា (T)។ ដើម្បីឱ្យមានភាពជឿជាក់ក្នុងការគណនា ទិន្នន័យត្រូវយកមកពីប្រភព (១) សាលារៀន (២) ការិយាល័យអប់រំក្រុងស្រុក ខណ្ឌ និង (៣) មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត សម្រាប់ចំនួនសិស្សថ្មីរៀននៅថ្នាក់ចុងក្រោយនៅភូមិសិក្សាមួយ។ ចំពោះចំនួនប្រជាជនដែលមានអាយុឆ្លើយតបទៅនឹងអាយុនៃថ្នាក់ចុងក្រោយរបស់ភូមិសិក្សាគឺទិន្នន័យបានមកពី (១) អាជ្ញាធរភូមិ ឃុំសង្កាត់ ក្រុងស្រុកខណ្ឌ ខេត្ត រាជធានី (២) មន្ទីរផែនការខេត្ត និង (៣) ការធ្វើចំណោលក្រុមអាយុពីចំនួនប្រជាជនសរុបនៃភូមិសាស្ត្រវិទ្យាល័យ។

ឧទាហរណ៍ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ សិស្សដែលបានចុះឈ្មោះចូលរៀនថ្នាក់ទី១២ ក្នុងវិទ្យាល័យA សរុបមានចំនួន១២០នាក់។ ដោយដឹងថាប្រជាជនដែលមានអាយុ១៧ឆ្នាំ មកពីឃុំចំនួន៤ ចំណុះឱ្យវិទ្យាល័យ A គឺ១៣៨នាក់។ ដូច្នេះ ការគណនាអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យA ក្នុងឆ្នាំសិក្សា២០១៧-២០១៨គឺ CR= $\frac{១២០}{១៣៨}$ x១០០ = ៨៦,៩៥% (EMIS, 2018, p.21)។ ចំពោះការបកស្រាយពីលទ្ធផលនៃការប្រើរូបមន្តខាងលើគឺថា ករណីទី១ អត្រាក្រោម១០០% មានន័យថា ប្រជាជនដែលមានអាយុត្រូវនឹងថ្នាក់ចុងក្រោយនៃភូមិសាស្ត្រណាមួយ មិនបានបញ្ចប់ការសិក្សាក្នុងភូមិសិក្សានោះអស់ពីភូមិសាស្ត្រ។ ករណីទី២ អត្រាស្មើ១០០% មានន័យថា ប្រជាជនដែលអាយុត្រូវនឹងថ្នាក់ចុងក្រោយនៃភូមិសិក្សាណាមួយបានបញ្ចប់ការសិក្សានោះអស់ពីភូមិសិក្សា។

ចំណែកឯ ការគណនាអត្រាបញ្ចប់ការសិក្សាដែលប្រើប្រាស់សម្រាប់ SDG4 វិញ (EMIS, 2018, p.22) អត្រាបញ្ចប់ការសិក្សាជាភាគរយនៃសិស្សក្នុងកូហាតឬក្រុមអាយុ (Cohort) ដែលមានអាយុ៣-៥ឆ្នាំលើសពីអាយុផ្លូវការ ដែលបញ្ចប់ថ្នាក់ចុងក្រោយនៃភូមិសិក្សានោះ។ អាយុផ្លូវការនៃថ្នាក់ចុងក្រោយនៃភូមិសិក្សានីមួយៗ ជាអាយុដែលសិស្សចូលរៀនក្នុងថ្នាក់ណាមួយ។ ប្រសិនបើពួកគេបានចាប់ផ្តើមចូលរៀនតាមអាយុផ្លូវការនៅភូមិសិក្សាណាមួយ បានសិក្សាពេញម៉ោង ដោយមិនគិតត្រួតថ្នាក់ឬផ្លោះថ្នាក់។ រូបមន្តនៃការគណនាគឺ CR = $\frac{\text{EAGn.AG (a + 3t5)}}{\text{PAG (a + 3t5)}}$ ក្នុងនោះ $EAG_{n.AG(a+3t5)}$ ជាប្រជាជនដែលមានអាយុ៣-៥ឆ្នាំ លើសពីអាយុផ្លូវការ a ដែលបានបញ្ចប់ថ្នាក់ចុងក្រោយនៃភូមិសិក្សា n ចំណែកឯ PAG(a+3t5) ជាប្រជាជនដែលមានអាយុ៣-៥ឆ្នាំលើសពីអាយុផ្លូវការ a ដែលត្រូវនឹងថ្នាក់ចុងក្រោយនៃភូមិសិក្សា n ។ ទិន្នន័យដែលត្រូវការសម្រាប់គណនាអត្រាបញ្ចប់ការសិក្សាដែលប្រើប្រាស់សម្រាប់ SDG4 គឺត្រូវមានប្រជាជនក្នុងក្រុមអាយុដែលត្រូវនឹងកម្រិតសិក្សាចុងក្រោយនៃភូមិសិក្សាណាមួយ។ អាយុចូលរៀន និងរយៈសិក្សាតាមភូមិសិក្សានីមួយៗដែលក្នុងនោះប្រភពទិន្នន័យបានមកពីទិន្នន័យជំរឿនប្រជាជន និងអង្កេតគ្រួសារ។ ក្នុងន័យនេះ ការបកស្រាយនៃអត្រាបញ្ចប់ការសិក្សាដែលខិតជិត១០០% បង្ហាញថាប្រជាជនដែលមានអាយុ៣-៥ឆ្នាំ លើសពីអាយុផ្លូវការដែលត្រូវនឹងថ្នាក់ចុងក្រោយនៃភូមិសិក្សាណាមួយ បានបញ្ចប់ការសិក្សាក្នុងភូមិសិក្សានោះជិតអស់ពីភូមិសាស្ត្រ។

អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា (Completion Rate in Primary School) ជាចំនួនសិស្សថ្មី (មិនរាប់សិស្សត្រួតថ្នាក់រៀននៅថ្នាក់ទី៦) នៅក្នុងឆ្នាំសិក្សាណាមួយគិតជាភាគរយនៃចំនួនកុមារអាយុ១១ឆ្នាំក្នុងឆ្នាំសិក្សានោះ (EMIS, Private Education Statistics & Indicators,

2017-2018)ចំណែកឯ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (Completion Rate in Secondary School) ជាចំនួនសិស្សសិស្សថ្មី (មិនរាប់សិស្សត្រួតថ្នាក់រៀននៅថ្នាក់ទី៩) នៅក្នុងឆ្នាំសិក្សាណាមួយគិតជាភាគរយនៃចំនួនកុមារអាយុ១៥ឆ្នាំក្នុងឆ្នាំសិក្សានោះ។

## ២.៣ សន្ទស្សន៍យុគតាពយេនឌ័រ

សន្ទស្សន៍យុគភាពយេនឌ័រ (Gender parity index-GPI) ជាតម្លៃផលធៀបរវាងស្ត្រី និងបុរសនៃសូចនាករណាមួយ (EMIS, Private Education Statistics & Indicators, 2017-2018)។ បើសូចនាករនៃសន្ទស្សន៍យុគភាពយេនឌ័រស្មើនឹង១ នោះមានន័យថាមានសមភាពយេនឌ័រ។ តែបើយោងតាម (EMIS, Public Education Statistics & Indicators, 2017-2018) សន្ទស្សន៍យុគភាពយេនឌ័រអប់រំ (Gender parity index-GPI) ជាផលធៀបនៃតម្លៃសូចនាករអប់រំណាមួយរបស់ស្រីទៅនឹងតម្លៃ សូចនាករអប់រំនោះរបស់បុរស។ បើសន្ទស្សន៍ស្ថិតនៅចន្លោះ០.៩៧ ទៅ១.០៣ នោះបានសេចក្តីថាមានយុគភាពយេនឌ័រដែលប្រើរូបមន្ត $\text{GPI} = \frac{\text{តម្លៃសូចនាករអប់រំណាមួយរបស់ស្រី}}{\text{តម្លៃសូចនាករអប់រំនោះរបស់ប្រុស}}$។ វិធានការនៃសន្ទស្សន៍យុគភាពយេនឌ័រអប់រំជួយពន្យល់ពីរបៀបចូលរួម និងកាលានុវត្តភាពក្នុងការរៀនសូត្រដោយប្រៀប ធៀបរវាងស្ត្រីនិងបុរស។ ដោយសង្កត់ធ្ងន់លើការអប់រំសម្រាប់ទាំងអស់គ្នា សន្ទស្សន៍យុគភាព យេនឌ័រអប់រំ ត្រូវបានប្រើជាញឹកញាប់ក្នុងការពិនិត្យពីវឌ្ឍនភាពឆ្ពោះទៅរកគោលដៅ[7]។ សន្ទស្សន៍ យុគភាពយេនឌ័រជួយក្នុងការប្រៀបធៀប ដោយបង្ហាញពីសមាមាត្រនៃតម្លៃស្ត្រីទៅនឹងបុរសសម្រាប់សូចនាករដែលបានផ្តល់ឱ្យ។ សន្ទស្សន៍នៃតម្លៃតិចជាង១បង្ហាញថាតម្លៃសូចនាករបុរសមានកម្រិតខ្ពស់ជាងស្ត្រី។ តែបើតម្លៃសន្ទស្សន៍ធំជាង១ បង្ហាញថាតម្លៃសូចនាករស្ត្រីខ្ពស់ជាងបុរស។ ផ្ទុយទៅវិញ បើលទ្ធផលនៃសន្ទស្សន៍យុគភាពយេនឌ័រស្មើ១ នោះមានន័យថាសន្ទស្សន៍យុគភាពយេនឌ័រត្រូវបានសម្រេច។

## ២.៤ មូលហេតុដែលធ្វើឱ្យអត្រាបញ្ចប់ការសិក្សាមានកម្រិតទាប

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវមួយបង្ហាញថា សិស្សភាគច្រើនមកពីប្រទេសឥណ្ឌូនេស៊ី នៅក្នុងគ្រួសារក្រីក្របានបោះបង់ការសិក្សាដោយសារតែឪពុកម្តាយរបស់ពួកគេមិនមានលទ្ធភាពបង់ថ្លៃសិក្សា។ ការរើសអើងយេនឌ័រ ក៏ជាបុព្វហេតុមួយក្នុងចំណោមបុព្វហេតុចម្បងៗដែលនាំឱ្យមានអត្រាបញ្ចប់ការសិក្សាទាប។ កត្តាមួយទៀតនៃការបោះបង់ការសិក្សាគឺបណ្តាលមកពីកុមារត្រូវឪពុកម្តាយស្លាប់ចោល (ក្មេងកំព្រា) ដែលកុមារទាំងនេះ មានឱកាសទ្វេដងក្នុងការបោះបង់ការសិក្សា។ ការប្រើពេលវេលារបស់ឪពុកម្តាយយកកូនទៅសាលារៀន

[7] https://www.epdc.org/topic/gender-parity-indices, retrieved on 14 November 2018

ក៏ជាបុព្វហេតុនាំឱ្យ អត្រាបញ្ចប់ការសិក្សាទាបដែរ។ បរិយាកាសសាលារៀន កត្តាគ្រួសារ ភាពក្រីក្រ កត្តាវប្បធម៌ សង្គម និងបញ្ហាយេនឌ័រនៅតែជាបញ្ហា។ ក្រៅពីនេះ ការចំណាយលើការដឹកជញ្ជូន ក៏ជាបញ្ហាដល់កុមារដែលមកពីគ្រួសារក្រីក្រនិងផ្ទះមានចម្ងាយឆ្ងាយពីសាលារៀន (Daniel Suryadarma, 2006)។ ស្រដៀងទៅនឹងការសិក្សារបស់ Wambua (2014) បង្ហាញថា ចម្ងាយឆ្ងាយ សម្ភាររូបវន្តរៀន និង + បង្រៀននានានៅសាលារៀន ការគ្រប់គ្រងពេលវេលាពលកម្មលើកុមារ បរិយាកាសដែលគ្មានការគាំទ្រ ការខ្វះការប្រឹក្សាយោបល់ ភាពក្រីក្រ ការអនុវត្ត វប្បធម៌ ការឆាប់មានគភ៌ និងអាកប្បកិរិយាអវិជ្ជមានរបស់មាតាបិតា។ ឪពុកម្ដាយដែលមានការអប់រំទាប ទំហំគ្រួសារ ការជួយមាតាបិតានៅក្នុងសកម្មភាពសេដ្ឋកិច្ច ការងារផ្ទះសម្បែងអវត្តមានច្រើន និងការបោះបង់ចោលការសិក្សា (Muli, 2014) ជាកត្តានាំឱ្យមានអត្រាបញ្ចប់ការសិក្សាទាប។ ភាពក្រីក្រនិងការលំបាកផ្នែកសេដ្ឋកិច្ចគឺជាកត្តាសំខាន់ដែលនៅពីក្រោយនៃការបោះបង់ការសិក្សាខ្ពស់ និងការរក្សាសិស្សឱ្យនៅរៀនទាបនៅក្នុងការអប់រំកម្រិតបឋមសិក្សា (Kushiyat, 2007 ដកស្រង់ចេញពី Shree Prasad Devkota, 2015, p.154)។ ជារួមការបោះបង់ការសិក្សា បញ្ហាសេដ្ឋកិច្ច និងបញ្ហារើសអើងយេនឌ័រ គឺមូលហេតុដែលនាំឱ្យអត្រាបញ្ចប់ការសិក្សាទាប។

យោងតាម (Farooq, 2010) សិស្សដែលចុះឈ្មោះចូលរៀនយឺតយ៉ាវ គឺជាបញ្ហាប្រឈមដូចជាការរៀនត្រួតថ្នាក់ ដែលនាំឱ្យមានអត្រានៃការបញ្ចប់កម្រិតទាបនៅក្នុងសាលារៀន ហើយកត្តាមួយផ្សេងទៀតដែលនាំឱ្យសិស្សចេញពីសាលា ដោយសារតែភាពឯកា (នៅតែម្នាក់ឯង) និងកង្វះមិត្តភាព ចំណែកឯសិស្សខ្លះទៀត មានការពិបាកក្នុងការរៀនសូត្រ។ សិស្សដែលខកខានមិនមានការបែងចែកធនធានសមស្របទៅរកកម្រិតអប់រំ និងកត្តាមូលដ្ឋានរបស់សាលារៀន គឺជាមូលហេតុនៃបញ្ហា។ ម៉្យាងវិញទៀត ភាគច្រើនសិស្សដែលខ្វះការគាំទ្រពីគ្រូបង្រៀនសាលារៀន និងកុមារដែលរស់នៅក្នុងផលប៉ះពាល់សង្គម ឬអារម្មណ៍អវិជ្ជមានចំពោះការសិក្សារបស់ពួកគេ ក៏ជាកត្តានាំឱ្យបោះបង់ការសិក្សា។ ឥរិយាបថរបស់គ្រូបង្រៀន អាចប៉ះពាល់ដល់អត្រាបញ្ចប់ការសិក្សារបស់សិស្សនៅក្នុងសាលារៀន ពោលគឺគ្រូបង្រៀនមានកម្រិតអប់រំទាបដែលសិស្សមិនសូវមានជំនឿទុកចិត្តលើការបង្រៀន ការប្រើប្រាស់ជំនាញវិជ្ជាជីវៈ ឬការសម្រេចចិត្តរបស់ពួកគេ (Chae Young Kim & Martyn Rouse, 2011)។

ទន្ទឹមនឹងនេះដែរ Ishiguro (2018) និង Shree Prasad Devkota (2015) បានរកឃើញថា ភាពក្រីក្រនិងកុមារមកពីតំបន់ជនបទបានបោះបង់ចោលសាលារៀនដើម្បីជួយឪពុកម្ដាយរបស់

ពួកគេ។ សមាជិកក្រុមជនជាតិដើមភាគតិច នៅមិនទាន់យល់ដឹងពីតម្លៃនៃការអប់រំ និងខ្វះចំណេះដឹងដោយសារការអប់រំទាប។ ស្រដៀងគ្នាទៅនឹងការស្រាវជ្រាវរបស់ Fata No (2012) បង្ហាញថា អត្រាអវត្តមានខ្ពស់ ការចុះឈ្មោះចូលរៀនយឺតយ៉ាវ និងលទ្ធផលនៃការសិក្សាទាប គឺជាមូលហេតុដែលនាំឱ្យមានអត្រាបញ្ចប់ការសិក្សាទាប។ លើសពីនេះទៀត តាមការស្រាវជ្រាវផ្សេងៗបង្ហាញថា ការផ្សារភ្ជាប់សង្គមក៏ជាបុព្វហេតុនៃការបញ្ចប់ការសិក្សាទាបនៅសាលាបឋមសិក្សាផងដែរ។ គោលនយោបាយអប់រំក៏មានផលប៉ះពាល់ទៅលើអត្រាបញ្ចប់ការសិក្សា ហើយនៅតែជាហានិភ័យនិងជាបញ្ហាប្រឈមរបស់យុវជននៅប្រទេសកម្ពុជាផងដែរ។ តាម Ok-wach Abagi (1997) បានលើកឡើងថាគោលនយោបាយអប់រំនិងដំណើរការគ្រប់គ្រងអាចនាំឱ្យមានអត្រានៃការបញ្ចប់ការសិក្សាទាប។ ស្រដៀងគ្នានេះដែរតាមការសិក្សារបស់ Ruff (2016) គាត់បានលើកឡើងថា គោលនយោបាយអប់រំក៏ជាបុព្វហេតុមួយដែលនាំឱ្យមានអត្រានៃការបញ្ចប់ការសិក្សាទាបផងដែរ។

Tracy Brunette (2017) បានកត់សម្គាល់ថា ការចាប់ផ្តើមចូលរៀននៅពីរបីថ្នាក់ដំបូងនៅសាលាបឋមសិក្សាក៏ជាមូលហេតុនៃបញ្ហានេះដែរ។ អត្រារៀនត្រួតថ្នាក់ខ្ពស់មានផលប៉ះពាល់ដល់ការប្រើប្រាស់ធនធាននៃការអប់រំ និងលទ្ធភាពរបស់សិស្សដើម្បីរៀនចប់នៅបឋមសិក្សា។ សុខភាពមិនល្អ ឬកង្វះអាហារូបត្ថម្ភ និងការលើកទឹកចិត្ត ការប្រើកម្លាំងពលកម្មលើកុមារ និងភាពក្រីក្រ កម្រិតសាលារៀន ទីតាំងសាលារៀន និងការផ្តល់ការអប់រំដែលមានគុណភាពមិនល្អ គឺបុព្វហេតុនាំឱ្យកុមារមិនអាចបញ្ចប់ការសិក្សា (Ricardo Sabates, 2011)។ អត្រាបញ្ចប់បឋមសិក្សារបស់កុមារី ត្រូវរងឥទ្ធិពលពីកត្តាបរិស្ថានសាលារៀនសេដ្ឋកិច្ច សង្គម វប្បធម៌ ភាពក្រីក្រ ពលកម្មលើកុមារ និងការថែទាំ (Ayub, 2018)។ កត្តាដែលពាក់ព័ន្ធនឹង (១) សាលារៀន (ការបង្រៀនគ្មានប្រសិទ្ធភាព គ្រូបង្រៀនមិនគ្រប់គ្រាន់ គ្រូអវត្តមាន សៀវភៅសិក្សា និងប្រព័ន្ធវាយតម្លៃការសិក្សាមិនសមរម្យ)(២)សិស្ស(មិនសូវមានការលើកទឹកចិត្តការលំបាកក្នុងការរៀនសូត្រ ស្ថានភាពសុខភាព បញ្ហាអាហារូបត្ថម្ភនិងអាកប្បកិរិយា) និង (៣) គ្រួសារ (ឪពុកម្តាយ ឬអាណាព្យាបាលមានការអប់រំទាប ឬមិនសូវយល់ដឹងពីតម្លៃនៃការអប់រំ បញ្ហាប្រាក់ចំណូលរបស់គ្រួសារ) (Admassu, 2015)។

## ២.៩ បញ្ហាប្រឈមបណ្តាលមកពីអត្រាបញ្ចប់ការសិក្សាទាប

ការមិនបានបញ្ចប់ការសិក្សា គឺជាកង្វល់ដ៏ចម្បងសម្រាប់វិស័យអប់រំដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពនិងសុភមង្គល កម្រិតជីវភាពរស់នៅ និងស្ថានភាពសេដ្ឋកិច្ចសង្គមជាដើមនៅក្នុង

សង្គមលោកខាងលិចជាច្រើន (Arnhild Myhr, et al., 2017)។ តាមរបាយការណ៍នៃនាយកដ្ឋានអប់រំ និងបណ្តុះបណ្តាលជំនាញនៃចក្រភពអង់គ្លេសបានបង្ហាញថា ក្រុមយុវជនដែលអាជ្ញាធរអង់គ្លេសកំណត់អត្តសញ្ញាណថាជាក្រុមយុវជនមិនទទួលបានការអប់រំ ក្រុមគ្មានការងារធ្វើ ឬក្រុមដែលមិនបានទទួលការបណ្តុះបណ្តាល (Young People not in Education, Employment or Training (NEET) គឺជាក្រុមមុខសញ្ញាដែលគេជឿជាក់ថាអាចនឹងបង្កបញ្ហាដល់សង្គម ឬក្រុមដែលមានអាកប្បកិរិយាប្រឆាំងសង្គម (Simmons)។ ស្រដៀងគ្នានេះដែរ Duke (1966) បានលើកឡើងថា ការអប់រំគឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការបណ្តុះស្មារតីជាតិនិយម។ ទំនាក់ទំនងមួយទៀតរវាងការអប់រំ និងសង្គម គឺឥទ្ធិពលជាវិជ្ជមាននៃការអប់រំទៅលើសុខភាពទាំងផ្លូវកាយ និងផ្លូវចិត្តរបស់ប្រជាពលរដ្ឋ ព្រោះថាការអប់រំធ្វើឱ្យប្រជាជនមានជំនឿចិត្ត លើកកម្ពស់គុណភាពរស់នៅ ការថែទាំសុខភាព បង្កើនប្រាក់ចំណូល ផ្តល់ជីវិតប្រសើរជាងមុន ទទួលបានការងារប្រកបដោយបរិស្ថានល្អ និងលក្ខខណ្ឌប្រសើរជាងមុន (Gathmann, Jurges & Reinhold, 2014)។ ចំណែក Muslim និង Mohd Noor (2011) បានបញ្ជាក់ថា សិស្សានុសិស្សគឺជាកញ្ចក់ឆ្លុះបញ្ចាំងពីតថភាព និងចរិតលក្ខណៈនៃសង្គមជាតិនៅពេលបច្ចុប្បន្ននិងពេលអនាគត។ ដូច្នេះប្រសិនបើកុមារមិនបានចូលរៀនឱ្យបានសមស្រប និងឆ្លងពីភូមិសិក្សាមួយទៅសិក្សាមួយ ឬមិនបានរៀនខ្ពស់ទៅតាមការកំណត់ ឬគោលដៅរបស់រដ្ឋាភិបាលទេ អាចបង្កភាពរញ៉េរញ៉ៃនៅក្នុងសង្គម ដូចជាការប្រើអំពើហិង្សាក្នុងគ្រួសារ ភាពចលាចលនៅក្នុងសង្គមជាដើម។ល។

Katharina, et al. (2018) បានវិភាគពីសំណាកគំរូដ៏ធំមួយពីភាពមិនប្រក្រតី និងសិក្សាពីស្ថានភាពសុខភាពរ៉ាំរ៉ៃ។ ដើម្បីកំណត់អត្តសញ្ញាណនៃការសិក្សា គាត់បានកំណត់ពីកំណែទម្រង់វិស័យអប់រំសំខាន់ៗពីរ ដែលទី១ កំណត់អាយុអប្បបរមាសម្រាប់ការបោះបង់ការសិក្សា និងទី២ កំណត់ពីផលប៉ះពាល់ដល់ការរីកចម្រើននៃការអប់រំ។ វិធីសាស្ត្រនេះ ប៉ាន់ស្មានយ៉ាងច្បាស់លាស់ អំពីផលប៉ះពាល់នៃការអប់រំលើស្ថានភាពសុខភាពដ៏ទូលំទូលាយ។ លទ្ធផលនៃការសិក្សានេះបានបង្ហាញថាការអប់រំបន្ថែម ដែលបានឆ្លងភូមិសិក្សាពីភូមិសិក្សាមួយទៅភូមិសិក្សាមួយគឺមានផលប៉ះពាល់តិចតួចទៅលើការរីករាលដាលនៃជំងឺរ៉ាំរ៉ៃជាពិសេសជំងឺទឹកនោមផ្អែម។

## ២.៥ យុទ្ធសាស្ត្របង្កើនអត្រាបញ្ចប់ការសិក្សា

យុទ្ធសាស្ត្រភាគច្រើនដែលអ្នកស្រាវជ្រាវប្រើ ដើម្បីទប់ស្កាត់អត្រាទាបបំផុត គឺត្រូវបណ្តុះបណ្តាលគ្រូបង្រៀន។ យោងទៅតាម Farooq គ្រូបង្រៀនគឺជាដំណោះស្រាយដ៏សំខាន់ដើម្បីកាត់បន្ថយការបោះបង់សិស្ស។ Ruff (2016) បានលើកឡើងថាអាកប្បកិរិយាដ៏រឹងមាំរបស់គ្រូ

បង្រៀនមានឥទ្ធិពលលើការរៀនសូត្ររបស់សិស្ស។ ស្រដៀងគ្នាទៅនឹង Okwach Abagi (1997) និងChae Young Kim & Martyn Rouse (2011) លើកឡើងថាគោលការណ៍និងគ្រូបង្រៀនគឺមានតួនាទីសំខាន់បំផុតក្នុងការអប់រំរបស់សិស្ស។ គ្រូបង្រៀនដើរតួនាទីដ៏ចម្បងក្នុងការថែរក្សាការអប់រំរបស់សិស្ស ប៉ុន្តែគ្រូបង្រៀនក៏ត្រូវការការបង្ហាត់បង្រៀន ដុសខាត់ បណ្តុះបណ្តាលបន្ថែមទៀតឱ្យបានច្រើន ដើម្បីបង្ហាត់បង្រៀនសិស្សឱ្យកាន់តែប្រសើរឡើង ។ ជាងនេះទៀត គ្រូត្រូវយកចិត្តទុកដាក់បន្ថែមទៀតទៅលើការរៀនសូត្ររបស់សិស្ស ហើយត្រូវដាក់គ្រូបង្រៀន ដែលមានបទពិសោធន៍បង្រៀននៅថ្នាក់ទី៣ (Ricardo Sabates, 2011)។ Chae Young Kim & Martyn Rouse (2011, p.426 as cited in MoEYS 2007b) បញ្ជាក់ថាមួយក្នុងចំណោមគោលវិធីនៃសាលាកុមារមេត្រី ទាមទារឱ្យមានការយកចិត្តទុកដាក់ទៅលើអាកប្បកិរិយា ឥរិយាបថ និងគុណតម្លៃរបស់គ្រូ ក្នុងន័យនេះ ប្រសិនបើការជំរុញលើកទឹកចិត្តគ្រូនៅមានកម្រិតអាចធ្វើឱ្យគ្រូមិនសូវយកទុកដាក់ និងទទួលខុសត្រូវក្នុងការបង្រៀនសិស្ស។ ដើម្បីបង្កើនអត្រាបញ្ចប់ការសិក្សា គឺទាមទារនូវការបណ្តុះបណ្តាលគ្រូបន្ថែម បន្ថែមសម្ភាររូបវន្តដើម្បីធ្វើឱ្យមានបរិយាកាសសិក្សាល្អ និងការផ្តល់ថ្នាក់បន្ថែមសមស្របដល់សិស្ស ដែលប្រឈមនឹងការរៀនត្រួតថ្នាក់ ការជួយទ្រទ្រង់លើបញ្ហាជីវភាព ដូចជាការដោះស្រាយលើសម្ភារ និងការចំណាយលើការសិក្សាជាដើម ការលើកកម្ពស់សុខភាពកុមារនិងការរៀនសូត្រ (Admassu, 2015)។ លើសពីនេះទៀត ត្រូវមានកម្មវិធីសិក្សា សម្ភារសិក្សា ម៉ោងបង្រៀន ការបង្រៀនក្នុងថ្នាក់រៀន សមត្ថភាពរៀនសូត្ររបស់សិស្ស ការបង្កើនអត្រាពិតនៃការសិក្សា រួមជាមួយនឹងអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា ការធ្វើឱ្យមានតុល្យភាពរវាងយេនឌ័រនៅទីក្រុង និងជនបទ (Boissiere, 2004) ស្រដៀងគ្នានេះដែរ Githaka Mwangi (2017) បានលើកឡើងថាការផ្តល់កម្មវិធីជួយដល់អ្នកក្រីក្រ គឺជាមធ្យោបាយល្អប្រសើរក្នុងការបង្កើនអត្រាបញ្ចប់នៃការសិក្សា។

កម្មវិធីផ្តល់អាហារូបករណ៍ អាហារថ្ងៃត្រង់ អាហារពេលល្ងាចតាមតម្រូវការ ការផ្តល់ សម្ភារបរិក្ខារនិងសម្ភារសិក្សាមូលដ្ឋាន ការពង្រឹងវិធីសាស្ត្របង្រៀនដែលមានគុណភាពសម្រាប់កុមារ ការណែនាំអំពីបទប្បញ្ញត្តិចំពោះការបោះបង់ការសិក្សា ការលើកទឹកចិត្តគ្រូនិងកុមារពីរភាសា (ភាសាកំណើត) ក៏ជាមធ្យោបាយធ្វើឱ្យអត្រាបញ្ចប់ការសិក្សាខ្ពស់ដែរ (Shree Prasad Devkota, 2015)។ ចំណែកឯ MULI (2014) លើកឡើងថាក្រសួងអប់រំ យុវជន និងកីឡាគួរបង្ហាញពីតម្លៃនៃការសិក្សានិងផ្តល់ការគាំទ្រដល់កុមារក្រីក្រអំពីការអប់រំដល់អ្នកពាក់ព័ន្ធ។

# ជំពូក ៣៖ ការរចនានិងវិធីសាស្ត្រនៃការសិក្សា

## ៣.១ វិសាលភាពនិងដែនកំណត់នៃការសិក្សា

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដោយគ្របដណ្ដប់លើ១២ខេត្ត ៣៦ក្រុងស្រុក និង១៤៤ សាលា ដែលមានអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិទាបជាង៤០% និងបឋមសិក្សាទាបជាង៨០% ដែលក្នុងនោះមានខេត្តបន្ទាយមានជ័យ បាត់ដំបង កែប កោះកុង ក្រចេះ ប៉ៃលិន ឧត្ដរមានជ័យ ព្រះសីហនុ រតនគិរី ស្ទឹងត្រែង ត្បូងឃ្មុំ និងមណ្ឌលគិរី។

## ៣.២ ប្រភេទអ្នកចូលរួមនៃការសិក្សា

សំណាកគំរូនៃការសិក្សានេះ ត្រូវបានជ្រើសរើសដោយចៃដន្យ ដែលធ្វើឡើងតាមប្រព័ន្ធកុំព្យូទ័រក្នុងចំណោមខេត្តទាំង១២ ដែលមានអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិទាបជាង៤០% និងទាបជាង៨០%សម្រាប់បឋមសិក្សា។ ក្នុងចំណោមអ្នកចូលរួមទាំងនោះរួមមាន ប្រធានឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាចំនួន១២នាក់ ប្រធានឬអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា៣៦នាក់ អាជ្ញាធរក្រុងស្រុក២៧នាក់ អាជ្ញាធរឃុំសង្កាត់ ៨៨នាក់ នាយកឬនាយករងនៃសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ១៤៣នាក់ លោកគ្រូអ្នកគ្រូបង្រៀនថ្នាក់ទី៦នៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិថ្នាក់ទី៩ចំនួន១៤៤នាក់ លើសពីនេះទៀត ដើម្បីឱ្យទិន្នន័យកាន់តែមានភាពជឿជាក់ ក្រុមការងារស្រាវជ្រាវបានជ្រើសរើសឪពុកម្ដាយសិស្សដែលមានកូនរៀនថ្នាក់ទី៦និងទី៩ចំនួន១៤៤នាក់ និងឪពុកម្ដាយសិស្សមានកូនអាយុពី១៣-២០ឆ្នាំចំនួន៦៣៤នាក់ ដែលសរុបអ្នកផ្ដល់ចម្លើយ១២០០នាក់ ហើយសាលាដែលបានជ្រើសរើសយកតែសាលារៀនគ្រប់កម្រិតតែប៉ុណ្ណោះ។

## ៣.៣ ឧបករណ៍នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះបានប្រើវិធីសាស្ត្របែបបរិមាណវិស័យ (Quantitative Method) ដោយអ្នកចូលរួមទាំងអស់ តម្រូវឱ្យបំពេញកម្រងសំណួរដែលបានរៀបចំរួច និងបែបគុណវិស័យ (Qualitative Method) តាមរយៈការសម្ភាសពាក់កណ្ដាលផ្លូវការដើម្បីបញ្ជាក់ពីភាពជឿជាក់នៃទិន្នន័យ។



## ៣.៤ ការប្រមូល ការបញ្ចូល និងការវិភាគទិន្នន័យ

បន្ទាប់ពីរៀបចំឧបករណ៍ស្រាវជ្រាវរួចរាល់ហើយ ក្រុមការងារស្រាវជ្រាវ នាយកដ្ឋានគោលនយោបាយ (DoPo) នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) និងនាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃ (M&E) បានចុះប្រមូលទិន្នន័យទៅតាមគោលដៅនិងទីកន្លែងដែលបានគ្រោងទុក។ ទិន្នន័យធ្វើឡើងតាមរយៈការសម្ភាសពាក់កណ្ដាលផ្លូវការនិងបំពេញកម្រងសំណួរក្នុងនោះអ្នកចូលរួមបានបំពេញកម្រងសំណួរដែលបានរៀបចំរួច ហើយសំណួរមួយចំនួនត្រូវសម្ភាសពាក់ កណ្ដាលផ្លូវការដើម្បីបកស្រាយបន្ថែមនិងបញ្ជាក់ពីភាពជឿជាក់។ ក្រោយពីបានប្រមូលទិន្នន័យរួចរាល់ហើយ ក្រុមការងារបានបញ្ចូលទិន្នន័យទៅក្នុងកម្មវិធី Excel ដែលបានរៀបចំជាគំរូ (Template) ហើយក្រុមការងារបានរៀបចំសម្អាតទិន្នន័យមុននឹងបំលែងទៅក្នុងកម្មវិធី SPSS, Version 23 ដើម្បីធ្វើការវិភាគទិន្នន័យផ្អែកទៅតាមគោលបំណង និងកម្រងសំណួរនៃការស្រាវជ្រាវហើយ ក្រុមស្រាវជ្រាវបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ពិភាក្សាផ្ដល់យោបល់ជាធាតុចូល និងផ្ទៀងផ្ទាត់ពីភាពជឿជាក់បន្ថែមលើទិន្នន័យដែលបានរកឃើញ។

## ៣.៥ ក្របខណ្ឌនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះផ្អែកជាចម្បងលើទិន្នន័យ ផ្ដល់ដោយនាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (សិស្សតាមអាយុ) និងទិន្នន័យពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ (ស្ថិតិចំណោលប្រជាជនតាមអាយុ)។ ម្យ៉ាងទៀត ដើម្បីធានានូវសុក្រឹតភាពនិងភាពជឿជាក់លើទិន្នន័យ ក្រុមស្រាវជ្រាវសម្ភាសបែបពាក់កណ្ដាលផ្លូវការ (ពាក់កណ្ដាលបើក)បន្ថែមទៀតជាមួយនឹងអ្នកផ្ដល់ចម្លើយនៅថ្នាក់ក្រោមជាតិ។ ក្រុមស្រាវជ្រាវក៏បានសិក្សាលើឯកសារពាក់ព័ន្ធរួមមានសូចនាករនិងគោលដៅរបស់សហគមន៍អ៊ឺរ៉ុប ទិន្នន័យប្រជាសាស្ត្រដែលបានមកពីការព្យាករណ៍ ជំរឿន និងឯកសារពាក់ព័ន្ធនឹងការអនុវត្តជាក់ស្ដែងលើការគណនា អត្រាបញ្ចប់ការសិក្សា ដែលធ្វើឡើងនៅប្រទេសកម្ពុជាក៏ដូចជាប្រទេសដទៃទៀត។

## ៣.៦ ការជ្រើសរើសសំណាកគំរូ និងទីតាំងសម្រាប់សិក្សា

ការជ្រើសរើសសំណាកគំរូ ផ្អែកទៅតាមទិន្នន័យរបស់នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ២០១៧-២០១៨ទាំងខេត្ត១២ ដែលមានអត្រាបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិទាបជាង៤០% និងបឋមសិក្សាទាបជាង៨០%។ ខេត្តទាំង១២ត្រូវបានជ្រើសរើសជាខេត្តគោលដៅក្នុងការសិក្សា ហើយស្រុកនីមួយៗ ក្រុមការងារស្រាវជ្រាវបានជ្រើសយកដោយចេតនានូវសាលារៀនបឋមសិក្សា២ និងអនុវិទ្យាល័យ២។

## ៣.៦ ការរៀបចំឧបករណ៍ស្រាវជ្រាវ

ក្រោយពីក្រុមការងារស្រាវជ្រាវបានរៀបចំឯកសារទស្សនទាន (Concept Note) និងមានការឯកភាពពីថ្នាក់ដឹកនាំនៃក្រសួងអប់រំ យុវជន និងកីឡារួចមក ក្រុមការងារស្រាវជ្រាវបានរៀបចំសំណើស្រាវជ្រាវ (Research Proposal) លំនាំនិងដំណើរការនៃការស្រាវជ្រាវជូនថ្នាក់ដឹកនាំ។ បន្ទាប់មកទៀតក្រុមការងារបានសិក្សាទៅលើឯកសារសំខាន់ៗដើម្បីបានជាគោលគំនិតក្នុងការរៀបចំបង្កើតឧបករណ៍ស្រាវជ្រាវឱ្យស្របទៅតាមគោលបំណងនៃការស្រាវជ្រាវ។ ការងារស្រាវជ្រាវនេះដឹកនាំដោយនាយកដ្ឋានគោលនយោបាយ សហការជាមួយនាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងនាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ។ ក្រៅពីនេះ គម្រោងស្រាវជ្រាវ ក៏បានសហការផងដែរពីនាយកដ្ឋានបឋមសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងនាយកដ្ឋានជំនាញដទៃទៀតនៃក្រសួងអប់រំ យុវជន និងកីឡា។



# ជំពូក ៤៖ របកគំហើញ

## ៤.១ របកគំហើញនៃការសិក្សា

### ៤.១.១ បម្រែបម្រួលចំនួនប្រជាជន

#### ៤.១.១.១ ស្ថិតិប្រជាជនតាមអាយុជាក់លាក់

ផ្អែកតាមទិន្នន័យបែបបរិមាណវិស័យនិងគុណវិស័យ ដែលទទួលបានពីមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក អាជ្ញាធរក្រុងស្រុក និងសាលារៀនបង្ហាញថា ស្ថិតិប្រជាជនតាមអាយុជាក់លាក់ឆ្នាំ២០១៧មានបញ្ហាប្រឈមខ្លះទាក់ទងនឹងទិន្នន័យប្រជាជនតាមអាយុ ជាពិសេសអាយុ១១ឆ្នាំដល់១៩ឆ្នាំ។ បញ្ហាទាំងនេះជាបុព្វហេតុដែលធ្វើឱ្យលំបាកក្នុងការគណនាអត្រាបញ្ចប់ការសិក្សានិងគណនាសូចនាករផ្សេងៗ។ មន្ទីរអប់រំ យុវជន និងកីឡា ១៦.៦៦%មិនមានទិន្នន័យប្រជាជនតាមអាយុពី១១ឆ្នាំដល់១៩ឆ្នាំនៅពេលការិយាល័យអប់រំ យុវជន និងកីឡា១១.១១% មិនមានទិន្នន័យប្រជាជនតាមអាយុពី១១ឆ្នាំដល់១៩ឆ្នាំ ហើយ ២.៧៧% មិនមានទិន្នន័យប្រជាជនចាប់ពី១៥ឆ្នាំដល់១៩ឆ្នាំ និង២.៧៧%ផ្សេងទៀត មិនមានទិន្នន័យប្រជាជនចាប់ពី១៨ឆ្នាំដល់១៩ឆ្នាំ ព្រមទាំង២២.២២%មិនមានទិន្នន័យប្រជាជនអាយុ១៩ឆ្នាំ។ ចំពោះអាជ្ញាធរក្រុងស្រុកវិញ ៩០.៧៤%មិនមានទិន្នន័យប្រជាជនចាប់ពី១១ឆ្នាំដល់១៩ឆ្នាំ រីឯសាលារៀន ២៨.៦៧%មិនមានទិន្នន័យប្រជាជនចាប់ពីអាយុ១១ឆ្នាំដល់១៩ឆ្នាំ។

#### ៤.១.១.២ ការប្រើប្រាស់ស្ថិតិប្រជាជន

មន្ទីរអប់រំ យុវជន និងកីឡាទាំង១២ មាន៧៥%ធ្លាប់ប្រើប្រាស់ស្ថិតិចំណោលប្រជាជន រីឯមន្ទីរអប់រំ យុវជន និងកីឡា២៥%ទៀតមិនដែលប្រើប្រាស់ស្ថិតិប្រជាជនទេ។ ក្នុងនោះមន្ទីរអប់រំ យុវជន និងកីឡាប្រើប្រាស់ស្ថិតិចំណោលប្រជាជន ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) គណនាសូចនាករផ្សេងៗ ដូចជាអត្រាចូលរៀន អត្រានៃការសិក្សា រកចំនួនប្រជាជនដល់វ័យសិក្សានៅមត្តេយ្យសិក្សាតាមអាយុ និងធ្វើតម្រូវទៅតាមច្បាប់ស្ថិតិដែលទទួលស្គាល់ជាផ្លូវការ។ ចំពោះការិយាល័យអប់រំ យុវជន និងកីឡា ៩១.៦៦%ធ្លាប់ប្រើស្ថិតិចំណោលប្រជាជនក្នុងគោលបំណងដើម្បីចង់ដឹងពីតួលេខច្បាស់លាស់ ព្រមទាំងរកឱ្យឃើញពីចំនួនប្រជាជនកើនថយ ឬជាក់ស្ដែង ប្រៀបធៀប និងប្រមូលជាក់ស្ដែង បំពេញសូចនាកររបស់នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) យកតាមផែនការរបស់មន្ទីរផែនការខេត្ត និងសម្រាប់គណនាសូចនាករផ្សេងៗ ដូចជាអត្រាបញ្ចប់ការសិក្សា គណនាអត្រាពិត អត្រារួមនៃការចូលរៀនរបស់

សិស្សជាដើម ប៉ុន្តែនៅមានការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក ៥៨.៣៥%មិនធ្លាប់ប្រើប្រាស់ស្ថិតិចំណោលប្រជាជនទេ។ ចំណែកអាជ្ញាធរក្រុងស្រុក៣៣.៣៥% ធ្លាប់យល់ដឹងពីស្ថិតិចំណោលប្រជាជនមានភាពខុសគ្នា ជាមួយនឹងស្ថិតិជាក់ស្តែង ដោយសារប្រជាជនផ្លាស់ចេញ ផ្លាស់ចូល ចំណាកស្រុករយៈពេលវែង (ទៅធ្វើការក្រៅប្រទេស) ចំណាកស្រុករយៈពេលខ្លីពោលគឺប្រជាជនចូលឬចេញទៅតាមរដូវកាល ដូចជារដូវប្រមូលផលកសិកម្ម។ម៉្យាងវិញទៀត ការទទួលឬផ្តល់ព័ត៌មានមិនច្បាស់លាស់ពីប្រជាជន ឬពីអ្នកប្រមូលខ្លួនឯងដែលស្ថិតិទាំងនេះទទួលបានមកពីស្ថិតិប្រជាជនរបស់អធិការដ្ឋាននគរបាលក្រុងស្រុក។ ក្រៅពីនោះ ក្រុងស្រុក ៦៦.៦៦%ផ្សេងទៀត មិនបានដឹងពីការធ្វើស្ថិតិចំណោលទេ (ឧបសម្ព័ន្ធ២)។

### ៤.១.១.៣ ស្ថិតិប្រជាជនជាក់ស្តែងនិងចំណោលប្រជាជន

មន្ទីរអប់រំ យុវជន និងកីឡា១០០% បានឆ្លើយថាស្ថិតិជាក់ស្តែងខុសពីស្ថិតិចំណោល ដែលកត្តានេះអាចបណ្តាលមកពីស្ថិតិចំណោលដោយគ្រាន់តែរាប់បន្ថែមពីមួយឆ្នាំទៅមួយឆ្នាំចំណែកឯស្ថិតិប្រជាជនប្រមូលជាក់ស្តែងកើនឬថយពីមួយឆ្នាំទៅមួយឆ្នាំ ហើយម៉្យាងទៀត ស្ថិតិប្រជាជនមានការកើនឡើងតិចតួច តែការធ្វើចំណោលប្រជាជនពីក្រសួងផែនការមានលក្ខណៈខ្ពស់ពេកខុសពីចំនួនជាក់ស្តែង ឧទាហរណ៍ នៅក្នុងក្រុងសែនមនោរម្យ គឺចំណោលខ្ពស់ជាងស្ថិតិជាក់ស្តែង។ នៅស្រុកពេជ្រាដាការធ្វើចំណោលទាប ចំណែកចំនួនប្រជាជនជាក់ស្តែងមានការកើនឡើងដោយមានចំណូលប្រជាជនពីក្រៅស្រុក។ ស្ថិតិចំណោលប្រជាជនគឺជាការប៉ាន់ស្មានចំណែកឯស្ថិតិប្រជាជនប្រមូលជាក់ស្តែងជាចំនួនមនុស្សពិតជាក់ស្តែង ព្រោះថា ប្រជាជនមានការផ្លាស់ប្តូរទីលំនៅ ចំណាកស្រុក ចំណូលស្រុក ម៉្យាងវិញទៀតស្ថិតិប្រជាជនរបស់ក្រសួងផែនការមានរយៈពេលវែង(រយៈពេល១០ឆ្នាំម្តងឬពាក់កណ្តាលជំរឿនថ្នាក់ជាតិ) តែផ្ទុយទៅវិញពីមួយឆ្នាំទៅមួយឆ្នាំចលនាប្រជាជនប្រែប្រួលពីកន្លែងមួយទៅកន្លែងមួយ ដោយសារប្រជាជនធ្វើចំណាកស្រុករកដីកសិកម្មថ្មីឬរកការងារធ្វើ។ ជាទូទៅស្ថិតិប្រជាជនមូលដ្ឋានច្រើនជាងស្ថិតិចំណោលរបស់ក្រសួងផែនការ ហើយតួលេខភាគច្រើនមានភាពស្មុគស្មាញ ដោយសារសាលាភាគច្រើនមិនបានធ្វើផែនទីតាមខ្នងផ្ទះ លើសពីនេះទៀត ពេលវេលានៃការប្រមូល ការស្រង់ចំនួនប្រជាជនរបស់ក្រសួងផែនការមិនឆ្លើយតបទៅនឹងការស្រង់ចំនួនប្រជាជនពីថ្នាក់ឃុំសង្កាត់ និងមន្ទីរអប់រំ យុវជន និងកីឡាជាក់ស្តែង ហើយកាលបរិច្ឆេទនៃការប្រមូលមានភាពខុសគ្នាដោយហេតុថា ស្ថិតិប្រជាជនជាក់ស្តែងមានការកើនឡើង ឬថយចុះមិនទៀងទាត់ ហើយការប្រមូលស្ថិតិជាក់ស្តែងមិនបានប្រើរូបមន្តព្យាករណ៍ឱ្យបានច្បាស់លាស់ ដោយគ្រាន់តែបូកសរុបតួលេខ

ទិន្នន័យប្រជាជន ដែលប្រមូលបានដោយផ្ទាល់តែប៉ុណ្ណោះ។ លើសពីនេះទៀត ភាពខុសគ្នារវាងស្ថិតិចំណោលនិងការរាប់ជាក់ស្តែង អាចបណ្តាលមកពីកត្តាប្រជាជនចំណូលថ្មី (កើតភូមិថ្មី) ការស្រង់មិនមានមូលហេតុច្បាស់ ការចុះអត្តសញ្ញាណមិនទាន់ត្រឹមត្រូវដែលការស្រង់គ្រាន់តែប៉ាន់ស្មាន មន្ត្រីស្រង់ស្ថិតិ (នាយកសាលា លោកគ្រូ អ្នកគ្រូ) ចុះស្រង់មិនបានពេញលេញ ខ្វះជំនាញ ហើយធ្វើមិនបានគ្រប់ជ្រុងជ្រោយដោយសារពេលខ្លះនៅពេលចុះស្រង់ស្ថិតិប្រជាជនកំពុងរស់នៅ តែពេលស្រង់ស្ថិតិរួច គាត់ចំណាកស្រុក ក្រៅពីនេះ ទិន្នន័យរបស់ឃុំសង្កាត់ដែលផ្តល់មកសាលារៀន ក៏ខុសគ្នាពីទិន្នន័យរបស់មន្ទីរផែនការខេត្តផងដែរ។ ម៉្យាងទៀតការធ្វើចំណោលគឺកើនឡើងតាមជាលក្ខណៈស៊ីត តែប្រជាជនជាក់ស្តែងមិនអាចកើនឡើងតាមលំដាប់ដែលបានគ្រោងទុកនោះទេ។ តួលេខរបស់មន្ទីរផែនការធ្វើតាមចំណោលច្រើនជាងតួលេខប្រជាជនចុះប្រមូលជាក់ស្តែង ព្រោះថាស្ថិតិប្រជាជនប្រមូលជាក់ស្តែងធ្វើឡើងមួយឆ្នាំម្តង ហើយចំណោលរបស់មន្ត្រីផែនការប្រើប្រាស់ទិន្នន័យឆ្នាំចាស់ តែការប្រមូលជាក់ស្តែងធ្វើឡើងតាមឆ្នាំនីមួយៗ ហើយប្រជាជនមានការប្រែប្រួលមិនទៀងទាត់ ដោយសារមានចំណាកស្រុក ចំណូលស្រុក ការផ្លាស់ទីលំនៅ មរណៈភាព ការចុះស្រង់មិនបានច្បាស់នៅតាមមូលដ្ឋាន។ល។ ដែលកត្តាទាំងនេះ ធ្វើឱ្យរបាយការណ៍ប្រជាជនទទួលបានមានភាពមិនប្រក្រតីខុសពីទិន្នន័យជាក់ស្តែង ដែលពេលខ្លះអាចផតឬប៉ោង។ ការិយាល័យអប់រំ យុវជន និងកីឡាចុះជំរឿនជាក់ស្តែង និងការបូកសរុបស្ថិតិថ្នាក់ក្រុងស្រុកផែនការ គណនាចំណោលប្រើរូបមន្តផ្សេងៗគ្នាហើយ កត្តាខុសគ្នាខ្លាំងលើបញ្ហាស្ថិតិ ដែលកត្តានេះអាចបណ្តាលមកពីកត្តាពេលវេលានៃការចុះប្រមូលទិន្នន័យ ដែលមានន័យថាការចុះប្រមូលទិន្នន័យប្រើពេលវេលាផ្សេងគ្នាទទួលបានទិន្នន័យខុសគ្នាដែរ។

### ៤.១.១.៤ ស្ថិតិសិស្សថ្នាក់បញ្ចប់បឋមសិក្សា

ខេត្តដែលមានសិស្សចូលរៀនថ្នាក់ទី៦នៃឆ្នាំសិក្សា២០១៧-២០១៨ ខ្ពស់ជាងគេក្នុងចំណោមខេត្តទាំង១២ (ឧបសម្ព័ន្ធ៣) គឺខេត្តបាត់ដំបងដែលមានសិស្សសរុប២១ ៧១០នាក់ (ស្រី១០ ៩២៦នាក់) និងខ្ពស់បន្ទាប់គឺខេត្តត្បូងឃ្មុំមាន១៥ ១០៨នាក់ (ស្រី៧៥៨៤) រីឯខេត្តខ្ពស់ទី៣គឺខេត្តបន្ទាយមានជ័យដែលសិស្សសរុប១២ ៥០៥នាក់ (ស្រី៦៤១៨នាក់) ចំណែកខេត្តដែលមានសិស្សទាបជាងគេគឺខេត្តកែប (សរុប៧០២នាក់ ស្រី៣៤៣នាក់) និងទាបបន្ទាប់គឺខេត្តប៉ៃលិន (សិស្សសរុប១ ២៩៤នាក់ ស្រី៦៧៦នាក់) និងខេត្តទាបបន្ទាប់ទី៣គឺខេត្តកោះកុងដែលមានសិស្សសរុប២១៩២នាក់ ស្រី១១៣៣នាក់)។ តាមស្ថិតិសិស្សចូលរៀនថ្នាក់ទី៦នៃឆ្នាំសិក្សា២០១៧-២០១៨

ឃើញថា ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ៣២២១នាក់ ស្រី១៦០៥នាក់ និងស្រុកចិត្របូរី៤២១៨នាក់ ស្រី៦៣៤នាក់ ខេត្តក្រចេះ មានសិស្សរៀនថ្នាក់ទី៦ខ្ពស់ជាងគេ និងខ្ពស់បន្ទាប់មានស្រុកកំរៀង និងស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលក្នុងនោះមានស្រុកដែលមានអត្រាទាបជាងគេ គឺស្រុកកោះញែក ខេត្តមណ្ឌលគិរី និងស្រុកសៀមប៉ាង ខេត្តរតនគិរី។

សិស្សថ្នាក់ទី៦តាមស្រុកក្រុងគោលដៅឆ្នាំសិក្សា២០១៧-២០១៨រវាងសិស្សស្រីនិងសិស្សប្រុសមានលក្ខណៈប្រហាក់ប្រហែលគ្នា លើកលែងតែស្រុកចិត្របុរីមួយប៉ុណ្ណោះ មានសិស្សប្រុសច្រើនលើសលុបជាងសិស្សស្រី។

*ក្រាហ្វិក១.១ ស្ថិតិសិស្សថ្នាក់ទី៦តាមស្រុកក្រុងគោលដៅឆ្នាំសិក្សា២០១៧-២០១៨*



### ៤.១.១.៥ ស្ថិតិសិស្សដើមឆ្នាំនិងត្រួតថ្នាក់ទី៦ឆ្នាំសិក្សា២០១៧-២០១៨

សិស្សដើមឆ្នាំនិងត្រួតថ្នាក់ទី៦តាមរាជធានីខេត្តឆ្នាំសិក្សា២០១៧-២០១៨ឃើញថា សិស្សត្រួតថ្នាក់ទី៦មានការប្រែប្រួលទៅតាមចំនួនសិស្សដើមឆ្នាំសិក្សា និងចំនួនសិស្សត្រួតថ្នាក់ ដែលមានន័យសិស្សដើមឆ្នាំច្រើន ក៏មានសិស្សត្រួតថ្នាក់សមាមាត្រទៅតាមចំនួននោះ ច្រើន ឬតិចទៅតាមខេត្តនីមួយៗ ឧទាហរណ៍ ខេត្តបាត់ដំបងមានសិស្សដើមឆ្នាំច្រើន (២១ ៧១០នាក់) ហើយមានសិស្សត្រួតថ្នាក់ ៤៩៧នាក់ និងខេត្តត្បូងឃ្មុំមានសិស្សដើមឆ្នាំ ១៥ ១០៨នាក់ ហើយសិស្សត្រួតថ្នាក់ ៣៨៦នាក់ បើប្រៀបធៀបខេត្តតូចដូចជាខេត្តកែបមានសិស្សដើមឆ្នាំ៧០២នាក់ រីឯសិស្សត្រួតថ្នាក់មាន២១នាក់ និងខេត្តប៉ៃលិនមានសិស្សដើមឆ្នាំ១ ២៩៤នាក់ ហើយសិស្សត្រួតថ្នាក់១៧នាក់។

*ក្រាហ្វិក១.២ សិស្សដើមឆ្នាំនិងត្រួតថ្នាក់ទី៦តាមរាជធានីខេត្តឆ្នាំសិក្សា២០១៧-២០១៨*




### ៤.១.១.៦ ស្ថិតិសិស្សដើមឆ្នាំនិងត្រួតថ្នាក់ទី៩ឆ្នាំសិក្សា ២០១៧-២០១៨

អត្រាបញ្ចប់ការសិក្សាក៏មានភាពប្រែប្រួលទៅតាមបរិមាណសិស្សរៀន នៅតាមរាជធានីខេត្តនីមួយៗផងដែរ ពោលគឺខេត្តមានសិស្សច្រើន ក៏មានសិស្សរៀនត្រួតថ្នាក់ច្រើនដែរ ដូចជាខេត្តបន្ទាយមានជ័យ បាត់ដំបង និងត្បូងឃ្មុំជាដើម ហើយខេត្តដែលតូចមានសិស្សរៀនតិច ក៏មានសិស្សត្រួតថ្នាក់តិចដែរ ដូចជាខេត្តកែប ប៉ៃលិន ព្រះសីហនុ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ជាដើម។ល។

*ក្រាហ្វិក១.៣ សិស្សដើមឆ្នាំនិងត្រួតថ្នាក់ទី៩តាមរាជធានីខេត្តឆ្នាំសិក្សា២០១៧-២០១៨*




## ៤.១.១.៧ ប្រភពស្ថិតិប្រជាជន

តាមការអនុវត្តជាក់ស្តែងតាមកម្រិតនីមួយៗចាប់ពីមន្ទីរអប់រំ យុវជន និងកីឡា រហូតដល់ថ្នាក់សាលារៀនឃើញថាមានការប្រើប្រាស់ស្ថិតិប្រជាជនមកពីប្រភពផ្សេងៗគ្នា ក្នុងនោះមន្ទីរអប់រំ យុវជន និងកីឡា៥៨.៣៣%បានបញ្ជាក់ថា គាត់បានប្រើប្រាស់ស្ថិតិប្រជាជនមកពីនាយកដ្ឋានប្រព័ន្ធគ្រប់គ្រងអប់រំ (EMIS) ក្រសួងផែនការនិងមន្ទីរផែនការខេត្ត ចំណែកឯមន្ទីរ ៥០% បានប្រើស្ថិតិ ប្រមូលជាក់ស្តែង។ ចំពោះការិយាល័យអប់រំ យុវជន និងកីឡា៣០.៥៥%បានប្រើស្ថិតិចំណោលប្រជាជនមកពីនាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) ការិយាល័យអប់រំ យុវជន និងកីឡា១៩.៤៤%យកទិន្នន័យពីឃុំសង្កាត់ និង ៦៣.៨៨%យកទិន្នន័យពីការប្រមូលជាក់ស្តែង ចំណែកឯ ១៦.៦៦%ទៀត យកទិន្នន័យពីប្រភពផ្សេងៗមកធ្វើចំណោល ដូចជាទិន្នន័យពីមណ្ឌលសុខភាពតាមភូមិចំណុះ ទិន្នន័យឃុំតាមខ្នងផ្ទះ សាលារៀនសាធារណៈ និងឯកជនតាមរយៈនាយក នាយិកាដែលមានប្រធានភូមិជាអ្នកប្រមូល។ ក្នុងចំណោមនាយកនាយិកា១៨៣នាក់ ៦២.២៣%បានប្រើ ស្ថិតិចំណោលប្រមូលជាក់ស្តែងតាមរយៈផែនទីខ្នងផ្ទះឬផែនទីសិក្សា ៥៩.៥៩% ប្រើស្ថិតិឃុំសង្កាត់ ចំណែកឯ២០.២៧%ប្រើស្ថិតិមេប៉ុស្តិ៍ (ប៉ូលីស) និង

៩.៧៩%ទៀតប្រើស្ថិតិពីប្រភពផ្សេងៗ ដូចជាការចុះធ្វើស្ថិតិតាមខ្នងផ្ទះ មេភូមិ មណ្ឌលសុខភាព ជំរឿនស្ថិតិបឋមសិក្សា ប្រមូលតាមគ្រូបន្ទុកថ្នាក់ (SEC) និងការិយាល័យអប់រំ យុវជន និងកីឡាស្រុកជាដើម។

លោកគ្រូអ្នកគ្រូ៦១.៨០% ឆ្លើយថា ប្រើស្ថិតិពីភូមិ ឃុំសង្កាត់ រីឯ៤០.៩៧% ថា ប្រើស្ថិតិមេប៉ុស្តិ៍ (ប៉ូលីស) ១៨.២៧% ថាប្រើស្ថិតិពីគណៈកម្មការទ្រទ្រង់សាលា និង៨.៣៣%ថា ប្រើពីប្រភពផ្សេង ដូចជាការចុះស្រង់ខ្លួនឯងតាមផ្ទះ ចុះធ្វើផែនទីសិក្សា ស្រង់ស្ថិតិដោយផ្ទាល់ លោកគ្រូអ្នកគ្រូស្រង់តាមផ្ទះ ទីចាត់ការសាលា (នាយក) ចុះធ្វើជំរឿន និងមកពីការិយាល័យអប់រំ យុវជន និងកីឡា។ អាជ្ញាធរស្រុក១៨.៥១%ប្រើស្ថិតិពីមន្ទីរអប់រំ យុវជន និងកីឡា ៣៧.០៣%ប្រើស្ថិតិពីការិយាល័យផែនការក្រុងស្រុក ៥៩.២៥%ប្រើស្ថិតិពីការប្រមូលជាក់ស្តែងពីភូមិឃុំចំណុះ ក្នុងក្រុងស្រុក ២៥.៩២%ប្រើស្ថិតិពីមេប៉ុស្តិ៍ (ប៉ូលីស) ឃុំសង្កាត់ ៣៣.៣៣% យកពីអធិការក្រុងស្រុក និង៧.៤០%យកពីប្រភពផ្សេងៗ ដូចជាអគ្រានុកូលដ្ឋានជាដើម។

*ក្រាហ្វិក១.៤ ប្រភពទិន្នន័យប្រជាជន*




## ៤.១.១.៨ ប្រភពស្ថិតិសិស្ស

មន្ទីរអយក.១០០% បានយកទិន្នន័យស្ថិតិសិស្សពីសាលារៀន ៥៨.៣៣%បានមកពីការិយាល័យអយក.ក្រុងស្រុក ៥០%បានមកពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) និង៨.៣៣% យកមកពីប្រភពផ្សេងៗ ដូចជាលោកគ្រូ អ្នកគ្រូទទួលបន្ទុកថ្នាក់។ ចំណែកឯការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក ៣០.៥៥%យកស្ថិតិសិស្សពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS)

១៩.៤៤%យកមកពីការិយាល័យផែនការស្រុក ១៩.៤៤%យកទិន្នន័យឃុំសង្កាត់ រីឯ៦៣.៨៨% យកពីការប្រមូលជាក់ស្តែង និង១៦.៦៦%បានមកពីប្រភពផ្សេងៗដូចជាការប្រមូលតាមរយៈ នាយកសាលា ប្រធានភូមិជាអ្នកប្រមូល មណ្ឌលសុខភាព តាមភូមិចំណុះ ទិន្នន័យឃុំតាមខ្នងផ្ទះ ប្រមូលមកពីសាលារៀន សាធារណៈនិងឯកជន ជំរឿនស្ថិតិសិស្សបូកសរុបពីសាលារៀន និងការបំពេញតារាង Pri, Pre, Sec. ជាដើម។

*ក្រាហ្វិក១.៥ ប្រភពស្ថិតិសិស្ស*




## ៤.១.១.៩ ស្ថិតិប្រជាជនដល់វ័យសិក្សា

លោកគ្រូអ្នកគ្រូ៦១.៨០% បានបញ្ជាក់ថាគាត់មានស្ថិតិប្រជាជនដល់វ័យសិក្សាជាក់លាក់ តាមអាយុនៅថ្នាក់រៀនតាមរយៈបញ្ជីហៅឈ្មោះសិស្ស ដែលក្នុងនោះទទួលបានពីភូមិឃុំសង្កាត់ ៦១.៨០% ពីប៉ូលីស១៨.០៥% គណៈកម្មការទ្រទ្រង់សាលា១៨.៧៥% និងទទួលបានពីប្រភព ផ្សេង១.៤% ដូចជាការចុះធ្វើផែនទីសិក្សា លោកគ្រូអ្នកគ្រូស្រង់ស្ថិតិស្រង់ជាក់ស្តែងដោយផ្ទាល់ តាមផ្ទះ ទីចាត់ការសាលា (នាយកសាលា) ចុះធ្វើជំរឿន និងការិយាល័យអប់រំ យុវជន និងកីឡា។

## ៤.១.១.១០ ស្ថានភាពទូទៅនៃការសិក្សារបស់សិស្ស

សិស្សភាគច្រើនរៀន (៨៣.៦២%) ត្រូវអាយុទៅតាមអាយុដែលបានកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា ហើយសិស្សមិនដែលរៀនត្រួតថ្នាក់មានរហូតដល់៨៧.០៦% ចំណែក

សិស្ស៧៦.៧៣%មិនដែលធ្លាប់បោះបង់ការសិក្សា នៅពេលដែលសិស្ស៨៣.៦៣% បានរៀនចប់បឋមសិក្សា តែផ្ទុយទៅវិញមានតែ១៦.៣៧%ប៉ុណ្ណោះដែលរៀនមិនចប់បឋមសិក្សា។ ក្នុងនោះដែរមានសិស្សចូលរៀនលើសអាយុ១១.០២% ហើយសិស្សរៀនក្រោមអាយុ១៥.១៥% និងសិស្សរៀនត្រួតថ្នាក់១២.៩៤% (ក្រាហ្វិក១.៦)។

*ក្រាហ្វិក១.៦ ការសិក្សារបស់សិស្ស*




## ៤.១.២ របៀបគណនាអត្រាបញ្ចប់ការសិក្សា

### ៤.១.២.១ ប្រទពគណនាអត្រាបញ្ចប់ការសិក្សា

របៀបគណនាអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សានៅក្នុងចំណោមមន្ទីរអប់រំ យុវជន និងកីឡាទាំង១២ បានយកតួលេខប្រជាជនសម្រាប់គណនាអត្រាបញ្ចប់ការសិក្សាមកពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ៥០% រីឯ ៣៣.៣៣%យកពីក្រសួងផែនការ (តួលេខចំណោល) ៨.៣៣% យកពីមន្ទីរផែនការខេត្ត និង៨.៣៣%ទៀត យកតួលេខជាក់ស្តែងពីអាជ្ញាធរ។ សម្រាប់ផ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាវិញ ២២.២២%យកតួលេខពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំការិយាល័យផែនការស្រុក២២.២២% ទិន្នន័យឃុំសង្កាត់៥.៥៥% ដែលភាគច្រើនប្រើលេខ

ប្រជាជនដែលប្រមូលជាក់ស្តែង៣៣.៣៣% ចំណែកឯ ១៦.៦៦%យកតួលេខផ្សេងៗដូចជាការប្រមូលពីសាលាតាមរយៈនាយកសាលាស្រង់ចេញពីផែនទីខ្នងផ្ទះតាមសាលា និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ចំពោះនាយកសាលាបានបញ្ជាក់ផងដែរថា ការគណនាអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា ប្រើប្រាស់ស្ថិតិប្រជាជន ដែល៣៩.៩៦%បានមកពីការប្រមូលជាក់ស្តែងតាមរយៈផែនទីខ្នងផ្ទះ ឬផែនទីសិក្សា ៩.៨៩%បានមកពីឃុំសង្កាត់ ១.៣៩%បានមកពីមេប៉ុស្តិ៍ និង១៥.៣៨%បានពីប្រភពផ្សេងៗដូចជាការប្រមូលជាក់ស្តែង ឃុំសង្កាត់ មេប៉ុស្តិ៍ (ប៉ូលីស) ជាដើម។

ចំពោះការគណនាអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិតាមទិន្នន័យ បានមកពីមន្ទីរអប់រំ យុវជន និងកីឡា៥០%បានមកពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) ចំណែក ៤១.៦៦%បានមកពីក្រសួងផែនការ (តួលេខចំណោល) និង៨.៣៣%ប្រើតួលេខជាក់ស្តែងពីអាជ្ញាធរមូលដ្ឋាន តែក្នុងចំណោមមន្ទីរអប់រំ យុវជន និងកីឡាទាំង១២ គ្មានមន្ទីរអប់រំ យុវជន និងកីឡាណាមួយប្រើតួលេខមកពីមន្ទីរផែនការខេត្តឡើយ។ ស្រដៀងគ្នានេះដែរការិយាល័យអយក១៦.៦៦%ប្រើតួលេខមកពីប្រព័ន្ធព័ត៌មានគ្រប់គ្រង (EMIS) ១៣.៨៨%ប្រើតួលេខនៃការិយាល័យផែនការស្រុក ៥.៥៥%យកទិន្នន័យឃុំសង្កាត់ ចំណែក ៤៧.២២%យកទិន្នន័យបានមកពីការប្រមូលជាក់ស្តែងនិង១៦.៦៦%បានមកពីប្រភពផ្សេងៗដូចជាការប្រមូលពីសាលាតាមនាយកសាលា ផែនទីខ្នងផ្ទះ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ការគណនាអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិនេះ នាយកសាលា ១៦.៧៨%បានបញ្ជាក់ថាប្រើប្រាស់ស្ថិតិប្រជាជនបានពីការប្រមូលជាក់ស្តែងតាមរយៈផែនទីខ្នងផ្ទះ ឬផែនទីសិក្សា ១៣.២៨%បានមកពីឃុំសង្កាត់ និង១.៣៩%បានមកពីមេប៉ុស្តិ៍ (ប៉ូលីស) ចំណែកឯ ៩.០៩%បានមកពីប្រភពផ្សេងៗដូចជាជំរឿនស្ថិតិពីបឋមសិក្សា ប្រមូលតាមគ្រូបន្ទុកថ្នាក់ (SEC) និងការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុកជាដើម។

*ក្រាហ្វិក១.៧ ប្រភពគណនាអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ*




## ៤.១.២.៣ របៀបគណនាអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា

របៀបគណនាអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាទាំងថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាយល់ឃើញថា មានលក្ខណៈប្រហាក់ប្រហែលគ្នាគឺថា ការគណនានេះមានលក្ខណៈត្រឹមត្រូវរហូតដល់ជាង៨០% ដែលក្នុងនោះមន្ទីរអប់រំ យុវជន និងកីឡាមាន៨៣.៣៣% រីឯការិយាល័យអប់រំ យុវជន និងកីឡា៨៦.១១% ដែលអំណះអំណាង នេះហាក់ដូចគ្នាដែលផ្ទុយទៅនឹងទិន្នន័យដែលទទួលពីនាយកសាលាដែលក្នុងចំណោមនាយក សាលាទាំង៨១ មានតែសាលា២៣.៤៥%ប៉ុណ្ណោះបាននិយាយថាត្រឹមត្រូវ តែផ្ទុយទៅវិញមាន រហូតដល់៧៦.៥៥% បាននិយាយថារបៀបគណនាអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមិន ត្រឹមត្រូវ។ ដូច្នេះ ទិន្នន័យរវាងមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និង កីឡាមានលក្ខណៈស្រដៀងគ្នាដែលផ្ទុយពីទិន្នន័យរបស់នាយកសាលា។

### ៨.១.២.៨ របៀបគណនាអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ

ក្នុងចំណោមមន្ទីរអេយក.៦៦.៦៦%នាយកសាលា៦៦.៦៦%និងការិយាល័យអេយក.៧៥% យល់ឃើញថារបៀបគណនាអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិត្រឹមត្រូវ ចំណែកឯមន្ទីរអេយក.២៥% ការិយាល័យអេយក.២៥% និងនាយកសាលា៣៣.៣៣% យល់ឃើញថារបៀបគណនាអត្រាបញ្ចប់ការសិក្សានេះមិនត្រឹមត្រូវតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយទេ។ ចំពោះលោកគ្រូអ្នកគ្រូវិញ១៦.៦៦%ប៉ុណ្ណោះ បានបញ្ជាក់ថារបៀបគណនាអត្រាបញ្ចប់ការសិក្សាគឺត្រឹមត្រូវ តែផ្ទុយទៅវិញ មានរហូតដល់៦៣.៨៨%យល់ឃើញថា របៀបគណនានៃអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិមិនបានត្រឹមត្រូវ នៅពេលដែល១៥.២៧% ឆ្លើយថាមិនដឹង និង៤.១៦% មិនបានឆ្លើយ។ ជារួម ប្រសិនមើលចម្លើយតបនៃអ្នកផ្តល់ទិន្នន័យនៅថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា និងនាយកសាលា ហាក់ដូចជាមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅលើរបៀបគណនាអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ តែផ្ទុយទៅវិញទិន្នន័យដែលទទួលបានពីលោកគ្រូអ្នកគ្រូហាក់ដូចជាមានលក្ខណៈផ្ទុយគ្នា។ ក្នុងនោះដែរក្នុងចំណោមអ្នកផ្តល់ព័ត៌មានទាំងអស់ ចាប់តាំងពីថ្នាក់មន្ទីរអេយក. ការិយាល័យអេយក. នាយកសាលា លោកគ្រូអ្នកគ្រូ និងមាតាបិតាសិស្សឃើញថា អ្នកដែលយល់ដឹងអំពីអត្រាបញ្ចប់ការសិក្សាបានត្រឹមត្រូវទៅតាមនិយមន័យកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡាមានភាគរយតិចតួចណាស់ ប៉ុន្តែបើតាមការអង្កេតជាទូទៅថ្នាក់មន្ទីរអេយក.ថ្នាក់ការិយាល័យអេយក.និងនាយកសាលាមានការយល់ដឹងខ្ពស់មធ្យម តែផ្ទុយទៅវិញក្នុងចំណោមមាតាបិតាសិស្សទាំង១ ៨ ៨ នាក់ពុំមានអ្នកណាម្នាក់មានចំណេះដឹង ឬយល់ដឹងត្រឹមត្រូវ ទៅតាមការកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡាអំពីអត្រាបញ្ចប់ការសិក្សាឡើយ។

*ក្រាហ្វិក១.៨ របៀបគណនាអត្រាបញ្ចប់ការសិក្សា*




## ៤.១.២.៥ ការបណ្តុះបណ្តាលទាក់ទងនឹងការគណនាអត្រាបញ្ចប់ការសិក្សា

ទោះបីការយល់ដឹងអំពីអត្រាបញ្ចប់ការសិក្សានៅមានកម្រិតក្តី តែការបណ្តុះបណ្តាលលើការគណនាសូចនាករអប់រំនៅថ្នាក់មន្ទីរអប់រំ យុវជន និងកីឡាបានជិត១០០% ពោលគឺថ្នាក់មន្ទីរអប់រំ យុវជន និងកីឡាទទួលបានការបណ្តុះបណ្តាលរហូតដល់៩១.៦៦% ដែលក្នុងនោះមានតែ៨.៣៤%ប៉ុណ្ណោះពុំធ្លាប់ទទួលបានការបណ្តុះបណ្តាល។ ចំណែកឯ ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាវិញ ៧២.២២%ធ្លាប់ទទួលការបណ្តុះបណ្តាលលើការគណនាសូចនាករអប់រំ ដែលក្នុងនោះអ្នកទទួលបានការបណ្តុះបណ្តាលជាមធ្យម២ដងក្នុងម្នាក់ ចំណែកអ្នកដែលមិនធ្លាប់បណ្តុះ បណ្តាលមានតែ២៧.៧៨%។ តែចំពោះនាយកសាលាវិញហាក់ដូចមានចំនួនតិចជាងថ្នាក់ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា និងថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា ពោលគឺមានតែ៥៣.៨៤%ធ្លាប់ទទួលបានការបណ្តុះបណ្តាលលើការគណនាសូចនាករអប់រំ ដែលម្នាក់ជាមធ្យម បណ្តុះបណ្តាល១.៣ដង រីឯ ៤៦.១៦%មិនធ្លាប់ទទួលបានការបណ្តុះបណ្តាលទេ។ ជារួមក្នុងចំណោមអ្នកចូលរួមនៅថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ថ្នាក់ការិយាល័យអប់រំ យុវជន

និងកីឡា និងនាយកសាលា មានតែថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា និងថ្នាក់ការិយាល័យទេ ដែលភាគច្រើនទទួលបានការបណ្តុះ បណ្តាលលើការគណនាសូចនាករអប់រំ តែផ្ទុយទៅវិញ ចំពោះនាយកសាលា ការបណ្តុះបណ្តាលលើការគណនាសូចនាករហាក់ដូចជាមានកម្រិតនៅឡើយ(ឧបសម្ព័ន្ធ៥)។

### ៤.១.៣ បញ្ហាប្រឈមក្នុងការប្រមូលទិន្នន័យ

យោងទៅតាមទិន្នន័យទទួលបានពីអ្នកពាក់ព័ន្ធឃើញថា អ្នកចុះប្រមូលទិន្នន័យប្រជាជនមានបញ្ហាប្រឈមជាច្រើន ដែលធ្វើឱ្យការប្រមូលទិន្នន័យមិនមានភាពសុក្រឹតទៅតាមការចង់បាន។ ខាងក្រោមនេះគឺបញ្ហាប្រឈមមួយចំនួនរបស់ការិយាល័យអប់រំ យុវជន និងកីឡា និងអាជ្ញាធរស្រុក៖ ការចុះប្រមូលទិន្នន័យមិនបានជួបម្ចាស់ផ្ទះ (ទៅរកស៊ីនៅស្រុកថៃ ឬផ្លាស់ប្តូរទីលំនៅ ចំណូលនិងចំណាកស្រុកដោយមិនបានជម្រាបភូមិ ឃុំ) ការផ្តល់ព័ត៌មាននិងរបាយការណ៍មករដ្ឋបាលក្រុងមានភាពយឺតយ៉ាវ ចំណែកឯ ការយល់ដឹងរបស់មេភូមិនៅមានកម្រិត ខ្វះមធ្យោបាយធ្វើដំណើរសម្រាប់ចុះប្រមូលទិន្នន័យនៅតាមភូមិ ហើយភូមិឃុំមួយចំនួនមិនសូវយកចិត្តទុកដាក់ក្នុងការចុះស្រង់ដែល ធ្វើឱ្យការប្រមូលមិនសូវបានគ្រប់ៗគ្រួសារ។ រីឯនៅភូមិឃុំពុំមានថវិកាសម្រាប់ចុះប្រមូលទិន្នន័យ ហើយការយឺតយ៉ាវក្នុងការតាមដានពីកំណើនប្រជាជន និងផ្តល់របាយការណ៍មិនបានទៀងទាត់។ចំណែកឯមន្ត្រីការិយាល័យផែនការគាំទ្រក៏មានចំនួនតិចមិនអាចចុះប្រមូលបានទិន្នន័យទៅតាមតម្រូវការ។ ម៉្យាងវិញទៀត តួលេខថ្នាក់មន្ទីរ និងឃុំមិនស៊ីគ្នា មិនសុក្រឹត មិនដឹងជ្រើសរើសយកមួយណាពិតប្រាកដ ជាពិសេស ពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការចុះប្រមូល ហើយពេលខ្លះពេលចុះប្រមូលជាក់ស្តែង ប្រជាជនមិននៅផ្ទះ (នៅស្រែចំការ) អ្នកចំណូលថ្មីមិនមានឯកសារ។ ក្រៅពីបញ្ហាទាំងនេះក៏មានភាពមិនប្រាកដប្រជាពីមេភូមិ មេឃុំក្នុងការប្រមូលទិន្នន័យផងដែរ។ របាយការណ៍ពីប្រភពផ្សេងៗគ្នាមិនសុក្រឹត ហើយអង្គភាពខ្លះធ្វើបច្ចុប្បន្នភាពប្រចាំខែ ខ្លះប្រចាំឆ្នាំ ឬផែនការច្រើនឆ្នាំ។

សម្រាប់បញ្ហាប្រឈមរបស់នាយកសាលាវិញ ប្រហាក់ប្រហែលទៅនឹងបញ្ហាប្រឈមរបស់ការិយាល័យអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡាដែរ ដែលក្នុងនោះនាយកសាលាបានលើកឡើងពីបញ្ហាប្រឈម ដូចជា ទិន្នន័យស្ថិតិចុះជាក់ស្តែងពុំដូចគ្នានឹងទិន្នន័យប្រមូលបានថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡា ហើយការចុះឈ្មោះយឺតយ៉ាវ ផែនទីខ្នងផ្ទះមានការប្រែប្រួល (ចំណាកនិងចំណូលស្រុក)។

លើសពីនេះទៀត ការប្រមូលទិន្នន័យមិនបានជាក់លាក់ពីមូលដ្ឋាន ខ្វះការទំនាក់ទំនងល្អរវាងគ្រូនិងអាជ្ញាធរមូលដ្ឋាន ដែលជាហេតុមានការពិបាកក្នុងការប្រមូលទិន្នន័យដល់ផ្ទះប្រជាជន ហើយលោកគ្រូអ្នកគ្រូខ្លះមិនទាន់យល់ច្បាស់ពីខ្លឹមសារកម្រងសំណួរស្ថិតិ ហើយខ្វះថវិការៀបចំពេលវេលាមិនគ្រប់គ្រាន់ ខ្វះជំនាញបច្ចេកទេស ខ្វះរូបមន្តគណនា និងខ្វះឯកសារ។ ចំពោះទិន្នន័យដែលទទួលបានពីប្រភពផ្សេងៗមានភាពខុសគ្នា ដោយទិន្នន័យតាមគ្រួសារនីមួយៗមិនសូវពិតប្រាកដ (ខុសអាយុ) ហើយគ្រួសារខ្លះមិនសូវចូលរួម នៅពេលដែលនាយកថ្មីវិញមិនសូវយល់ដឹងអំពីការងារស្ថិតិ ហើយប្រជាពលរដ្ឋខ្លះមានទីលំនៅមិនពិតប្រាកដ គ្រួសារខ្លះគ្មានឯកសារគ្រប់គ្រាន់(គ្មានសំបុត្រកំណើតឬអត្រានុកូលដ្ឋាន) ហើយអ្នកប្រមូលវិញពុំយល់ច្បាស់ពីវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ ក្នុងនោះដែរមានអាណាព្យាបាលខ្លះមិនទាន់យល់ពីតម្លៃនៃការសិក្សា ដែលជាហេតុមិនបានជំរុញកូនឱ្យមកចុះឈ្មោះ ហើយខ្លះទៀត ចុះឈ្មោះហើយមិនមករៀន ឬបោះបង់ការសិក្សាពាក់កណ្តាលទី រីឯសិស្សខ្លះទៀតផ្អាកការសិក្សារយៈពេលខ្លីដោយមិនបានផ្តល់ដំណឹងដល់សាលា។

យ៉ាងណាក៏ដោយឃុំ សង្កាត់ក៏មានបញ្ហាប្រឈមស្រដៀងទៅនឹងការិយាល័យអប់រំ យុវជននិងកីឡា និងនាយកសាលាផងដែរ បើទោះបីឃុំសង្កាត់មួយចំនួនតូចបានលើកឡើងថា មិនមានបញ្ហាប្រឈមក្នុងការប្រមូលទិន្នន័យប្រជាជនក៏ដោយ ដែលបញ្ហាប្រឈមទាំងនោះរួមមានការងារឃុំច្រើនពេកគ្មានពេលចុះប្រមូលទិន្នន័យ ខ្វះការយល់ដឹងអំពីការប្រមូលទិន្នន័យ ខ្វះមធ្យោបាយចុះស្រង់ស្ថិតិតាមកោះ ហើយការងារស្ថិតិគឺស្មៀនជាអ្នកទទួលខុសត្រូវ រីឯការគ្រប់គ្រងស្ថិតិក្នុងភូមិមិនច្បាស់លាស់ ខ្វះរបាយការណ៍អំពីប្រជាជនកើត ស្លាប់និងចាកចេញ ដោយសារចំណូល និងចំណាកស្រុកច្រើនតែមិនបានជូនដំណឹងអាជ្ញាធរ ប្រជាពលរដ្ឋមិនបានចុះសំបុត្រកំណើត។ ក្រៅពីនេះពេលខ្លះ អ្នកប្រមូលទិន្នន័យទៅមិនជួបប្រជាជនដោយគាត់ទៅធ្វើស្រែចម្ការ ហើយការយល់ដឹងពីស្ថិតិប្រជាជននៅមានកម្រិត។ ប្រជាពលរដ្ឋមិនសូវយល់អំពីការរៀនរបស់កូន ខ្វះសៀវភៅគ្រួសារ ផ្ទះប្រជាពលរដ្ឋនៅរាយប៉ាយ ហើយចំណេះដឹងមេភូមិនៅមានកម្រិត គ្មានថវិកាចុះស្រង់ ស្ថិតិប្រជាជន ហើយការផ្លាស់ទីលំនៅមិនបានប្រាប់នគរបាលទាំងចេញនិងចូល ចំណែកឯកុមារមួយចំនួនមិនបានបញ្ចូលឈ្មោះក្នុងសៀវភៅស្នាក់នៅនិងសៀវភៅគ្រួសារ ពិបាកណាត់ជួបព្រោះប្រជាជនទៅរកស៊ីនៅឆ្ងាយ មិនសូវសហការ មានអ្នកចំណូលថ្មីមិនទាន់ផ្ទេរពីភូមិចាស់មក លំបាកក្នុងការប្រាស្រ័យទាក់ទងដោយប្រើភាសាជនជាតិ ស្ថិតិប្រជាជនមានលំអៀងគ្នា ដោយមានការកើតនិងស្លាប់។

បញ្ហាប្រឈមសម្រាប់ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា និងនាយកសាលា រួមមាន នាយកសាលា ការិយាល័យអប់រំ យុវជន និងកីឡា និងអាជ្ញាធរមិនទាន់យល់ច្បាស់លាស់និងការយល់ដឹងនៅមានកម្រិតអំពីរបៀបនៃការប្រមូលទិន្នន័យ រីឯ ការប្រមូលទិន្នន័យនៅមានភាពយឺតយ៉ាវ ដោយសារតែប្រជាជនមួយចំនួនចំណាកស្រុក ហើយទិន្នន័យប្រមូលបានមិនទាន់បានស៊ីឬត្រូវគ្នាឬសហការគ្នាល្អទៅតាមអ្វីដែលក្រសួងអប់រំ យុវជន និងកីឡាចង់បានឡើយ ដោយសារការផ្តល់ទិន្នន័យមិនទាន់ច្បាស់លាស់ ទិន្នន័យដែលប្រមូលបានមិនទាន់ស៊ីគ្នានៅគ្រប់លំដាប់ថ្នាក់។ ម្យ៉ាងវិញទៀតការគ្រប់គ្រងទិន្នន័យនៅមានការពិបាកពីព្រោះប្រជាជនចំណាកស្រុក ឬចំណូលស្រុកមិនបានផ្តល់ព័ត៌មានដល់អាជ្ញាធរមូលដ្ឋាន ឱ្យបានច្បាស់លាស់ ហើយមានការពិបាកក្នុងការចុះប្រមូលដោយសារផ្ទះប្រជាជននៅឆ្ងាយៗពីគ្នាដែលត្រូវចំណាយពេលច្រើនក្នុងការចុះប្រមូល លើសពីនេះទៀត ធនធានថវិកាមានកំណត់ក្នុងការចុះប្រមូលទិន្នន័យហើយមានការទម្លាក់កំហុសឱ្យគ្នាទៅវិញទៅមកចំណែកឯការផ្តល់របាយការណ៍ជូនអាជ្ញាធរ ឬថ្នាក់ជាតិ មិនមានភាពសុក្រឹតឬច្បាស់លាស់ដោយសារការចុះប្រមូលទិន្នន័យមិនបានគ្រប់ខ្នងផ្ទះ ហើយទិន្នន័យមានភាពខុសគ្នាតាមគ្រូសារនីមួយៗ។ ក្រៅពីនេះ ក៏មានការផ្លាស់ប្តូរអ្នកគ្រប់គ្រងទិន្នន័យធ្វើឱ្យមានការពិបាកក្នុងការគ្រប់គ្រងទិន្នន័យ។

### ៤.១.៣.១ ទិន្នន័យប្រជាជន

ទិន្នន័យដែលទទួលបានពីមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាមានបញ្ហាប្រឈម ដូចជាទិន្នន័យរបស់មន្ទីរផែនការនិងក្រសួងផែនការ មិនត្រូវ ឬស៊ីគ្នានឹងទិន្នន័យរបស់ការិយាល័យអប់រំ យុវជន និងកីឡា និងសាលារៀន ហើយទិន្នន័យរបស់ភូមិឃុំក៏មិនត្រូវឬស៊ីនឹងទិន្នន័យប្រមូលជាក់ស្តែងរបស់សាលានិងការិយាល័យអប់រំ យុវជន និងកីឡាដែរ។ លើសពីនេះទៀត គ្មានប្រព័ន្ធប្រមូលស្ថិតិប្រជាជនច្បាស់លាស់ដែលធ្វើឱ្យពិបាកគ្រប់គ្រងទិន្នន័យនិងចលនាផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន ចំណែកភូមិឃុំមួយចំនួនពុំបានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រជាជនធ្វើឱ្យមិនមានទិន្នន័យច្បាស់លាស់ (តួលេខនិងចំនួនជាក់ស្តែងពុំត្រូវគ្នា) ហើយអាជ្ញាធរដែនដីភូមិឃុំមួយចំនួនពុំទាន់ប្រមូលទិន្នន័យច្បាស់លាស់ ធ្វើឱ្យពិបាកក្នុងការគណនាទៅលើអត្រាផ្សេងៗ។ រីឯ ការចុះជំរឿនប្រជាជនមានការលំបាក ដោយសារប្រជាជនធ្វើចំណាកស្រុក គ្រោះធម្មជាតិ កត្តាភូមិសាស្ត្រ ខ្វះមន្ត្រី គ្មានថវិកាចុះជំរឿន ខ្វះមធ្យោបាយប្រជាពលរដ្ឋមិនសូវចូលរួមជាដើម។ ម្យ៉ាងទៀត រដ្ឋបាលភូមិឃុំពុំមានទិន្នន័យប្រជាជនតាមអាយុច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ ហើយសាលាមួយចំនួនមិនបានចុះប្រមូលទិន្នន័យដោយប្រើតែទិន្នន័យឆ្នាំចាស់ ហើយសាលាមួយចំនួនទៀតប្រើទិន្នន័យតាមរយៈមេភូមិដែលធ្វើឱ្យមាន

ការលំបាក ដោយសារមេភូមិខ្លះគាត់មិនបានស្រង់ស្ថិតិតាមឆ្នាំថ្មីទេ គាត់បានយកតួលេខឆ្នាំចាស់មកឱ្យ ហើយអាជ្ញាធរខ្លះមិនសូវមានការសហការ មិនសូវចូលរួមប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ រីឯអ្នកផ្តល់ទិន្នន័យខ្លះ មានការចង្អៀតចង្អល់ក្នុងការផ្តល់ទិន្នន័យ ដែលធ្វើឱ្យទិន្នន័យទទួលបានមិនច្បាស់លាស់ មិនបានគ្រប់គ្រាន់តាមតម្រូវការ។

### ៤.១.៣.២ ទិន្នន័យសិស្ស

តាមការស្រង់ឬប្រមូលទិន្នន័យសិស្សរបស់មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាជួបនូវបញ្ហាប្រឈមដូចជាការស្រង់ទិន្នន័យសិស្សតាមអាយុមិនពិតប្រាកដ (ស្រង់តាមលេខកាំជណ្តើរ ហើយមន្ត្រីទទួលបន្ទុកស្ថិតិថ្មីមានការផ្លាស់ប្តូរញឹកញាប់ ការផ្តល់ស្ថិតិសិស្សមានការយឺតយ៉ាវ មិនយកចិត្តទុកដាក់ក្នុងការបំពេញស្ថិតិ ហើយតំបន់មួយចំនួនជួបការលំបាកដែលពិបាកក្នុងការប្រមូលស្ថិតិ) ចំណែកឯនាយកគ្រប់គ្រងស្ថិតិ ពុំបានច្បាស់លាស់នៅក្នុងតំបន់ជួបការលំបាកដោយសារការចូលរៀនយឺត ការផ្តល់ស្ថិតិពុំឯកភាពគ្នារវាងការិយាល័យផែនការនិងការិយាល័យជំនាញ អាយុសិស្សចូលរៀនថ្នាក់ដំបូងពុំត្រឹមត្រូវទៅតាមអាយុពិតប្រាកដ និងសិស្សផ្ទេរពីស្រុកផ្សេងដោយគ្មានឯកសារបញ្ជាក់ច្បាស់លាស់ ចំណាកស្រុក តាមឪពុកម្តាយធ្វើឱ្យប្រែប្រួលចំនួនកុមារតាមភូមិ និងស្ថានភាពភូមិសាស្ត្រលំបាកក្នុងការធ្វើដំណើរ (ផ្លូវទឹក ផ្លូវពិបាក)។ ក្រៅពីនេះ ការផ្តល់ទិន្នន័យពីសាលាមិនទាន់ពេលវេលា (យឺតយ៉ាវតគ្នា) ហើយទិន្នន័យខុសគ្នា រីឯការិយាល័យផែនការ មិនមានកម្រងសំណួរសម្រាប់ប្រមូលទិន្នន័យសិស្សច្បាស់លាស់ ហើយនាយកសាលាមួយចំនួនមានការយល់ដឹងនៅមានកម្រិត ដោយមិនសូវយល់ពីរបៀបស្រង់ស្ថិតិក្នុងតារាងជំរឿនជាដើម។

### ៤.១.៣ សន្ទស្សន៍យុគនាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សា

ភាគច្រើនពួកគាត់ជំរុញកូនទាំងពីរ (ទាំងកូនប្រុសនិងកូនស្រី) រហូតដល់៨៣.៦២% ដោយសារមូលហេតុថា ទាំងកូនប្រុសក៏ដូចជាកូនស្រីត្រូវតែចេះទាំងអស់គ្នាព្រោះថាការសិក្សាអាចធ្វើឱ្យមានភាពងាយស្រួលរកការងារដើម្បីអនាគតនិងជួយគ្រួសារ ហើយបើកូនចេះដឹងទាំងពីរ (ស្រីប្រុស) ទៅថ្ងៃក្រោយមិនសូវឱ្យឪពុកម្តាយពិបាកម្យ៉ាងវិញទៀតគាត់ចង់ឱ្យកូនមានកិត្តិយសមានការងារធ្វើដោយប្រើបញ្ញា ហេតុដូច្នេះហើយ បានជាគាត់ផ្តល់ឱកាសស្មើៗគ្នាក្នុងការរៀនសូត្រ។ ម្យ៉ាងវិញទៀតកូនមានសិទ្ធិស្មើៗគ្នាក្នុងការទទួលចំណេះដឹង ព្រោះកូនត្រូវមានចំណេះដឹងជ្រៅជ្រះស្មើៗគ្នាដើម្បីរស់ក្នុងសង្គម ហើយនៅពេលអនាគត ឪពុកម្តាយអាចពឹងអាស្រ័យលើកូនទាំងពីរ។

ឪពុកម្តាយ៩.៤៨% ចង់ឱ្យកូនប្រុសរៀនជាងកូនស្រីដោយផ្អែកទៅលើមូលហេតុដែលថា កូនប្រុសងាយស្រួលធ្វើដំណើរ ដោយមិនចាំបាច់បារម្ភពីសុវត្ថិភាព កូនប្រុសមានភាពឈ្លាសវៃជាង ចង់ឱ្យកូនប្រុសមានចំណេះដឹងច្រើនជាង ម៉្យាងទៀតកូនប្រុសតស៊ូរៀនជាងកូនស្រី ហើយកូនប្រុសអាចរស់នៅឆ្ងាយម្នាក់ឯងបាន ដូច្នេះ ផ្តល់អាទិភាពឱ្យកូនប្រុស ចំណែកកូនស្រីវិញមានការពិបាកក្នុងការទៅរៀនឆ្ងាយ។ ផ្ទុយទៅវិញ ឪពុកម្តាយ៦.៨៩% បែរជាចង់ឱ្យកូនស្រីរៀនច្រើនជាងកូនប្រុស ផ្អែកលើហេតុផលដែលថាឱ្យកូនស្រីមានចំណេះដឹង កុំឱ្យល្ងិតល្ងង់ដូចពួកគាត់ដែលជាឪពុកម្តាយ ម៉្យាងទៀតដើម្បីឱ្យកូនចេះដឹងនឹងគេដែលអាចងាយស្រួលរកការងារធ្វើ និងមានអនាគតល្អ ចំណែកកូនស្រីឆ្លាតជាងកូនប្រុស ហើយចំណែកអ្នកខ្លះដោយសារគាត់មានតែកូនស្រី និងឱ្យកូនស្រីបានចេះដឹងមានចំណេះក្នុងខ្លួន។

អ្នកចូលរួម៥២.៥៨%ផ្តល់ចម្លើយ បានដឹងពីការលើកកម្ពស់យេនឌ័រក្នុងការជំរុញលើកទឹកចិត្តក្នុងមូលដ្ឋាន ដែលក្នុងនោះ៤៧.៤២%មិនបានដឹងទាល់តែសោះ។ តាមការបញ្ជាក់របស់ពួកគាត់ សកម្មភាពលើកកម្ពស់យេនឌ័រ ដូចជាការលើកកម្ពស់សិទ្ធិសេរីភាពស្មើគ្នារវាងបុរស និងស្ត្រី កុមារមានសិទ្ធិស្មើគ្នាដោយហេតុថា មិនថាស្រីឬប្រុសទេអាចចូលរួមធ្វើការងារសង្គមដូចគ្នា។

*ក្រាហ្វិក១.៩ ការយល់ដឹងនិងការលើកកម្ពស់យុគភាពយេនឌ័រ*



## ៤.១.៤.១ សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា

សន្ទស្សន៍យុគភាពយេនឌ័រ[8] នៃអត្រាបញ្ចប់ការសិក្សា នៅបឋមសិក្សា ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ សម្រាប់មន្ទីរអយក. ការិយាល័យអយក. នៅតំបន់ក្រុងនិងជនបទគោលដៅ ទូទាំងខេត្តគោលដៅ សាលាគោលដៅ គ្រូបង្រៀននិងអាជ្ញាធរក្រុងស្រុក ភាគច្រើនផ្តល់តម្លៃសូចនាករស្ត្រីខ្ពស់ជាងបុរស (សន្ទស្សន៍ធំជាង១)។

អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាភាគច្រើនថា តម្លៃសូចនាករសិស្សស្រីខ្ពស់ជាងសិស្សប្រុស តាមទិន្នន័យផ្តល់ដោយមន្ទីរអយក. ការិយាល័យអយក. និងអាជ្ញាធរក្រុងស្រុក តែផ្ទុយទៅវិញ ទិន្នន័យផ្តល់ដោយលោកគ្រូអ្នកគ្រូបង្រៀនឃើញថា តម្លៃសូចនាករសិស្សប្រុសខ្ពស់ជាងសិស្សស្រី(សន្ទស្សន៍យុគភាព០.៨៨៨៥) រីឯសន្ទស្សន៍យុគភាពយេនឌ័ររបស់សាលាគោលដៅវិញ គឺអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមានយុគភាពយេនឌ័ររវាងសិស្សស្រី និងសិស្សប្រុស (សន្ទស្សន៍០.៩៧៥៣)។

*ក្រាហ្វិក១.១០ សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សា*




[8] មានសន្ទស្សន៍យុគភាពយេនឌ័រគឺធំជាង១

### ៤.១.៤.២ សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សានៅមធ្យម សិក្សាបឋមភូមិ

ក្រាហ្វិក១.១០ បង្ហាញពីសន្ទស្សន៍យុគភាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ ដែលទិន្នន័យមកពីមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា សាលាគោលដៅ លោកគ្រូអ្នកគ្រូ និងអាជ្ញាធរក្រុងស្រុកគឺមានលក្ខណៈប្រហាក់ប្រហែល ទៅនឹងសន្ទស្សន៍យុគភាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាដែរ ពោលគឺតួលេខស្មើរតែទាំងអស់បញ្ជាក់ថា អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិឱ្យតម្លៃសូចនាករសិស្សស្រីជាងសិស្សប្រុស (សន្ទស្សន៍ធំជាង ១) លើកលែងទិន្នន័យផ្តល់ដោយលោកគ្រូអ្នកគ្រូ ឱ្យតម្លៃសិស្សប្រុសជាងសិស្សស្រី (សន្ទស្សន៍ ០.៨៧៣៩) ដែលតម្លៃនេះស្មើរតែដូចគ្នាទៅនឹងទិន្នន័យផ្តល់ដោយលោកគ្រូអ្នកគ្រូនៅបឋមសិក្សា។ ដូច្នេះយុគភាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ គឺភាគច្រើននៃអ្នកចូលរួមបញ្ជាក់ថា តម្លៃយុគភាពយេនឌ័ររបស់សិស្សស្រីច្រើនជាងសិស្សប្រុស ទោះបីនាយក នាយិកាបានបញ្ជាក់ថា មានសមភាពយេនឌ័ររវាងសិស្សស្រីនិងសិស្សប្រុសក៏ដោយ។

### ៤.១.៤.២ មូលហេតុខុសគ្នារវាងសិស្សប្រុស និងស្រី

មូលហេតុដែលធ្វើឱ្យមានភាពខុសគ្នានៃអត្រាបញ្ចប់ការសិក្សារវាងសិស្សស្រី និងសិស្សប្រុស បើមើលជារួមនៃទិន្នន័យចាប់ពីថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យ អប់រំ យុវជន និងកីឡា អាជ្ញាធរក្រុងស្រុក នាយកសាលាគឺដោយសារៈ

១. កត្តាជីវភាព សិស្សប្រុសភាគច្រើនត្រូវជួយកិច្ចការឪពុកម្តាយ ដូចជាទៅនេសាទត្រី ដកជំឡូង ធ្វើសំណង់ ។ល។ ចំណែកកូនស្រីត្រូវទៅធ្វើការនៅតាមរោងចក្រ ឬបម្រើការតាមផ្ទះ ដើម្បីជួយបំពេញសេចក្តីត្រូវការនិងកង្វះខាតជីវភាពរស់នៅ ដែលបញ្ហានេះ តម្រូវឱ្យពួកគេប្រឈមមុខធ្វើចំណាកស្រុក បោះបង់ការសិក្សា ចំណែកឯ សិស្សមួយចំនួនត្រូវផ្លាស់ប្តូរទីលំនៅទៅតាមឪពុកម្តាយ។

២. កត្តាគ្រួសារ គ្រួសារមួយចំនួនមិនសូវជួយជំរុញកូន ឬជំរុញតែកូនស្រី ឬតែកូនប្រុស ឬគាត់មិនសូវយល់ដឹងពីតម្លៃនៃការអប់រំ ហើយគ្រួសារខ្លះទៀតមិនចង់ឱ្យកូននៅឆ្ងាយពីផ្ទះព្រោះកូន គាត់មិនមានសុវត្ថិភាព ជាពិសេសកូនស្រី។ ឪពុកម្តាយខ្លះមិនចេះអក្សរ ល្ងិតល្ងង់ មានជីវភាពក្រីក្រលំបាក ដែលគាត់មិនបានគិតឬចេះគិតគូរ

ឱ្យបានវែងឆ្ងាយអំពីអនាគតរបស់កូនដែលជាហេតុនាំឱ្យគាត់ ឱ្យកូនឈប់រៀន ឬបោះបង់ការសិក្សា។

៣. កត្តាទំនៀមទម្លាប់ប្រពៃណី គ្រួសារខ្លះយកប្រពៃណីជាធំដោយគាត់គិតថាកូនស្រីត្រូវរៀបការនៅវ័យក្មេងជាងកូនប្រុស កូនស្រីមិនចាំបាច់រៀនខ្ពស់ ហើយឱ្យតម្លៃនៃការសិក្សាតែទៅលើកូនប្រុស ដោយកូនប្រុសអាចរៀនឬធ្វើការនៅឆ្ងាយពីផ្ទះ ចំណែកកូនស្រីត្រូវនៅជួយកិច្ចការផ្ទះ ជួយថែទាំឪពុកម្តាយដែលកូនស្រីមានបន្ទុកការងារផ្ទះច្រើនជាងកូនប្រុស។ ចំណែក ប្រពៃណីទំនៀមទម្លាប់ជនជាតិភាគតិចគឺកូនស្រីត្រូវធ្វើការនៅផ្ទះ ហើយកូនប្រុសត្រូវរកស៊ីចិញ្ចឹមគ្រួសារ អីចឹងត្រូវរៀនច្រើនជាងកូនស្រី។

៤. កត្តាទីតាំងភូមិសាស្ត្រ សិស្សខ្លះសម្រេចបោះបង់ការសិក្សាដោយសារផ្លូវពិបាកធ្វើដំណើរ ផ្ទះនៅឆ្ងាយពីសាលាហើយមិនហ៊ានធ្វើដំណើរ បញ្ហាសុវត្ថិភាព ជាពិសេសសិស្សស្រី។

៥. កត្តាផ្នត់គំនិត ឪពុកម្តាយឬអាណាព្យាបាលខ្លះនៅមានទស្សនៈតឹងរឹងអំពីកូនៗរបស់ខ្លួន ដោយឱ្យតម្លៃនៃការសិក្សាតែទៅលើកូនប្រុសជាងកូនស្រី ពោលគឺកូនប្រុសជាធំដូច្នេះកូនប្រុសអាចរៀនបានខ្ពស់ជាងកូនស្រី កូនស្រីទៅរៀនបារម្ភពីបញ្ហាសុវត្ថិភាពជាដើម។

៦. បរិមាណសិស្សក្នុងចំណោមសិស្សដែលចុះឈ្មោះចូលរៀននិងមករៀនគឺចំនួនសិស្សស្រីច្រើនជាងចំនួនសិស្សប្រុស រីឯ កំណើនប្រជាពលរដ្ឋនៅក្នុងសហគមន៍វិញក៏មានភាពខុសគ្នាដែរ ពោលគឺចំនួនក្មេងស្រីច្រើនជាងក្មេងប្រុស។

៧. កត្តាសង្គម កត្តាអូសទាញពីបរិយាកាសខាងក្នុងនិងខាងក្រៅសាលាដែលធ្វើសិស្សមួយចំនួនបោះបង់ការសិក្សាទាំងនៅក្មេង ជាពិសេសសិស្សប្រុស ដូចជាការសេពគ្រឿងញៀន ការសេពគប់មិត្តភក្តិ និងសម្ភារនិយមជាដើម។

### ៤.១.៤.៣ សកម្មភាពលើកកម្ពស់សមតាពយេនឌ័រ

សកម្មភាពលើកកម្ពស់យេនឌ័រជាទូទៅធ្វើសកម្មភាពផ្សេងៗគ្នាដូចជា៖

១. ការលើកទឹកចិត្ត ផ្សព្វផ្សាយលើកទឹកចិត្តដល់ស្ត្រីក្នុងការរកការងារ តាមរយៈការផ្តល់ឱកាសជាថ្នាក់ដឹកនាំ សុំបង្កើនអាហារូបករណ៍សិស្សក្រីក្រជួបការលំបាក និងសិស្សក្នុងស្ថានភាពលំបាក ជាពិសេសសិស្សស្រី លើកទឹកចិត្តជាប្រចាំក្នុងម៉ោងបង្រៀន

និងពលកម្ម លើកទឹកចិត្តដល់លោកគ្រូ អ្នកគ្រូឱ្យចូលរួមក្នុងការងារដឹកនាំអង្គភាពឱ្យបានច្រើនគ្នា ដូចជា ការចូលរួមការប្រកួតជ្រើសរើសគ្រូល្អ នាយិកា នាយិការងដើម្បីដឹកនាំអង្គភាព ផ្តល់ឱ្យកុមារីមានលទ្ធភាពក្នុងការដឹកនាំជាប្រធានថ្នាក់ ប្រធានក្រុមប្រឹក្សាកុមារី បង្កើតក្រុមប្រឹក្សាកុមារី ក្រុមកីឡាកុមារី ក្រុមកាយរឹទ្ធិ ចូលរួមប្រកួតតែងនិពន្ធ និងសូត្រកំណាព្យដើម្បីទទួលពានរង្វាន់ លើកកម្ពស់ឱ្យកុមារីឱ្យចូលជាសមាជិកក្រុមប្រឹក្សាកុមារី ក្រុមប្រឹក្សាយុវជន បញ្ចូលអ្នកគ្រូធ្វើជាគណៈគ្រប់គ្រងសាលា តែងតាំងអ្នកគ្រប់គ្រងជាស្ត្រី លើកកម្ពស់សមភាពធ្វើជាមេដឹកនាំដោយស្ត្រីមានសិទ្ធិស្មើនឹងបុរស។

២. ការរៀបចំផែនការយុទ្ធសាស្ត្រ ដាក់យុទ្ធសាស្ត្រនៃការលើកកម្ពស់សកម្មភាពយេនឌ័រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំរាជធានីខេត្ត និងដាក់សកម្មភាពទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ ព្រមទាំងបញ្ចូលបញ្ហាស្ត្រីទៅក្នុងផែនការអភិវឌ្ឍ ឃុំសង្កាត់ ក្រុងស្រុក និងកម្មវិធីវិនិយោគ។

៣. ការផ្តល់ឱកាស រៀបចំឱ្យមានស្ត្រីមានតួនាទីក្នុងគណៈកម្មការផ្សេងៗរបស់សាលាផ្តល់តួនាទីសំខាន់ដល់ស្ត្រី ផ្តល់អាហារូបករណ៍ដល់សិស្សស្រីនិងចូលរួមក្នុងការងារសង្គម ជំរុញសាលារៀនឱ្យរៀបចំគណៈកម្មការទីប្រឹក្សាកុមារី លើកផែនការ ដាក់ស្ត្រីក្នុងការដឹកនាំក្នុងថ្នាក់រៀន សាលារៀន ផ្តល់អាទិភាពផ្សេងៗសម្រាប់ស្ត្រីក្នុងការចូលរួមសកម្មភាពផ្សេងៗ រៀបចំបង្គន់អនាម័យ បន្ទប់ទឹកដាច់ដោយឡែកសម្រាប់សិស្សប្រុស សិស្សស្រី បញ្ជូនកុមារីឱ្យចូលរួមបោះជំរុំក្នុងនិងក្រៅខេត្ត និងបញ្ចូលស្ត្រីទៅក្នុងក្រុមប្រឹក្សាកុមារនិងកាយរឹទ្ធិជាតិជាដើម។

៤. ការបណ្តុះបណ្តាល បើកវគ្គបណ្តុះបណ្តាលផែនការអភិវឌ្ឍសាលារៀន ប្រើថវិកាសកម្មភាពគោល ចុះតាមភូមិ បង្កើតក្រុមសកម្មភាពយេនឌ័រ និងបើកវគ្គបណ្តុះបណ្តាលសមភាពយេនឌ័រដោយលើកកម្ពស់សិទ្ធិស្មើភាពគ្នារវាងបុរសនិងស្ត្រី។

៥. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ធ្វើបង្គន់អនាម័យដោយជំរុញសាលារៀនឱ្យរៀបចំបង្គន់អនាម័យសិស្សស្រីដាច់ពីសិស្សប្រុស ព្រមទាំងណែនាំឱ្យនាយកសាលារៀបចំគណៈកម្មការនានាតាមសាលា តាមថ្នាក់តម្រូវឱ្យនារីជាប្រធាន អនុប្រធាន។

៦. ផ្សព្វផ្សាយតាមរយៈសិក្ខាសាលាពីយេនឌ័រអប់រំឪពុកម្តាយតាមខ្នងផ្ទះនិងសហគមន៍ដោយឱ្យកុមារីចូលរួមសកម្មភាពសង្គមឱ្យបានច្រើន ឱ្យកុមារីជាប្រធានក្រុមកុមារ

តាមសាលា ឬធ្វើជាប្រធានថ្នាក់ ប្រជុំផ្សព្វផ្សាយដល់សិស្សឱ្យយល់ពីតម្លៃនៃការសិក្សា និងដល់សហគមន៍អំពីសារប្រយោជន៍គុណតម្លៃការអប់រំ (ការរៀនសូត្ររបស់កូន) ផ្សព្វផ្សាយដល់អង្គភាពក្រោមឱវាទឱ្យយកចិត្តទុកដាក់លើសមភាពយេនឌ័រ ផ្សព្វផ្សាយនិងបញ្ជ្រាបប្រយេនឌ័រតាមរយៈប្រជុំជាមួយនាយក លោកគ្រូអ្នកគ្រូ បុគ្គលិក ព្រមទាំងផ្សព្វផ្សាយតាមភូមិឃុំ សាលារៀនដើម្បីអប់រំផ្លូវចិត្តសិស្សស្រី ឧបត្ថម្ភសម្ភារសិក្សាសិស្សក្រីក្រតាមរយៈគណៈកម្មការស្ត្រីនិងកុមារ។

៧. ទំនាក់ទំនង ទំនាក់ទំនងជាមួយអង្គការដៃគូ ដើម្បីស្វែងរកអាហារូបករណ៍ជួយដល់សិស្សស្រីតាមរយៈការប្រជុំឃុំរាយការណ៍តាមភូមិឃុំសុវត្ថិភាព ទាក់ទងជាមួយមាតាបិតាដោយពន្យល់ពីផលប៉ះពាល់កូនស្រីដែលមិនចេះអក្សរ សហការតាមអង្គភាពរដ្ឋ ឯកជន ជំរុញការងារយេនឌ័រ អប់រំពាក់ព័ន្ធសុខភាព លើកកម្ពស់សិទ្ធិស្មើគ្នា និងប្រជុំធ្វើផែនការវិនិយោគ។

## ៤.១.៤ វិធានការបង្កើនការចូលរៀន

យោងតាមស្ថិតិ របាយការណ៍និងការសម្ភាសផ្ទាល់ជាមួយមន្ទីរអប់រំ យុវជន និងកីឡាគោលដៅទាំង១២បង្ហាញថា មានកំណើនសិស្សសរុប០.៧៥% ក្នុងនោះសិស្សប្រុសកើនឡើង ០.៨២% និងស្រីកើនឡើង១.៦៧% ហើយការកើននេះគឺផ្អែកលើកំណើនប្រជាជន មាតាបិតា និងអាណាព្យាបាលបានបញ្ជូនកូនមកសាលាមានការកើនឡើង ដោយសារពួកគាត់យល់កាន់តែច្បាស់អំពីតម្លៃនៃការសិក្សា យុទ្ធនាការប្រមូលសិស្សបានទូលំទូលាយជាងមុន ផ្តល់អាហារូបករណ៍ កំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ជីវភាពប្រជាជនប្រសើរជាងមុន និងកាត់បន្ថយ ចំណាកស្រុក មានចរិកាចុះផ្សព្វផ្សាយដល់មូលដ្ឋាន ឃុំ សាលា ផែនទីតាមខ្នងផ្ទះ ការចុះឈ្មោះចូលរៀនមិនតម្រូវឱ្យបង់ថ្លៃ និងការទប់ស្កាត់ការធ្វើចំណាកស្រុករបស់ប្រជាជន។ ផ្ទុយទៅវិញ ទោះបីជា តួលេខរួមនៃខេត្តគោលដៅមួយចំនួនធំបង្ហាញថាមានការកើនឡើងក៏ដោយ ក៏មានខេត្តមួយចំនួនតូចថយចុះផងដែរ ដែលកត្តានេះអាចបណ្តាលមកពីកត្តាជីវភាព ចំណាកស្រុក ខ្វះកន្លែងស្នាក់នៅ អាណាព្យាបាលខ្លះមិនមានការយល់ដឹងពីគុណតម្លៃនៃការសិក្សា ហើយកុមារដល់អាយុចូលរៀនមានចំនួនតិចជាងឆ្នាំសិក្សាកន្លងមក។

ដើម្បីកៀរគរប្រមូលកុមារចូលរៀន មន្ទីរអប់រំ យុវជន និងកីឡា ក៏បានចូលរួមនិងបង្កើតសកម្មភាព ដូចជាជំរុញឪពុកម្តាយឱ្យបញ្ជូនកូនមករៀន ធ្វើការផ្សព្វផ្សាយទៅដល់សហគមន៍មាតាបិតាសិស្សឱ្យនាំកុមារដែលដល់វ័យសិក្សាមកចុះឈ្មោះចូលរៀន ធ្វើយុទ្ធនាការប្រមូល

កុមារចូលរៀន កៀរគរអង្គការដៃគូដើម្បីជួយគាំទ្រ អប់រំណែនាំមាតាបិតាពីសារសំខាន់នៃការសិក្សា ហើយសហគមន៍និងអាជ្ញាធរមូលដ្ឋានបានយល់ដឹងពីគុណតម្លៃនៃការអប់រំប្រសើរជាងមុន។ លើសពីនេះទៀត មន្ទីរអប់រំ យុវជន និងកីឡាក៏បានបើកយុទ្ធនាការប្រមូលសិស្សចូលរៀនផ្សព្វផ្សាយតាមវិទ្យុខេត្ត ហ្វេសប៊ុករបស់មន្ទីរអប់រំ យុវជន និងកីឡាដើម្បីបញ្ចុះបញ្ចូលសិស្សចូលរៀន ប្រជុំផ្សព្វផ្សាយដល់អាជ្ញាធរដែនដី គណៈកម្មការទ្រទ្រង់សាលាឱ្យជួយប្រមូលកុមារចូលរៀនឱ្យបានច្រើន គណៈកម្មការទ្រទ្រង់សាលាបានចុះជួយប្រមូលដល់ផ្ទះប្រជាជនដែលដល់វ័យចូលរៀនអាយុ៦ឆ្នាំ រៀបចំសាលារៀនជាទីមេត្រីរបស់សិស្សដោយបំពាក់បង្គន់អនាម័យព្រមទាំងពង្រឹងសុវត្ថិភាព សន្តិសុខ និងការសិក្សារបស់សិស្សដោយសហការជាមួយសហគមន៍និងអាជ្ញាធរដែនដីឱ្យកាន់តែជិតស្និទ្ធ។

ចំណែកឯនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុកវិញឃើញថា ការចូលរៀនមានការកើនឡើងជាមធ្យម២.៣១% ក្នុងនោះសិស្សប្រុសកើនជាមធ្យម៤.៩១% និងសិស្សស្រីកើនជាមធ្យម៣.២២% ហើយកំណើននៃការចូលរៀននៅតាមក្រុងស្រុកបណ្តាលមកពីកត្តាប្រជាជនយល់ដឹង មានទំនុកចិត្តលើការសិក្សា សាលារៀនបានកើនឡើងនៅជិតផ្ទះប្រជាជនកំណើតប្រជាជនកើន គណៈកម្មការទ្រទ្រង់សាលាមានការយល់ដឹងច្រើន ដោយបានចូលរួមក្នុងការងារសាលាច្រើន ដូចជា ជួយថែទាំអគារសិក្សា ប្រមូលកុមារចូលរៀន ចូលរួមពិនិត្យវត្តមានសិស្សគ្រូ បង្កើនការផ្សព្វផ្សាយបានទូលំទូលាយដល់សហគមន៍និងអាជ្ញាធរពាក់ព័ន្ធ។ ទន្ទឹមនឹងមានកំណើនសិស្សចូលរៀននៅក្រុងស្រុកមួយចំនួន ក៏មានបញ្ហាមួយចំនួនដែលធ្វើឱ្យសិស្សធ្លាក់ចុះនូវការចូលរៀនតាមបណ្តាក្រុងស្រុកមួយចំនួនផងដែរ ដែលកត្តាទាំងនេះអាចមកពីចំណាកស្រុកនិងកុមារមួយចំនួននៅឆ្ងាយពីសាលា ជាពិសេសនៅតាមភូមិឧបសម្ព័ន្ធប្រជាជនពន្យាកំណើត តំបន់ខ្លះសាលារៀននៅឆ្ងាយពីផ្ទះ សាលាមិនសមស្រប (អគារឈើ ខ្វះតុកៅអី) សហគមន៍មិនសូវជួយជំរុញចំនួនកុមារដល់អាយុចូលរៀនមានចំនួនថយចុះកុមារផ្ទេរការសិក្សាទៅរៀនទៅភ្នំពេញ ឬប្តូរទៅរៀនសាលាឯកជន។ល។

នៅក្នុងនោះដែរ ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុកក៏បានអនុវត្ត និងចូលរួមសកម្មភាពមួយចំនួន ដើម្បីប្រមូលកុមារចូលរៀនផងដែរ ដូចជាបង្កើតគណៈកម្មការទ្រទ្រង់សាលារៀន ចុះធ្វើជំរឿនមួយឆ្នាំម្តង ធ្វើបច្ចុប្បន្នភាពផែនទីសិក្សា កំណត់មុខសញ្ញា យុទ្ធនាការប្រមូលកុមារចូលរៀន ចូលរួមជាមួយសហគមន៍ក្នុងការប្រមូលសិស្សចូលរៀន រៀបចំផែនទីខ្នងផ្ទះតាមភូមិគោលដៅ ប្រមូលកុមារចូលរៀនគ្រប់រូបភាព ប្រជុំផ្សព្វផ្សាយដល់គ្រប់អ្នកពាក់

ព័ន្ធដើម្បីកៀរគរកុមារចូលរៀន ធ្វើបច្ចុប្បន្នភាពស្ថិតិដែលមានស្រាប់ដើម្បីរកកុមារដល់វ័យសិក្សា ចូលរួមសហការជាមួយអង្គការដៃគូដើម្បីជួយពង្រឹងសមត្ថភាពគណៈកម្មការបន្ថែមទៀត ជំរុញនាយក នាយិកាធ្វើចលនាផ្សព្វផ្សាយឱ្យសិស្សចុះឈ្មោះចូលរៀនគ្រប់បវេសនកាល ទំនាក់ទំនងជាមួយអាជ្ញាធរភូមិឃុំស្រុកដើម្បីជួយទប់ស្កាត់ប្រជាជនចំណាកស្រុក ពង្រឹងលើការអនុវត្តតួនាទីភារកិច្ចរបស់មន្ត្រី និងគ្រូបង្រៀន ផ្តល់ព័ត៌មានសិស្សបោះបង់ការសិក្សា ក៏ដូចជាចំនួនសិស្សដែលបានចូលរៀនទៅឃុំសង្កាត់ ប្រជុំជាមួយនាយកសាលាដើម្បីធ្វើការផ្សព្វផ្សាយតាមរយៈការឃោសនា ការដាក់បដា ពាក្យស្លោក ហើយពង្រឹងវិន័យគ្រូ សិស្ស រៀបចំបរិស្ថាន សាលារៀន រៀបចំស្នើសុំអគារសិក្សា និងបង្កើនកិច្ចសហការជាមួយអាជ្ញាធរនិងព្រះសង្ឃតាមវត្ត។

នៅកម្រិតសាលារៀន នាយកសាលាបានបញ្ជាក់ថា ចំនួនសិស្សចូលរៀនមានការកើនឡើងជាមធ្យម៧.០៧% ក្នុងនោះសិស្សប្រុសជាមធ្យមកើន៦.១៩% និងសិស្សស្រីជាមធ្យមកើន ៩.៨០% ហើយមូលហេតុដែលមានការកើនឡើងគឺដោយសារ ឪពុកម្តាយមានការយល់ដឹងច្រើនពីអត្ថប្រយោជន៍នៃការសិក្សានិងបានជំរុញឱ្យមករៀន លោកគ្រូ អ្នកគ្រូយកចិត្តទុកដាក់បង្រៀន និងមានការទទួលខុសត្រូវខ្ពស់ក្នុងការបំពេញការងារនិងសិស្សចុះឈ្មោះចូលរៀនបានកើនឡើង មានការចូលរួមនិងមានទំនុកចិត្តពីអាណាព្យាបាលសិស្ស សហគមន៍និងអាជ្ញាធរគ្រប់កម្រិត អង្គការ ផ្តល់ជំនួយជាសម្ភារសិក្សាគ្រប់គ្រាន់ដល់សិស្ស។ តែទោះយ៉ាងណាក៏ដោយក៏នៅក្នុងសាលារៀនមួយចំនួន មានសិស្សថយចុះផងដែរ ដែលការថយចុះនេះបណ្តាលមកពីការផ្លាស់ប្តូរទីលំនៅ ជីវភាពក្រក្រី ចំណាកស្រុកទៅធ្វើការស្រុកក្រៅ កុមារគ្រប់អាយុចូលរៀនមានចំនួនតិចជាងមុន អាណាព្យាបាលសិស្សនាំសិស្សទៅរកស៊ីនៅស្រុកថៃ សិស្សឡើងមកពីបឋមមានចំនួនតិច ខ្វះមធ្យោបាយធ្វើដំណើរ សាលាគ្មានអាហារូបករណ៍ឱ្យសិស្ស កុមារថយចុះ(ប្រជាជនពន្យាកំណើត)មានការបង្កើតសាលាថ្មីសិស្សផ្ទេរទៅរៀននៅសាលាផ្សេងឬសាលាឯកជន។ នៅក្នុងនោះដែរដើម្បីបង្កើនចំនួនសិស្សចូលរៀន សាលារៀននីមួយៗក៏បានចូលរួមនិងធ្វើសកម្មភាពក្នុងការប្រមូលសិស្សផងដែរ ដូចជា ចុះណែនាំអាណាព្យាបាលដល់ផ្ទះឱ្យនាំកូនមកចុះឈ្មោះចូលរៀន កែលម្អបរិស្ថានសាលាឱ្យមានសោភ័ណភាពល្អ ពង្រឹងវិន័យគ្រូចុះជួបអាណាព្យាបាលសិស្សដល់ផ្ទះ ដើម្បីជំរុញឱ្យកូនរៀន និងពន្យល់ឱ្យអាណាព្យាបាលយល់ពីតម្លៃនៃការសិក្សា ប្រជុំប្រចាំខែនៅសាលាឃុំផ្តល់បញ្ជីឈ្មោះសិស្សដែលឈប់ច្រើនទៅឱ្យអាណាព្យាបាល ចុះជំរឿនតាមផែនទីសិក្សា និងធ្វើយុទ្ធនាការប្រមូលសិស្ស ចុះដល់ផ្ទះសិស្សដែលមានអវត្តមានច្រើន ឬទូរស័ព្ទទៅអាណាព្យាបាលសិស្ស ចុះទៅដល់ផ្ទះសិស្សដែលមិនទាន់

ចុះឈ្មោះចូលរៀន ចែកខិតប័ណ្ណ ផ្សព្វផ្សាយ ជួយបំប៉នសិស្សដែលបោះបង់ឱ្យចូលរៀនវិញ រៀបចំបណ្ណាញតាមភូមិចំណុះសាលាជាដើម។

### ៤.១.៤.១ ការបោះបង់ការសិក្សា

យោងទៅតាមទិន្នន័យផ្តល់ដោយមន្ទីរអប់រំ យុវជន និងកីឡា ឃើញថាការបោះបង់ការសិក្សាមានការថយចុះ១.៩០%ជាមធ្យមនៅថ្នាក់មន្ទីរអប់រំយុវជននិងកីឡាហើយការថយចុះនេះគឺអាចបណ្តាលមកពីមាតាបិតាមានការយល់ដឹងពីសារសំខាន់នៃការសិក្សា ហើយចង់ឱ្យកូនរបស់ខ្លួនមានការងារសមរម្យនៅពេលអនាគត ឪពុកម្តាយបានជួយជំរុញកូនមករៀន និងរៀននៅផ្ទះបន្ថែម ក្រៅពីនេះមន្ទីរអប់រំ យុវជន និងកីឡាក៏មានផែនការច្បាស់លាស់ជាងមុន (ដំណើរធ្វើផែន ការនិងពិនិត្យតាមដានប្រសើរជាងមុន) ព្រមទាំងមានការបង្កើតសាលារៀនគ្រប់តំបន់ប្រជាជនរស់នៅចាប់តាំងពីសាលាមិនគ្រប់កម្រិតឡើងទៅ។ តែផ្ទុយទៅវិញក៏មានខេត្តមួយចំនួនតូចនៅតែមានអត្រាបោះបង់ការសិក្សាកើនឡើងផងដែរ ដែលកត្តានេះមកពីការប្រមូលទិន្នន័យមិនបានត្រឹមត្រូវ ឪពុកម្តាយមួយចំនួនមិនបានជំរុញឱ្យកូនមករៀន ហើយឪពុកម្តាយខ្លះទៀតអូសទាញកម្លាំងពលកម្មកូនឱ្យជួយធ្វើការងារដើម្បីជីវភាពរស់នៅ។

ស្រដៀងគ្នានេះដែរ ទិន្នន័យផ្តល់ដោយការិយាល័យអប់រំ យុវជន និងកីឡាវិញឃើញថាការបោះបង់ការសិក្សានៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡាមានការថយចុះជាមធ្យម ០.៥៣%ដែលការថយចុះនោះអាចបណ្តាលមកពីគណៈកម្មការមានការចូលរួមច្រើនដោយបានចុះសាកសួរ ព័ត៌មានសិស្សដែលបោះបង់ការសិក្សា ពន្យល់ដល់អាណាព្យាបាលដើម្បីឱ្យកូនគាត់មកចូលរៀនវិញ លើសពីនេះទៀត ថ្នាក់គ្រប់គ្រងយកចិត្តទុកដាក់ គ្រូមានមនសិការវិជ្ជាជីវៈ សិស្សខិតខំរៀន មាតាបិតាទប់ស្កាត់ការបោះបង់ និងជំរុញឱ្យកូនចូលរៀន មានសាលារៀន និងគ្រូបង្រៀនគ្រប់នៅតាមសាលារៀន ព្រមទាំងមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ហើយប្រជាពលរដ្ឋយល់ដឹងពីតម្លៃនៃការសិក្សារបស់កូន មានការលើកកម្ពស់ដល់សិស្សក្រីក្រ ក្រៅពីនេះ ក៏មានកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ កម្មវិធីអាហារពេលព្រឹកនៅតាមសាលារៀន ជីវភាពប្រជាជនល្អប្រសើរ ហើយការិយាល័យអប់រំ យុវជន និងកីឡាក៏បានប្រជុំនិងផ្សព្វផ្សាយដល់សហគមន៍មាតាបិតាសិស្ស នាយក និងសហគមន៍ចុះប្រមូលសិស្សបោះបង់ការសិក្សា ជូនដំណឹងដល់អាជ្ញាធរពាក់ព័ន្ធឱ្យជួយជំរុញមាតាបិតាជាដើម។ ថ្វីត្បិតតែអត្រាបោះបង់នៃការសិក្សាមានការថយចុះក្នុងការិយាល័យអប់រំ យុវជន និងកីឡាមួយចំនួនធំក៏ដោយ ដែលក្នុងនោះក៏មានក្រុងស្រុកមួយចំនួនតូចក៏មានការបោះបង់ច្រើនផងដែរ ដែលកត្តានេះអាចបណ្តាល

មកពីនាយកសាលាភាគច្រើនយល់ច្រឡំថាការផ្ទេរសិក្សារបស់សិស្សជាការបោះបង់ ឪពុកម្តាយធ្វើចំណាកស្រុកនិងរៀនសាសនាឥស្លាម (ខ្មែរឥស្លាម) ទៅជួយធ្វើការងារឪពុកម្តាយ រៀបអាពាហ៍ពិពាហ៍ ទៅធ្វើការងាររោងចក្រ និងផ្លាស់ប្តូរទីលំនៅតាមឪពុកម្តាយជាដើម។

ចំពោះទិន្នន័យដែលផ្តល់ដោយនាយកសាលាវិញ ឃើញថាការបោះបង់ការសិក្សានៅកម្រិតសាលារៀនជាមធ្យមថយចុះ៣.៧៩% ដែលការថយចុះនេះអាចមកពីសិស្សរៀនពូកែច្រើន មាតាបិតាយកចិត្តទុកដាក់លើការសិក្សារបស់កូន មានអន្តេវាសិកដ្ឋានសម្រាប់សិស្សមកពីឆ្ងាយស្នាក់នៅ អាណាព្យាបាលយល់ពីតម្លៃនៃការសិក្សា លោកគ្រូអ្នកគ្រូលើកទឹកចិត្តសិស្សានុសិស្ស កាត់បន្ថយការរៀបការវ័យក្មេងនិងចំណាកស្រុក ជួយបង្រៀនបន្ថែមសិស្សរៀនយឺត មាតាបិតាសិស្សជួយតាមដានលើការសិក្សារបស់កូន ហើយគណៈគ្រប់គ្រងសាលាចុះជួបអាណាព្យាបាលសិស្សដែលឈប់ច្រើន និងជំរុញឱ្យសិស្សមករៀនវិញ។ នៅពេលដែលសាលាភាគច្រើនមានអត្រាបោះបង់ថយចុះ ក៏មានសាលាមួយចំនួនតូចនៅមានការបោះបង់ច្រើនផងដែរ ដែលកត្តានេះបណ្តាលមកពីបញ្ហាមាតាបិតាផ្លាស់ប្តូរទីលំនៅ ចំណាកស្រុក ទៅរកស៊ីឆ្ងាយឬទៅតាមឪពុកម្តាយ គេចសាលាច្រើនដោយសារបញ្ហាជីវភាព រៀបការវ័យក្មេង មានការបង្កើតរោងចក្រនៅក្បែរសាលាច្រើន គ្រួសារផ្លាស់ប្តូរទីលំនៅញឹកញាប់ និងប្តូរទៅរៀននៅសាលាឯកជន។ល។

លោកគ្រូអ្នកគ្រូបង្រៀនដែលបានផ្តល់ព័ត៌មានតាមរយៈការសម្ភាស និងបំពេញកម្រងសំណួរ ហាក់ដូចជាផ្ទុយទៅនឹងទិន្នន័យទទួលបានពីមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា និងនាយក ដែលក្នុងនោះគាត់បានបញ្ជាក់អំពីការបោះបង់ការសិក្សាមានការកើនឡើង០.២៣% ដែលការបោះបង់ការសិក្សាអាចបណ្តាលមកពីជួយកិច្ចការចំការស៊ីឈ្នួល និង ចំណាកស្រុក ធ្វើការរោងចក្រ ចំនួនសិស្សដើមឆ្នាំថយចុះ ទៅរៀនសាលាឯកជន ជីវភាពគ្រួសារ សាលានៅឆ្ងាយ សិស្សចូលរៀនតិច មិនមានការយកចិត្តទុកដាក់ជំរុញបន្ថែមពីអាណាព្យាបាល សិស្សមិនចង់រៀន ផ្លាស់ទីលំនៅ គ្រួសារក្រីក្រ ផ្ទះឆ្ងាយ និងរៀបការ សង្គមអូសទាញ សិស្សរៀនយឺត ឬចូលរៀនលើសអាយុជាដើម។

រីឯទិន្នន័យផ្តល់ដោយអាជ្ញាធរក្រុងស្រុក ឃុំសង្កាត់វិញ និងឪពុកម្តាយសិស្សឃើញថាមានលក្ខណៈស្រដៀងគ្នាទៅលើការបោះបង់ការសិក្សាគឺថាមានកម្រិតតិចតួច ដែលមូលហេតុការបោះបង់អាចបណ្តាលមកពីការបំលាស់ទីទៅរកការងារធ្វើ សម្ភារនិយម និងរៀបអាពាហ៍ពិពាហ៍ ខ្វះលទ្ធភាពក្នុងការសិក្សាដោយត្រូវជួយរកចំណូលសម្រាប់គ្រួសារ សិស្សថ្នាក់ទី១តាម

ឪពុកម្តាយទៅធ្វើស្រែចំការ ឪពុកម្តាយមិនបានជំរុញកូន មិនសូវយល់ពីសារសំខាន់នៃការសិក្សា ខ្វះមធ្យោបាយធ្វើដំណើរ មើលគំរូអ្នកដទៃ (អ្នកខំរៀនពីមុននៅតែគ្មានការងារធ្វើ) សាមីខ្លួនមិនចង់រៀន ក្មេងខិលខូច រៀនមិនចេះ រៀនខ្សោយ ឈប់រៀន សេពគ្រឿងញៀន និងអំពើហិង្សាក្នុងគ្រួសារ។

### ៤.១.៥.២ ការបង្ការនិងទប់ស្កាត់ការបោះបង់ការសិក្សា

ដើម្បីទប់ស្កាត់ការបោះបង់ការសិក្សារបស់សិស្សានុសិស្ស អ្នកពាក់ព័ន្ធទាំងអស់ចាប់ពីថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា អាជ្ញាធរក្រុងស្រុក ឃុំសង្កាត់ ក៏ដូចនាយកសាលា ឪពុកម្តាយបានធ្វើសកម្មភាពមួយចំនួនដូចខាងក្រោម៖

១. គ្រូ បង្កើនសមត្ថភាពគ្រូបង្រៀន និងតាមដានការងារគ្រូជាប្រចាំលើការងារគ្រូបង្រៀន និងរៀន ហើយលោកគ្រូអ្នកគ្រូមានផែនការបង្រៀនច្បាស់លាស់ គោរពពេលវេលា មានឆន្ទៈក្នុងការបង្រៀន មានទំនាក់ទំនងល្អជាមួយសិស្សនិងអាណាព្យាបាល ហើយគ្រូបង្រៀនត្រូវផ្តល់ដំណឹងដល់មាតាបិតាពេលដែលសិស្សមិនចូលសាលា។

២. សិស្ស ផ្តល់អាហារូបករណ៍ ផ្តល់កន្លែងស្នាក់នៅដល់សិស្ស ជំរុញនិងបង្កើតសាលារៀនឱ្យគ្រប់កម្រិត ផ្តល់ប្រឹក្សាសុខភាពសម្រាប់សិស្សស្រី គ្រូត្រូវតាមដានវត្តមានសិស្ស រកដៃគូអភិវឌ្ឍជួយឧបត្ថម្ភជាសម្ភារសិក្សាដល់សិស្សក្រីក្រ គ្រូបន្ទុកថ្នាក់ចុះសួរសិស្សអវត្តមានច្រើន ព្យាយាមពន្យល់សិស្ស ចុះដល់ផ្ទះសិស្សបោះបង់ ទំនាក់ទំនងមាតាបិតាតាមរយៈសិស្ស ទូរស័ព្ទ ប្រជុំផ្សព្វផ្សាយជា មួយភូមិឃុំនិងអាណាព្យាបាលសិស្សឱ្យបានយល់ច្បាស់ពីសារសំខាន់នៃការសិក្សា និងស្វែងយល់ពីស្ថានភាពសិស្ស។

៣. ឪពុកម្តាយសិស្ស ចុះតាមសួររកហេតុផលដល់ផ្ទះ ពន្យល់ណែនាំឱ្យគាត់យល់ពីតម្លៃនៃការសិក្សា ជាពិសេសពិនិត្យលទ្ធភាពផ្តល់អាហារូបករណ៍ ជំរុញឪពុកម្តាយឱ្យនាំកូនចៅឱ្យមកសិក្សា និងផ្សព្វផ្សាយដល់ឪពុកម្តាយឱ្យយល់ពីសារសំខាន់នៃការសិក្សាដល់ផ្ទះប្រជាជន (ខិតខំជំរុញកូនឱ្យមកសិក្សាកុំយកកុមារមកប្រើ ព្រមទាំងខិតខំបង្រៀនបន្ថែមនៅផ្ទះ) តាមរយៈគណៈកម្មការស្ត្រី អាណាព្យាបាលត្រូវជួយលើកទឹកចិត្តកូនឱ្យកូនខិតខំរៀនសូត្រដើម្បីទទួលបានផលល្អ ដើម្បីឱ្យកូនក្លាយជាពលរដ្ឋល្អក្នុងសង្គមជាតិ។ លើសពីនេះទៀត ទំនាក់ទំនងជាប្រចាំជាមួយសិស្ស អាណាព្យាបាល លោកគ្រូអ្នកគ្រូពីបញ្ហានៃការសិក្សារបស់សិស្ស សួរសុខទុក្ខសិស្ស

ចុះណែនាំតាមផ្ទះ ឬក្នុងកម្មវិធីផ្សេងៗតាមសហគមន៍ និងទប់ស្កាត់ការធ្វើចំណាកស្រុក និងការជួញដូរគ្រឿងញៀន។

៤. ការិយាល័យអប់រំ យុវជន និងកីឡា ចុះជួយណែនាំសិស្សដែលបម្រុងបោះបង់ការសិក្សានិងផ្តល់សម្ភារសិក្សា លើកទឹកចិត្តចែកអាហារូបករណ៍ ឬមធ្យោបាយធ្វើដំណើរដល់សិស្សក្រីក្រ គ្រប់គ្រងទិន្នន័យនៅសាលារៀនរដ្ឋនិងឯកជនក្នុងមូលដ្ឋាន ប្រជុំជាមួយគណៈកម្មការនារីនិងកុមារ លោកគ្រូ អ្នកគ្រូនិងអ្នកពាក់ព័ន្ធរកវិធីទប់ស្កាត់ រៀបចំប្រព័ន្ធគ្រូតពិនិត្យតាមដាន ពង្រឹងគណៈកម្មការគ្រប់គ្រងសាលា ក្រៅពីនេះលួងលោមសិស្សពីហេតុផលនៃការរៀនសូត្រ ប្រជុំផ្សព្វផ្សាយដល់មាតាបិតាឱ្យយល់អំពីតម្លៃនៃការសិក្សានិងផលវិបាកនៃការឈប់រៀន សហការជាមួយអាជ្ញាធរមូលដ្ឋានប្រជុំសហគមន៍១ខែម្តង។

៥. មន្ទីរអប់រំ យុវជន និងកីឡា ផ្តល់កន្លែងស្នាក់នៅដល់សិស្ស ជំរុញនិងបង្កើតសាលារៀនឱ្យគ្រប់កម្រិត ប្រជុំក្រុមការងារថ្នាក់ការិយាល័យជំនាញក្នុងមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុករកឫសគល់នៃបញ្ហា និងចុះទៅរកគោលដៅដែលមានបញ្ហាដើម្បីដោះស្រាយបន្ទាន់ ចែកជូនសៀវភៅសិក្សាគោលឱ្យបានគ្រប់ចំនួនដល់សិស្ស អនាម័យ សោភ័ណភាពក្នុងសាលា មានកម្មវិធីល្បែងសិក្សាជាមួយសិស្សជាប្រចាំ ផ្តល់អគារសិក្សា និងផ្តល់កម្មវិធីចូលរៀនឡើងវិញ ពង្រឹងការគ្រប់គ្រងសាលារៀន កែលម្អរចនាសម្ព័ន្ធសាលារៀន រក្សាសុវត្ថិភាពការសិក្សារបស់សិស្ស បង្កើតសាលារៀនគ្រប់កម្រិត និងសហការជាមួយអាជ្ញាធរចុះទៅអប់រំដល់ មូលដ្ឋាន សាងសង់បង្គន់អនាម័យ កន្លែងលាងដៃ សាងសង់ផ្ទះស្នាក់នៅសម្រាប់សិស្សមកពីឆ្ងាយ។

### ៤.១.៥.៣ ការរៀនត្រួតថ្នាក់

តាមរយៈទិន្នន័យផ្តល់ដោយមន្ទីរអប់រំ យុវជន និងកីឡាពីខេត្តគោលដៅបានបង្ហាញថា ការរៀនត្រួតថ្នាក់របស់សិស្សមានការថយចុះជាមធ្យមប្រមាណ០.៦៥% ហើយការថយចុះនេះអាចមកពីការតេស្តឡើងថ្នាក់ដើមឆ្នាំនិងចុងឆ្នាំ ការបង្កើនថវិកាសាលារៀន និងការកែទម្រង់ជាបន្តបន្ទាប់ ការខិតខំរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ការចូលរួមរបស់អង្គការដៃគូ ការខិតខំរបស់សិស្ស ការយល់ដឹងរបស់អាជ្ញាធរ សហគមន៍ មាតាបិតានិងសិស្សានុសិស្ស លើសពីនេះទៀត អាណាព្យាបាលមានការយល់ដឹងពីតម្លៃនៃការអប់រំរបស់កូនដោយជួយណែនាំកូនបន្ថែម។

ស្របជាមួយគ្នានេះដែរ ការិយាល័យអប់រំ យុវជន និងកីឡាក៏បានបញ្ជាក់ផងដែរថា ការរៀនត្រួតថ្នាក់មានការថយចុះជាមធ្យមប្រមាណ០.៣១% ដោយសារតែក្នុងរយៈពេលកន្លងមកក្រសួងអប់រំ យុវជន និងកីឡាបានកែប្រែកម្មវិធីសិក្សាសមស្រប មានសៀវភៅសិក្សាគោលគ្រប់គ្រាន់ និងមានការកែសម្រួលតាមបែបលក្ខណៈជាតិ លើសពីនេះទៀត ការិយាល័យអប់រំ យុវជន និងកីឡាក៏បានជំរុញឱ្យការបង្រៀនបន្ថែមថ្ងៃព្រហស្បតិ៍ និងមានកម្មវិធីចូលរៀនឡើងវិញ (Re-entry)។ ក្រៅពីនេះ ការិយាល័យអប់រំ យុវជន និងកីឡាក៏បានចុះជួយគ្រូទាក់ទងនឹងការបង្រៀននិងរៀន (ការធ្វើកិច្ចតែងការ ផលិតសម្ភារឧបទេស វិធីសាស្ត្របង្រៀន) ហើយគណៈគ្រប់គ្រងសាលានិងលោកគ្រូអ្នកគ្រូយកចិត្តទុកដាក់ខ្ពស់ក្នុងការគ្រប់គ្រង និងបង្រៀនសិស្សដោយមិនរើសអើង មកបង្រៀនបានទៀងទាត់ពេលវេលា ហើយមានការចុះពិនិត្យតាមដានពីគ្រប់អ្នកពាក់ព័ន្ធលើការងារបង្រៀន និងរៀន ព្រមទាំងតាមដានលទ្ធផលសិស្សតាមខែ ឆមាស និងឆ្នាំ បំប៉នសិស្សរៀនយឺតឬខ្សោយ ជាពិសេស មានការកើនឡើងនូវការយល់ដឹងរបស់អាណាព្យាបាលសិស្សពីតម្លៃនៃការអប់រំដោយមិនសូវអូសទាញកម្លាំងពលកម្មរបស់កូន។

តែផ្ទុយទៅវិញ តាមរយៈទិន្នន័យទទួលបានពីនាយក នាយិកាបានបង្ហាញថា អត្រាត្រួតថ្នាក់ជាមធ្យមកើនឡើង០.៦៤% ដែលហាក់ដូចជាផ្ទុយពីទិន្នន័យនៃមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា ដែលការកើនឡើងនៃការត្រួតថ្នាក់នេះ អាចបណ្តាលមកពីសិស្សរៀនខ្សោយ អវត្តមានច្រើន ជីវភាពគ្រួសារក្រីក្រ មករៀនមិនទៀងទាត់ព្រោះទីលំនៅឆ្ងាយពីសាលា សិស្សផ្លាស់ប្តូរទីលំនៅញឹកញាប់ សិស្សច្រើនមករៀនយឺត គ្រូមិនសូវយកចិត្តទុកដាក់លើសិស្សខ្សោយ ហើយសិស្សខ្លះមិនយកចិត្តទុកដាក់រៀនសូត្រ ឬមិនមកប្រឡងជាដើម។ ដូចគ្នានេះដែរ លោកគ្រូអ្នកគ្រូបង្រៀនបានបញ្ជាក់ថា អត្រាត្រួតថ្នាក់កើនឡើងជាមធ្យម០.៣៧% ដែលកត្តានេះបណ្តាលមកពីសិស្សអវត្តមានច្រើន ទៅតាមឪពុកម្តាយ ផ្លាស់ប្តូរទីលំនៅតាមឪពុកម្តាយ សិស្សអាយុច្រើនឈប់រៀន ដើរលេងច្រើន ចូលរៀនតិច ការសិក្សាខ្សោយ ឪពុកម្តាយមិនបានជំរុញ ខ្វះចំណេះដឹងមូលដ្ឋានពីថ្នាក់ក្រោម និងកម្មវិធីសិក្សាមិនទាន់បានល្អ។

ផ្ទុយទៅវិញ ទោះបីមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាខ្លះបានលើកឡើងពីអត្រារៀនត្រួតថ្នាក់ថយចុះនៅក្នុងមន្ទីរនិងការិយាល័យរបស់ខ្លួនក្តី ក៏នៅមានមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាមួយចំនួនតូច ការរៀនត្រួតថ្នាក់នៅមានការកើនឡើងតិចតួចផងដែរ ដែលកត្តានេះអាចបណ្តាលមកពីសិស្សរៀន

ខ្សោយ មិនបានមករៀនទៀងទាត់ អវត្តមានច្រើន ខ្វះការជួយបំប៉នដល់សិស្សរៀនយឺត សាលាមិនបានបង្កើតថ្នាក់រៀនបន្ថែម គ្រូមិនសូវសហការជាមួយអាណាព្យាបាលសិស្ស បង្រៀនមិនសូវដិតដល់និងទៀងទាត់ មិនគោរពពេលម៉ោងបង្រៀន បង្រៀនគ្មានកិច្ចតែងការ សិស្សធ្លាក់មធ្យមភាគមួយចំនួនពុំបានចូលរួមធ្វើតេស្តឡើងថ្នាក់ គ្រូគាត់គិតពីគុណភាពការសិក្សាជាគោលដែលអ្នកមិនចេះមិនឱ្យឡើងថ្នាក់ ឪពុកម្តាយមួយចំនួនមិនសូវគិតគូរដល់ការរៀនសូត្ររបស់កូនៗជាដើម។

ស្រដៀងគ្នានេះដែរអាជ្ញាធរក្រុងស្រុក ឃុំសង្កាត់ និងឪពុកម្តាយឬអាណាព្យាលសិស្សក៏បានលើកឡើងពីការយល់ឃើញរបស់ខ្លួនថា មានការកើនឡើងតិចតួចលើអត្រាត្រួតថ្នាក់ ដោយហេតុថា កត្តាសិស្ស សិស្សមួយចំនួនតូចពុំសូវយកចិត្តទុកដាក់លើការសិក្សានិងមួយចំនួនទៀតមករៀនមិនសូវជាប់លាប់(អវត្តមានច្រើន)ផ្ទះនៅឆ្ងាយពីសាលា សិស្សខ្លះសមត្ថភាពនៅមានកម្រិតដែលមិនយល់អ្វីគ្រូពន្យល់ ហើយក្នុងចំណោមនោះ ភាគច្រើនជាសិស្សដែលមិនគ្រប់អាយុនិងមកពីគ្រួសារក្រីក្រ ខ្ជិលរៀនដោយរវល់នឹងការរកប្រាក់ទទួលទាន អវត្តមានច្រើនទៅជួយឪពុកម្តាយ និងទៅស៊ីឈ្នួលគេក្នុងនិងក្រៅស្រុក សិស្សមួយចំនួនចូលរៀនមិនទៀងទាត់ (ឈប់ច្រើនលើសការកំណត់) ខ្លះរៀនមិនចូលរៀន (រៀនខ្សោយឬរៀនមិនទាន់គេ) មានស្មារតីមិនល្អ ភ្លេចមុខភ្លេចក្រោយ បោះបង់ការសិក្សាពាក់កណ្តាលឆ្នាំនិងចូលរៀនវិញ សិស្សខ្លះរៀនខ្សោយ។ កត្តាជីវភាព សិស្សខ្លះជាប់រវល់ជួយធ្វើកិច្ចការឪពុកម្តាយ ចំណាកស្រុក កុមារនៅឆ្ងាយពីសាលា ជីវភាពឪពុកម្តាយក្រីក្រ ពុំមានការយល់ដឹងនិងឱ្យតម្លៃលើការសិក្សា។ កត្តាសង្គម សិស្សខ្លះមានមិត្តភក្តិគេចសាលាមិនចូលរៀន សេពគ្រឿងញៀន ដើរលេងមិនចូលផ្ទះ។ កត្តាគ្រប់គ្រង មកពីវិន័យរបស់សាលារៀនដែលធូររលុង ពោលគឺគ្រប់គ្រងមិនបានដិតដល់និងគ្រប់ជ្រុងជ្រោយ។ កត្តាគ្រួសារឪពុកម្តាយមិនបានតាមដានការសិក្សារបស់កូន។ ក្រៅពីនេះមកពីកត្តាគ្រូ គ្រូគិតលើគុណភាព មានការតាមដានសិស្សដែលមិនមករៀន គិតពីក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ពេក ហើយយកចិត្តទុកដាក់ជាមួយសិស្ស រឹតបន្តឹងច្បាប់ទម្លាប់និងតាមដានសិស្សច្បាស់លាស់។ កត្តាចុងក្រោយគឺកត្តាអាជ្ញាធរ មិនសូវបានផ្សព្វផ្សាយដល់មាតាបិតាជួយជំរុញកូនឱ្យមករៀន ឬពេលខ្លះសាលាមិនបានសហការជាមួយអាជ្ញាធរមូលដ្ឋានឱ្យបានជាប្រចាំ។

### ៤.១.៤.៤ ការបង្ការនិងទប់ស្កាត់ការត្រួតថ្នាក់

ដើម្បីបង្ការនិងទប់ស្កាត់ការត្រួតថ្នាក់ មន្ទីរអប់រំ យុវជន និងកីឡា បានបង្កើនអាហារូបករណ៍ជាពិសេសសិស្សស្រីបង្កើនបង្គន់អនាម័យតាមសាលារៀនរក្សាសុវត្ថិភាពរបស់សិស្សស្រី

អាជ្ញាធរដែនដីជួយជំរុញប្រជាជនឱ្យដឹងពីតម្លៃនៃការអប់រំ ពង្រឹងវិន័យក្នុងការរៀន និងបង្រៀន ធ្វើតេស្ត វាយតម្លៃនិងជួយគាំទ្រផ្នែកបច្ចេកទេស និងសម្ភារៈព្រមទាំងប្រជុំបូកសរុបលទ្ធផលសិក្សាប្រចាំសប្ដាហ៍ជាមួយការិយាល័យជំនាញ និងអង្គភាពក្រោមឱវាទ ជំរុញនិងលើកទឹកចិត្តគ្រូដែលមានស្នាដៃល្អ បង្រៀនបន្ថែមក្នុងវិស្សមកាលធំ ជំរុញឱ្យអាណាព្យាបាលជួយបំប៉នកូនបន្ថែម ជំរុញគ្រូឱ្យមកបង្រៀនឱ្យបានទៀងទាត់ពេលវេលា រៀបចំផែនការបង្រៀនច្បាស់លាស់ បំប៉នសិស្សខ្សោយ ហើយគ្រូបន្ទុកថ្នាក់ត្រូវសហការជាមួយអាណាព្យាបាលសិស្សឱ្យបានល្អ និងសុំកិច្ចអន្តរាគមន៍ពីអ្នកពាក់ព័ន្ធ បង្កើតថ្នាក់បង្រៀនបន្ថែមគ្រប់សាលា។ ចំណែកឯការិយាល័យអប់រំ យុវជន និងកីឡា និងអាជ្ញាធរក្រុងស្រុកក៏បានធ្វើសកម្មភាពមួយចំនួនផងដែរដើម្បីទប់ស្កាត់ការរៀនត្រួតថ្នាក់ ដូចជា រៀបចំឱ្យមានថ្នាក់បំប៉នពិសេសនិងក្លឹបសិក្សាសម្រាប់សិស្សរៀនយឺត ពង្រឹងការគ្រប់គ្រងអវត្តមានសិស្ស ធ្វើតេស្តចុងឆ្នាំនិងដើមឆ្នាំ ពង្រឹងសមត្ថភាពគ្រូ និងវិធីសាស្ត្រក្នុងការបង្រៀនរបស់គ្រូ ពង្រឹងការបង្រៀន រៀន និងវិន័យរបស់គ្រូនិងសិស្ស ជំរុញឱ្យគ្រូធ្វើកិច្ចតែងការបង្រៀន ហើយបង្រៀនត្រូវមានសម្ភារឧបទេស គោរពពេលម៉ោង និងយកចិត្តទុកដាក់ចំពោះសិស្សរៀនយឺត និងបណ្ដុះបណ្ដាលគ្រូពីវិធីសាស្ត្រថ្មីៗ កាត់បន្ថយគ្រូកិច្ចសន្យាពីថ្នាក់ពីរពេលគួប បង្កើតក្រុមប្រឹក្សាកុមារនៅតាមសាលា ដើម្បីជួយសិស្សរៀនយឺតនៅពេលចេញលេងនិងម៉ោងទំនេរ ព្រមទាំងជំរុញមាតាបិតាសិស្សឱ្យជួយបង្រៀនកូននៅផ្ទះបន្ថែម។លើសពីនេះទៀតការិយាល័យអប់រំយុវជននិងកីឡាស្រុកក៏បានបង្កើតកម្មវិធីរៀនសិស្សជួយសិស្ស ចុះពិនិត្យតាមដាន DTMT ទៀងទាត់ទាន់ពេលវេលា ពង្រឹងទៅលើការងារគ្រប់គ្រង(វត្តមានគ្រូសិស្ស) ចុះអធិការកិច្ចថ្នាក់រៀន តាមដានលទ្ធផលសិក្សារាល់៦ខែម្ដង ចុះដល់ផ្ទះសិស្សអវត្តមានច្រើនដោយផ្ទាល់ និងបន្តសហការជាមួយអាជ្ញាធរ គណៈកម្មការទ្រទ្រង់សាលាប្រជុំនាយកសាលាស្ដីពីការអនុវត្តតួនាទីភារកិច្ច ដូចជាប្រសិទ្ធភាពការចាយថវិកា ការធ្វើតេស្តឡើងថ្នាក់សម្រាប់សិស្សធ្លាក់មធ្យមភាគ ប្រសិទ្ធភាពការប្រជុំបច្ចេកទេស ក្រៅពីនេះក៏បានទំនាក់ទំនងជាមួយមាតាបិតាឬអាណាព្យាបាលសិស្សពេលឃើញសិស្សអវត្តមានច្រើន (ណាត់ជួបឪពុកម្ដាយសិស្ស) ជំរុញនៅពេលមានការប្រជុំភូមិ ឃុំ គណៈកម្មការទ្រទ្រង់សាលាពិនិត្យតាមដានបង្កើនអាហារូបករណ៍សិស្ស លើកទឹកចិត្តសិស្សក្រីក្រឱ្យចូលរៀន។ អាជ្ញាធរស្រុក និងឃុំសង្កាត់បានចុះជួយដោះស្រាយធុរៈគ្រួសារដែលមានការលំបាក សម្របសម្រួលជាមួយពេទ្យដោះស្រាយបញ្ហាជាក់ស្ដែងនិងតាមលទ្ធភាព ពង្រឹងវិន័យគ្រូ អាណាព្យាបាលសិស្សឱ្យខិតខំបង្រៀនសិស្សប្រកបដោយមនសិការវិជ្ជាជីវៈ ពង្រឹងការទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស ជំរុញអាណាព្យាបាលពិនិត្យតាមដានសៀវភៅសិក្ខាគារិកប្រចាំខែ ប្រជុំផ្សព្វផ្សាយតាម

ភូមិ ឃុំពីសកម្មភាពសិស្សនិងជួបផ្ទាល់ជាមួយឪពុកម្តាយសិស្ស បានជំរុញដល់ការិយាល័យអយក. បើកថ្នាក់បំប៉នដល់សិស្សរៀនខ្សោយបន្ថែម និងតាមដានសៀវភៅទិន្នន័យសិស្សជាប្រចាំ។ ផ្តល់យោបល់ដល់សិស្ស និងអាណាព្យាបាលឱ្យជំរុញកូនយកចិត្តទុកដាក់រៀនសូត្រ និងឱ្យគ្រូពន្យល់កុំឱ្យឈប់ច្រើនពេក យកចិត្តទុកដាក់សិស្សស្រីដោយសង់បង្គន់អនាម័យ ប្រជុំពិភាក្សាជាមួយអាណាព្យាបាលសិស្សរកមូលហេតុអវត្តមាន និងយកចិត្តទុកដាក់លើសិស្សរៀនខ្សោយ ព្រមទាំងបើកយុទ្ធនាការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់តម្លៃការសិក្សា ប្រជុំជាមួយគ្រូស្វែងយល់ពីចំណាត់ថ្នាក់សិស្សនិងរកវិធីលើកកម្ពស់កែតម្រូវឡើងវិញ ជាពិសេសអាជ្ញាធរបានជួយអន្តរាគមន៍ទិញកង់ឱ្យសិស្សនៅឆ្ងាយនិងសម្ភារសិក្សា និងរាយការណ៍ទៅឪពុកម្តាយពេលសិស្ស មិនមករៀនដោយឥតមូលហេតុ។

ចំណែកឯ នាយក នាយិកា និងលោកគ្រូអ្នកគ្រូវិញក៏បានចូលរួមយ៉ាងសកម្មក្នុងការទប់ស្កាត់និងបង្ការការរៀនត្រួតថ្នាក់ ដូចជាណែនាំអាណាព្យាបាលឱ្យជួយជំរុញកូនឱ្យមករៀនទៀងទាត់ និងណែនាំឱ្យគ្រូរៀបចំផែនការជួយសិស្សជាប្រចាំ ព្រមទាំងពង្រឹងការបង្រៀនគ្រប់កម្រិតដោយជួយតាមដានសិស្សដែលខ្សោយជាប្រចាំ ហើយជួយបង្រៀនបន្ថែមថ្ងៃព្រហស្បតិ៍ កំណត់រកសិស្សដែលរៀនខ្សោយដើម្បីងាយស្រួលបំប៉នបន្ថែម។ លើសពីនេះបានសហការជាមួយគណៈកម្មការទ្រទ្រង់សាលា និងសហគមន៍ ដោយចុះណែនាំដល់ផ្ទះរបស់សិស្សដែលរៀនខ្សោយ។ គណៈកម្មការទ្រទ្រង់សាលានិងគ្រូៗបានអប់រំសិស្សដែលអវត្តមានច្រើន ផ្តល់ព័ត៌មានដល់មាតាបិតាសិស្សឱ្យប្រាប់សិស្សមករៀនឱ្យទៀងទាត់ព្រមទាំងចុះជួបអាណាព្យាបាលសិស្សដែលរៀនយឺត និងត្រួតពិនិត្យអវត្តមានសិស្សជាប្រចាំ ហើយបានជំរុញគ្រូៗឱ្យយកចិត្តទុកដាក់លើការបង្រៀនសិស្សនិងវិធីសាស្ត្របង្រៀន ហើយក៏បានជំរុញសិស្សឱ្យខិតខំរៀន និងពង្រឹងវិន័យវត្តមានតឹងរឹង ដោយចុះតាមដាន និងវាយតម្លៃការសិក្សាសិស្សតាមថ្នាក់ឱ្យបានញឹកញាប់ រួមទាំងធ្វើតេស្តចុងឆ្នាំ និងដើមឆ្នាំជាដើម។ ក្នុងនោះផងដែរលោកគ្រូ អ្នកគ្រូក៏បានចូលរួមសកម្មភាពមួយចំនួន ក្នុងការទប់ស្កាត់ការរៀនត្រួតថ្នាក់ ដូចជា បានខិតខំបង្រៀនឱ្យអស់សមត្ថភាពដោយជួយសិស្សដែលខ្សោយ លើកទឹកចិត្តសិស្ស បំប៉នសិស្ស ហើយគ្រូក៏បានរិះរកវិធីសាស្ត្រល្អៗ រៀបចំកិច្ចតែងការបង្រៀន បង្កើតបរិយាកាសឱ្យសិស្សសិក្សា មានល្បែងកីឡាផ្តល់ប័ណ្ណសរសើរលើកទឹកចិត្ត ព្រមទាំងរកវិធីសាស្ត្រធ្វើឱ្យសិស្សឆាប់យល់ ចុះដល់ផ្ទះសិស្សពន្យល់ដល់អាណាព្យាបាលឱ្យពិនិត្យលទ្ធផលរបស់កូន ហើយបានតាមដាន វាយតម្លៃនៃការសិក្សារបស់សិស្ស បង្កើតទំនាក់ទំនងល្អជាមួយមាតាបិតាដើម្បីជួយសិស្សរៀនយឺត។ ចំពោះ

អាណាព្យាបាលសិស្សវិញក៏បានរួមចំណែកលើការទប់ស្កាត់រៀនត្រួត ថ្នាក់ផងដែរគឺបានជំរុញកូនឱ្យខំរៀនសូត្រ (មិនប្រើកូនច្រើនពេក) បង្រៀនអប់រំកូនបន្ថែមដោយលើកតម្កើងការសិក្សាពោលគឺត្រូវបញ្ជូនកូនឱ្យមករៀនទៀងទាត់ ពេលឈប់ត្រូវមានច្បាប់ ជំរុញឱ្យកូនរៀននៅផ្ទះបន្ថែម ជាងនេះទៀត គ្រូបង្រៀនត្រូវតាមដានការសិក្សារបស់សិស្សកុំរើសអើងមានឬក្រ និងមានវគ្គបំប៉នបន្ថែម មានតេស្តចុងឆ្នាំនិងដើមឆ្នាំជាដើម។ល។

### ៤.១.៩.៤ ការយល់ឃើញកត្តានាំឱ្យអត្រាបញ្ចប់ការសិក្សាទាប

តាមទិន្នន័យដែលលើកឡើងដោយមន្ទីរអយក.គោលដៅបានបង្ហាញថា កត្តាដែលធ្វើឱ្យអត្រាបញ្ចប់ការសិក្សាមានកម្រិតទាប បណ្តាលមកពីកត្តាសិស្សបោះបង់ច្រើន ខ្ពស់ជាងគេ (១០០%) ក្នុងចំណោមហេតុផលនានា ដែលហេតុផលខ្ពស់បន្ទាប់គឺចំណាកស្រុក៩១.៦៦% ក្រីក្រ៧៥% ចំណែកហេតុផលទី៤នោះ គឺសិស្សត្រួតថ្នាក់ច្រើននិងកុមាររៀនលើសអាយុ ៦៦.៦៦% រីឯអត្រាបញ្ចប់ការសិក្សាទាបបណ្តាលមកពីសិស្សជនជាតិដើមភាគតិច មានតែ ៤១.៦៦%បណ្តាលមកពីសិស្សពិការភាព៥០% និងបណ្តាលមកពីបញ្ហាផ្សេងៗមាន៨.៣៣%។

ការិយាល័យអយក.បង្ហាញថា កត្តានាំឱ្យអត្រាបញ្ចប់ការសិក្សាទាបបណ្តាលមកពីសិស្សក្រីក្រ៧២.៥៨% ហេតុផលសំខាន់បន្ទាប់ បណ្តាលមកពីចំណាកស្រុក៥១.៨៥% បោះបង់ការសិក្សា៣២.១៧% កុមាររៀនលើសអាយុ២៤.៨៨% សិស្សជនជាតិដើមភាគតិច៧.៧៦% និងបណ្តាលមកពីសិស្សពិការភាព៦.៩៧% រីឯ១៧.៥៩% បណ្តាលមកពីកត្តាផ្សេងៗដូចជា កត្តាភូមិសាស្ត្រ ផ្ទះនៅឆ្ងាយពីសាលា ផ្លូវពិបាកធ្វើដំណើរ កត្តាសង្គម ការអូសទាញរបស់មិត្តភក្តិ ឆាប់រៀបអាពាហ៍ពិពាហ៍ កត្តាជីវភាព ការប្រើប្រាស់កម្លាំងពលកម្មកុមារ ចំណាកស្រុកតាមឪពុកម្តាយ ចេញរកការងារតាមជំនាញ កត្តាសិស្ស (សិស្សចូលរៀនចិនច្រើន) និងកត្តាស្ថិតិ ស្ថិតិប្រជាជនមិនទាន់ច្បាស់លាស់ អត្រាបញ្ចប់ការសិក្សាកម្រិតទាប។

ទិន្នន័យពីអាជ្ញាធរក្រុងស្រុកវិញ ហាក់ដូចជាមានលក្ខណៈផ្ទុយពីទិន្នន័យពីមន្ទីរអយក. និងការិយាល័យអយក.គឺថាមូលហេតុដែលនាំឱ្យអត្រាបញ្ចប់ការសិក្សាទាប បណ្តាលមកពីសិស្សបោះបង់ច្រើន(៣៣.៣៣%) រីឯ៥១.៨៥%បណ្តាលមកពីចំណាកស្រុក ២៥.៩២%មកពីសិស្សត្រួតថ្នាក់ច្រើន ២២.២២%មកពីកុមារលើសអាយុ ៦៦.៦៦%មកពីសិស្សក្រីក្រ ២៩.៦២%មកពីសិស្សជនជាតិដើមភាគតិច និង៧.៤០%មកពីសិស្សពិការភាព ចំណែកឯ ១៤.៨១%មកពីកត្តាផ្សេងៗ រួមមានកត្តាជីវភាព ខ្វះហេដ្ឋារចនាសម្ព័ន្ធសមស្រប ឃុំលិចទឹកពិបាកធ្វើដំណើរ និងចំណាយថវិកាច្រើន រៀបការនិងរកការងារធ្វើជាដើម។ ក្នុងនោះដែរ ទិន្នន័យពីឃុំសង្កាត់

មានលក្ខណៈប្រហាក់ប្រហែលទៅនឹងអាជ្ញាធរក្រុងស្រុក ដែលមកពីសិស្សក្រីក្រ៦៩.៣២% ២១.៥៩%មកពីសិស្សបោះបង់ច្រើន ៥៨.៨១%មកពីចំណាកស្រុក ១១.៣៦%មកពីសិស្សត្រួតថ្នាក់ច្រើន ១៨.១៨%មកពីកុមាររៀនលើសអាយុ ១២.៥%មកពីសិស្សជនជាតិដើមភាគតិច និង ៧.៩៥%មកពីសិស្សពិការ រីឯ២០.៤៥%មកពីកត្តាផ្សេងៗ ដូចជាខ្វះគ្រូបង្រៀនមុខវិជ្ជាមួយចំនួន ខ្វះថវិកា ខ្វះមធ្យោបាយធ្វើដំណើរ ខ្វះសាលារៀនឬសាលានៅឆ្ងាយ ខ្វះសោហ៊ុយធ្វើដំណើរទៅរៀន ឬគ្មានថវិកា ការសេពគ្រឿងញៀន ចូលទៅធ្វើការតាមរោងចក្រ មានជម្ងឺប្រចាំកាយ រងឥទ្ធិពលពីមជ្ឈដ្ឋានជុំវិញ រាប់អានមិត្តភក្តិមិនល្អ ឪពុកម្តាយកេងកម្លាំងពលកម្ម និងកត្តាសិស្សផ្ទាល់ មិនសូវយកចិត្តទុកដាក់ និងអំពីហិង្សាក្នុងគ្រួសារជាដើម។

ស្រដៀងគ្នានេះ នាយក នាយិកាបានលើកឡើងថា បណ្តាលមកពីសិស្សក្រីក្រមានរហូតដល់៨០.៤២% រីឯ៧៦.៩២%មកពីចំណាកស្រុក ៥៥.២២%មកពីសិស្សបោះបង់ច្រើន រីឯ ៣០.៧៧%មកពីកុមាររៀនលើសអាយុ ២៦.៥៧%មកពីសិស្សត្រួតថ្នាក់ច្រើន ១៦.៧៨%មកពីសិស្សជនជាតិដើមភាគតិច និង៤.៨៩%មកពីសិស្សពិការភាព ចំណែក៥.៥៩%ទៀតមកពីកត្តាផ្សេងៗ ដូចជាបញ្ហាជីវភាព សិស្សចូលរៀនសាលាឯកជន ឈប់ទៅរៀបការ ហើយអាណាព្យាបាលគ្មានការយល់ដឹងអំពីតម្លៃនៃការអប់រំ និងមិនបានបញ្ជូនកូនមករៀន។

លោកគ្រូអ្នកគ្រូបានបង្ហាញថា កត្តានាំឱ្យអត្រាបញ្ចប់ការសិក្សាទាប ៥៥.២២%មកពីសិស្សបោះបង់ច្រើន ៨០.៥៥%មកពីសិស្សក្រីក្រ ៧២.៩២%មកពីចំណាកស្រុក ២៧.០៨%មកពីកុមារលើសអាយុ ២០.១៤%មកពីសិស្សត្រួតថ្នាក់ច្រើន ១៣.៨៨%មកពីសិស្សជនជាតិដើមភាគតិច និងមកពីសិស្សពិការភាព៣.៤៧% ដែលក្នុងនោះ១.៣៨%មកពីកត្តាផ្សេងៗ ដូចជាខ្វះមធ្យោបាយធ្វើដំណើរ ផ្ទះនៅឆ្ងាយពីសាលា ជីវភាពគ្រួសារទៅជួយធ្វើការឪពុកម្តាយ សម្ភារនិយម ខ្វះខាតគ្រូ ឪពុកម្តាយមិនសូវឱ្យតម្លៃលើការសិក្សា មាតាបិតាយល់ដឹង បរិយាកាសសង្គម សិស្សមិនយកចិត្តទុកដាក់រៀន សិស្សអវត្តមានច្រើន ឪពុកម្តាយមិនសូវជំរុញកូន និងឪពុកម្តាយលែងលះគ្នា។

ការយល់ឃើញរបស់ឪពុកម្តាយឬអាណាព្យាបាលបានបង្ហាញថា ៧៩.១៣%មកពីសិស្សក្រីក្រ ៩៩.៨៣%មកពីចំណាកស្រុក ២៨.៩៥%មកពីសិស្សបោះបង់ច្រើន ១៨.១០%មកពីកុមាររៀនលើសអាយុ ១៥.៥១%មកពីសិស្សត្រួតថ្នាក់ច្រើន ៦.៨៩%មកពីសិស្សជនជាតិដើមភាគតិច ៩.៤៨%មកពីសិស្សពិការភាព ចំណែកឯ២៥%ពីបញ្ហាផ្សេងៗ ដូចជាកត្តាខ្លួនឯង (រៀនមិនយល់ឬមិនខិតខំរៀនឬរៀនមិនចេះ និងមិនទាន់យល់ដឹងអំពីតម្លៃនៃការសិក្សា) កត្តាមិត្តភក្តិ

(ការអូសទាញពីមិត្តភក្តិ) កត្តាសង្គម (ការអូសទាញពីសង្គម ប្រើគ្រឿងញៀន) កត្តាគ្រួសារ (ខ្វះការជំរុញពីឪពុក ម្ដាយ អូសទាញជួយការងារផ្ទះ គ្មានឪពុកម្ដាយ) កត្តាជីវភាព (សិស្សក្រីក្រ ជីវភាពខ្វះខាត) និងកត្តាភូមិសាស្ត្រ (ផ្ទះនៅឆ្ងាយពីសាលារៀនពិបាកធ្វើដំណើរ)។

ចំពោះគ្រួសារសិស្សដែលមានកូនអាយុ១៣-២០ឆ្នាំលើកឡើងថា ៧២.៥៨%មកពីសិស្សក្រីក្រ ៤១.៨៤%មកពីចំណាកស្រុក ៣២.១៧%មកពីសិស្សបោះបង់ច្រើន ២៥.៦៧%មកពីសិស្សត្រួតថ្នាក់ច្រើន ២៤.៨៨%មកពីកុមារលើសអាយុ ៧.៧៦%សិស្សជនជាតិដើមភាគតិច ៦.៩៧%មកពីសិស្សពិការភាព ចំណែកឯ១៧.៥៩%មកពីកត្តាផ្សេងៗ ដូចជាខ្វះមធ្យោបាយធ្វើដំណើរទៅមកសាលា កង្វះជីវភាព ការជ្រើសរើសគូស្រករ កង្វះសាលារៀន (ជាពិសេស គ្មានអនុវិទ្យាល័យក្នុងភូមិ) ការតម្រូវរបស់គ្រួសារឱ្យមកជួយការងារស្រែចម្ការ ការប្រព្រឹត្តអំពើអបាយមុខ ការប្រើប្រាស់គ្រឿងញៀន ការសេពគប់មិត្តភក្តិមិនល្អ មិនខំរៀន មិនប្រឹងប្រែងរៀនសូត្ររៀនខ្សោយ មានស្នេហានិងការរៀបការ មិនមានការយល់ដឹងពីសារសំខាន់នៃការសិក្សា ការអូសទាញពីបរិយាកាសអវិជ្ជមាននៃសង្គម អត់មធ្យោបាយធ្វើដំណើរមករៀន អស់ថ្នាក់រៀនព្រោះមានត្រឹមថ្នាក់ទី៩ និងអំពើហឹង្សាក្នុងគ្រួសារជាដើម។

*ក្រាហ្វិក១.១១ កត្តានាំឱ្យអត្រាបញ្ចប់ការសិក្សាទាប*



### ៤.១.៤.៦ វិធានការដែលបានអនុវត្តកន្លងមកក្នុងការបង្កើនអត្រាបញ្ចប់ការសិក្សា

ដើម្បីឱ្យអត្រាបញ្ចប់ការសិក្សាកើនឡើង កន្លងមកមន្ទីរអប់រំ យុវជន និងកីឡាបានផ្តល់អាហារូបករណ៍ទាំងរដ្ឋនិងឯកជនតាមរយៈសប្បុរសជននានា ពង្រឹងសមត្ថភាពគ្រូ (វិធីសាស្ត្របង្រៀននិងសីលធម៌គ្រូ) ពង្រីកវិទ្យាល័យឱ្យកាន់តែមកជិតសហគមន៍ ជាពិសេសទប់ស្កាត់សិស្សបោះបង់ការសិក្សាច្រើន ត្រួតថ្នាក់ច្រើន ទប់ស្កាត់ការធ្វើចំណាកស្រុក ព្រមទាំងបណ្តុះបណ្តាល គណៈកម្មការទ្រទ្រង់សាលាក្នុងខេត្តពីតួនាទីនិងភារកិច្ចក្នុងការជួយសាលា ចុះពិនិត្យតាមដានដល់ផ្ទះ ផ្សព្វផ្សាយពីសារសំខាន់នៃការរៀនសូត្ររបស់សិស្ស បង្កើតឱ្យមានសាលាគ្រប់កម្រិត ផ្តល់សម្ភារ និងកន្លែងស្នាក់នៅសម្រាប់គ្រូនិងសិស្ស ពង្រឹងការគ្រប់គ្រងសាលារៀន ផ្តល់ថវិកាបន្ថែមដល់សាលារៀន កែលម្អបរិស្ថានសាលារៀន កន្លែងសិក្សាប្រកបដោយសុវត្ថិភាព ពង្រឹងការធ្វើ តេស្តចុងឆ្នាំនិងដើមឆ្នាំសិក្សា អនុវត្តប្រព័ន្ធឡើងថ្នាក់ដោយស្វ័យប្រវត្តិ ពង្រឹងការប្រជុំបច្ចេកទេសកម្រងដើម្បីពិនិត្យលទ្ធផលសិក្សារបស់សិស្ស លើកទឹកចិត្តឱ្យសិស្សចូលរៀន ហើយជំរុញគ្រូឱ្យបង្រៀនឱ្យបានពេញលេញនិងមានមនសិការលើការងាររបស់ខ្លួន និងជំរុញឱ្យមានគ្រូគ្រប់គ្រាន់នៅតាមជនបទ។ ចំណែកឯការិយាល័យអប់រំ យុវជន និងកីឡាវិញក៏បានចូលរួមសកម្មភាពផងដែរ ដូចជារៀបចំកម្មវិធីផ្សព្វផ្សាយពីគុណតម្លៃនៃការអប់រំរៀនសូត្រ បង្កើនកម្មវិធីដល់សិស្សក្រីក្រតាម រយៈដៃគូអភិវឌ្ឍនានា ជំរុញលើកទឹកចិត្តដល់សិស្សក្រីក្រ ផ្សព្វផ្សាយដល់គ្រប់អ្នកពាក់ព័ន្ធដើម្បីជួយដល់អាណាព្យាបាលសិស្សឱ្យកូនចៅបន្តការសិក្សាឱ្យបានចប់ចុងចប់ដើម ពង្រឹងការរៀននិងបង្រៀន ធ្វើតេស្តឡើងថ្នាក់សម្រាប់សិស្សធ្លាក់ និងពង្រឹងការងារគ្រប់គ្រងដល់សាលា តាមដានសិស្សអវត្តមានច្រើន។ លើសពីនេះទៀត ក៏បានកែលម្អគុណភាពបង្រៀននិងរៀន គ្រប់គ្រងការចុះប្រមូលទិន្នន័យកុមារឱ្យបានច្បាស់លាស់ កៀរគរឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ ព្រមទាំងកំណត់ម៉ោងចេញចូលឱ្យបានត្រឹមត្រូវ និងរៀបចំបរិស្ថានសាលាទាំងក្នុងនិងក្រៅដោយបណ្តុះផ្នត់គំនិតថ្មីៗ។ ក្រៅពីនោះ ក៏បានជួយពង្រឹងសមត្ថភាពគ្រូ ទាក់ទងនឹងការបង្រៀនដោយមានកិច្ចតែងការបង្រៀន វិធីសាស្ត្របង្រៀនជាពិសេស និយ័តការងារដោយជួយណែនាំដល់មាតាបិតាឬអាណាព្យាបាលជួយជំរុញកូនឱ្យបានមករៀនទៀងទាត់ ជួយតាមដានការសិក្សារបស់កូននៅផ្ទះបន្ថែម ហើយក៏បានធ្វើជំរឿនស្ថិតិប្រជាជន ស្ថិតិសិស្សឱ្យបានច្បាស់លាស់និងទាន់ពេលវេលា និងប្រជុំផ្សព្វផ្សាយដល់មាតាបិតាឬអាណាព្យាបាល អាជ្ញាធរដែនដីពាក់ព័ន្ធនឹងអត្រាបញ្ចប់ការសិក្សា ចុះពិនិត្យតាមដានជួយគាំទ្រសាលារៀនភូមិគោលដៅ ជាពិសេសផ្សព្វផ្សាយពីគោលនយោបាយរបស់ក្រសួងអប់រំ

យុវជន និងកីឡាដល់នាយក នាយិកានិងលោកគ្រូអ្នកគ្រូគ្រប់គ្រឹះស្ថានសិក្សា ដើម្បីចូលរួមជួយសិស្សនៅតាមសាលានីមួយៗ ដើម្បីឱ្យអត្រាបញ្ចប់ការសិក្សាកើនឡើង។ ការិយាល័យអប់រំយុវជន និងកីឡាក៏បានប្រជុំផ្សព្វផ្សាយដល់មាតាបិតាសិស្សគាត់យល់ពីតម្លៃនៃការសិក្សា និងប្រមូលកុមារដល់វ័យសិក្សាឱ្យបានចូលរៀនគ្រប់ៗគ្នា ដោយមិនរើសអើងក្នុងការផ្តល់សេវាអប់រំ។ ក្នុងនោះផងដែរអាជ្ញាធរក្រុងស្រុកក៏បានចូលរួមសកម្មភាពមួយចំនួនផងដែរក្នុងការចូលរួមចំណែកជួយឱ្យអត្រាបញ្ចប់ការសិក្សាមានការកើនឡើង ដូចជា ផ្សព្វផ្សាយដល់ឪពុកម្តាយសិស្សជួយជំរុញតាមដានសិស្សឱ្យចូលរៀនទៀងទាត់ ចងក្រងជាសហគមន៍នៅតាមមូលដ្ឋានឱ្យលោកគ្រូអ្នកគ្រូមានទំនាក់ទំនងល្អជាមួយសិស្សគោលដៅ ចុះដល់មូលដ្ឋានដើម្បីអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងពីតម្លៃនៃការអប់រំជំរុញឱ្យឪពុកម្តាយនាំកូនមករៀន ណែនាំសិស្សឱ្យយល់ពីអនាគតខ្លួននិងសារសំខាន់នៃការសិក្សា លើកទឹកចិត្តជារង្វាន់ដល់សិស្សបញ្ចប់ការសិក្សា។ នាយក នាយិកាត្រូវតាមដានការបង្រៀនរបស់លោកគ្រូអ្នកគ្រូ ហើយលោកគ្រូអ្នកគ្រូតាមបន្ទប់ថ្នាក់ត្រូវខិតខំបង្ហាត់បង្រៀនសិស្សប្រកបដោយមនសិការវិជ្ជាជីវៈ ព្រមទាំងឱ្យឪពុកម្តាយត្រូវតាមដានការសិក្សារបស់កូនជាប់ជាប្រចាំ និងខិតខំព្យាយាមបង្រៀនកូនបន្ថែម (ពេលនៅផ្ទះ)។ ចំពោះឃុំសង្កាត់វិញក៏បានចូលរួមសកម្មភាពមួយចំនួនផងដែរដោយខំជំរុញលើកទឹកចិត្ត និងពន្យល់មាតាបិតាពីតម្លៃនៃការសិក្សា ចុះពន្យល់ប្រជាពលរដ្ឋនិងទប់ស្កាត់យុវជនមិនគ្រប់អាយុទៅធ្វើការរោងចក្រ និងទប់ស្កាត់ចំណាកស្រុក ជំរុញលោកគ្រូ អ្នកគ្រូឱ្យគោរពវិន័យ និងផ្តល់អគារសិក្សា កន្លែងស្នាក់នៅ និងអាហារូបករណ៍ដល់សិស្សក្រីក្រ ហើយនាយកសាលាត្រូវតាមដានគ្រូនិងសិស្សជាប្រចាំដើម្បីឱ្យលោកគ្រូអ្នកគ្រូ បង្រៀនទៅតាមកម្មវិធីសិក្សាដែលបានកំណត់។

រីឯនាយក នាយិកាសាលាវិញបានចូលរួមសកម្មភាព ដូចជាណែនាំអាណាព្យាបាលពីតម្លៃនៃការសិក្សាផ្សព្វផ្សាយឱ្យសិស្សយកចិត្តទុកដាក់រៀន ដោយលើកទឹកចិត្តសិស្ស និងពង្រឹងការបង្រៀន ព្រមទាំងធ្វើយុទ្ធនាការនានាដើម្បីប្រមូលកុមារគ្រប់អាយុឱ្យបានចុះឈ្មោះចូលរៀនជំរុញអាណាព្យាបាលសិស្សឱ្យបញ្ជូនកូនមករៀន ដោយសហការជាមួយអាជ្ញាធរដើម្បីទប់ស្កាត់ចំណាកស្រុក និងណែនាំអាណាព្យាបាលសិស្សជំរុញកុំឱ្យកូនឈប់រៀន ក្នុងនោះដែរ កាត់បន្ថយអត្រាត្រួតថ្នាក់និងអត្រាបោះបង់ការសិក្សា ដោយកែលម្អបរិស្ថានសាលាឱ្យមានសោភ័ណភាពល្អ និងគ្រប់គ្រងការបង្រៀនរបស់គ្រូឱ្យបានទៀងទាត់ និងជួយបំប៉នបន្ថែមដល់សិស្សដែលរៀនយឺត ហើយគ្រូៗត្រូវលើកទឹកចិត្តដល់សិស្សនិងចុះតាមដានការសិក្សាសិស្សតាមថ្នាក់។ នាយក

សាលាត្រូវមានទំនាក់ទំនងល្អជាមួយអាជ្ញាធរនិងមាតាបិតាជាប់ជាប្រចាំ ដោយលើកទឹកចិត្តឱ្យរៀនយ៉ាងហោចឱ្យបញ្ចប់មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៩) លើសពីនេះទៀត នាយកត្រូវសហការជាមួយអាជ្ញាធរនិង គណៈកម្មការទ្រទ្រង់សាលាដើម្បីណែនាំអាណាព្យាបាលសិស្សកុំឱ្យប្រើអំពើហិង្សាក្នុងគ្រួសារ។ ក្នុងនោះដែរដើម្បីជំរុញឱ្យអត្រាបញ្ចប់ការសិក្សាកើនឡើង កន្លងមកលោកគ្រូ អ្នកគ្រូបានធ្វើសកម្មភាពដូចជាផ្តល់កាដូលើកទឹកចិត្តចុងឆ្នាំ ជំរុញសិស្សខិតខំសិក្សា តាមរយៈការមកបង្រៀននិងរៀនទៀងទាត់ គ្រូមានវិន័យ ក្រមសីលធម៌ មានយុទ្ធសាស្ត្រច្បាស់លាស់ តាមដានការសិក្សារបស់សិស្ស ចុះជួបផ្ទាល់ជាមួយមាតាបិតាសិស្សដែលរៀនយឺត ចុះប្រឹក្សាដល់គ្រួសារកុមារដែល អវត្តមានច្រើន បង្កើតក្លឹបសិក្សាតាមភូមិ ជំរុញឱ្យកុមារមករៀនបានទៀងទាត់ លើកទឹកចិត្តសិស្សក្រីក្រ តាមដានសិស្សរៀនយឺតជាប្រចាំ សហការជាមួយអាណាព្យាបាលសិស្សជាប្រចាំ និងលើកកម្ពស់គុណភាពសិស្ស។ លើសនេះទៀត ក៏បានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន អប់រំប្រជាពលរដ្ឋឱ្យយល់ដឹងពីតម្លៃនៃការអប់រំ ជាពិសេសរៀបចំសាលាឱ្យក្លាយជាសាលាមេត្រី អភិវឌ្ឍផ្លូវចេញចូល និងបង្កើតវិទ្យាល័យឱ្យជិតទីតាំងមូលដ្ឋាន ព្រមទាំងសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់អំពើអបាយមុខផ្សេងៗ។ ចំណែកឯ ឪពុកម្ដាយឬអាណាព្យាបាលសិស្សវិញ បានចូលរួមសកម្មភាពជួយឱ្យអត្រាបញ្ចប់ការសិក្សាកើនឡើង ដូចជា ផ្សព្វផ្សាយស្ដីពីសារសំខាន់នៃចំណេះដឹងតាមរយៈកម្មវិធីផ្សេងៗ ដោយជួយពន្យល់ក្មេងៗឱ្យយល់ពីតម្លៃនៃការសិក្សា ណែនាំកូនកុំឱ្យសេពគ្រឿងញៀន ព្រមទាំងចូលរួមពិភាក្សាជាមួយគ្រូបង្រៀន ដើម្បីទាក់ទងអាណាព្យាបាលឱ្យគាត់យល់ពីការសិក្សារបស់កូនចៅ។ ស្រដៀងគ្នានេះដែរ គ្រួសារសិស្សបានចូលរួមសកម្មភាពដូចជាជំរុញឱ្យសិស្សប្រឹងសិក្សាខ្លួនឯងបន្ថែម នាយកគ្រប់គ្រងគ្រូនិងសិស្សបានហ្មត់ចត់ កុំប្រើកូនធ្វើការងារផ្ទះច្រើនពេកនិងមានទំនាក់ទំនងជាមួយគ្រូបន្ទុកជាប្រចាំ។ ម៉្យាងទៀត លោកគ្រូអ្នកគ្រូបង្រៀនសិស្សបានជិតដល់ មានភាពទន់ភ្លន់ជាមួយសិស្សទាំងកាយ វាចា ចិត្ត និងមានទំនាក់ទំនងល្អជាមួយនឹងអាណាព្យាបាលសិស្ស។

## ៤.២ ទស្សនៈទូទៅនិងបញ្ហាប្រឈមនៃអត្រាបញ្ចប់ការសិក្សា

### ៤.២.១ ការពេញចិត្តលើអត្រាបញ្ចប់ការសិក្សា

ទិន្នន័យរួមពីអ្នកចូលរួមទាំងអស់ឃើញថា មានការមិនពេញចិត្តនឹងអត្រាបញ្ចប់ការសិក្សាទាល់តែសោះមានតែ៩.៧៧% និងពេញចិត្តតិចតួច១១.៩៣% តែផ្ទុយទៅវិញអ្នកដែលពេញ

ចិត្តមធ្យម៣២.៣៦% រីឯ៣៧.០៣ពេញចេញភាគច្រើន នៅពេលដែល២២.៤២%ពេញចិត្តទាំងស្រុងចំពោះអត្រាបញ្ចប់ការសិក្សា។ ដូច្នេះ ទិន្នន័យនេះបញ្ជាក់ថាភាគច្រើននៃអ្នកចូលរួមទាំងអស់ពេញចិត្តនឹងអត្រាបញ្ចប់ការសិក្សា ថ្វីបើមន្ទីរអប់រំ យុវជន និងកីឡាទាំង១២ គ្មានខេត្តណាមួយពេញចិត្តទាំងស្រុង នឹងអត្រាបញ្ចប់ការសិក្សានៅក្នុងមន្ទីររបស់ខ្លួននៅឡើយក្តី នៅពេលដែលការិយាល័យអប់រំ យុវជន និងកីឡាតិចតួច មិនពេញចិត្តនឹងលទ្ធផលនៃអត្រាបញ្ចប់ការសិក្សាទាល់តែសោះ ដែលទិន្នន័យពីអាជ្ញាធរក្រុងស្រុក មានលក្ខណៈប្រហាក់ប្រហែលទៅនឹងទិន្នន័យនៃការិយាល័យអប់រំ យុវជន និងកីឡាដែរ។

*ក្រាហ្វិក១.១២ ការពេញចិត្តនឹងអត្រាបញ្ចប់ការសិក្សា*




## ៤.២.២ បញ្ហាប្រឈមលើការបំពេញនាទកិច្ច

ទោះបីកន្លងមកក្រសួងអប់រំ យុវជន និងកីឡាគ្រប់លំដាប់ថ្នាក់តាំងពីក្រសួង មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា សាលាបានខិតខំធ្វើកំណែទម្រង់ទៅលើហិរញ្ញវត្ថុ ហេដ្ឋារចនាសម្ព័ន្ធ សម្ភារបរិក្ខាររៀននិងបង្រៀន ព្រមទាំងអភិវឌ្ឍសមត្ថភាពដល់

បុគ្គលិកអប់រំយ៉ាងណាក៏ដោយ ក៏វិស័យអប់រំនៅតែមានបញ្ហាប្រឈម ដែលក្នុងនោះមន្ទីរអប់រំ យុវជន និងកីឡាទាំង១២ខេត្ត ដូចជាការប្រមូលទិន្នន័យមិនបានគ្រប់គ្រាន់ពីកន្លែងផ្សេងៗ ការផលិតទិន្នន័យនៅមានកម្រិត ការអនុវត្តថវិកាមិនសូវរលូន ការិយាល័យក្រុងស្រុកនៅខ្វះសម្ភារបច្ចេកទេសដូចជាកុំព្យូទ័រម៉ាស៊ីនហ្វូតូកូពីជាដើម ហើយមន្ត្រីមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុកពុំទាន់មានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងភាសាអង់គ្លេសល្អនៅឡើយ លើសពីនេះទៀត មន្ត្រីតាមការិយាល័យអប់រំ យុវជន និងកីឡាហាក់ខ្លះដូចជាមិនសូវយកចិត្តទុកដាក់នឹងការងារ ហើយកាន់ការងារច្រើនមុខ ជាពិសេសសមត្ថភាពដឹកនាំនិងគ្រប់គ្រងនៅមានកម្រិត បច្ចេកទេសនិងការគ្រប់គ្រងមិនទាន់មានភាពរលូន ទម្លាប់ពុំមានការកែទម្រង់ពីក្រសួង មន្ត្រីគ្មានមនសិការវិជ្ជាជីវៈ ពុំមានការលើកទឹកចិត្តសម្រាប់អ្នកខំធ្វើការពីថ្នាក់ដឹកនាំ ការកសាងសមត្ថភាពនៅមានកម្រិត ជាពិសេស មន្ត្រីពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំផែនការបច្ចេកទេសក្នុងការគណនាអត្រាផ្សេងៗ ក្រៅពីនេះក៏នៅខ្វះគ្រូច្រើនសម្រាប់បម្រើការតាមសាលានីមួយៗផងដែរ។ ស្រដៀងគ្នានេះដែរ ទិន្នន័យផ្តល់ដោយការិយាល័យអប់រំ យុវជន និងកីឡាក៏បានលើកជាកង្វល់និងបញ្ហាប្រឈមមួយចំនួនផងដែរ ដូចជាការប្រើប្រាស់ក្នុងកុំព្យូទ័រនៅមានកម្រិត ការងាររដ្ឋបាលមិនច្បាស់លាស់ ខ្វះថវិកាក្នុងការជួសជុលកុំព្យូទ័រ ម៉ាស៊ីនថតចម្លង កន្លែងធ្វើការតូចចង្អៀត (គ្មានសម្ភារប្រើប្រាស់គ្រប់គ្រាន់) ចំណែកឯ នាយកសាលាភាគច្រើនមិនសូវយល់ពីបញ្ហាបច្ចេកវិទ្យា (IT) មិនសូវមានចំណេះដឹងអំពីការកសាងផែនការអភិវឌ្ឍសាលារៀន ឬផែនការប្រតិបត្តិប្រចាំឆ្នាំ មិនទាន់ចេះតាមដាននិងពិនិត្យវាយតម្លៃលើផែនការប្រតិបត្តិរបស់ខ្លួន មិនទាន់មានផែនការសកម្មភាពប្រចាំខែ ខ្វះបុគ្គលិកបង្រៀន ហើយការបង្រៀនរបស់លោកគ្រូអ្នកគ្រូខ្លះ មិនទាន់ឆ្លើយតបតម្រូវការរបស់ក្រសួង។ នាយកសាលាខ្លះពុំទាន់បានចូលរួមវគ្គបណ្តុះបណ្តាលអំពីការងារគ្រប់គ្រងនិងដឹកនាំ។ ការអនុវត្តមិនទាន់ស៊ីសង្វាក់គ្នាដោយនៅមើលបំណាំគ្នា ធ្វើការប្រៀបធៀប ការអនុវត្តវិន័យមិនទាន់បានម៉ឺងម៉ាត់ទាំងបុគ្គលិក ទាំងសិស្ស ដែលលោកគ្រូអ្នកគ្រូខ្លះនៅចង់បានលាភសក្ការៈពីសិស្ស (ការបង្រៀនឈ្នួលក្រៅម៉ោង) ខ្វះគ្រូក្របខណ្ឌបឋមសិក្សានិងមត្តេយ្យសិក្សានិងគ្រូឯកទេសគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ដែលគ្រូខ្លះបង្រៀនមិនតាមឯកទេស ហើយគ្រូភាគច្រើនមិនចេះភាសាអង់គ្លេស និងកុំព្យូទ័រសម្រាប់បម្រើកិច្ចការរដ្ឋបាលតាមសាលាដែលធ្វើឱ្យការងាររាំងស្ទះ ខ្វះអគារសិក្សា កម្មវិធីសិក្សាមានការផ្លាស់ប្តូរតែពុំបានបំប៉នគ្រូ។ ក្នុងនោះដែរ អាជ្ញាធរក្រុងស្រុកបានជួបនូវបញ្ហាប្រឈម ដូចជាការអនុវត្តការងារប្រចាំថ្ងៃមិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ដូចជាភាពយឺតយ៉ាវលើរបាយការណ៍ប្រចាំថ្ងៃ ទីកន្លែងធ្វើការរបស់

ការិយាល័យអប់រំមិនត្រូវស្តង់ដារការងារ ខ្វះគ្រូគ្រប់មុខវិជ្ជា ជាពិសេសនៅជនបទដាច់ស្រយាល ហើយសមត្ថភាពគ្រូនិងនាយកមួយចំនួននៅមានកម្រិត (គ្រូខ្លះមិនសូវយកចិត្តទុកដាក់ក្នុងការបង្រៀន) និងខ្វះអគារសិក្សា។ ការទំនាក់ទំនងរវាងនាយក សាលាជាមួយអាជ្ញាធរមូលដ្ឋាននៅមានកម្រិត ព្រមទាំងខ្វះការចូលរួមពីអាណាព្យាបាលឬមាតាបិតាសិស្ស ហើយក្រុងស្រុកក៏ពុំមានថវិកាជួយពាក់ព័ន្ធនឹងការងារអប់រំ ពេលវេលាខ្លីមិនគ្រប់គ្រាន់ព្រោះថាមានការងារបន្ទាន់ច្រើន។ អាជ្ញាធរស្រុកមានមន្ត្រីតិចសម្រាប់ទទួលបន្ទុកការងារអប់រំ មធ្យោបាយធ្វើដំណើរចុះត្រួតពិនិត្យតាមដាននៅមានកម្រិត មានការលំបាកដោយអាជ្ញាធរស្រុកភាគច្រើនមិនរៀនអំពីជំនាញអប់រំ ហើយរដ្ឋបាលក្រុងស្រុក ឃុំសង្កាត់ នៅខ្វះព័ត៌មានពីសាលារៀន ហើយអត្រាត្រួតថ្នាក់នៅមានកម្រិតខ្ពស់ រៀនមិនបានតាមកម្មវិធីសិក្សាដែលក្រសួងកំណត់។ រីឯឃុំសង្កាត់វិញបានលើកឡើងពីបញ្ហាប្រឈម ដូចជា កង្វះរបាយការណ៍អប់រំពីសាលារៀន មិនបានគ្រោងកញ្ចប់ថវិកាសម្រាប់អប់រំ ការងារសង្កាត់ច្រើនមិនបានបំពេញការងារអប់រំញឹកញាប់ អាណាព្យាបាលមិនសូវចូលរួម ការប្រើទូរស័ព្ទដៃរបស់សិស្សក្នុងថ្នាក់រៀន ការមិនយកចិត្តទុកដាក់ និងកិច្ចសហការពីភូមិឃុំនិងមាតាបិតាសិស្ស ការមិនឱ្យតម្លៃពីសង្គម ដូចជាកូនស្រីមិនអាចធ្វើការកើត ជាគំនិតចាស់គំរិលពីសម័យមុន ខ្វះខាតទំនាក់ទំនងរវាងគ្រូនិងអាជ្ញាធរ ខ្វះការចូលរួមពីមាតាបិតា ខ្វះគ្រូ ការបង្រៀនមិនសូវបានទៀងទាត់ គ្រូមកពីឆ្ងាយៗ ខ្វះគ្រូបង្រៀន ខ្វះឯកសាររៀននិងបង្រៀន ខ្វះទិន្នន័យស្ថិតិពីសាលា។ល។

ចំពោះនាយក នាយិកាសាលា បានលើកឡើងពីបញ្ហាប្រឈមដូចជាទីធ្លាសាលាតូចចង្អៀត នាយកថ្មីមិនបានទទួលការបណ្តុះបណ្តាលលើសមត្ថភាពគ្រប់គ្រង ដឹកនាំការងាររដ្ឋបាល និងព័ត៌មានវិទ្យា ការផ្តល់របាយការណ៍មិនទាន់ពេលវេលា ខ្វះសម្ភារប្រើប្រាស់ ដូចជាកុំព្យូទ័រជាដើម ខ្វះអាគារសិក្សា ខ្វះតុអង្គុយសិក្សា ខ្វះបណ្ណាល័យនិងបន្ទប់ការិយាល័យ ខ្វះការចូលរួមពីសហគមន៍ ខ្វះការបំប៉នបច្ចេកទេសថ្មីៗដល់គ្រូនិងប្រធានក្រុមបច្ចេកទេស ខ្វះគ្រូបង្រៀនតាមមុខវិជ្ជា ខ្វះសៀវភៅគោល ខ្វះសម្ភារៈបង្រៀននិងរៀន ខ្វះទិន្នន័យស្ថិតិប្រជាជន ហើយគ្រូមួយចំនួនផ្លាស់ចេញញឹកញាប់ គ្រូខ្លះមិនសូវយកចិត្តទុកដាក់និងមកសាលាមិនទៀងទាត់។ ស្រដៀងគ្នានេះដែរ លោកគ្រូអ្នកគ្រូបានលើកឡើងពីបញ្ហាប្រឈម ដូចជា ការគ្រប់គ្រងរដ្ឋបាលសាលានៅមានកម្រិតខ្វះកុំព្យូទ័រការទុកដាក់ឯកសារនិងបញ្ជីគណនេយ្យនៅមានកម្រិត ខ្វះកន្លែងស្នាក់នៅសម្រាប់គ្រូនិងសិស្ស ខ្វះការចូលរួមពីសហគមន៍ ក្មេងមិនសូវយកចិត្តទុកដាក់លើសិក្សា ខ្វះការបណ្តុះបណ្តាលការងារបច្ចេកទេស គ្មានអគ្គិសនី និងអេឡិចត្រូនិច ខ្វះតុសិស្ស

ខ្វះសម្ភារ ខ្វះសៀវភៅសិក្សាគោល ខ្វះកិច្ចតែងការបង្រៀន។ សាលាពុំមានបង្គន់អនាម័យគ្រប់គ្រាន់បន្ទប់រៀនចាស់ទ្រុឌទ្រោមបង្គន់ជាប់ថ្នាក់រៀន។ចំណែកឯនាយកវិញមានការងារច្រើនមុខដែលនាំឱ្យបំពេញការងារមិនបានពេញដៃពេញជើង។

### ៤.២.៣ សំណូមពររបស់អ្នកចូលរួមពីអត្រាបញ្ចប់ការសិក្សា

ដើម្បីឆ្លើយតបទៅនឹងទិសដៅ ក៏ដូចជាគោលបំណងរបស់ក្រសួងអប់រំ យុវជន និងកីឡា ទាក់ទងទៅនឹងអត្រាបញ្ចប់ការសិក្សាទាំងបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ មន្ទីរអប់រំ យុវជន និងកីឡាបានសំណូមពរឱ្យក្រសួងផ្តល់អាហារូបករណ៍ដល់សិស្សឱ្យបានច្រើន ទាន់ពេល ព្រមទាំងបំប៉នសមត្ថភាពដល់មន្ត្រីការិយាល័យដើម្បីឱ្យពួកគាត់ចុះទៅផ្សព្វផ្សាយដល់លំនៅដ្ឋាន នាំកុមារចុះឈ្មោះចូលរៀន លើសពីនេះទៀត គួរជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបថរបស់មាតាបិតាចំពោះកូនស្រី បង្កើនការងារស្ត្រីក្នុងសង្គមឱ្យបានច្រើន ពង្រឹងសុវត្ថិភាពរបស់សិស្សស្រី ព្រមទាំងជួយបំប៉នសមត្ថភាពដល់មន្ត្រីបច្ចេកទេសពីថ្នាក់សាលារៀន ការិយាល័យអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡា ហើយទម្លាក់ថវិកាដល់សាលាឱ្យទាន់ពេលវេលា ចុះអធិការកិច្ចតាមសាលា មានថ្នាក់ក្រសួងបើអាចធ្វើទៅបាន ផ្តល់អគារសិក្សានៅតំបន់សាលាដែលខ្វះអគារ ផ្តល់គ្រូតាមមុខវិជ្ជាដល់សាលាដែលខ្វះខាតគ្រូ បណ្តុះបណ្តាលមន្ត្រីនៅមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡាពីនាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ព្រមទាំងបណ្តុះបណ្តាលនាយកសាលាឱ្យចេះប្រើកុំព្យូទ័រ បើកវគ្គបំប៉នពីវិធីសាស្ត្របង្រៀន និងសីលធម៌គ្រូ បំពាក់បង្គន់ អនាម័យតាមស្តង់ដារឱ្យបានគ្រប់សាលាចាប់ពីបឋមសិក្សាដល់វិទ្យាល័យ សាងសង់និងជួសជុលអគារសិក្សាឱ្យបានសមស្រប ពង្រឹងសមត្ថភាពគ្រូពីការបង្រៀននិងវិធីសាស្ត្រថ្មីៗ លើកទឹកចិត្តបុគ្គលិកដែលមានស្នាដៃល្អពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ជួយពង្រឹងការងារបង្រៀនតាមសាលាឱ្យបានទៀងទាត់ពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ធ្វើអធិការកិច្ចជាប្រព័ន្ធ មានខ្ទង់ថវិកាសម្រាប់ចុះប្រមូលទិន្នន័យដល់សាលាប្រចាំឆ្នាំ ព្រោះថាទិន្នន័យប្រជាជនជាទិន្នន័យដែលអាចធ្វើឱ្យលទ្ធផលសូចនាករអាចជឿជាក់បាន។

រីឯ ការិយាល័យអប់រំ យុវជន និងកីឡា អាជ្ញាធរក្រុងស្រុក និងអាជ្ញាធរឃុំសង្កាត់វិញបានលើកជាសំណើឱ្យក្រសួងផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ សិស្សពូកែ បើកវគ្គបណ្តុះបណ្តាលលើការងាររដ្ឋបាល ជួសជុលកុំព្យូទ័ររយៈពេលខ្លី ផ្តល់សម្ភាររូបវន្តសម្រាប់បម្រើការងារការិយាល័យ ផ្តល់គ្រូក្របខណ្ឌកម្រិតបឋមសិក្សានិងមត្តេយ្យសិក្សាឱ្យបានគ្រប់ចំនួនតាម

សាលានីមួយៗ ផ្តល់គ្រូឯកទេសគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវៈវិទ្យា គ្រូកុំព្យូទ័រ (IT) ដល់សាលាមធ្យមសិក្សាដែលខ្វះគ្រូឱ្យបានគ្រប់ចំនួនទៅតាមសំណូមពរ បណ្តុះបណ្តាលនាយកនាយិកាថ្មីនិងបំប៉ននាយក នាយិកាពីភាពជាអ្នកដឹកនាំ គ្រប់គ្រង ជំនាញកុំព្យូទ័រ និងពីរបៀបធ្វើផែនការសាលារៀន ជួយដល់សិស្សក្រីក្រ (មធ្យោបាយ សំលៀកបំពាក់ សម្ភារសិក្សារបស់សិស្ស) ព្រមទាំងជួយពង្រឹងការពិនិត្យតាមដាន លទ្ធផលសិក្សារបស់សិស្សបានញឹកញាប់។ ក្រសួងអប់រំ យុវជន និងកីឡាគួរសង់អន្តេវាសិកដ្ឋានសម្រាប់សិស្សគ្រប់ឃុំ ជួយផ្តល់វគ្គតម្រង់ទិសភាសាខ្មែរ និងគណិតវិទ្យាដល់គ្រូបង្រៀនថ្នាក់ទី៦ ពង្រីកអនុវិទ្យាល័យឱ្យបានគ្រប់ឃុំ និងសង់អគារសិក្សាឱ្យបានគ្រប់គ្រាន់នៅតាមអនុវិទ្យាល័យនីមួយៗ លើកទឹកចិត្តគ្រូដែលទៅបង្រៀននៅតំបន់ដាច់ស្រយាលដោយសង់ផ្ទះសំណាក់សម្រាប់គ្រូ និងបំប៉នបន្ថែមទៀតពីលើក្រុមការងារ DTMT ស្រុក។ ក្រសួងនិងមន្ទីរអប់រំ យុវជន និងកីឡាត្រូវចុះណែនាំឪពុកម្តាយតាមសហគមន៍កុំឱ្យកូនបោះបង់ការសិក្សា កំណត់តួនាទីនិងកិច្ចសហការរវាងអ្នកពាក់ព័ន្ធ ស្ថាប័នអប់រំ អាជ្ញាធរដែនដី សាលារៀនសហគមន៍។ លោកគ្រូអ្នកគ្រូគួរចុះជួបជាមួយអាណាព្យាបាលមួយឆ្នាំ២ដង និងត្រូវយកចិត្តទុកដាក់ជាមួយសិស្សរបស់ខ្លួន និងជួយបំប៉ន សមត្ថភាពគ្រូ ព្រមទាំងដាក់ពិន័យគ្រូបង្រៀនដែលមិនគោរពវិន័យ ហើយជួយបណ្តុះផ្នត់គំនិតឪពុកម្តាយអំពីតម្លៃនៃការអប់រំ ណែនាំមាតាបិតាឱ្យចេះទំនាក់ទំនងសួរនាំគ្រូ តាមដានការសិក្សារបស់កូន។ លើសពីនេះទៀតគួររៀបចំរចនាសម្ព័ន្ធសាលាឱ្យបានគ្រប់គ្រាន់ ដោះស្រាយទីធ្លាសង់សាលារៀន បង្កើនការងារដល់សិស្ស ទប់ស្កាត់ការជួញដូរគ្រឿងញៀន និងពង្រឹងប្រព័ន្ធអប់រំតាមភូមិ ហើយពេលបវេសនកាលសាលាត្រូវលើកទឹកចិត្តសិស្សរៀនពូកែ និងត្រូវរៀបចំហេដ្ឋារចនា សម្ព័ន្ធស្អាត សាលារៀនស្អាតដើម្បីទាក់ទាញសិស្ស។ ក្រៅពីនេះទៀត ត្រូវជួយបណ្តុះបណ្តាលលើការងារបច្ចេកទេសនិងសមត្ថភាពគ្រូបន្ថែម ផ្តល់គ្រូឯកទេសដែលខ្វះខាត និងលើកទឹកចិត្តសិស្សដោយផ្តល់ជារង្វាន់លើកទឹកចិត្ត ដូចជាសម្ភារសិក្សា ជួយផ្តល់ជាគំនិតសម្រាប់អភិវឌ្ឍសាលា ពង្រឹងការងារទិន្នន័យនៅបឋមសិក្សាដើម្បីឱ្យការប្រមូលសិស្សបានច្បាស់លាស់ ជួយបង្រៀនលើការងារបច្ចេកទេសតាមរយៈបើកវគ្គបំប៉នពីកម្មវិធីសិក្សាថ្មីៗដល់ថ្នាក់ដឹកនាំ ព្រមទាំងជួយបណ្តុះបណ្តាលបន្ថែមដល់គ្រូៗដែលមានកម្រិតវប្បធម៌ទាប និងលើមុខវិជ្ជាព័ត៌មានវិទ្យា និងផ្តល់ជាសម្ភាររដ្ឋបាល ដូចជាកុំព្យូទ័រ និងម៉ាស៊ីនថតចម្លងជាដើម។ ក្រៅពីនេះ គួរបង្កើតគម្រោងថវិកាបន្ថែមដើម្បីអភិវឌ្ឍសាលា។ សម្រាប់កម្មវិធីសិក្សា កុំដូរសៀវភៅញឹកញាប់ពេក និងផ្តល់សៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់ ព្រមទាំងបំប៉នគ្រូតាមឯកទេស ហើយគួរតម្លើងប្រាក់បៀវត្សនិងផ្តល់ប្រាក់ឧបត្ថម្ភដល់លោកគ្រូ អ្នកគ្រូឱ្យបានសមរម្យ និងជំរុញឱ្យសិស្សខិតខំ

រៀន លុបបំបាត់ការសុីសំណូក និងការរើសអើងក្នុងសាលា។ ក្នុងនោះដែរឪពុកម្ដាយឬអាណាព្យាបាល ក៏បានលើកជាសំណូមពរឱ្យជួយបង្ហាត់បង្រៀនឱ្យបានច្រើនក្នុងម៉ោងសិក្សាជាជាងយកទៅបង្រៀនពេលម៉ោងគួរហើយក្រសួងអប់រំ យុវជន និងកីឡា គួរចុះមកពិនិត្យឱ្យបានញឹកញាប់និងផ្ដល់សៀវភៅសិក្សាគោលឱ្យសមស្របតាមកម្រិតកែលម្អបរិស្ថានផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រនិងសិស្សរៀនពូកែ ហើយឪពុកម្ដាយគួរជំរុញលើកទឹកចិត្តកូនឱ្យប្រឹងប្រែងរៀនសូត្រ។ ដើម្បីជំរុញសិស្សឱ្យខំសិក្សារៀនសូត្រ គ្រូបង្រៀនត្រូវមកបង្រៀនឱ្យបានទៀងទាត់ និងយកចិត្តទុកដាក់ក្នុងការអប់រំ លើកទឹកចិត្តសិស្សឱ្យមានចិត្តចង់រៀន ជាពិសេសបង្រៀនសិស្សខ្សោយបន្ថែម ព្រមទាំងរឹតបណ្ដឹងវិន័យសិស្ស ហើយគ្រូបង្រៀននិងឪពុកម្ដាយត្រូវមានទំនាក់ទំនងគ្នាឱ្យបានញឹកញាប់។ គ្រួសារសិស្ស គួរផ្ដល់ព័ត៌មានដល់នាយក លោកគ្រូអ្នកគ្រូឱ្យទាន់ពេលចំពោះសិស្សដែលរៀនខ្សោយឬគេចសាលា ផ្ដល់សម្ភារសិក្សា ដូចជាសៀវភៅ ប៊ិច និងមធ្យោបាយធ្វើដំណើរឱ្យកូនឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា។ ចូលរួមកែលម្អបរិស្ថានសាលារៀន ជួយពង្រឹងវិន័យសិស្សឬកូន ជាពិសេសម៉ោងរៀន ហាមលេងទូរស័ព្ទ ជួយរឹតបន្តឹងតាមច្បាប់ដែលបានកំណត់ ហើយមាតាបិតាត្រូវជំរុញកូនឱ្យរៀនសូត្រនៅផ្ទះបន្ថែម តស៊ូដើម្បីកូនបានទៅរៀន បង្កពេលវេលាសម្រាប់ឱ្យកូនចូលរៀន និងគួរចុះពិនិត្យតាមដានសាលាឱ្យបានញឹកញាប់។

# ជំពូក ៥៖ ការពិភាក្សា

## ៥.១ ការពិភាក្សារបកគំហើញនៃការសិក្សា

### ៥.១.១ បម្រែបម្រួលប្រជាជន

ដោយផ្អែកទៅតាមរបកគំហើញនៃការស្រាវជ្រាវខាងលើឃើញថា ចាប់ពីមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក អាជ្ញាធរក្រុងស្រុក និងសាលាមួយចំនួនតូចមានបញ្ហាស្ថិតិប្រជាជនតាមអាយុជាក់លាក់ ជាពិសេសអាយុ១១ឆ្នាំដល់១៩ឆ្នាំ ដែលបញ្ហាទាំងនេះ គឺជាបុព្វហេតុដែលធ្វើឱ្យមានការលំបាកក្នុងការគណនាអត្រាបញ្ចប់ការសិក្សា និងការគណនាសូចនាករផ្សេងៗ។អាជ្ញាធរក្រុងស្រុក៤០.៧៥%មិនមានទិន្នន័យប្រជាជនដែលភាគរយនេះគឺខ្ពស់ជាងគេបំផុតក្នុងចំណោមអ្នកចូលរួមទាំងអស់។ ក្នុងនោះដែរ តាមរយៈការអនុវត្តកន្លងមក ការិយាល័យអប់រំ យុវជន និងកីឡា៥៨.៣៣% និងអាជ្ញាធរ៦៦.៦៦% មិនធ្លាប់ប្រើប្រាស់ស្ថិតិចំណោលប្រជាជនទេ ពោលគឺមានតែមន្ទីរអប់រំ យុវជន និងកីឡាប៉ុណ្ណោះ ដែលភាគច្រើន (៧៥%) បានប្រើស្ថិតិចំណោលប្រជាជន ហើយគោលបំណងនៃការប្រើស្ថិតិនេះគឺដើម្បីចង់ដឹងពីតួលេខច្បាស់លាស់ ព្រមទាំងរកឱ្យឃើញពីចំនួនប្រជាជនកើន ថយ ឬជាក់ស្តែងប្រៀបធៀបនឹងការប្រមូលជាក់ស្តែង បំពេញសូចនាកររបស់នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) និងប្រើសម្រាប់គណនាសូចនាករផ្សេងៗ ដូចជាអត្រាបញ្ចប់ការសិក្សា គណនាអត្រាពិត អត្រារួមនៃការចូលរៀនរបស់សិស្សជាដើម។

ប្រភពស្ថិតិដែលបានប្រើកន្លងមកគឺទទួលបានមកពីប្រភពផ្សេងៗ ដូចជា ការប្រមូលជាក់ស្តែង ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) ឃុំសង្កាត់ (ប៉ូលីស) គណៈកម្មការទ្រទ្រង់សាលា ការិយាល័យផែនការក្រុងស្រុក អធិការស្រុក និងមកពីប្រភពផ្សេងៗជាដើម។ ចំណែកឯ ស្ថិតិប្រជាជនដល់វ័យសិក្សាក៏មានប្រភពខុសៗគ្នាផងដែរ ដូចជា បានមកពីលោកគ្រូអ្នកគ្រូ ភូមិ ឃុំ ប៉ូលីស គណៈកម្មការទ្រទ្រង់សាលា មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា ឬការប្រមូលជាក់ស្តែងជាដើម។ ចំពោះការចូលរៀនធៀបនឹងអាយុ គឺក្មេងភាគច្រើន (៨៣.៦២%) បានចូលរៀនត្រូវទៅតាមអាយុកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ហើយមានតែ១១.២០% ប៉ុណ្ណោះចូលរៀនលើសអាយុ។ ក្នុងនោះដែរ កុមារមួយចំនួនតូចធ្លាប់រៀនត្រួតថ្នាក់ (១២.៩៣%) និង២៣.២៧% បានបោះបង់ការសិក្សា រីឯ ១៦.៣៧% មិនបានរៀនចប់បឋមសិក្សា តែមានរហូតដល់៤៣.៩៦%មិនបានរៀនចប់មធ្យមសិក្សាបឋមភូមិ ដែលតួលេខនេះពិតជាតួលេខដែលគួរឱ្យព្រួយបារម្ភ ព្រោះថា វាជាបញ្ហាប្រឈមយ៉ាងខ្លាំងទៅលើអត្រាបញ្ចប់ការ

សិក្សារបស់សិស្សទាំងនៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ។

ចំពោះស្ថិតិជាក់ស្តែង មានភាពខុសគ្នាពីស្ថិតិចំណោលដោយសារតែស្ថិតិចំណោលគ្រាន់តែរាប់បន្ថែមពីមួយឆ្នាំទៅមួយឆ្នាំ ចំណែកស្ថិតិប្រជាជនប្រមូលជាក់ស្តែងកើនឬថយពីមួយឆ្នាំទៅមួយឆ្នាំ ហើយម៉្យាងទៀត ស្ថិតិប្រជាជនមានការកើនឡើងតិចតួច តែផ្ទុយទៅវិញ ការធ្វើចំណោល ប្រជាជនពីក្រសួងផែនការមានលក្ខណៈខ្ពស់ពេកខុសពីចំនួនជាក់ស្តែង។ ម៉្យាងវិញទៀត ស្ថិតិចំណោលប្រជាជនជាការប៉ាន់ស្មាន ចំណែកស្ថិតិប្រជាជនប្រមូលជាក់ស្តែង ជាចំនួនមនុស្សពិតប្រាកដព្រោះថាប្រជាជនអាចផ្លាស់ប្តូរទីលំនៅ ចំណាកស្រុក ចំណូលស្រុក។ ស្ថិតិប្រជាជនរបស់ក្រសួងផែនការមានរយៈពេលវែង (រយៈពេល១០ឆ្នាំម្តង ឬពាក់កណ្តាលជំរឿនថ្នាក់ជាតិ) តែផ្ទុយទៅវិញ ស្ថិតិជាក់ស្តែងធ្វើទៅតាមចំនួនប្រជាជនរស់នៅក្នុងមូលដ្ឋានពិតប្រាកដចំណែកប្រជាជនមានការប្រែប្រួលពីកន្លែងមួយទៅកន្លែងមួយ។ស្ថិតិប្រជាជនជាក់ស្តែងអាចច្រើនជាងឬតិចជាង ស្ថិតិចំណោលរបស់ក្រសួងផែនការ ដោយសារតួលេខខ្លះស្ទួនគ្នាបន្ថែមលើនេះទៀត កាលបរិច្ឆេទនៃការប្រមូលទិន្នន័យក៏មានភាពខុសគ្នា ដោយហេតុថា ស្ថិតិប្រជាជនជាក់ស្តែងមានការកើនឡើង ឬថយមិនទៀង ហើយការប្រមូលស្ថិតិជាក់ស្តែង មិនបានប្រើរូបមន្តព្យាករណ៍ឱ្យបានច្បាស់លាស់ គ្រាន់តែបូកសរុបតួលេខទិន្នន័យប្រជាជន ដែលប្រមូលបានជាក់ស្តែង។ ហេតុផលមួយផ្សេងទៀតដែលនាំឱ្យខុសគ្នាគឺដោយសារកត្តាប្រជាជនចំណូលថ្មី (កើតភូមិថ្មី) ការស្រង់មិនមានមូលហេតុច្បាស់ ចុះអត្តសញ្ញាណមិនទាន់ត្រឹមត្រូវដែលការស្រង់គ្រាន់តែប៉ាន់ស្មាន មន្ត្រីស្រង់ស្ថិតិ (នាយក លោកគ្រូអ្នកគ្រូ) ចុះស្រង់មិនបានពេញលេញខ្វះជំនាញ និងស្រង់មិនបានគ្រប់ជ្រុងជ្រោយ។ ម៉្យាងទៀតការធ្វើចំណោលមានការកើនឡើងតាមជាលក្ខណៈស្វ័ត តែប្រជាជនជាក់ស្តែងពន្យាកំណើតដែលប្រជាជនមិនអាចកើនឡើងតាមលំដាប់ដែលបានគ្រោងទុកនោះទេ។ តួលេខរបស់មន្ទីរផែនការធ្វើតាមចំណោល ហើយតួលេខរបស់មន្ទីរផែនការមានចំនួនប្រជាជន ច្រើនជាងតួលេខចុះប្រមូលជាក់ស្តែង ព្រោះថាស្ថិតិប្រជាជនប្រមូលជាក់ស្តែងធ្វើឡើងមួយឆ្នាំម្តង ដែលចំណោលរបស់មន្ត្រីផែនការប្រើប្រាស់ទិន្នន័យឆ្នាំចាស់ ហើយស្ថិតិចំណោលជាក់ស្តែងប្រមូលជាក់ស្តែងធ្វើឡើងតាមឆ្នាំនីមួយៗ ហើយប្រជាជនមានការប្រែប្រួលមិនទៀងទាត់ ដោយមានចំណាកស្រុក ចំណូលស្រុក ការផ្លាស់ទីលំនៅមរណៈភាព ការចុះស្រង់មិនបានច្បាស់នៅតាមមូលដ្ឋាន ។ល។ កត្តាដូចបានលើកឡើងខាងលើបានធ្វើឱ្យរបាយការណ៍ប្រជាជនទទួលបាន មានភាពមិនប្រក្រតីខុសពីទិន្នន័យជាក់ស្តែងដែលពេលខ្លះអាចផតឬប៉ោង ហើយមួយវិញទៀត កត្តាខុសគ្នាខ្លាំងលើនេះក៏ជាបញ្ហាការធ្វើស្ថិតិ

ដែលនាំឱ្យមានបញ្ហាទៅលើការគណនាពីអត្រាផ្សេងៗផងដែរ។

### ៥.១.២ ការគណនាអត្រាបញ្ចប់ការសិក្សា

របៀបគណនាអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ចាប់តាំងមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា នាយក ឃើញថា បានយកតួលេខប្រជាជនពីប្រភពផ្សេងៗពីគ្នា ដូចជាមកពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) ក្រសួងផែនការ (តួលេខចំណោល) មន្ទីរផែនការខេត្ត ឃុំសង្កាត់ និងតួលេខជាក់ស្តែងពីអាជ្ញាធរ (ប៉ូលីស) ជាដើម ដែលក្នុងចំណោមនោះ យកតួលេខពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំច្រើនជាងបន្ទាប់គឺយកមកពីការប្រមូលជាក់ស្តែង។

ចំណែកឯ របៀបនៃការគណនាអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា ទាំងមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាជាង៨០% គិតថារបៀបគណនាអត្រាបញ្ចប់ការសិក្សាមានភាពត្រឹមត្រូវ តែផ្ទុយទៅវិញ សម្រាប់នាយកសាលាវិញមានតែ២៣.៥៥% ប៉ុណ្ណោះ ដែលគិតថារបៀបគណនាអត្រាបញ្ចប់ការសិក្សាត្រឹមត្រូវ។ រីឯរបៀបគណនាអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិវិញ ភាគច្រើននៃមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា និងនាយកសាលាគិតរបៀបគណនាអត្រាបញ្ចប់ការសិក្សាត្រឹមត្រូវ តែផ្ទុយទៅវិញ លោកគ្រូ អ្នកគ្រូជាង៦០% គិតថារបៀបគណនានេះមិនត្រឹមត្រូវ។ ដូច្នេះ ចម្លើយតបនៃអ្នកផ្តល់ទិន្នន័យនៅថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា និងនាយកសាលាហាក់ដូចជាមានលក្ខណៈប្រហាក់ប្រហែលគ្នា ពីរបៀបគណនាអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ តែផ្ទុយទៅវិញទិន្នន័យទទួលបានពីលោកគ្រូអ្នកគ្រូហាក់ដូចជាមានលក្ខណៈផ្ទុយគ្នាស្រឡះ។

### ៥.១.៣ ការប្រៀបធៀបអត្រាបញ្ចប់ការសិក្សា

ការគណនាអត្រាបញ្ចប់ការសិក្សារវាងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ការិយាល័យអយក. និងការគណនាជាក់ស្តែងនៃការស្រាវជ្រាវឃើញថា ទិន្នន័យដែលប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំខ្ពស់ជាងការិយាល័យអយក.មាន៦ក្រុងស្រុក ហើយបរិមាណលើសគឺតិចតួចបំផុត ផ្ទុយទៅវិញការគណនាជាក់ស្តែងខ្ពស់ជាងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ គឺមានចំនួនច្រើនលើសលុបរហូតដល់២៧ក្រុងស្រុកក្នុងចំណោម៣៦ក្រុងស្រុក។ ផ្ទុយទៅវិញមានក្រុងស្រុក៥ទិន្នន័យគណនាជាក់ស្តែងទាប ជាងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំរួមមានស្រុកមណ្ឌលសីម៉ា ក្រុងប៉ៃលិន ស្រុកសាលាក្រៅ ក្រុងព្រះសីហនុ និងស្រុកលំផាត់ នៅពេលដែលក្រុងស្រុក៤ពុំមានទិន្នន័យ

ពេញលេញ ដូចជាស្រុកអូរជុំ ស្រុកវើនសៃ ស្រុកកំរៀង និងក្រុងខេមរភូមិន្ទ។

*ក្រាហ្វិក១.១៣(ក) ប្រៀបធៀបអត្រាបញ្ចប់ការសិក្សាតាមការិយាល័យអយក.*




*ក្រាហ្វិក១.១៣(ខ) ប្រៀបធៀបអត្រាបញ្ចប់ការសិក្សាតាមការិយាល័យអយក.*



## ៥.១.៤ ការយល់ដឹងពីអត្រាបញ្ចប់ការសិក្សា

ក្នុងចំណោមអ្នកផ្ដល់ព័ត៌មានចាប់តាំងពីថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលា លោកគ្រូអ្នកគ្រូ និងមាតាបិតាសិស្សឃើញថា អ្នកដែលយល់ដឹងអំពីអត្រាបញ្ចប់ការសិក្សាបានត្រឹមត្រូវទៅតាមនិយមន័យ កំណត់ដោយប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំគឺមានភាគរយតិចណាស់ ប៉ុន្តែបើតាមតួលេខជាក់ស្តែងឃើញថា ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា និងនាយកសាលា មានការយល់ដឹងខ្ពស់មធ្យមអំពី អត្រាបញ្ចប់ការសិក្សា តែផ្ទុយទៅវិញក្នុងចំណោមមាតាបិតាសិស្សទាំង១៩៤នាក់ពុំមានអ្នកណាម្នាក់មានចំណេះដឹងឬយល់ដឹងត្រឹមត្រូវទៅតាមការកំណត់ដោយក្រសួងអំពីអត្រាបញ្ចប់ការសិក្សាឡើយ។ ការមិនយល់ដឹងអំពីអត្រាបញ្ចប់ការសិក្សានេះ ក៏ជាបច្ច័យមួយក្នុងការជំរុញកូនឱ្យខិតខំរៀនសូត្រ ហើយក៏បច្ច័យនាំឱ្យមានសិស្សអវត្តមានច្រើន ឬបោះបង់ការសិក្សា ដោយពុំមានអ្នកជួយជំរុញ ឬលើកទឹកចិត្ត ដោយសារ អ្នកនៅជុំវិញមិនបានយល់ដឹងច្បាស់លាស់ អំពីគុណតម្លៃនៃការសិក្សាឱ្យបានច្បាស់លាស់ ដែលលក្ខខណ្ឌនេះស្រដៀងទៅនឹងការលើកឡើងរបស់ (Admassu, 2015) ថាកត្តាដែលពាក់ព័ន្ធនឹងសាលារៀន ការបង្រៀនគ្មានប្រសិទ្ធភាព គ្រូបង្រៀនមិនគ្រប់គ្រាន់ គ្រូអវត្តមាន សៀវភៅសិក្សា និងប្រព័ន្ធវាយតម្លៃការសិក្សាមិនសមរម្យ ការលើកទឹកចិត្ត ការលំបាកក្នុងការរៀនសូត្រ ស្ថានភាពសុខភាព បញ្ហាអាហារូបត្ថម្ភនិងអាកប្បកិរិយា) គ្រួសារ ឪពុកម្តាយ ឬអាណាព្យាបាលមានការអប់រំទាប ឬមិនសូវយល់ដឹងពីតម្លៃនៃការអប់រំ បញ្ហាប្រាក់ចំណូលរបស់គ្រួសារ)។ ក្នុងឆ្នាំ២០១៨ មានខេត្តតែ ១៣ បានសម្រេចនូវអត្រាបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ៥០% ហើយគោលដៅសម្រាប់ឆ្នាំ ២០១៩-២០២០ គឺត្រូវមានខេត្តសម្រេចអត្រាបញ្ចប់ការសិក្សានេះចំនួន១៤ខេត្ត (ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០១៨) តែផ្ទុយទៅវិញ នៅមានបញ្ហាប្រឈមជាច្រើនដែលរារាំងដល់ការសម្រេចអត្រាបញ្ចប់ការសិក្សានេះរួមមានការចំណាកស្រុក ការបោះបង់ការសិក្សា ការរៀបការ ភាពក្រីក្រ ការបួសជាសង្ឃ ការផ្លាស់ទីលំនៅតាមឪពុកម្តាយ ឬអាណាព្យាបាលត្រូវទៅធ្វើការនៅក្រៅប្រទេស ការមិនឱ្យតម្លៃការអប់រំ។

## ៥.១.៤ បញ្ហាប្រឈមនៃការប្រមូលទិន្នន័យ

បញ្ហាប្រឈមសម្រាប់ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា និងនាយកសាលារួមមាន នាយកសាលា ការិយាល័យអប់រំ យុវជន និងកីឡា និងអាជ្ញាធរមិនទាន់យល់ច្បាស់លាស់និងការយល់ដឹងនៅមានកម្រិតអំពីរបៀបនៃការប្រមូលទិន្នន័យ រីឯការ

ប្រមូលទិន្នន័យនៅមានភាពយឺតយ៉ាវ ដោយសារតែប្រជាជនមួយចំនួនចំណាកស្រុក ហើយទិន្នន័យប្រមូលបានមិនទាន់បានស៊ី ឬត្រូវគ្នា ឬសហការគ្នាល្អ ទៅតាមអ្វីដែលក្រសួងអប់រំ យុវជន និងកីឡាចង់បានឡើយ ដោយសារការផ្តល់ទិន្នន័យមិនទាន់ច្បាស់លាស់ ទិន្នន័យដែលប្រមូលបានមិនទាន់ស៊ីគ្នានៅគ្រប់ថ្នាក់។ ម្យ៉ាងវិញទៀត ការគ្រប់គ្រងទិន្នន័យនៅមានការពិបាកពីព្រោះប្រជាជន ចំណាកស្រុកឬចំណូលស្រុកមិនបានផ្តល់ព័ត៌មានដល់អាជ្ញាធរមូលដ្ឋានឱ្យបានច្បាស់លាស់ហើយ មានការពិបាកក្នុងការចុះប្រមូល ដោយសារផ្ទះប្រជាជននៅឆ្ងាយៗពីគ្នាដែលត្រូវចំណាយពេលច្រើនក្នុងការចុះប្រមូល លើសពីនេះទៀត ធនធានថវិកាមានកំណត់ក្នុងការចុះប្រមូលទិន្នន័យ ហើយមានការទម្លាក់កំហុសឱ្យគ្នាទៅវិញទៅមក ចំណែកឯការផ្តល់របាយការណ៍ជូនអាជ្ញាធរ ឬថ្នាក់ជាតិ មិនមានភាពសុក្រឹត ឬច្បាស់លាស់ដោយសារការចុះប្រមូលទិន្នន័យមិនបានគ្រប់ខ្នងផ្ទះ ហើយទិន្នន័យមានភាពខុសគ្នាតាមគ្រួសារនីមួយៗ។ ក្រៅពីនេះ ក៏មានការផ្លាស់ប្តូរអ្នកគ្រប់គ្រងទិន្នន័យធ្វើឱ្យមានការពិបាកក្នុងការគ្រប់គ្រងទិន្នន័យ។ ទិន្នន័យរបស់មន្ទីរផែនការ និងក្រសួងផែនការ មិនត្រូវ ឬស៊ីគ្នានឹងទិន្នន័យរបស់ការិយាល័យអប់រំ យុវជន និងកីឡា និងសាលារៀន ហើយទិន្នន័យរបស់ភូមិឃុំ ក៏មិនត្រូវឬស៊ីនឹងទិន្នន័យប្រមូលជាក់ស្តែងរបស់សាលានិងការិយាល័យអប់រំ យុវជន និងកីឡាដែរ។ លើសពីនេះទៀត គ្មានប្រព័ន្ធប្រមូលស្ថិតិប្រជាជនច្បាស់លាស់ដែលធ្វើឱ្យពិបាកគ្រប់គ្រងទិន្នន័យ និងចលនាផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន ចំណែកឯភូមិ ឃុំមួយចំនួនពុំបានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រជាជនធ្វើឱ្យមិនមានទិន្នន័យច្បាស់លាស់ (តួលេខ និងចំនួនជាក់ស្តែងពុំត្រូវគ្នា) ហើយអាជ្ញាធរដែនដីភូមិឃុំមួយចំនួន ពុំទាន់ប្រមូលទិន្នន័យច្បាស់លាស់ ធ្វើឱ្យពិបាកក្នុងការគណនាទៅលើអត្រាផ្សេងៗ។ រីឯការប្រើប្រាស់ស្ថិតិប្រជាជន (Population) របស់វិទ្យាស្ថានជាតិស្ថិតិ (NIS) បានធ្វើឱ្យលទ្ធផលសូចនាករមួយចំនួនដែលប្រើជាលេខប្រជាជនមានលទ្ធផលទាប ហើយការចុះជំរឿនប្រជាជនមានការលំបាក ដោយសារប្រជាជនធ្វើចំណាកស្រុក គ្រោះធម្មជាតិ កត្តាភូមិសាស្ត្រ ខ្វះមន្ត្រី គ្មានថវិកាចុះជំរឿន ខ្វះមធ្យោបាយ ប្រជាពលរដ្ឋមិនសូវចូលរួមជាដើម។ ម្យ៉ាងទៀត រដ្ឋបាលភូមិឃុំពុំមានទិន្នន័យ ប្រជាជនតាមអាយុច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ ហើយសាលាមួយចំនួនមិនបានចុះប្រមូលទិន្នន័យ ដោយប្រើតែទិន្នន័យឆ្នាំចាស់ ហើយសាលាមួយចំនួនទៀតប្រើទិន្នន័យតាមរយៈមេភូមិដែលមានការលំបាក ដោយសារមេភូមិខ្លះគាត់មិនបានស្រង់ស្ថិតិតាមឆ្នាំថ្មីទេ គាត់បានយកតួលេខឆ្នាំចាស់មកឱ្យ ហើយអាជ្ញាធរខ្លះមិនសូវមានការសហការ មិនសូវចូលរួមប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ រីឯ អ្នកផ្តល់ទិន្នន័យខ្លះមានការចង្អៀតចង្អល់ក្នុងការផ្តល់ទិន្នន័យដែលធ្វើឱ្យទិន្នន័យទទួលបានមិនច្បាស់លាស់ មិនបាន

គ្រប់គ្រាន់តាមតម្រូវការ។

### ៤.១.៤ បុព្វហេតុនាំឱ្យអត្រាបញ្ចប់ការសិក្សាទាប

យោងតាមរបកគំហើញពីអ្នកចូលរួមពីមន្ទីរអេយក. ការិយាល័យអេយក. អាជ្ញាធរក្រុងស្រុក ឃុំសង្កាត់ នាយកសាលា លោកគ្រូអ្នកគ្រូ ឪពុកម្តាយសិស្ស និងឪពុកម្តាយឬអាណាព្យាលដែលមានកូនអាយុ១៣-២០ឆ្នាំឃើញថា អត្រាបញ្ចប់ការសិក្សាមានកម្រិតទាបបណ្តាលមកពីកត្តាសិស្សក្រីក្រគឺខ្ពស់ជាងគេ(៧៤.៥៥%)និងខ្ពស់បន្ទាប់គឺបញ្ហាចំណាកស្រុក(៦៣.៥៣%)ចំណែកហេតុផលទី៣គឺបណ្តាលមកពីសិស្សបោះបង់ច្រើន (៥០.៥៦%) រីឯបណ្តាលមកពីកត្តារៀនត្រួតថ្នាក់និងចូលរៀនលើសអាយុមានប្រមាណ៣០% ដែលកត្តានេះ ស្រដៀងទៅនឹងការលើកឡើងរបស់ Farooq (២០១០) ថាសិស្សដែលចុះឈ្មោះចូលរៀនយឺតយ៉ាវ និងការរៀនត្រួតថ្នាក់គឺជាកត្តាដែលនាំឱ្យមានអត្រានៃការបញ្ចប់ការសិក្សាទាបនៅតាមសាលារៀន។ កត្តាបណ្តាលមកពីសិស្សចូលរៀនលើសអាយុ (៣១.៨៨%) និងសិស្សរៀនត្រួតថ្នាក់ (២៨.៨៣%) សិស្សជនជាតិដើមភាគតិច (១៩.៣៨%) និងសិស្សពិការភាពមានប្រមាណ១៣% និងមកពីកត្តាផ្សេងៗ១៣.០៣% ហើយមកពីកត្តាផ្សេងៗ រួមមានកត្តាភូមិសាស្ត្រ ផ្ទះនៅឆ្ងាយពីសាលាពិបាកធ្វើដំណើរ ខ្វះមធ្យោបាយធ្វើដំណើរ(ផ្ទះនៅឆ្ងាយពីសាលា)ខ្វះសោហ៊ុយធ្វើដំណើរ។កត្តាសង្គម ការអូសទាញពីមិត្តភក្តិឬសង្គម ការសេពគប់មិត្តភក្តិមិនល្អ ឆាប់រៀបការ ការអូសទាញពីការប្រើប្រាស់គ្រឿងញៀន ការប្រព្រឹត្តអំពីអបាយមុខ មិនខំប្រឹងប្រែងរៀនសូត្រ។ កត្តាជីវភាព ការប្រើប្រាស់កម្លាំងពលកម្មកុមារ ចំណាកស្រុកតាមឪពុកម្តាយ រកការងារធ្វើឬធ្វើការរោងចក្រដែល Ishiguro (២០១៨) បានរកឃើញថាភាពក្រីក្រ និងកុមារមកពីតំបន់ជនបទបានបោះបង់សាលារៀនដើម្បីទៅជួយការងារឪពុកម្តាយរបស់គេ។ កត្តាសិស្សឬខ្លួនឯង រៀនមិនយល់ ឬខ្សោយ ឬរៀនមិនចេះ មិនសូវយកចិត្តទុកដាក់រៀនសូត្រ អវត្តមានច្រើន មានជម្ងឺប្រចាំកាយរងឥទ្ធិពលពីមជ្ឈដ្ឋានជុំវិញរាប់អានមិត្តភក្តិមិនល្អ។កត្តាស្ថិតិស្ថិតិប្រជាជនមិនទាន់ច្បាស់លាស់អត្រាបញ្ចប់ការសិក្សាកម្រិតទាប។ កត្តារចនាសម្ព័ន្ធ ខ្វះហេដ្ឋារចនាសម្ព័ន្ធសមស្រប ដូចជាអគារទ្រុឌទ្រោម ខ្វះបន្ទប់ទឹកបង្គន់ អនាម័យ ដែលក្នុងនោះ Ayub (២០១៨) បានលើកឡើងផងដែរថា អត្រាបញ្ចប់បឋមសិក្សារបស់កុមារីត្រូវរងឥទ្ធិពលពីកត្តាបរិស្ថានសាលារៀន កត្តាសេដ្ឋកិច្ចសង្គម វប្បធម៌ ពលកម្មលើកុមារនិងការថែទាំ។ កត្តាគ្រូ ខ្វះគ្រូបង្រៀនតាមមុខវិជ្ជា គ្រូមិនសូវយកចិត្តទុកដាក់ក្នុងការបង្រៀន ដែលក្នុងនោះ Chae Young Kim & Martyn Rouse (២០១១) បានលើកឡើងថា ឥរិយាបថរបស់គ្រូបង្រៀន អាចប៉ះពាល់ដល់អត្រាបញ្ចប់ការសិក្សា

របស់សិស្សនៅក្នុងសាលារៀន ដូចជាគ្រូមានកម្រិតអប់រំទាប ការប្រើប្រាស់ជំនាញវិជ្ជាជីវៈ ការសម្រេចចិត្តជាដើម។ល។ កត្តាឪពុកម្តាយ អាណាព្យាបាល ឬឪពុកម្តាយមិនមានការយល់ដឹង ឬមិនសូវឱ្យតម្លៃនៃការអប់រំ ដោយមិនបានជំរុញកូនឱ្យខិតខំរៀនសូត្រ អូសទាញកូនឱ្យជួយការងារផ្ទះ ឬមិនបានបញ្ជូនកូនមករៀន ឬឪពុកម្តាយលែងលះគ្នាឬសិស្សគ្មានឪពុកម្តាយ។

*ក្រាហ្វិក១.១៤ កត្តានាំឱ្យអត្រាបញ្ចប់ការសិក្សាទាប*




## ៤.១.៦ សន្ទស្សន៍យុគនាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សា

ការជំរុញលើកទឹកចិត្តរវាងកូនប្រុស និងកូនស្រីឱ្យកូនរៀនរបស់ឪពុកម្តាយសិស្សវិញ ឃើញថា ភាគច្រើនក្នុងចំណោមអ្នកចូលរួមទាំងអស់ឃើញថា ពួកគាត់ជំរុញកូនទាំងពីរ (ទាំងកូនប្រុសនិងកូនស្រី) រហូតដល់ជាង៨០% ដោយហេតុថាសម័យនេះ កូនប្រុសក៏ដូចជាកូនស្រីត្រូវមានចំណេះដឹងស្មើៗគ្នា ម្យ៉ាងវិញទៀតការសិក្សាអាចធ្វើឱ្យមានភាពងាយស្រួលរកការងារដើម្បីអនាគតល្អនិងអាចជួយគ្រួសារ ហើយបើកូនចេះដឹងទាំងពីរ (ស្រីប្រុស) ថ្ងៃក្រោយគឺកូនទាំងនោះអាចទំនុកបម្រុងឪពុកម្តាយឬគ្រួសារ ឬកូនរស់នៅមិនសូវដាក់សម្ពាធមកលើគ្រួសារ ឬឪពុកម្តាយ (មិនសូវឱ្យឪពុកម្តាយពិបាក) លើសពីនេះទៀត ឪពុកម្តាយខ្លះចង់ឱ្យកូនមានកិត្តិយស មានការងារធ្វើដោយប្រើបញ្ញា ហេតុដូច្នេះហើយ បានជាគាត់ផ្តល់ឱកាសស្មើៗ

គ្នាក្នុងការរៀនសូត្រ មានឱកាសដូចគ្នាដោយទទួលចំណេះដូចៗគ្នា កុំឱ្យល្ងង់ដូចឪពុកម្ដាយ ព្រោះថាឪពុកម្ដាយធ្លាប់លំបាក ហេតុនេះមិនចង់ឱ្យកូនលំបាកដូចគាត់ដែរ។ សម្រាប់ឪពុកម្ដាយដែលមានកូនអាយុពី១៣-២០ឆ្នាំពួកគាត់ជំរុញឱ្យកូនរៀនបានខ្ពង់ខ្ពស់ទាំងកូនស្រីទាំងកូនប្រុស ដោយសារពួកគាត់ចង់ឱ្យកូនៗរបស់គាត់មានចំណេះដឹងខ្ពង់ខ្ពស់មានការងារធ្វើល្អមានប្រាក់ខែខ្ពស់ អាចរកស៊ីចិញ្ចឹមជីវិត ចិញ្ចឹមគ្រួសារ និងជួយឪពុកម្ដាយពេលចាស់ជរា ក៏ដូចជាជួយសង្គមជាតិផងដែរ។

ផ្ទុយទៅវិញមានឪពុកម្ដាយតិចតួចប៉ុណ្ណោះដែលចង់ឱ្យកូនប្រុសរៀនជាងកូនស្រី ឬកូនស្រីរៀនជាងកូនប្រុសដោយផ្អែកទៅលើមូលហេតុដែលថាកូនប្រុសងាយស្រួលធ្វើដំណើរ មិនចាំបាច់បារម្ភពីសុវត្ថិភាពកូនប្រុសមានភាពឈ្លាសវៃជាង ចង់ឱ្យកូនប្រុសមានចំណេះដឹងច្រើនជាង ម៉្យាងទៀតកូនប្រុសតស៊ូរៀនជាងកូនស្រី ហើយកូនប្រុសអាចរស់នៅឆ្ងាយម្នាក់ឯង ដូច្នេះផ្ដល់អាទិភាពឱ្យកូនប្រុស ព្រោះកូនស្រីមានការពិបាកក្នុងការទៅរៀនឆ្ងាយ។ រីឯអ្នកចង់ឱ្យកូនស្រីរៀនច្រើនជាងកូនប្រុស ដោយហេតុថាឱ្យកូនស្រីមានចំណេះដឹង កុំឱ្យល្ងិតល្ងង់ដូចពួកគាត់ដែលជាម្ដាយឪពុក ម៉្យាងទៀតដើម្បីឱ្យកូនចេះដឹងនឹងគេដែលអាចស្រួលរកការងារធ្វើ និងមានអនាគតល្អ ចំណែកកូនស្រីឆ្លាតជាងកូនប្រុស ហើយចំណែកអ្នកខ្លះដោយសារគាត់មានតែកូនស្រី និងចង់បានកូនស្រីបានចេះដឹងមានចំណេះក្នុងខ្លួន។ សម្រាប់គ្រួសារដែលមានកូនអាយុ១៣ឆ្នាំដល់២០ឆ្នាំ បានជំរុញលើកទឹកចិត្តដល់ការសិក្សារបស់កូន ដែលក្នុងនោះអ្នកជំរុញតែកូនប្រុសឬកូនស្រីរៀនសូត្រមានប្រហាក់ ប្រហែលគ្នាគឺប្រមាណ៧% ហើយការដែលជំរុញតែកូនប្រុសនោះផ្អែកលើមូលហេតុចង់ឱ្យកូនចេះដឹងនិងងាយរកការងារធ្វើ កូនស្រីមិនសូវចង់រៀន ហើយកូនប្រុសឆ្លាតជាងកូនស្រី ឬកូនស្រីឆ្លាតជាង (នេះដោយសារគាត់មានតែកូនប្រុសឬតែកូនស្រី) ហើយកូនប្រុសអាចធ្វើការឆ្ងាយបានជាងកូនស្រី អាចធ្វើការធំជាងកូនស្រី ហើយជាមេឬបង្គោលគ្រួសារ ចំណែកកូនស្រីមិនសូវសំខាន់សាលារៀននៅឆ្ងាយពីផ្ទះ កូនប្រុសអាចងាយស្រួលធ្វើដំណើរជាង ឯកូនស្រីបារម្ភពីសុវត្ថិភាព។

សន្ទស្សន៍យុគភាពយេនឌ័រជួយក្នុងការប្រៀបធៀប ដោយបង្ហាញពីសមាមាត្រនៃតម្លៃស្ត្រីទៅនឹងបុរសសម្រាប់សូចនាករដែលបានផ្ដល់ឱ្យ (Gender parity index-GPI) ដែលក្នុងនោះ បើសន្ទស្សន៍នៃតម្លៃតូចជាង១ នោះចង្អុលបង្ហាញថាតម្លៃសូចនាករបុរសមានកម្រិតខ្ពស់ជាងស្ត្រី។ តែបើតម្លៃសន្ទស្សន៍ធំជាង១ បង្ហាញថាតម្លៃសូចនាករស្ត្រីខ្ពស់ជាងបុរស។ ផ្ទុយទៅវិញ បើលទ្ធផលនៃ សន្ទស្សន៍យុគភាពយេនឌ័រស្មើ១ នោះមានន័យថា សន្ទស្សន៍យុគភាពយេនឌ័រ ត្រូវ

បានសម្រេច (EMIS, Public Education Statistics & Indicators, 2017-2018)។ យោងតាមទិន្នន័យរបកគំហើញនៃការស្រាវជ្រាវខាងលើ ស្តីពីសន្ទស្សន៍យុគភាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងឆ្នាំសិក្សា២០១៧-២០១៨ មានលក្ខណៈប្រហាក់ប្រហែលទៅនឹងសន្ទស្សន៍យុគភាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាដែរ ពោលគឺតួលេខស្ទើរតែទាំងអស់ (នៅក្នុងមន្ទីរ ក្រុងស្រុក ជនបទគោលដៅ) បញ្ជាក់ថាតម្លៃនៃសន្ទស្សន៍យុគភាពយេនឌ័រធំជាង១អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិមានយុគភាពយេនឌ័រដែលសរបញ្ជាក់ថា តម្លៃសូចនាករស្ត្រីខ្ពស់ជាងបុរស។ ក្នុងនោះលើកលែងតែទិន្នន័យផ្តល់ដោយសាលាគោលដៅ និងលោកគ្រូអ្នកគ្រូនៅបឋមសិក្សាប៉ុណ្ណោះ ឃើញថាអត្រាបញ្ចប់ការសិក្សានៅបឋមភូមិឱ្យតម្លៃសូចនាករបុរសមានកម្រិតខ្ពស់ជាងស្ត្រី ដោយសារតម្លៃនៃយុគភាពយេនឌ័រតូចជាង ១ ដែលនេះមានន័យថា ការអនុវត្តកន្លងមកភាគច្រើនឱ្យតម្លៃសូចនាករបុរសខ្ពស់ជាងស្ត្រី។ សរុបមក បើមើលជារួម តម្លៃសូចនាករស្ត្រីខ្ពស់ជាងបុរសលើយុគភាពយេនឌ័រនៃអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សានៅក្នុងចំណោមមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា និងសាលារៀនដែលបានអនុវត្តកន្លងមក។ នេះមានន័យថាមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា និងសាលាបានឱ្យតម្លៃលើស្ត្រីខ្លាំងព្រមទាំងជំរុញលើកទឹកចិត្តខ្លាំងលើសិស្សស្រីទៅលើសកម្មភាពផ្សេងៗ ដូចជាការងារគ្រប់គ្រងដឹកនាំ សមភាពយេនឌ័រ ការងារសាលា ការងារសង្គម ជាពិសេសលើការងារអប់រំ។

## ៥.១.៦ អត្រាបញ្ចប់ការសិក្សារវាងសិស្សស្រី និងសិស្សប្រុស

យោងទៅតាមរបកគំហើញ ពីមូលហេតុដែលនាំឱ្យអត្រាបញ្ចប់ការសិក្សារវាងសិស្សប្រុស និងសិស្សស្រីអាចបណ្តាលមកពី កត្តាជីវភាព សិស្សប្រុសភាគច្រើនត្រូវជួយកិច្ចការឪពុកម្តាយដូចជាទៅនេសាទត្រី ដកដំឡូង ធ្វើសំណង់ ។ល។ ចំណែកឯកូនស្រីវិញត្រូវទៅធ្វើការតាមរោងចក្រ ឬបម្រើការតាមផ្ទះ ដើម្បីជួយបំពេញសេចក្តីត្រូវការនិងកង្វះខាតជីវភាពរស់នៅ ដែលបញ្ហានេះតម្រូវឱ្យពួកគេប្រឈមមុខធ្វើចំណាកស្រុក បោះបង់ការសិក្សា ចំណែកឯ សិស្សមួយចំនួនត្រូវផ្លាស់ប្តូរទីលំនៅទៅតាមឪពុកម្តាយ។ កត្តាមួយទៀតបណ្តាលមកពីកត្តាគ្រួសារ ពោលគឺគ្រួសារមួយចំនួនមិនសូវជួយជំរុញកូន ឬជំរុញតែកូនស្រី ឬតែកូនប្រុស ឬគាត់មិនសូវយល់ដឹងពីតម្លៃនៃការអប់រំ ហើយគ្រួសារខ្លះទៀត មិនចង់ឱ្យកូននៅឆ្ងាយពីផ្ទះព្រោះកូនគាត់មិនមានសុវត្ថិភាព ជាពិសេសកូនស្រី។ ឪពុកម្តាយខ្លះមិនចេះអក្សរ ល្ងិតល្ងង់ មានជីវភាពក្រីក្រលំបាកដែលគាត់មិនបានគិត ឬចេះគិតគូរឱ្យបានវែងឆ្ងាយអំពីអនាគតរបស់កូន ដែលនាំឱ្យគាត់បង្ខំ

កូនឱ្យឈប់រៀន ឬបោះបង់ការសិក្សា។ កត្តាទំនៀមទម្លាប់ប្រពៃណី ដែលគ្រួសារខ្លះយកប្រពៃណីជាធំដោយគាត់គិតថាកូនស្រីត្រូវរៀបការនៅវ័យក្មេងជាងកូនប្រុស កូនស្រីមិនចាំបាច់រៀនខ្ពស់ ហើយឱ្យតម្លៃនៃការសិក្សាតែទៅលើកូនប្រុស ដោយកូនប្រុសអាចរៀនឬធ្វើការនៅឆ្ងាយពីផ្ទះ ចំណែកឯកូនស្រីត្រូវនៅជួយកិច្ចការផ្ទះ ជួយថែទាំឪពុកម្តាយដែលកូនស្រីមានបន្ទុកការងារផ្ទះច្រើនជាងកូនប្រុស។ ចំពោះប្រពៃណីទំនៀមទម្លាប់ជនជាតិភាគតិចគឺកូនស្រីត្រូវធ្វើការនៅផ្ទះ ហើយកូនប្រុសត្រូវរកស៊ីចិញ្ចឹមគ្រួសារ អីចឹងត្រូវរៀនច្រើនជាងកូនស្រី។ កត្តាទី៤គឺបណ្តាលមកពីកត្តាទីតាំងភូមិសាស្ត្រ ពោលគឺសិស្សមួយចំនួនសម្រេចបោះបង់ការសិក្សាដោយសារផ្លូវពិបាកធ្វើដំណើរ ផ្ទះនៅឆ្ងាយពីសាលាហើយមិនហ៊ានធ្វើដំណើរដោយសារបញ្ហាសុវត្ថិភាព ជាពិសេសសិស្សស្រី។ បន្ថែមលើនេះ ទៀតគឺបណ្តាល មកពីកត្តាផ្នត់គំនិត ដែលឪពុកម្តាយឬអាណាព្យាបាលខ្លះនៅមានទស្សនៈតឹងរឹងអំពីកូនៗរបស់ខ្លួនដោយឱ្យតម្លៃនៃការសិក្សាតែទៅលើកូនប្រុសជាងកូនស្រី គឺកូនប្រុសជាធំ ដូច្នេះកូនប្រុសអាចរៀនបានខ្ពស់ជាងកូនស្រី ហើយកូនស្រីទៅរៀនមានបញ្ហាសុវត្ថិភាពជាដើម។ កត្តាមួយទៀតគឺបណ្តាលមកពីបរិមាណសិស្សដែលក្នុងចំណោមសិស្សចុះឈ្មោះចូលរៀន និងមករៀនគឺចំនួនសិស្សស្រីច្រើនជាងចំនួនសិស្សប្រុស រីឯកំណើនប្រជាពលរដ្ឋនៅក្នុងសហគមន៍វិញក៏មានភាពខុសគ្នាដែរពោលគឺចំនួនក្មេងស្រីច្រើនជាងក្មេងប្រុស។ កត្តាចុងក្រោយគឺបណ្តាលមកពីកត្តាសង្គម ដែលក្នុងនោះអាចមកពីកត្តាអូសទាញពីបរិយាកាសខាងក្នុងនិងខាងក្រៅសាលាដែលធ្វើសិស្សមួយចំនួនបោះបង់ការសិក្សាទាំងនៅក្មេង ជាពិសេស សិស្សប្រុសដូចជាការសេពគ្រឿងញៀន ការសេពគប់មិត្តភក្តិ សម្ភារនិយមជាដើម។

## ៤.១.៧ វិធានការបង្កើនអត្រាបញ្ចប់ការសិក្សា

យោងតាមលទ្ធផលខាងលើឃើញថា សមាសភាពក្នុងការអន្តរាគមន៍ដើម្បីបង្កើនអត្រាបញ្ចប់ការសិក្សាមានដូចជា ក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡាតាមរាជធានីខេត្តបានចូលរួមយ៉ាងសកម្មដូចជា ផ្តល់អាហារូបករណ៍ ផ្តល់អាហារពេលព្រឹកតាមសាលារៀន ផ្តល់អគារសិក្សា ក៏ដូចជាបង្កើតទីតាំងសាលាថ្មីៗដើម្បីបង្និតឱ្យកាន់តែជិតផ្ទះរបស់ប្រជាជន ការបណ្តុះបណ្តាលគ្រូ ក៏ដូចជានាយកព្រមទាំងមានផ្តល់ជាសម្ភារសិក្សា សម្ភារឧបទេសដល់សាលារៀនគោលដៅដើម្បីបង្កើនគុណភាព។ល។ សម្រាប់អាជ្ញាធរ និងសហគមន៍វិញ ក៏បានចូលរួមនូវសកម្មភាពសប្បុរសធម៌ដល់គ្រួសារជួបការលំបាក ក៏ដូចជាចុះពន្យល់ណែនាំឱ្យមាតាបិតាឬអាណាព្យាបាលឱ្យយល់ពីតម្លៃនៃការអប់រំ ជាពិសេស ចូលរួមទប់ស្កាត់

គ្រប់រូបភាពនូវអំពើអបាយមុខ ផ្សេងៗ ដែលធ្វើឱ្យប៉ះពាល់ដល់សិស្ស លើសពីនេះទៀត បានចុះពង្រឹងនិងជំរុញលោកគ្រូអ្នកគ្រូឱ្យគោរពវិន័យ លើកទឹកចិត្តក៏ដូចជាផ្តល់កន្លែងស្នាក់នៅ និងអាហារូបករណ៍ដល់សិស្សក្រីក្រផងដែរ។ ចំណែកឯ លោកនាយក នាយិកា លោកគ្រូអ្នកគ្រូក៏បានចូលរួមក្នុងការណែនាំដល់មាតាបិតាឱ្យយល់ពីតម្លៃនៃការសិក្សា កែលម្អបរិស្ថានសាលារៀន អនាម័យ ពង្រឹងការរៀននិងបង្រៀន បង្កើតក្រុមប្រឹក្សាកុមារនិងក្រុមសិស្សដើម្បីជួយតាមដាន និងលើកទឹកចិត្តដល់សិស្សដែលប្រឈមនឹងការបោះបង់ដូចជាបង្កើតក្លឹបសិក្សាដើម្បីជួយលើកកម្ពស់គុណភាពនៃការសិក្សានិងទាក់ទាញឱ្យសិស្ស ដែលប្រឈមនឹងការសិក្សាមានការចូលរួមនិងមិនឱ្យមានភាពឯកាជាពិសេសការបង្កើនភាពទំនាក់ទំនងជាមួយមាតាបិតាសិស្ស។

### ៤.១.៨ បញ្ហាប្រឈមនៃអត្រាបញ្ចប់ការសិក្សា

ទិន្នន័យលើកឡើងដោយអ្នកផ្តល់ចម្លើយគោលដៅបានបង្ហាញថា កត្តាដែលប្រឈមនៃអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិអាចបណ្តាលមកពីកត្តាសិស្សដូចជាបោះបង់ច្រើន ការចំណាកស្រុក សិស្សក្រីក្រ សិស្សត្រួតថ្នាក់ច្រើន សិស្សមិនយកចិត្តទុកដាក់រៀន សិស្សអវត្តមានច្រើន កុមាររៀនលើសអាយុ សិស្សជនជាតិដើមភាគតិច សិស្សពិការភាពនិងបណ្តាលមកពីបញ្ហាផ្សេងៗទៀតដូចជាកត្តាភូមិសាស្ត្រ(ផ្ទះនៅឆ្ងាយពីសាលា ផ្លូវពិបាកធ្វើដំណើរ ឃុំលិចទឹកពិបាកក្នុងការធ្វើដំណើរនិងចំណាយថវិកាច្រើន ខ្វះមធ្យោបាយធ្វើដំណើរ ខ្វះសាលារៀនឬសាលានៅឆ្ងាយ) កត្តាសង្គម (ការអូសទាញរបស់មិត្តភក្តិ ឆាប់រៀបអាពាហ៍ពិពាហ៍ ការសេពគ្រឿងញៀន រងឥទ្ធិពលពីមជ្ឈដ្ឋានជុំវិញ រាប់អានមិត្តភក្តិមិនល្អ) កត្តាជីវភាព (ការប្រើប្រាស់កម្លាំងពលកម្មកុមារ ចំណាកស្រុកតាមឪពុកម្តាយ ចេញរកការងារតាមជំនាញ ចូលទៅធ្វើការតាមរោងចក្រ) កត្តាស្ថិតិ (ស្ថិតិប្រជាជនមិនទាន់ច្បាស់លាស់ អត្រាបញ្ចប់ការសិក្សាកម្រិតទាប មានកត្តាជីវភាពក្នុងគ្រួសារ) កត្តាគ្រូ (ខ្វះគ្រូបង្រៀនមុខវិជ្ជាមួយចំនួន) ឪពុកម្តាយកេងចំណេញកម្លាំង ពលកម្មនិងកត្តាសិស្សផ្ទាល់ មិនសូវយកចិត្តទុកដាក់ និងអំពីហិង្សាក្នុងគ្រួសារជាដើម។ កត្តាគ្រួសារ (សិស្សចូលរៀនសាលាឯកជន អាណាព្យាបាលគ្មានការយល់ដឹងអំពីតម្លៃនៃការអប់រំ និងមិនបានបញ្ជូនកូនមករៀន សម្ភារនិយម ឪពុកម្តាយមិនសូវជំរុញកូនឬឪពុកម្តាយលែងលះគ្នា)។

ម៉្យាងវិញទៀត ការប្រមូលស្ថិតិជាក់ស្តែងមានលក្ខណៈច្បាស់លាស់ និងសុក្រឹតជាងស្ថិតិចំណោលប្រជាជន ដោយសារតែដឹងចំនួនប្រជាជនតាមភូមិ តាមគ្រួសារថានៅក្នុងស្រុកមានប៉ុន្មាននាក់ និងនៅក្រៅស្រុកមានប៉ុន្មាននាក់។ សម្រាប់ការិយាល័យអប់រំ យុវជន និងកីឡា

ក្រុងស្រុកក៏បានឯកភាពលើបញ្ហាខុសគ្នារវាងស្ថិតិចំណោល និងការរាប់ជាក់ស្តែងនេះផងដែរ ដែលកត្តាទាំងអស់នេះគឺអាចបណ្តាលមកពីកត្តាប្រជាជនចំណូលថ្មី (កើតភូមិថ្មី) ការស្រង់ស្ថិតិមិនមានមូលហេតុនិងមូលដ្ឋានច្បាស់លាស់ ចុះអត្តសញ្ញាណមិនទាន់ត្រឹមត្រូវដែលការស្រង់ស្ថិតិគ្រាន់តែជាការប៉ាន់ស្មាន។ មន្ត្រីស្រង់ស្ថិតិ ចុះស្រង់មិនបានពេញលេញ ខ្វះជំនាញ និងមិនគ្រប់ជ្រុងជ្រោយ ជាពិសេសទិន្នន័យដែលឃុំសង្កាត់ផ្តល់មកសាលារៀនក៏ខុសគ្នាពីទិន្នន័យរបស់មន្ទីរផែនការខេត្ត។ លើសពីនេះទៀតការធ្វើចំណោលមានការកើនឡើងតាមលក្ខណៈស៊ីត តែប្រជាជនជាក់ស្តែងពន្យាកំណើត ដែលប្រជាជនមិនអាចកើនតាមលំដាប់ដែលបានគ្រោងទុកនោះទេ។ សម្រាប់តួលេខរបស់មន្ទីរផែនការធ្វើតាមចំណោល ហើយតួលេខរបស់មន្ទីរផែនការមានចំនួនច្រើនជាងតួលេខចុះប្រមូលជាក់ស្តែង ព្រោះថា ស្ថិតិប្រជាជនប្រមូលជាក់ស្តែងធ្វើឡើងមួយឆ្នាំម្តង ដែលចំណោលរបស់មន្ត្រីផែនការប្រើប្រាស់ទិន្នន័យឆ្នាំចាស់។ ក្រៅពីនេះ ជាទូទៅចំនួនប្រជាជនប្រែប្រួលមិនទៀងទាត់ ដោយមានចំណាកស្រុក ចំណូលស្រុក ការផ្លាស់ទីលំនៅ មរណភាព ការចុះស្រង់មិនបានច្បាស់នៅតាមមូលដ្ឋាន។ល។ កត្តាទាំងអស់នេះ ដែលធ្វើឱ្យរបាយការណ៍ចំនួនប្រជាជនមានភាពមិនប្រក្រតីខុសពីទិន្នន័យ និងស្ថានភាពជាក់ស្តែងដែលពេលខ្លះអាចផតឬប៉ោងនៅតាមតំបន់ខ្លះ។ ចំណុចពិសេសមួយទៀត ការិយាល័យអប់រំ យុវជន និងកីឡាចុះជំរឿនជាក់ស្តែង និងការបូកស្ថិតិថ្នាក់ក្រុងស្រុកផែនការការគណនាចំណោល ប្រើរូបមន្តផ្សេងៗ ហើយកត្តាខុសគ្នាខ្លាំងលើបញ្ហា ស្ថិតិគឺអាចបណ្តាលមកពីកត្តាពេលវេលានៃការចុះប្រមូលទិន្នន័យ ដែលមានន័យថា ការចុះប្រមូលទិន្នន័យប្រើពេលវេលាផ្សេងគ្នានាំឱ្យទិន្នន័យទទួលបានក៏ខុសគ្នាដែរ។

### ៤.១.៩ ការពេញចិត្តនឹងអត្រាបញ្ចប់ការសិក្សា

នៅក្នុងចំណោមអ្នកចូលរួមទាំងអស់ដែលបានចូលរួមផ្តល់ចម្លើយនៃការស្រាវជ្រាវ ចាប់ពីថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា នាយក លោកគ្រូអ្នកគ្រូ ឪពុកម្តាយឬអាណាព្យាបាលឃើញថា ពេញចិត្តនឹងអត្រាបញ្ចប់ការសិក្សាភាគច្រើននិងពេញចិត្តទាំងស្រុងចំពោះអត្រាបញ្ចប់ការសិក្សា តែផ្ទុយទៅវិញ អ្នកដែលមិនពេញចិត្តនឹងអត្រាបញ្ចប់ការសិក្សាទាល់តែសោះមានតិចតួចប៉ុណ្ណោះ។ លទ្ធផលនេះបញ្ជាក់ថា ទោះបីអត្រាបញ្ចប់នៃការសិក្សាមិនទាន់ជាទីពេញចិត្តទាំងស្រុង ក៏ដោយ ក៏អ្នកពាក់ព័ន្ធនឹងការអប់រំមានការពេញចិត្តទៅលើអត្រាបញ្ចប់ការសិក្សាភាគច្រើនដែរ។

# ជំពូក ៦៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៦.១ សេចក្តីសន្និដ្ឋាន

### ៦.១.១ បម្រែបម្រួលកុមារដល់វ័យសិក្សា (ប្រជាជន)

បើមើលទិន្នន័យជារួមដោយប្រៀបធៀបទិន្នន័យចំណោលរបស់វិទ្យាស្ថានជាតិស្ថិតិ (NIS) ធៀបនឹងទិន្នន័យប្រជាជនចំណោលនៃប្រជាជនអាយុ១១ឆ្នាំឃើញថា ទិន្នន័យចំណោលប្រជាជនស្ទើរតែគ្រប់ស្រុកទាំងអស់ គឺទិន្នន័យចំណោលខ្ពស់ជាងទិន្នន័យប្រជាជនជាក់ស្តែង ដែលស្រុកខ្លះមានភាពខុសគ្នាខ្លាំងដូចជាស្រុកត្បូងឃ្មុំ ក្រុងបាត់ដំបង ស្រុកថ្មគោល ស្រុកក្រូចឆ្មារ និងក្រុងប៉ោយប៉ែត លើកលែងតែស្រុកមួយចំនួនតូចប៉ុណ្ណោះ ដែលទិន្នន័យចំណោលនិងទិន្នន័យជាក់ស្តែងមានលក្ខណៈប្រហាក់ប្រហែលគ្នាដូចជាស្រុកកែវសីមា ស្រុកអូរាំង ក្រុងព្រះសីហនុ និងស្រុកលំផាត់។

*ក្រាហ្វិក១.១៥ ទិន្នន័យសិស្សអាយុ១១ឆ្នាំជាក់ស្តែងនិងទិន្នន័យប្រជាជនអាយុ១១ឆ្នាំចំណោលតាមក្រុងស្រុកឆ្នាំ២០១៧-២០១៨*




អត្រាបញ្ចប់ការសិក្សាមានកម្រិតទាបបណ្តាលមកពីកត្តាសិស្សក្រីក្រគឺខ្ពស់ជាងគេ ហើយបញ្ហាចម្បងបន្ទាប់គឺចំណាកស្រុក ចំណែកឯហេតុផលទី៣មកពីសិស្សបោះបង់ច្រើន ទី៤មកពីកត្តារៀនត្រួតថ្នាក់និងចូលរៀនលើសអាយុ ហើយកត្តាមកពីសិស្សជនជាតិភាគតិច សិស្សពិការ

ភាពនិងមកពីកត្តាផ្សេងមានចំនួនតិចតួចទេ។ កត្តាផ្សេងៗអាចមកពីកត្តាសង្គម កត្តាជីវភាព កត្តាសិស្សឬខ្លួនឯង កត្តាស្ថិតិ កត្តារចនាសម្ព័ន្ធ កត្តាគ្រូ កត្តាឪពុកម្តាយជាដើម។ល។

ចំណែកកត្តាវប្បធម៌ ជាបញ្ហាមួយក្នុងចំណោមបញ្ហាប្រឈមនានាដែលនាំឱ្យអត្រាបញ្ចប់ការសិក្សាទាបផងដែរ ដូចជាជនជាតិភាគតិចនៅតែយកបញ្ហាវប្បធម៌ជាធំ ដូចជាឆាប់ឱ្យកូនរៀបការនៅវ័យក្មេង ឱ្យតែកូនស្រីឬកូនប្រុសរៀនសូត្រ ឱ្យតម្លៃនៃការសិក្សាទាបសម្រាប់កូនស្រីជាដើម ហើយដោយសារតែឱ្យតម្លៃនៃការសិក្សាទាបនេះហើយ ជាហេតុធ្វើឱ្យគាត់កៀរគរកម្លាំងកូន ដើម្បីជួយការងារផ្ទះដើម្បីដោះស្រាយបញ្ហាជីវភាពរស់នៅ ដែលកត្តាទាំងនេះចង់ឬមិនចង់ គឺកូនត្រូវបង្ខំចិត្តរៀនបន្តិចបន្តួចឬបោះបង់ការសិក្សាតែម្តង។

បញ្ហាទីតាំងភូមិសាស្ត្រ ដែលសាលាមួយចំនួនស្ថិតនៅក្នុតំបន់ជួបការលំបាក ដូចជាតំបន់ភ្នំ តំបន់កោះ គ្មានផ្លូវគមនាគមន៍ (ភក់ បឹងបួ) ដែលជាហេតុធ្វើឱ្យសិស្សពិបាកធ្វើដំណើរទៅមកសាលា អវត្តមានញឹកញាប់ ឬបោះបង់ការសិក្សា ហើយកង្វះមធ្យោបាយធ្វើដំណើររឹតតែជាបញ្ហា ប្រឈមទៅនឹងការបោះបង់ការសិក្សា។

បម្រែបម្រួលសិស្ស អត្រាបញ្ចប់ការសិក្សាជាក់ស្តែងនៅថ្នាក់ការិយាល័យអយក. ភាគច្រើនលើសលុប មានអត្រាបញ្ចប់ការសិក្សាច្រើនជាងអត្រាបញ្ចប់ការសិក្សានៃទិន្នន័យផ្តល់ដោយ EMIS ដែលក្នុងនោះមានតែស្រុកមួយចំនួនតូចតែប៉ុណ្ណោះ ដែលអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាទាបជាងទិន្នន័យពីនាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ។ ក្នុងចំនោមសិស្សដែលចុះឈ្មោះចូលរៀនថ្នាក់ទី១ទាំងអស់ មានតែសិស្ស២០%ប៉ុណ្ណោះដែលបានបន្តការសិក្សាទៅអនុវិទ្យាល័យ និង១០% ប៉ុណ្ណោះដែលបានបានបន្តការសិក្សាទៅវិទ្យាល័យ (PISA-D)។

កត្តាសិស្សក្រីក្រ បោះបង់ច្រើន ចំណាកស្រុក រៀនត្រួតថ្នាក់ និងសិស្សចូលរៀនលើសអាយុនៅតែមានកម្រិតខ្ពស់។ តាមលទ្ធផលសិក្សាបាន រកឃើញថានៅកម្ពុជា សិស្សប្រុសប្រឈមនឹងការរៀនត្រួតថ្នាក់ច្រើនជាងសិស្សស្រីប្រហែលជាង ១.៤ដង ហើយការរៀនត្រួតថ្នាក់នេះមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយការរៀនខ្សោយរបស់សិស្ស។ ទិន្នន័យក៏បានបង្ហាញផងដែរថា លទ្ធផលសិក្សារបស់សិស្សស្រីមានលក្ខណៈប្រសើរជាងលទ្ធផលសិក្សារបស់សិស្សប្រុសនៅពីថ្នាក់ទី៧ ដល់សិស្សថ្នាក់ទី១២។ សិស្សកម្ពុជាអាយុ១៥ ឆ្នាំដែលសិក្សាពីថ្នាក់ទី៧ទៅថ្នាក់ទី១២ មានតែ២៨.១% នៃប្រជាជានកម្ពុជាដែលមានអាយុ១៥ឆ្នាំ បានន័យថា យុវជនកម្ពុជាអាយុ១៥ឆ្នាំ ៧២%បោះបង់ការសិក្សា ឬចូលរៀនយឺត ជាពិសេសក្នុងចំណោមសិស្សប្រុស (PISA-D)។

កត្តាគ្រួសារ មកពីគ្រួសារមួយចំនួនមិនសូវជួយជំរុញកូន ឬជំរុញតែកូនស្រីឬតែកូនប្រុស ឬគាត់មិនសូវយល់ដឹងពីតម្លៃនៃការអប់រំ ហើយគ្រួសារខ្លះទៀតមិនចង់ឱ្យកូននៅឆ្ងាយពីផ្ទះ ព្រោះកូនគាត់មិនមានសុវត្ថិភាព ជាពិសេសកូនស្រី។ ឪពុកម្ដាយខ្លះមិនចេះអក្សរ មិនបានគិតវែងឆ្ងាយ មានជីវភាពក្រីក្រលំបាក ដែលគាត់មិនបានគិតឬចេះគិតគូរឱ្យបានវែងឆ្ងាយអំពីអនាគតរបស់កូនដែលជាហេតុនាំឱ្យគាត់ឱ្យកូនឈប់រៀនឬបោះបង់ការសិក្សា។

កត្តាទំនៀមទម្លាប់ប្រពៃណី គ្រួសារខ្លះយកប្រពៃណីជាធំដោយគាត់គិតថាកូនស្រី ត្រូវរៀបការនៅវ័យក្មេងជាងកូនប្រុស កូនស្រីមិនចាំបាច់រៀនខ្ពស់ ហើយឱ្យតម្លៃនៃការសិក្សាតែទៅលើកូនប្រុស ដោយកូនប្រុសអាចរៀនឬធ្វើការនៅឆ្ងាយពីផ្ទះ ចំណែកកូនស្រីត្រូវនៅជួយកិច្ចការផ្ទះ ជួយថែទាំឪពុកម្ដាយដែលកូនស្រីទទួលបន្ទុកការងារផ្ទះច្រើនជាងកូនប្រុស។

កត្តាសង្គម កត្តាអូសទាញពីបរិយាកាសខាងក្នុង និងខាងក្រៅសាលា ដែលធ្វើឱ្យសិស្សមួយចំនួនបោះបង់ការសិក្សាទាំងវ័យក្មេង ជាពិសេសសិស្សប្រុស ដូចជាការសេពគ្រឿងញៀន ការសេពគប់មិត្តភក្តិ សម្ភារនិយមជាដើម។

អត្រាបញ្ចប់ការសិក្សានៅពេលបច្ចុប្បន្ន គឺគណនាតែលើស្ថិតិសិស្សដែលរៀននៅសាលារដ្ឋ មិនបានបូកបញ្ចូលសិស្សរៀននៅសាលាឯកជនទេ។ ចំពោះសិស្ស គាត់ផ្លាស់ប្ដូរពីកន្លែងមួយទៅកន្លែងមួយ ឬពីសាលាមួយទៅសាលាមួយ។ កន្លងមកទិន្នន័យដែលប្រើសម្រាប់តែសិស្សរៀនសាលារដ្ឋតែប៉ុណ្ណោះ ពោលគឺទិន្នន័យមិនបានបូកបញ្ចូលស្ថិតិសាលាឯកជនទេ ដែលករណីនេះសិស្សអាចប្ដូរពីសាលារដ្ឋទៅរៀននៅសាលាឯកជន ឬពីសាលាឯកជនទៅសាលារដ្ឋ ដែលហេតុផលនេះ ធ្វើឱ្យមានការលំបាកគ្រប់គ្រងទិន្នន័យសិស្សទូទាំងប្រទេស (រដ្ឋ និងឯកជន)។ ម៉្យាងវិញទៀត ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំពុំបានស្រង់ស្ថិតិទិន្នន័យទៅលើសាលាសុខាភិបាល ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សាលារចនា និងវិចិត្រសិល្បៈទេ។

ក្រៅពីអ្វីដែលបានលើកឡើងខាងលើ សាលាមិនគ្រប់កម្រិតនៅបឋមសិក្សា[៩] នៅតែមានច្រើននៅឡើយ បើមើលជារួមនៅក្នុងចំណោមបណ្ដារាជធានីខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះខេត្តរតនគិរីមានច្រើនជាងគេរហូតដល់៧៦សាលា ហើយខ្ពស់បន្ទាប់ គឺត្បូងឃ្មុំ (៦៥សាលា) និងខេត្តខ្ពស់ទី៣គឺខេត្តកំពង់ធំ (៤៣សាលា) និងខេត្តពោធិសាត់ (៤១សាលា) ផ្ទុយទៅវិញមានតែខេត្តកែបមួយប៉ុណ្ណោះដែលពុំមានសាលាមិនគ្រប់កម្រិត។

[៩] នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

ចំណែកសាលាមិនគ្រប់កម្រិតនៅមធ្យមសិក្សាបឋមភូមិ[10]ក៏នៅតែមានផងដែរ ដែលក្នុងនោះ ខេត្តឧត្តរមានជ័យមានច្រើនជាងគេ រហូតដល់៦សាលានិងខេត្តដែលឈរខ្ពស់បន្ទាប់ គឺខេត្តព្រះវិហារ (៤សាលា) និងខេត្តឈរលំដាប់ទី៣គឺខេត្តបន្ទាយមានជ័យ (៣សាលា) ដែលក្នុងចំណោម២៥រាជធានីខេត្តមានតែ៧ទេ ដែលពុំមានសាលាមធ្យមសិក្សាបឋមភូមិមិនគ្រប់កម្រិត រួមមានខេត្ត កំពង់ធំ កំពត កែប មណ្ឌលគិរី រាជធានីភ្នំពេញ ព្រះសីហនុ និងស្ទឹងត្រែង។ ដូច្នេះ ដោយសារសាលាមិនគ្រប់កម្រិតច្រើនអាចនាំឱ្យអត្រាបញ្ចប់ការសិក្សាទាប។

*ក្រាហ្វិក១.១៦ សាលាមិនគ្រប់កម្រិតតាមរាជធានីខេត្ត២០១៧-២០១៨*




## ៦.២ អនុសាសន៍

គោលបំណងសំខាន់ៗនៃការស្រាវជ្រាវ គឺឈ្វេងយល់លើបម្រែបម្រួលប្រជាជន និងសិស្សនៅក្នុងតំបន់គោលដៅ យុគភាពយេនឌ័រក្នុងអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សា បឋមភូមិ និងកំណត់បទអន្តរាគមន៍ជាក់លាក់ដើម្បីដោះស្រាយអត្រាបញ្ចប់ការសិក្សាទាបនៅតាម សាលាគោលដៅនៃបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ។ យោងទៅតាមរបកគំហើញតាមរយៈការវិភាគ សេចក្ដីសន្និដ្ឋានខាងលើ ក្រុមអ្នកស្រាវជ្រាវផ្ដល់ជាអនុសាសន៍ដូចខាងក្រោម៖

[10] នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

### ៦.២.១ បម្រែបម្រួលប្រជាជន

បម្រែបម្រួលប្រជាជន គឺជាប្រភពមួយដ៏សំខាន់ពាក់ព័ន្ធទៅនឹងការគណនាអត្រាផ្សេងៗ ដូចជាអត្រាចុះឈ្មោះចូលរៀនអត្រាបោះបង់នៃការសិក្សាអត្រាឡើងថ្នាក់អត្រាបញ្ចប់ការសិក្សាជាដើម ហេតុដូច្នេះ អ្នកពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំ គួរសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ (NIS) ដើម្បីធ្វើចំណោលប្រជាជនក្រោយពីជំរឿនឆ្នាំ២០១៩ និងសហការដំណើរការស្ថិតិនៅគ្រប់លំដាប់ថ្នាក់ឱ្យបានច្បាស់លាស់និងជាក់លាក់ ហើយតួលេខប្រជាជនត្រូវបែងចែកទៅតាមភេទ ជនជាតិភាគតិច បរិយាបន្ន (ពិការភាព) អាយុជាក់លាក់ និងទីតាំងភូមិសាស្ត្រ និងសុំឱ្យប្រើប្រាស់ តួលេខប្រជាជនពីប្រភពតែមួយដែលមានប្រភពច្បាស់លាស់។

### ៦.២.២ បម្រែបម្រួលសិស្ស

ចំណែកឯបម្រែបម្រួលនៃអត្រាបញ្ចប់ការសិក្សារបស់សិស្សវិញ គឺអត្រាបញ្ចប់ការសិក្សានៅពេលបច្ចុប្បន្នគឺគណនាតែលើស្ថិតិសិស្សដែលរៀននៅសាលារដ្ឋប៉ុណ្ណោះ តែផ្ទុយទៅវិញមិនបានបូកបញ្ចូលសិស្សរៀននៅសាលាឯកជនទេ ដូច្នេះដើម្បីឱ្យមានភាពគ្រប់ជ្រុងជ្រោយលើការងារស្ថិតិសិស្ស គួរស្ថិតិនិងរាប់បញ្ចូលសិស្សដែលមកពីប្រភពផ្សេងៗទៀត ដូចជាសាលាឯកជន ធម្មការនិងសាសនា វប្បធម៌និងវិចិត្រសិល្បៈផងដែរ ក្រៅពីនេះក៏គួរបង្កើនសកម្មភាពផ្សេងៗដើម្បីកាត់បន្ថយអត្រាបោះបង់និងអត្រាត្រួតថ្នាក់របស់សិស្សទាំងនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ហើយ ម្យ៉ាងទៀត គួរប្រែក្លាយសាលាមិនគ្រប់កម្រិតទាំងអស់ឱ្យទៅជាសាលាគ្រប់កម្រិតថ្នាក់នៅគ្រប់ភូមិសិក្សា។ លើសពីនេះទៀត នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំគួរប្រមូលទិន្នន័យពីមូលដ្ឋានថ្នាក់រៀន អាជ្ញាធរមូលដ្ឋាន មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាឱ្យបានសុក្រឹតនិងទុកចិត្តបាន ហើយទិន្នន័យដែលយកមកប្រើត្រូវប្រើពីប្រភពតែមួយ ចៀសវាងការប្រើប្រាស់ទិន្នន័យពីប្រភពច្រើនដែលនាំឱ្យមានភាពមិនច្បាស់លាស់។

### ៦.២.៣ សន្ទស្សន៍យុគតាពយេនឌ័រក្នុងអត្រាបញ្ចប់ការសិក្សា

ការគណនាសន្ទស្សន៍យុគភាពយេនឌ័រ គឺដើម្បីស្វែងរកពីតម្លៃផលធៀបរវាងស្ត្រីនិងបុរសនៃសូចនាករណាមួយ ហើយដើម្បីសម្រេចបាននូវសន្ទស្សន៍យុគភាពយេនឌ័រក្នុងអត្រាបញ្ចប់ការសិក្សាទាំងបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់នៃវិស័យអប់រំ គួរបង្កើនអត្រាបញ្ចប់ការសិក្សាលើសិស្សស្រីនៅមធ្យម

សិក្សាបឋមភូមិនៅតាមតំបន់មួយចំនួនដែលមានអត្រាសិស្សស្រីបញ្ចប់ការសិក្សាទាបព្រមទាំងពង្រឹងនិងជំរុញសកម្មភាពយេនឌ័រនៅតាមតំបន់ ខេត្ត ស្រុក និងសាលារៀនបន្ថែមទៀតឱ្យកាន់តែមានប្រសិទ្ធភាព ក្រៅពីនេះក៏គួរពង្រឹងក្រុមប្រឹក្សាកុមារីនៅតាមសាលារៀន និងបង្កើនការផ្តល់អាហារូបករណ៍ដល់តំបន់ក្រីក្រដូចដែលអាចធ្វើទៅបាន។

## ៦.២.៤ អន្តរាគមន៍លើអត្រាបញ្ចប់ការសិក្សា

ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវទាំងស្រុង ដើម្បីបង្កើនអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធក្នុងវិស័យអប់រំគួរៈ

- បង្កើននិងពង្រឹងអាហារូបករណ៍ដល់សិស្សឱ្យបានច្រើននិងទាន់ពេលវេលា
- បំប៉នសមត្ថភាពដល់មន្ត្រីបច្ចេកទេសនៅថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា និងសាលារៀនលើការងារគ្រប់គ្រងទិន្នន័យ
- ផ្តល់ការបណ្តុះបណ្តាលនាយកសាលាអំពីការប្រើប្រាស់កុំព្យូទ័រមូលដ្ឋាន និងភាពជាអ្នកគ្រប់គ្រង ដឹកនាំ និងការធ្វើផែនការសាលារៀន (នាយកថ្មី)
- បង្កើនការចុះពិនិត្យតាមដាន និងវាយតម្លៃនៅថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា និងសាលារៀន
- រៀបចំហេដ្ឋារចនាសម្ព័ន្ធ សុខភាព អនាម័យ និងបរិស្ថានសាលារៀនឱ្យបានគ្រប់សាលាឱ្យបានសមស្រប
- បង្កើនការសង់អន្តេវាសិកដ្ឋានសម្រាប់គ្រូនិងសិស្ស (ជាពិសេសសិស្សស្រី) នៅតំបន់ជួបការលំបាក
- ផ្តល់ថវិកាសម្រាប់ចុះស្រង់ទិន្នន័យសម្រាប់ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា និងសាលារៀន
- ពង្រឹងសមត្ថភាពគ្រូនិងបំប៉នពីវិធីសាស្ត្របង្រៀនថ្មីៗ ដើម្បីឱ្យលោកគ្រូអ្នកគ្រូមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀនសិស្ស
- ផ្តល់គ្រូឯកទេសឱ្យបានគ្រប់ជំនាញឯកទេសនិងគ្រប់សាលា

- សហការជាមួយវិទ្យាស្ថានជាតិស្ថិតិ (NIS) ដើម្បីធ្វើចំណោលប្រជាជនក្រោយពីជំរឿនឆ្នាំ២០១៩ និងគ្រប់លំដាប់ថ្នាក់ ហើយតួលេខប្រជាជនត្រូវបែងចែកទៅតាមភេទ ជនជាតិភាគតិច បរិយាបន្ន (ពិការភាព) អាយុជាក់លាក់ និងតាមភូមិសាស្ត្រឱ្យបានច្បាស់លាស់
- សាងសង់អគារនៅតាមសាលាដែលខ្វះអគារសិក្សា ព្រមទាំងបំពាក់គ្រឿងបរិក្ខារបង្រៀន និងរៀនឱ្យបានសមស្រប
- ផ្តល់សៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់ដល់សិស្សនិងទាន់ពេលវេលា ព្រមទាំងបង្កើតបណ្ណាល័យគំរូ
- ពង្រឹងសហប្រតិបត្តិការក្នុងការប្រមូលទិន្នន័យ និងធ្វើបច្ចុប្បន្នភាពជាក់ស្តែងនៅមូលដ្ឋាន។

## ឯកសារយោង


Admassu, K. (2015). *African Population and Health Research Center.* Retrieved 2015, from aphrc.org: www.aphrc.org.

Australian Institute for Teaching and School Leadership. (2011). *National Professional Standard for Principals.* Melbourne: Education Services Australia.

Arnhild Myhr, et al (2017). *Do family and neighborhood matter in secondary school completion? A multilevel study of determinants and their interactions in a life-course perspective.*

Ayub, M. J. (2018). factor contributing to low completion rates of girl in primary schools in Mogotio sub county, Barigo county, Kanya. *International Journal of Scientific Research and Innovative Technology*, 2313-3759.

Boissiere, M. (2004). Determinants of Primary Education. *The World Bank Operations Evaluation,* 1-44.

Chae Young Kim, M. R. (2011). Reviewing the role of teachers in achieving Education for All in Cambodia. *Prospect*, 415-428.

Daniel Suryadarma, A. S. (2006). Causes of Low Secondary School Enrollment in Indonesia. *Research Gate*, 5.

Duke, B. C. (1966). The Karachi plan: Master design for compulsory education in Asia. *International Review of Education: Journal of Lifelong Learning*, *12*, 73-79.

Farooq, M. S. (2010). Causes of Primary School Students' Dropout in Punjab. *Journal of Elementary Education*, 57-76.

Farooq, M. S. (n.d.). Causes of Primary School Students' Dropout in Punjab. *Journal of Elementary Education*, 57-79.

Fata No, Y. H. (2012). Identifying causes of dropout through longitudinal quantitative analysis in rural Cambodia basic school. 25-39.

Gathmann, C., Jurges, H., & Reinhold, S. (2014). Compulsory schooling reforms, education and mortality in twentieth century Europe. *Social Science & Medicine*, *XXX*, 1-9.

Githaka Mwangi, S. K. (2017). Enhancing Completion Rates in Public Day Secondary Schools in Kenya; the Role of Government Bursary Subsidy. *Asian Journal of Education and Training*, 69-73.

Ishiguro, K. (2018). An Overview of School Dropout in Central America: Unresolved Issues and New Challenges for Education Progress. *European Journal of Educational Research*, 235-259.

Katharina Janke, David W. johnton, Carol Propper,Michael A. Shields. (2018). *The Causal Affect of Education on Chronic Health Conditions.*

Ministry of Education, Youth and Sport. (2018). Document on Management, Analysis, and Education Usage. Phnom Penh, Cambodia: EMIS.

Mininstry of Educa tion, Youth and Sport. (2014). *Education Strategic Plan 2014-2018.* Phnom Penh: MoEYS.

Mininstry of Educ a tion, Youth and Sport. (2017). *Principal Standard.* Phnom Penh: MoEYS.

Mininstry of Education, Youth and Sport. (2018). *Education Congress: The Education, Youth and Sport Performance in the academic year 2016-2017 and goals for the academic year 2017-2018.* Phnom Penh: MoEYS.

MULI, N. E. (2014). Factors Influencing Student's Completion Rate in Public Day and Boarding Secondary Schools in Kibwezi District, Makueni County- Kenya. 20.

Muslim, N. & Mohd Noor, M. (2012). Evaluation of effectiveness of teaching compulsory course in public institutions of higher education in Malaysia. *Procedia - Social and Behavioral Sciences*, *59*, 227-236.

National Policy Board for Educational Administration. (2015). *Professional Standards for Educational Leaders 2015.* Reston, VA: The Wallace Foundation. Retrieved from http://www.npbea.org

Okwach Abagi, G. O. (1997). Efficiency of Primary Eudcation in Kenya: Situational Analysis and Implications for Educational Reform.1-41.

Ricardo Sabates, K. A. (2011). School Drop out: Patterns, Causes, Changes and. *Education for All Global Monitoring Report 2011*, 1-25.

Ruff, R. R. (2016). The Impacts of Retention, Expenditures, and Class. *International of Education Policy and Leadership*, 3-13.

Ruff, R. R. (2016). The Impacts of Retention, Expenditures, and Class Size on Primary School Completion in Sub-Saharan Africa: A Cross-National Analysis. *Education, Policy and Leadership*, 1-13.

Shavelson, Richard J. , Lorraine M. McDonnell & Jeannie Oakes. (1991, November). Practical Assessment, Research & Evaluation. *Apeer-reviewed electronicjournal, 2*(11), 1-3.

Shree Prasad Devkota, S. B. (2015). Primary Education and Dropout in Nepal. *Journal of Education and Practice*, 1-6.

Simmons, R. (2008). "Raising the Age of Compulsory Education in England: a NEET Solution?". *British Journal of Educational Studies*, 56(4), 420-439

Shree Prasad Devkota, S. B. (2015). Primary Education and Dropout in Nepal. *Journal of Education and Practice*, 1-6.

Tracy Brunette, L. C. (2017). Primary 1 Repetition and Pre-Primary Education. *RTI International*, 1-4.

UN. (2015). *Goal 4: Ensure inclusive and quality education for all and promote lifelong learning*. Retrieved from Sustainable Development Goal: http://www.un.org/ sustainable development/education.

Wambua, D. K. (2014). Influence of Socio-Economic Factors on Pupils' Completion Rates in Pimary School Education in Evurori Division, MBeere North District, Kenya. 9.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១ ប្រភេទអ្នកចូលរួម

| ល.រ | ប្រភេទអ្នកផ្តល់ចម្លើយ | ចំនួន |
|---|---|---|
| ០១ | អនុប្រធាន ឬ ប្រធានមន្ទីរអប់រំ យុវជន និងកីឡា | ១២ |
| ០២ | ឬអនុប្រធាន ប្រធានការិយាល័យអប់រំ យុវជន និងកីឡា | ៣៦ |
| ០៣ | អាជ្ញាធរក្រុងស្រុក | ២៧ |
| ០៤ | អាជ្ញាធរឃុំសង្កាត់ | ៨៨ |
| ០៥ | នាយកឬនាយករងនៃសាលាបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ | ១៩៣ |
| ០៦ | គ្រូបង្រៀននៃសាលាបឋមសិក្សា(ថ្នាក់ទី៦)<br>និងមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៩) | ១៩៩ |
| ០៧ | ឪពុកម្តាយសិស្សដែលមានកូនរៀនថ្នាក់ទី៦និងទី៩ | ១១៦ |
| ០៨ | ឪពុកម្តាយសិស្សដែលមានកូនអាយុពី១៣-២០ឆ្នាំ (៥នាក់<br>ក្នុងមួយសាលា) | ៦៣៩ |
| | សរុប | ១២០០ |

## ឧបសម្ព័ន្ធ២ ភាគរយមិនមានទិន្នន័យប្រជាជនអាយុ១៨-១៩ឆ្នាំ




## ឧបសម្ព័ន្ធ៣ ការប្រើស្ថិតិប្រជាជន



## ឧបសម្ព័ន្ធ៨ ស្ថិតិសិស្សថ្នាក់ទី៦តាមខេត្តឆ្នាំសិក្សា២០១៧-២០១៨




## ឧបសម្ព័ន្ធ៨ ការប្រើស្ថិតិចំណោលប្រជាជន



## ឧបសម្ព័ន្ធ៦ ស្ថិតិប្រជាជនដល់វ័យសិក្សា




## ឧបសម្ព័ន្ធ៧ ការបណ្ដុះបណ្ដាលលើការគណនាអត្រាបញ្ចប់ការសិក្សា



## ឧបសម្ព័ន្ធ៨ ការយល់ដឹងពីអត្រាបញ្ចប់ការសិក្សា

យោងតាមទិន្នន័យតាមបែបគុណវិស័យ ដែលទទួលបានពីអ្នកចូលរួមនៅថ្នាក់មន្ទីរអប់រំ យុវជន និងកីឡាទាំង១២យល់ឃើញថា អត្រាបញ្ចប់ការសិក្សាគឺជាៈ

(១) កុមារអាយុ១៨ឆ្នាំបានបញ្ចប់ការសិក្សាប៉ុន្មានភាគរយ (២) សិស្សបានឡើងថ្នាក់ពីបឋមទៅមធ្យមសិក្សា (៣) សិស្សបានមកអង្គុយរៀននៅថ្នាក់ចុងក្រោយនៃភូមិសិក្សានីមួយៗ (៤) ជាភាគរយសិស្ស ដែលបានឆ្លងភូមិសិក្សាតាមកម្រិតអប់រំថ្នាក់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ ឬមធ្យមទុតិយភូមិ (៥) ភាគរយសិស្សដែលបានរៀនចប់នៅតាមភូមិសិក្សាធៀបនឹងអាយុកុមារតាមភូមិសិក្សា (៦) ភាគរយនៃកុមារក្នុងក្រុមមួយ (Cohort) ដែលមានអាយុ៣-៥ឆ្នាំលើសអាយុផ្លូវការដែលបានបញ្ចប់ថ្នាក់ចុងក្រោយនៃភូមិសិក្សានោះ (៧) ចំនួនសិស្សរៀនបានបញ្ចប់នៅក្នុងកម្រិតភូមិសិក្សាណាមួយ (៨) ចំនួនកុមារបានបន្តការសិក្សាត្រឹមភូមិសិក្សានីមួយៗ (បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ) បង្ហាញពីប្រសិទ្ធភាពនៃការផ្តល់សេវា ឬប្រមូលកុមារចូលរៀនតាមភូមិសិក្សានីមួយៗ (៩) ចំនួនសិស្ស ថ្មីដែលអង្គុយរៀននៅថ្នាក់ចុងក្រោយ មិនរាប់សិស្សត្រួតនៅបឋមសិក្សា ឬមធ្យមសិក្សាឆ្នាំថ្មីធៀបនឹង ចំនួនកុមារអាយុ១១ឆ្នាំក្នុងឆ្នាំថ្មី និង (១០) ការបង្ហាញអំពីស្ថានភាពនៃការចូលរៀនរបស់សិស្សមួយ ក្រុមមានអាយុដំណាលគ្នាដែលចូលរៀនដំណាលគ្នាដោយមិនគិតពីការជាប់ធ្លាក់ឬបោះបង់រហូតដល់ កម្រិតថ្នាក់ចុងក្រោយ។

ស្រដៀងគ្នានេះដែរ ការិយាល័យអប់រំ យុវជន និងកីឡាយល់ឃើញថា អត្រាបញ្ចប់ការសិក្សា គឺជាៈ(១) កុមារដែលដល់អាយុសិក្សាក្នុងភូមិសិក្សាណាមួយបានចូលរៀន ហើយបានបញ្ចប់ការសិក្សា របស់ពួកគេក្នុងភូមិសិក្សានោះ (២) មានន័យថាទិន្នន័យគិតជាភាគរយ (៣) អត្រាបញ្ចប់ការសិក្សា មានន័យថាសិស្សត្រូវបានប្រឡងជាប់ឆ្លងចូលភូមិសិក្សា (៤) អត្រាបញ្ចប់ការសិក្សាជាសមាមាត្រនៃចំនួនសិស្សក្នុងភូមិសិក្សាធៀបនឹងចំនួនកុមារគ្រប់អាយុក្នុងឆ្នាំសិក្សា (៥) មានន័យថាសិស្សប្រឡងជាប់មធ្យមភាគ (៦) សិស្សបានប្រឡងបញ្ចប់ឆ្នាំសិក្សាណាមួយ (៧) ជាចំនួនសិស្សថ្មីដែលរៀនចប់ នៅក្នុងភូមិសិក្សាដោយធៀបនិងចំនួនកុមារដែលគ្រប់អាយុត្រូវរៀននៅក្នុងភូមិសិក្សានោះ (៨) សិស្ស បានបញ្ចប់នៅថ្នាក់ចុងក្រោយនៅភូមិសិក្សាមួយ (៩) កុមារទាំងពីរភេទបានរៀនជាប់មធ្យមភាគក្នុង កម្រិតថ្នាក់ទី៦និងទី៩ (១០) គេចង់ដឹងពីគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំនៅក្នុងភូមិសិក្សានីមួយៗ (១១) ការបង្ហាញពីអត្រារបស់សិស្សដែលបានរៀនបញ្ចប់នៅភូមិសិក្សានីមួយៗ (១២) ផលធៀបចំនួនសិស្សចុងឆ្នាំ

ក្នុងភូមិសិក្សាធៀបប្រជាជនអាយុ ១១ឬ១៤ (១៣) កុមារអាយុត្រឹម១៤ឆ្នាំ ត្រូវបានបញ្ចប់ថ្នាក់ទី៩ (១៤) កុមារគ្រប់អាយុបានចូលរៀននិងរៀនចប់ទាន់ពេលតាមកម្រិតសិក្សា (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) (១៥) លទ្ធភាពកុមារបានបញ្ចប់ការសិក្សានៅតាមកម្រិត សិក្សាធៀបនឹងអាយុទាន់ពេលកម្រិតណា បើតួលេខធំជាង100%មានន័យថាកុមារចូលរៀនមិនទាន់ពេលការកំណត់(១៦)សិស្សបានចូលរៀនដល់ថ្នាក់ចុងក្រោយនៃភូមិសិក្សាណាមួយ ដោយមិនរាប់សិស្សត្រួត (១៧) សមាមាត្រចំនួនសិស្សថ្មីក្នុងថ្នាក់ទី៦និងទី៩ (មិនរាប់សិស្សត្រួតថ្នាក់) ក្នុងឆ្នាំ សិក្សា T ធៀបនឹងអាយុសិស្ស១១ឆ្នាំនិង១៤ឆ្នាំ (១៨) ជាលទ្ធផលរបស់សិស្សដែលបានឆ្លងការសិក្សាពីកម្រិតមួយទៅកម្រិតមួយ (១៩) អត្រាសិស្សដែលបានរៀននៅថ្នាក់បញ្ចប់ចុងក្រោយនៃឆ្នាំសិក្សា ឧទាហរណ៍ សិស្សដែលកំពុងរៀននៅថ្នាក់ទី៧នៃឆ្នាំបន្ទាប់ (២០) កុមារដែលរៀននៅថ្នាក់ទី៦សរុប ទាំងអស់ប៉ុន្មាន? ហើយរកឱ្យឃើញចំនួនកុមារដែលរៀនចប់កម្រិតបឋមសិក្សា និងមធ្យមសិក្សា(២១)កុមារដែលបានរៀនចប់នៅកម្រិតភូមិសិក្សាណាមួយដែលត្រូវនឹងអាយុរបស់ពួកគេដោយមិនមានការត្រួតថ្នាក់និងលើសអាយុឡើយ(២២)ចំនួនកុមារអាយុ១១ឆ្នាំហើយបានប្រឡងជាប់ថ្នាក់ទី៦នៃសាលាបឋមសិក្សា ឬជាកុមារអាយុ១៤ឆ្នាំ ហើយបានប្រឡងជាប់ថ្នាក់ទី៩ (២៣) កុមារអាយុ១១ឆ្នាំបានចុះឈ្មោះចូលរៀននៅថ្នាក់ទី៦ (២៤) អត្រាបញ្ចប់ការសិក្សាមានន័យថា ជាសមាមាត្រនៃចំនួនសិស្សថ្មី រៀននៅថ្នាក់ទី៦ក្នុងឆ្នាំសិក្សាចាស់ឆ្លងចូលថ្នាក់ទី៧ក្នុងឆ្នាំសិក្សាថ្មី (២៥) ប្រសិទ្ធភាពនៃការសិក្សាអប់រំរបស់សិស្សឆ្លុះបញ្ចាំងអំពីការប្រើប្រាស់ធនធានគ្រួសារសម្រាប់សិស្សក្នុងការបញ្ចប់ភូមិសិក្សានីមួយៗ (សិស្សចូលរៀនឆ្លើយតបតាមអាយុកាលដែរឬទេ) (២៦) សិស្សរៀនចប់តាមកម្រិតថ្នាក់ទី៦ ៩ ១០ ១២ និងបន្តទៅកម្រិតថ្នាក់មួយទៀត (២៧) ផលធៀបរវាងចំនួនសិស្សថ្មី (មិនរាប់សិស្សត្រួត) ក្នុងឆ្នាំសិក្សា និងចំនួនកុមារក្នុងភូមិគុណនឹង១០០ (២៨) ភាគរយនៃចំនួនសិស្សថ្មីដែល បានចូលរៀន៦ ឬទី៩នៃឆ្នាំ សិក្សាមួយដោយមិនគិតពីចំនួនសិស្សត្រួតថ្នាក់ធៀបនឹងកុមារ ដែលមានអាយុ១១ឆ្នាំឬ១៤ឆ្នាំនៅក្នុងឆ្នាំសិក្សានោះ។

ក្នុងចំណោមនាយកសាលាទាំង១៤៣នាក់បានយល់ឃើញថា អត្រាបញ្ចប់ការសិក្សាខុសៗគ្នាទៅតាមការយល់ឃើញរៀងៗខ្លួនដែលខាងក្រោមនេះ គឺការយល់ឃើញរបស់នាយកសាលាមួយចំនួនអំពីអត្រាបញ្ចប់ការសិក្សាថាជា៖ (១) ការឆ្លងផុតកម្រិតបឋមរហូតទៅដល់មធ្យមសិក្សាបឋមភូមិ (២) ការបានរៀនបញ្ចប់នៅបឋមសិក្សា ឬធ្យមសិក្សាទុតិយភូមិ (៣) ការសិក្សានៅបឋម៦ឆ្នាំ ហើយបន្តទៅរៀននៅថ្នាក់អនុវិទ្យាល័យ (៤) ការសិក្សារបស់សិស្ស

ប្រកបដោយគុណភាពនៅកម្រិតបឋមសិក្សា ហើយត្រូវបានឡើងថ្នាក់ជាបន្តបន្ទាប់ (៥) កុមារដែលមានអាយុ១១ឆ្នាំបានបញ្ចប់ការសិក្សានៅក្នុងកម្រិតបឋម (៦) កុមារដែលមានអាយុ១៤ឆ្នាំបានបញ្ចប់ការសិក្សា នៅក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ (៧) កុមារអាយុ១៥ឆ្នាំបានបញ្ចប់ការសិក្សាថ្នាក់ទី៩ (៨) កំណត់បានកុមាររៀនចប់នៅកម្រិតបឋម ចំនួនសិស្សបោះបង់ និងចំនួនសិស្សរៀនក្នុងថ្នាក់ទី៦ធៀបនឹងអាយុ (៩) លទ្ធផលនៃការបញ្ចប់ការសិក្សានៅតាមឆ្នាំសិក្សានីមួយៗគិតជាភាគរយ (១០) អត្រាបោះបង់ការសិក្សាដោយមិនបានបញ្ចប់តាមកម្រិតថ្នាក់ណាមួយពិតប្រាកដ (១១) ចំនួនសិស្សដែលឆ្លងភូមិសិក្សា (១២) ចំនួនសិស្សដែលបានឆ្លងភូមិសិក្សាឡើងថ្នាក់ទី១០ ធៀបនឹងប្រជាជនដែលគ្រប់អាយុនៅក្នុងមូលដ្ឋាន (១៣) ចំនួនសិស្សដែលបានរៀនចប់តាមកម្រិត (១៤) ចំនួនសិស្សថ្មី (មិនរាប់សិស្សត្រួតថ្នាក់) ដែលរៀនថ្នាក់ទី៦សិក្សាឆ្នាំ (T) ឆ្លងទៅថ្នាក់ទី៧ (១៥) ចំនួនសិស្សបានបញ្ចប់ការសិក្សាឆ្នាំថ្មីដែលបានបញ្ចប់ឆ្នាំសិក្សាធៀបនឹងសិស្សឆ្នាំចាស់ (១៦) ការគណនារកភាគរយនៃចំនួនអ្នកដែលបានរៀនចប់នៅកម្រិតថ្នាក់មួយ (១៧) ការប្រៀបធៀបរវាងការសិក្សាថ្នាក់ទី៦នឹងប្រជាពលរដ្ឋក្នុងផែនទីអាយុ១២ឆ្នាំក្នុងភូមិសិក្សាផ្នែកបឋម (១៨) ការសិក្សាសិស្សដែលបានបញ្ចប់កាសិក្សាមួយកម្រិតនៅក្នុងសាលា (១៩) ចំនួនសិស្សដែលបានបញ្ចប់ការសិក្សានៅបឋមសិក្សាហើយឡើងទៅថ្នាក់ទី៧ជាក់ស្តែងគុណនឹង១០០ចែកនឹងចំនួន សិស្សថ្នាក់ទី៦ឆ្នាំចាស់ (២០) ចំនួនសិស្សដែលបានបញ្ចប់ថ្នាក់ទី៦ ហើយបានបន្តទៅសិក្សាថ្នាក់ទី៧ ឆ្នាំសិក្សាថ្មី (២១) ចំនួនសិស្សដែលប្រឡងជាប់ទី៩ ហើយគុណនឹង១០០ រួចហើយចែកនឹងចំនួនសិស្សសរុបដែលរៀនថ្នាក់ទី៧ (២២) ចំនួនសិស្សដែលឡើងថ្នាក់ទី១ដល់ទី៦ (២៣) ចំនួនសិស្សថ្មីដែលបានបញ្ចប់ឆ្នាំសិក្សាធៀបនឹងសិស្សឆ្នាំចាស់ (២៤) ចំនួនសិស្សអាយុ៦ឆ្នាំដែលបានចុះឈ្មោះចូលរៀនថ្នាក់ទី១ ៦ឆ្នាំមុននឹងឡើងថ្នាក់ទី៧នៃឆ្នាំសិក្សានេះ (២៥) ផលធៀបចំនួនសិស្សទី៩ថ្មី និងចំនួនប្រជាជនដែលមានអាយុ១៤ឆ្នាំនៅភូមិចំណុះ (២៦) ផលធៀបចំនួនសិស្សនៅថ្នាក់ដំបូងនៃភូមិសិក្សាបន្ទាប់ ធៀបនឹងសិស្សបញ្ចប់ការសិក្សានៅថ្នាក់ចុងក្រោយនៃភូមិសិក្សាមុន រួចហើយគុណនឹង១០០ (២៧) ភាគរយនៃចំនួនសិស្សដែលបានប្រឡងនៅឆ្នាំសិក្សាថ្មីធៀបនឹងចំនួនសិស្ស ដែលមានអាយុឆ្លើយតបនឹងអាយុនៃថ្នាក់ចុងក្រោយក្នុងភូមិសិក្សានៅឆ្នាំសិក្សានោះគុណនឹង១០០ (២៨) ភាគរយនៃចំនួនសិស្សថ្នាក់រៀនទី៩ ដែលប្រឡងជាប់ធៀបទៅនឹងចំនួនប្រជាជនដែលមានអាយុ១៤ឆ្នាំនៅក្នុងភូមិ (២៩) ភាគរយនៃចំនួនសិស្សថ្មី មិនរាប់សិស្សត្រួតថ្នាក់រៀនទី៦ ធៀបនឹងចំនួនកុមារអាយុ១១ឆ្នាំ (៣០) ភាគរយនៃលទ្ធផលសិក្សានៃចុងឆ្នាំសិក្សានីមួយៗ (៣១) ភាគរយសិស្សដែលបានឡើងថ្នាក់ ត្រួតថ្នាក់ និងសិស្សដែលបោះបង់ (៣២) លទ្ធផលនៃការសិក្សាសិស្ស

ដែលបានប្រឡងជាប់ថ្នាក់ចុងក្រោយ (៣៣) លទ្ធផលនៃការសិក្សាសិស្សពេញមួយឆ្នាំ (៣៤) សមាមាត្រចំនួនសិស្សថ្មីថ្នាក់ទី៦ (មិនរាប់សិស្សត្រួតថ្នាក់) ក្នុងឆ្នាំT ធៀបនឹងចំនួនកុមារអាយុ ១១ឆ្នាំក្នុងឆ្នាំ T (៣៥) ជាសិស្សរៀនចប់តាមភូមិសិក្សានីមួយៗនៃកម្រិតសិក្សា (៣៦) អត្រាដែលសិស្សបានបញ្ចប់ការសិក្សាតាមភូមិសិក្សានីមួយៗ (៣៧) ប្រជាជនដែលមានអាយុ១៨ឆ្នាំនៅក្នុងភូមិសាស្ត្រមិនបានបញ្ចប់ការសិក្សានៅក្នុងភូមិសិក្សា (៣៨) ផលធៀបនៃចំនួនសិស្សថ្មីរៀននៅថ្នាក់ចុងក្រោយនៃភូមិសិក្សាមួយ (មិនរាប់សិស្សត្រួត) ឆ្នាំសិក្សាចាស់នឹងចំនួនប្រជាជនដែលមានអាយុឆ្លើយតបទៅនឹងអាយុនៃថ្នាក់ចុងក្រោយនៃភូមិសិក្សានោះឆ្នាំចាស់ (គិតជាភាគរយ) (៣៩) ភាគរយដែលសិស្សបានបញ្ចប់ការសិក្សាតាមកម្រិតថ្នាក់នីមួយៗ (៤០) ភាគរយនៃការបញ្ចប់ការសិក្សាថ្នាក់ទី៦ របស់សិស្សនៅបឋមសិក្សា (៤១) ភាគរយនៃសិស្សឡើងថ្នាក់ធៀបនឹងសិស្សដើមឆ្នាំ (៤២) មានន័យថាកុមាររៀនចប់ថ្នាក់ទី៧ដល់ថ្នាក់ទី៩ (៤៣) កុមារអាយុ១១ឆ្នាំទាំងអស់នៅក្នុងឃុំត្រូវបានរៀនចប់ថ្នាក់ទី៦ (៤៤) សិស្សម្នាក់ៗបានបំពេញកាតព្វកិច្ចគឺរៀននៅអនុវិទ្យាល័យពីថ្នាក់ទី៧បញ្ចប់ទី៩ (៤៥) សិស្សដែលបានរៀនចប់ក្នុងរយៈពេល១ឆ្នាំកន្លងផុតទៅក្នុងថ្នាក់នីមួយៗ (៤៦) យកសិស្សថ្នាក់ទី៩ គុណនឹង១០០ ចែកចំនួនប្រជាជនក្នុងឃុំ ១៨ឆ្នាំ ហើយដឹងពីកម្រិតអត្រាបញ្ចប់ការសិក្សានៅក្នុងឃុំ (៤៧) រៀនពីថ្នាក់ទី១ដល់ទី៦ ពេលប្រឡងជាប់គឺមានន័យថាបានបញ្ចប់នៅបឋមសិក្សា (៤៨) សម្រាប់ប្រាប់ឱ្យដឹងចំនួនកុមារដែលបានរៀន និងមិនបានរៀន (៤៩) សិស្សដែលជាប់មធ្យមភាគប្រចាំឆ្នាំ ហើយបន្តការសិក្សាបន្ត (៥០) សិស្សដែលបានជាប់មធ្យមសិក្សា (ថ្នាក់ទី៦) ឆ្លងភូមិសិក្សាទៅរៀននៅសាលាអនុវិទ្យាល័យ (៥១) សិស្សដែលបានបញ្ចប់កម្រិតបឋមនៅអាយុ១១ឆ្នាំដែលឆ្លងចូលមធ្យមសិក្សា (៥២) សិស្សដែលបានបញ្ចប់ឆ្នាំសិក្សាដោយមិនគិតពីលទ្ធផលសិក្សា (៥៣) សិស្សដែលបានសិក្សានៅថ្នាក់ទី៩ក្នុងឆ្នាំសិក្សាចាស់ (៥៤) សិស្សទាំងពីរភេទបានបញ្ចប់ការសិក្សាកម្រិតមូលដ្ឋាន (ថ្នាក់ទី៩) បានប្រឡងសញ្ញាប័ត្រមធ្យមបឋមភូមិជាប់ជាស្ថាពរ (៥៥) សិស្សបានរៀនចប់ពីទី១ ដល់ទី១២ (៥៦) សិស្សបានរៀននៅចុងបញ្ចប់នៃកម្រិតសិក្សានីមួយៗ ធៀបនឹងប្រជាជនដែលមានអាយុឆ្លើយតបនៃថ្នាក់ចុងក្រោយ (៥៧) សិស្សរៀនចប់និង ជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (៥៨) សិស្សរៀនបានបញ្ចប់ការសិក្សាគ្រប់កម្រិត និង(៥៩)អត្រាបញ្ចប់ការសិក្សាគឺសិស្សជាប់ថ្នាក់ទី៦គុណនឹង១០០ចែកនឹងចំនួនសិស្សថ្នាក់ទី៦ទាំងអស់។

ក្នុងចំណោមលោកគ្រូ អ្នកគ្រូទាំង១៨៤នាក់ ២៧.៧៧%មិនបានយល់ដឹងពីអត្ថន័យនៃអត្រាបញ្ចប់ការសិក្សាទេ។ តែយ៉ាងណាក្តីក៏មានលោកគ្រូ អ្នកគ្រូបង្រៀនភាគច្រើនទៀតបាន

យល់ឃើញថា អត្រាបញ្ចប់ការសិក្សាជា៖ (១) ការបានរៀនចប់នៅភូមិសិក្សា (២) ការរៀនចប់ក្នុង១ឆ្នាំ (៣) កុមារដែលមានអាយុ ១១ឆ្នាំបានបញ្ចប់ការសិក្សានៅកម្រិតបឋម (៤) កុមារដែលមានអាយុ៦ ឆ្នាំដែលបានចូលរៀនថ្នាក់ទី១ រយៈពេល៦ ឆ្នាំក្រោយមកបានបញ្ចប់បឋមសិក្សាបានប៉ុន្មានភាគរយបើធៀបក្នុងភូមិសិក្សា (៥) កុមារមានអាយុ១៥ឆ្នាំទាំងអស់បានបញ្ចប់ការសិក្សាថ្នាក់ទី៩ (៦) កុមារអាយុ១១ឆ្នាំទាំងអស់បានបញ្ចប់ថ្នាក់ទី៦ (៧) ផលធៀបនៃចំនួនសិស្សថ្មីរៀននៅថ្នាក់ចុងក្រោយនៃភូមិសិក្សា(៨)ភាគរយនៃការបញ្ចប់ការសិក្សារបស់សិស្ស(៩) ចំនួនភាគរយសិស្សដែលបានឆ្លងភូមិសិក្សា និងចំនួនភាគរយសិស្សដែលត្រួតថ្នាក់ (១០) ចំនួនសិស្សដែលបានឈប់រៀន (១១) ចំនួនសិស្សដែលបានបញ្ចប់ការសិក្សានៅភូមិសិក្សា ធៀបសិស្សចូលរៀនសរុបគិតជាភាគរយ (១២) ចំនួនសិស្សថ្មីរៀនថ្នាក់ទី៦ ដោយមិនគិតសិស្សត្រួត (១៣) ចំនួនអ្នកឈប់រៀន (១៤) ការគណនាភាគរយនៃសិស្សប្រឡងជាប់និងសិស្សប្រឡងធ្លាក់ (១៥) ផលធៀបថ្នាក់ដំបូងនៃភូមិសិក្សាធៀបនឹងសិស្សបញ្ចប់ការសិក្សា (១៦) ភាគរយកើន ឬថយនៃការបញ្ចប់ការសិក្សាកម្រិតណាមួយ(១៧)ភាគរយដែលសិស្សបានបញ្ចប់ការសិក្សា(១៨) ភាគរយនៃចំនួនសិស្សដែលបានប្រឡងបញ្ចប់ (១៩) ភាគរយនៃដំណាច់ឆ្នាំរបស់សិស្ស (២០) ភាគរយរបស់សិស្សថ្នាក់ទី១ដល់ទី១២ (២១) លទ្ធផលរបស់សិស្សពេញមួយឆ្នាំ (២២)អត្រាដែលកុមារដល់អាយុ១៤ឆ្នាំបានរៀនថ្នាក់បញ្ចប់ភូមិសិក្សាបឋមភូមិ (២៣) វាស់ស្ទង់កម្រិតយល់ដឹងស្វែងរកអនាគត ចូលរួមសង្គម សិស្សបានរៀន (២៤) បានបញ្ចប់ការសិក្សាបឋមសិក្សា (២៥) ភាគរយកុមារដែលបានចូលរៀនពីទី១ដល់ទី៦មិនបោះបង់(២៦)ភាគរយនៃការបញ្ចប់ការសិក្សារបស់សិស្សស្រីប្រុស (២៧) ភាគរយនៃសិស្សបានប្រឡងជាប់នៃចំនួនសិស្សបានដាក់ពាក្យ (២៨) ភាគរយសិស្សឆ្នាំថ្មីធៀបឆ្នាំចាស់ (២៩) ភាគរយសិស្សជាប់ការសិក្សាជាស្ថាពរក្នុងរយៈពេលនៃឆ្នាំសិក្សា (៣០) ភាគរយសិស្សដែលប្រឡងជាប់ (៣១) លទ្ធផលរបស់សិស្សចុងឆ្នាំ (៣២) សិស្សជាប់មធ្យមសិក្សា (៣៣) សិស្សដែលបានបញ្ចប់ការសិក្សាតាមកម្រិត (៣៤) សិស្សដែលបានបញ្ចប់ភូមិសិក្សា និងសិស្សបោះបង់ការសិក្សា (៣៥) សិស្សទាំងអស់បានបញ្ចប់ការសិក្សាលទ្ធផលជាប់ (៣៦) សិស្សទាំងអស់ប្រឡងជាប់ហើយទទួលបានទាំងបរិមាណនិងគុណភាព (៣៧) សិស្សបានរៀនចប់កម្រិតមូលដ្ឋាន (៣៩) សិស្សបានរៀនចប់មួយកម្រិតទៅមួយកម្រិតទៀត (៣៩) សិស្សបោះបង់ការសិក្សាចោល (៤០) សិស្សមិនបោះបង់ការសិក្សា (៤១) អត្រាបញ្ចប់ការសិក្សាគឺជាភាគរយនៃការសិក្សា ដែលប្រឡងជាប់ភូមិសិក្សាធៀបនឹងចំនួនសិស្សនៅដើមឆ្នាំសិក្សា និង (៤២) អត្រាសិស្សដែលបានប្រឡង។

ក្នុងចំណោមមាតាបិតាសិស្ស១១៦នាក់ ៦៣.៣៧%ឆ្លើយថាមិនយល់ដឹងពីអត្ថន័យនៃអត្រាបញ្ចប់ការសិក្សាទេ។ ប៉ុន្តែយ៉ាងណាក៏ដោយ ពួកគាត់មួយចំនួនយល់ឃើញអត្រាបញ្ចប់ការសិក្សាគឺជា៖(១) កូនៗបានរៀនចប់ថ្នាក់ទី១២ (២) សិស្សរៀនក្នុងភូមិសិក្សា (៣) ចំនួនស្ថិតិបញ្ចប់ការសិក្សា (៤) ចំនួនសិស្សដែលឈប់រៀន (៥) បានរៀនចប់ថ្នាក់ (៦) ប្រៀបធៀបរវាងសិស្សបញ្ចប់ និងសិស្សដែលកំពុងរៀន (៧) រយៈពេលដែលក្មេងចូលរៀនពីដើមឆ្នាំនៅចុងឆ្នាំ (៨) រៀនចប់ថ្នាក់ ហើយបន្តយកជំនាញ (៩) រៀនចប់ភូមិសិក្សា (១០) លទ្ធផលសិក្សារបស់កូនពេញមួយឆ្នាំ។

## ឧបសម្ព័ន្ធ៩ តារាងម៉ាទ្រិកស្តីពីមូលហេតុនៃអត្រាបញ្ចប់ការសិក្សាទាបនិងអន្តរាគមន៍

យោងទៅតាមលទ្ធផលនៃការស្រាវជ្រាវ និងឆ្លងតាមការពិភាក្សាក្រុមទៅលើកត្តាដែលនាំឱ្យអត្រាបញ្ចប់ការសិក្សាទាប ក្រុមអ្នកស្រាវជ្រាវបានរៀបចំជាតារាងម៉ាទ្រិកទៅលើមូលហេតុនាំឱ្យអត្រាបញ្ចប់ការសិក្សាទាប ការធ្វើអន្តរាគមន៍ដើម្បីឱ្យអត្រាបញ្ចប់ការសិក្សាកើនឡើង អ្នកពាក់ព័ន្ធក្នុងការបង្កើនអត្រាបញ្ចប់ការសិក្សា និងការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា ដូចបង្ហាញនៅក្នុងតារាងខាងក្រោម៖

១. ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា

| កត្តានាំឱ្យអត្រាបញ្ចប់ការសិក្សាទាប | អន្តរាគមន៍ដើម្បីឱ្យ អត្រាបញ្ចប់ការសិក្សាកើនឡើង | អ្នកពាក់ព័ន្ធក្នុងការបង្កើនអត្រាបញ្ចប់ការសិក្សា | ការគាំទ្រពីក្រសួងអយក. |
|---|---|---|---|
| ១.កត្តាសិស្ស | • បំប៉នសិស្សរៀនយឺតតាមគ្រប់ទម្រង់ (បង្កើតក្លឹបសិក្សា បំប៉នថ្ងៃព្រហស្បតិ៍<br>• បង្កើនចំនួនសិស្សអាហារូបករណ៍<br>• ជំរុញការធ្វើតេស្តឡើងថ្នាក់ | • អាណាព្យាបាលសិស្ស<br>• គ្រូ ការិ.អយក.ស្រុក<br>• មន្ទីរអយក. | • ផ្តល់អាហារូបករណ៍<br>• ផ្តល់អាហារូបត្ថម្ភ<br>• ផ្តល់សម្ភារសិក្សា<br>• បង្កើតបណ្ណាល័យឱ្យបានគ្រប់សាលា |

| | | | |
|---|---|---|---|
| ២.កត្តាមាតាបិតា | • ពន្យល់មាតាបិតាពីអត្ថប្រយោជន៍នៃការសិក្សា<br>• បង្កើនទំនាក់ទំនងល្អរវាងគ្រូនិងមាតាបិតាសិស្ស | • មាតាបិតាសិស្ស<br>• សហគមន៍<br>• អាជ្ញាធរមូលដ្ឋាន | • បង្កើតច្បាប់កាតព្វកិច្ចសិក្សា |
| ៣.កត្តាសហគមន៍ | • ជំរុញគណៈកម្មការគ្រប់គ្រងសាលារៀន | • សហគមន៍<br>• អាជ្ញាធរ | • គាំទ្រនិងពង្រឹងគណៈកម្មការគ្រប់គ្រងសាលា |
| ៤.កត្តាស្ថិតិ (ផ្តល់ព័ត៌មានមិនត្រឹមត្រូវ) | • ជំរុញការប្រើប្រាស់ស្ថិតិតាមតួលេខ EMIS | • សហគមន៍<br>• សាលារៀន<br>• ការិ.អយក.<br>• មន្ទីរអយក. | • ពង្រឹងយន្តការនៃការប្រមូលនិងបំពេញស្ថិតិអប់រំ<br>• បណ្តុះបណ្តាលអ្នកពាក់ព័ន្ធពីការប្រើប្រាស់និងវិភាគទិន្នន័យអប់រំ |
| ៥. កត្តាសង្គម | • ពង្រឹងសុជីវធម៌ សីលធម៌ដល់អ្នកពាក់ព័ន្ធ<br>• ជំរុញនិងផ្សព្វផ្សាយទប់ស្កាត់ឱ្យបានទូលាយនូវការជួញដូរ គ្រឿងញៀន<br>• ជំរុញសុវត្ថិភាពកុមារ | • គ្រូ<br>• សហគមន៍<br>• អាជ្ញាធរពាក់ព័ន្ធ | • ចេញគតិយុត្តិ<br>• (ភ្ជាប់លិខិតបទដ្ឋានសេចក្តីណែនាំ នានា)<br>• ជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព |
| ៦. កត្តាគ្រូ | • ពង្រឹងគុណវុឌ្ឍិគ្រូបង្រៀន<br>• និយ័តភាពការងារ<br>• ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | • នាយក<br>• គ្រូ<br>• ការិ.អយក.<br>• មន្ទីរអយក.<br>• ក្រសួងអយក. | • បណ្តុះបណ្តាលគ្រូបន្ថែមលើវិធីសាស្ត្រនិងកម្មវិធីថ្មី (តម្រូវការគ្រូនិងបំពេញចំណេះដឹង គ្រូគ្រប់ជំនាញ)<br>• លើកទឹកចិត្តដល់គ្រូមានចំណេះដឹងភាសាបរទេស(បឋមសិក្សា) |

| | | | |
|---|---|---|---|
| ៧. កត្តាភូមិសាស្ត្រ | • ទីតាំងសមស្របសម្រាប់បង្កើតសាលារៀន<br>• បង្កើតអន្តេវាសិកដ្ឋានសិស្ស/គ្រូ | • អាជ្ញាធរ<br>• ការិ.អយក.<br>• មន្ទីរអយក.<br>• ក្រសួងអយក | • ផ្តល់អគារសិក្សាតាមតម្រូវការមូលដ្ឋាន |
| ៨. កត្តាសង្គម | • ពង្រឹងសុជីវធម៌ សីលធម៌ដល់អ្នកពាក់ព័ន្ធ<br>• ជំរុញនិងផ្សព្វផ្សាយទប់ស្កាត់ឱ្យបានទូលាយនូវការជួញដូរគ្រឿងញៀន<br>• ជំរុញសុវត្ថិភាពកុមារ | • គ្រូ<br>• សហគមន៍<br>• អាជ្ញាធរពាក់ព័ន្ធ | • ចេញច្បាប់គតិយុត្តិ (ភ្ជាប់លិខិតបទដ្ឋានសេចក្តីណែនាំនានា<br>• ជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព |
| ៩.កត្តាទីផ្សារពលកម្មក្នុងខេត្តមួយចំនួន (ខេត្តព្រះសីហនុ កែបបន្ទាយមានជ័យ ឧត្តរមានជ័យ ប៉ៃលិន កោះកុង) | • ទប់ស្កាត់ការកែតម្រូវសំបុត្រកំណើតកុមារ (ករណីម្នាក់មានលើសពីមួយ) កិបកេងកម្លាំងពលកម្មកុមារ<br>• ពង្រឹងច្បាប់ការងារតាមសហគ្រាស (កុំឱ្យក្មេងមិនទាន់គ្រប់អាយុចូលធ្វើការ) | • អាជ្ញាធរពាក់ព័ន្ធ | • បង្កើនសាលាមធ្យមសិក្សាបច្ចេកទេសឱ្យបានគ្រប់ខេត្ត<br>• បង្កើនសាលាមធ្យមសិក្សាបច្ចេកទេសឱ្យបានគ្រប់ខេត្ត |

## ២. ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា

| កត្តានាំឱ្យអត្រាបញ្ចប់ការសិក្សាទាប | អន្តរាគមន៍ដើម្បីឱ្យអត្រាបញ្ចប់ការសិក្សាកើនឡើង | តួនាទីការិ.អយក ដើម្បីបង្កើនអត្រាបញ្ចប់ការសិក្សា | ការគាំទ្រពីក្រសួងអយក. |
|---|---|---|---|
| ១.ស្ថិតិ៖ នៅមិនទាន់មានសង្គតិភាពរវាងសាលារៀន ឃុំ សង្កាត់ អាជ្ញាធរស្រុក ការិ.អយក. និងមន្ទីរអយក. នៅឡើយ ដែលធ្វើឱ្យការគណនាសូចនាករមិនឆ្លើយតបនឹងលទ្ធផលជាក់ស្តែង | • ប្រជុំប្រឹក្សាលើការប្រើស្ថិតិនៅស្រុកជាមួយអ្នកពាក់ព័ន្ធ (ឃុំសង្កាត់ ភូមិ ប៉ុស្តិ៍រដ្ឋបាល) ដើម្បីទទួលយកស្ថិតិជាក់ស្តែងនិងមានការឯកភាពគ្នាប្រភពតែ១លើស្ថិតិប្រជាជននិងញែកតាមអាយុជាក់លាក់<br>• ពិភាក្សាជាមួយថ្នាក់មន្ទីរអយក. ក្រសួងអយក. ដើម្បីប្រើប្រាស់ស្ថិតិប្រជាជនតាមជាក់ស្តែងឱ្យឆ្លុះបញ្ចាំងពីលទ្ធផលជាក់លាក់ជាជាងប្រើប្រាស់ស្ថិតិប្រជាជនដែលធ្វើចំណោល | • ខែសីហា រៀងរាល់ឆ្នាំប្រជុំផ្សព្វផ្សាយនាយកនិងកម្រងសាលារៀនអំពីការចុះស្រង់ស្ថិតិកុមារដោយបែងចែកឱ្យរាប់តាមខ្នងផ្ទះ<br>• ចែកទម្រង់របាយការណ៍ អាយុប្រជាជន តាមឆ្នាំជាក់លាក់ (ពី០ឆ្នាំដល់៤៥+) និងបែងចែកភេទ បានចូលរៀន និងមិនបានចូលរៀន<br>• កំណត់កាលបរិច្ឆេទប្រមូលតាមគោលដៅដែលរៀបចំដោយនាយកសាលាដោយមានការឯកភាពពីភូមិនិងឃុំសង្កាត់<br>• បូកសរុបស្ថិតិប្រជាជន និងបញ្ជូនទៅមន្ទីរអយក.<br>• សាលាខ្លះយកតួលេខពីមេភូមិ សាលាខ្លះប្រើថវិកាសម្រាប់ឱ្យគ្រូចុះប្រមូលតាមផ្ទះ | • ផ្តល់ទម្រង់ឧបករណ៍ស្រង់ស្ថិតិប្រជាជនតាមអាយុជាក់លាក់ (គំរូដែលធ្លាប់មាន ICS – International Child Support, ChildFund, ក្រុងសែនមនោរម្យ)<br>• ផ្តល់ថវិកាសម្រាប់ចុះប្រមូលទិន្នន័យ<br>• ប្រើលេខប្រជាជនជាក់ស្តែងរបស់ស្រុកខេត្ត ក្នុងការគណនាសូចនាករផ្សេងៗ |

| | | | |
|---|---|---|---|
| ២.ភូមិសាស្ត្រ៖ ទីតាំងសាលាបឋមនៅឆ្ងាយពីអនុវិទ្យាល័យនិងសាលារាយប៉ាយ ដែលធ្វើឱ្យសិស្សបោះបង់ការសិក្សា | • បង្កើតសាលាអនុវិទ្យាល័យបន្ថែម ដែលមានទីតាំងជិតបឋមសិក្សា<br>• ផ្តល់អន្តេវាសិកដ្ឋានសម្រាប់សិស្ស និងគ្រូស្នាក់នៅ<br>• បង្កើនសាលាដែលមិនគ្រប់កម្រិតឱ្យទៅជាគ្រប់កម្រិតនៅបឋមសិក្សា | • ធ្វើសំណើតម្រូវការបង្កើតអនុវិទ្យាល័យ អគារសិក្សា និង អន្តេវាសិកដ្ឋាន<br>• ពិគ្រោះយោបល់ជាមួយអាជ្ញាធរ ដើម្បីរកទីតាំងសង់អគារសិក្សា | • ផ្តល់អគារសិក្សា និងអន្តេវាសិកដ្ឋាន<br>• ផ្តល់គ្រូបង្រៀន |
| ៣.កត្តាជីវភាព៖ អាណាព្យាបាលខ្លះក្រីក្របង្ខំកូនឱ្យជួយធ្វើការងារផ្ទះ និងរកប្រាក់ចំណូល ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ដែលធ្វើឱ្យសិស្សបោះបង់ | • ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងឱ្យចំទិសដៅ និងទាន់ពេលវេលា<br>• ប្រឹក្សាយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការជួយបង្កើតមុខរបរដល់ប្រជាជនក្រីក្រ<br>• សហការជាមួយអាជ្ញាធរ សហគមន៍ និងអាណាព្យាបាល ជួយជំរុញ និងបង្ករភាពងាយស្រួលឱ្យកូនមករៀនឱ្យបានទៀងទាត់<br>• បង្កើតមូលនិធិសម្រាប់ជួយប្រជាជនក្រីករ | • ចូលរួមពិនិត្យលើដំណើរការនៃការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ<br>• ប្រជុំនិងផ្សព្វផ្សាយដល់អាណាព្យាបាលសិស្សអំពីតម្លៃនៃការអប់រំ<br>• ប្រជុំជាមួយគណៈគ្រប់គ្រងសាលារៀនដើម្បីកំណត់មុខសញ្ញាសិស្សក្រីក្រ និង ប្រឈមបោះបង់ | • បង្កើនចំនួនសិស្សទទួលអាហារូបករណ៍ បង្កើនបរិមាណអាហារូបករណ៍ និងបើកប្រាក់អាហារូបករណ៍ឱ្យទាន់ពេលវេលា |

| | | | |
|---|---|---|---|
| ៤.ចំណាកស្រុក៖ យកកូនទៅតាម ដែលធ្វើឱ្យចំនួនសិស្សជាក់ស្ដែងថយចុះ | • ទប់ស្កាត់ចំណាកស្រុករបស់ប្រជាពលរដ្ឋ<br>• ផ្ដល់ជំនាញវិជ្ជាជីវៈដល់ប្រជាពលរដ្ឋដើម្បីបង្កើតមុខរបរក្នុងស្រុក | • ផ្សព្វផ្សាយពីបញ្ហាប្រឈមនៃចំណាកស្រុក ដូចជាចាញ់បោកគេ កូនរៀនមិនបានរៀនសូត្រ<br>• ចុះប្រមូលទិន្នន័យប្រជាពលរដ្ឋដែលមានតម្រូវការបណ្ដុះបណ្ដាលវិជ្ជាជីវៈ | • ផ្សព្វផ្សាយអំពីបញ្ហាចំណាកស្រុកឱ្យបានទូលំទូលាយ<br>• បង្កើតកម្មវិធី និងថវិកាបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់ប្រជាពលរដ្ឋនៅ ម.ស.ស តាមឃុំសង្កាត់<br>• ផ្ដល់អគារម.ស.ស ឱ្យត្រូវតាមស្ដង់ដារ |
| ៥.បញ្ហាកែសំបុត្រកំណើតរបស់សិស្ស៖ ជនជាតិភាគតិច (កែឈ្មោះដោយខ្លួនឯង) ដែលមិនអនុញ្ញាតឱ្យប្រឡងមធ្យមសិក្សាបឋមភូមិ | • រឹតបន្តឹងការកែសំបុត្រកំណើត | • ពន្យល់ណែនាំអំពីបញ្ហាឬផលប៉ះពាល់នៃការកែសំបុត្រកំណើតដល់សិស្ស មាតាបិតា និងសហគមន៍ | • ចេញសេចក្ដីណែនាំដល់សិស្សជាពិសេសជនជាតិដើមភាគតិចឱ្យបានដឹងអំពីបញ្ហាកែសំបុត្រកំណើត |

| | | | |
|---|---|---|---|
| ៦.សិស្សរៀនយឺត អត់ចេះអាន ត្រួតថ្នាក់នាំឱ្យគាត់ធុញនិងការសិក្សា បណ្ដាលឱ្យបោះបង់ការសិក្សា | • បំប៉នសិស្សរៀនយឺតគ្រប់កម្រិតថ្នាក់ (បឋមសិក្សាលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា) និង (មធ្យមសិក្សាបឋមភូមិលើ មុខវិជ្ជារូបវិទ្យា គណិតវិទ្យា និងភាសាខ្មែរ) | • ជួបជាមួយអាណាព្យាបាលសិស្សដែលរៀនយឺតនិងសហគមន៍ដើម្បីពិភាក្សារកវិធីសាស្ត្របំប៉ន<br>• ជំរុញឱ្យសាលារៀនអនុវត្តសកម្មភាពបំប៉នសិស្សរៀនយឺតទៅតាមផែនការប្រតិបត្តិប្រចាំឆ្នាំ (AOP)<br>• ជំរុញនាយកសាលាឱ្យបង្កើតក្រុមសិស្សជួយសិស្ស | • បង្កើនកញ្ចប់ថវិកាសម្រាប់បំប៉នសិស្សរៀនយឺត |
| ៧.គ្រូមិនបានធ្វើតេស្តវាស់សមត្ថភាពសិស្សដើម្បីជួយគាត់ និងជួបប្រឹក្សាជាមួយឪពុកម្ដាយសិស្ស បណ្ដាលឱ្យសិស្សរៀនយឺត ត្រួតថ្នាក់ និងបោះបង់ | • ជំរុញឱ្យគ្រូធ្វើតេស្តវាស់សមត្ថភាពសិស្សដើមឆ្នាំ ប្រចាំខែឱ្យបានទៀងទាត់<br>• ប្រជុំបង្ហាញលទ្ធផលតេស្តជាមួយអាណាព្យាបាលសិស្សដែលរៀនយឺត | • ជំរុញនាយក និងប្រធានក្រុមបច្ចេកទេសក្នុងការធ្វើសំណួរតេស្តប្រចាំខែនៅតាមសាលារៀនឱ្យមានលក្ខណៈស្តង់ដា<br>• ចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តតេស្ត | • ផ្ដល់គ្រូឧទ្ទេសថ្នាក់ជាតិដើម្បីជួយលើការងារបច្ចេកទេសរៀបចំតេស្តប្រឡងប្រចាំខែនៅតាមសាលាឱ្យត្រូវតាមស្តង់ដា<br>• ឧបត្ថម្ភថវិកាជួយក្រុម DTMT |

| | | | |
|---|---|---|---|
| ៨.សិស្សចូលរៀនលើសអាយុ (៧ ឬ ៨ ឆ្នាំទើបចូលរៀនថ្នាក់ទី១) ដែលធ្វើឱ្យអត្រាបញ្ចប់ការសិក្សាទាប | • ចុះប្រមូលកុមារដែលដល់អាយុឱ្យចូលរៀន | • ជំរុញឱ្យសាលាផ្សព្វផ្សាយតាមភូមិឃុំសង្កាត់ ឱ្យបានជ្រាបពីព័ត៌មានចូលរៀនឱ្យបានទូលំទូលាយ | • ចេញសេចក្តីជូនដំណឹងដល់គ្រប់ក្រសួង ស្ថាប័ននានាឱ្យចូលរួមសហការក្នុងការប្រមូលកុមារចូលរៀន |
| ៩.សិស្សផ្ទេរការសិក្សាពីជនបទទៅប្រជុំជនដែលធ្វើឱ្យការគណនាអត្រាបញ្ចប់ការសិក្សាទាប | • ធ្វើបច្ចុប្បន្នកម្មស្ថិតិប្រជាជននិងសិស្សដែលផ្ទេរការសិក្សា | • ការិយាល័យអយក. ស្រង់ទិន្នន័យសិស្សផ្ទេរតាមសាលាឱ្យបានច្បាស់លាស់ | • កត់ត្រាសិស្សផ្ទេរចេញ ផ្ទេរចូល ទៅក្នុងតារាង ASCF របស់ EMIS ឱ្យបានត្រឹមត្រូវនិងការណែនាំ |
| ១០.ឆាប់រៀបអាពាហ៍ពិពាហ៍និងមានការងារធ្វើ | • ពង្រឹងការអនុវត្តច្បាប់រៀបអាពាហ៍ពិពាហ៍និងច្បាប់ការងារ (រៀនយ៉ាងហោចណាស់ថ្នាក់មូលដ្ឋានថ្នាក់ទី៩) | • ជួយផ្សព្វផ្សាយ ណែនាំដល់សាលារៀនអំពីច្បាប់រៀបអាពាហ៍ពិពាហ៍និងច្បាប់ការងារ | • ផ្សព្វផ្សាយ ណែនាំដល់សាលារៀនអំពីច្បាប់រៀបអាពាហ៍ពិពាហ៍និងច្បាប់ការងារ |
| ១១.កុមារខ្វះអាហារូបត្ថម្ភដែលធ្វើឱ្យចូលរៀនយឺត | • ជំរុញមាតាបិតាឱ្យយកកូនទៅពិនិត្យសុខភាពញឹកញាប់ | • សហការជាមួយប៉ុស្តិ៍សុខភាពភូមិ ឬ មណ្ឌលសុខភាព<br>• ប្រជុំជាមួយគ.ក.ន.ក ដើម្បីផ្សព្វផ្សាយពីសុខមាលភាពរបស់កុមារ | • សហការជាមួយក្រសួងសុខាភិបាលក្នុងការផ្តល់អាហារូបត្ថម្ភដល់កុមារដើម្បីឱ្យចូលរៀនទាន់ពេល |

| | | | |
|---|---|---|---|
| ១២.សិស្សខ្វះអាហារពេលព្រឹក | • ផ្តល់អាហារពេលព្រឹកដល់សិស្សនៅតំបន់ជួបការលំបាក | • ចុះត្រួតពិនិត្យការប្រើប្រាស់អាហារពេលព្រឹក និងគុណភាពស្បៀង<br>• ផ្សព្វផ្សាយដល់សហគមន៍ឱ្យចូលរួមក្នុងការផ្តល់អាហារពេលព្រឹក | • បង្កើនការផ្តល់អាហារពេលព្រឹកឱ្យបានគ្រប់សាលា |
| ១៣.បរិស្ថានសាលា៖ ខ្វះអនាម័យ ខ្វះបន្ទប់ទឹក ដែលធ្វើឱ្យសិស្សបោះបង់ | • កែលម្អបរិស្ថានសាលា | • ជំរុញឱ្យសាលារៀនលើកសំណើតម្រូវការកែលម្អបរិស្ថានសាលា បន្ទប់ទឹក បង្គន់អនាម័យ ទឹកស្អាត | • បង្កើនថវិកាកែលម្អសាលារៀន |

៣. នាយកសាលា

| កត្តានាំឱ្យអត្រាបញ្ចប់ការសិក្សាទាប | អន្តរាគមន៍ដើម្បីឱ្យ អត្រាបញ្ចប់ការសិក្សាកើនឡើង | តួនាទីនាយកដើម្បីបង្កើនអត្រាបញ្ចប់ការសិក្សា | ការគាំទ្រពីក្រសួងអយក. |
|---|---|---|---|
| ១. ការផ្លាស់ទីលំនៅនិងចំណាកស្រុក | • ផ្សព្វផ្សាយក្នុងការប្រជុំជាមួយអាជ្ញាធរ<br>• ផ្តល់អាជីពក្នុងមូលដ្ឋាន | • ផ្សព្វផ្សាយដល់មាតាបិតាសិស្សឱ្យយល់ពីតម្លៃនៃការសិក្សា | • លើកទឹកចិត្តតាមរយៈផ្តល់អាហារូបករណ៍<br>• រៀបចំគន្លងអាជីពក្នុងមូលដ្ឋាន |
| ២.អំពើហិង្សាក្នុងគ្រួសារ | • រាយការណ៍ជូនអាជ្ញាធរមូលដ្ឋាន | • ផ្សព្វផ្សាយអំពីផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ<br>• បញ្ជ្រាបអំពីអំពើហិង្សាក្នុងម៉ោងសិក្សាដល់សិស្ស | • ផ្តល់ឯកសារអំពីអំពើហិង្សា |

| | | | |
|---|---|---|---|
| ៣.បញ្ហាជីវភាពក្រីក្ររបស់សិស្សដែលត្រូវជួយការងារម្ដាយឪពុក | • ស្នើសុំជំនួយពីអ្នកពាក់ព័ន្ធ | • ជំរុញលើកទឹកចិត្ត និងបន្ថែមអាហារូបករណ៍ដល់សិស្ស<br>• កៀរគររកមូលនិធិសម្រាប់សិស្សក្រីក្រ | • ផ្ដល់អាហារូបករណ៍បន្ថែម |
| ៤.ទីតាំងភូមិសាស្ត្រ | • បង្កើតសាលារៀននៅជិតដើម្បីសម្រួលដល់ការសិក្សា<br>• រៀបចំអន្តេវាសិកដ្ឋានសម្រាប់គ្រូ សិស្ស<br>• ផ្ដល់មធ្យោបាយធ្វើដំណើរ<br>• ជួសជុលកែលម្អ និងបង្កើតហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន | • ស្នើសុំបង្កើតអគារសិក្សា អន្តេវាសិកដ្ឋានសម្រាប់គ្រូ សិស្ស និងមធ្យោបាយធ្វើដំណើរដល់សិស្ស<br>• សម្រួលឯកសារផ្ទេរការសិក្សារបស់សិស្ស | • សម្រួលការរៀបចំឯកសារសិស្សផ្ទេរមានភាពងាយស្រួលដល់សិស្ស (សម្រាប់សិស្សផ្ទេរឆ្លងខេត្ត) |
| ៥.ស្ថិតិនៅអាជ្ញាធរមូលដ្ឋាននិងសាលារៀនមិនទាន់ច្បាស់លាស់ | • ស្នើសុំដល់អាជ្ញាធរប្រមូលទិន្នន័យប្រជាពលរដ្ឋឱ្យបានច្បាស់លាស់ | • ចុះប្រមូលទិន្នន័យជាក់ស្ដែងពីសហគមន៍ និងធ្វើផែនទីខ្នងផ្ទះ និងផែនទីសិក្សា | • សហការជាមួយក្រសួងមហាផ្ទៃ អំពីបញ្ហាស្ថិតិ សម្រាប់ថ្នាក់មូលដ្ឋាន |
| ៦.សិស្សរៀនយឺតពីបឋមសិក្សា | • ស្វែងរកថវិកាសម្រាប់បំប៉នសិស្សរៀនយឺត | • បំប៉នសិស្សរៀនយឺត និងធ្វើតេស្តឡើងថ្នាក់<br>• ពង្រីកកម្មវិធីមិត្តអប់រំមិត្តតាមរយៈ ក្លឹបសិក្សាឱ្យបានទូលំទូលាយ | • បង្កើនថវិកាបំប៉នសិស្សរៀនយឺតបន្ថែម |
| ៧.បញ្ហាភាសាតាមតំបន់ជនជាតិដើមភាគតិច | • ផ្សព្វផ្សាយដល់អាជ្ញាធរដើម្បីស្វែងរកគ្រូជនជាតិដើមភាគតិច | • បន្ថែមគ្រូពីរភាសាសម្រាប់សាលាខ្វះគ្រូពីរភាសា | • បណ្ដុះបណ្ដាលគ្រូនៅក្នុងមូលដ្ឋានជនជាតិដើមភាគតិច |

| | | | |
|---|---|---|---|
| ៨.បញ្ហាកង្វះគ្រូ | • ជ្រើសរើសគ្រូបន្ថែម និងប្រើប្រាស់គ្រូកិច្ចសន្យា<br>• ប្រើប្រាស់គ្រូពីរវេន និងថ្នាក់គួប (សម្រាប់បឋមសិក្សា) | • បន្ថែមគ្រូនិងប្រើប្រាស់គ្រូដែលខុសឯកទេស<br>• ជ្រើសរើសគ្រូកិច្ចសន្យា (សម្រាប់បឋមសិក្សា)<br>• ប្រើប្រាស់គ្រូពីរវេន និងថ្នាក់គួប (សម្រាប់បឋមសិក្សា) | • បណ្តុះបណ្តាលគ្រូ និងពង្រាយគ្រូឱ្យបានទៅតាមតម្រូវការ<br>• បង្កើនថវិកាលើកទឹកចិត្តគ្រូនៅតំបន់ដាច់ស្រយាល និងជួបការលំបាកឱ្យបាន៥០%នៃប្រាក់បៀវត្សន៍គោល |
| ៩.បញ្ហាសុខភាពសិស្សក្នុងតំបន់ | • ផ្សព្វផ្សាយអំពីការថែទាំសុខភាពដល់អ្នកពាក់ព័ន្ធជាប្រចាំ<br>• សហការជាមួយអាជ្ញាធរដ្ឋាន មណ្ឌលសុខភាព និងកាំកុងត្រូលដើម្បីត្រួតពិនិត្យលើការលក់ចំណីអាហារក្នុងសហគមន៍ និងសាលារៀន | • ផ្សព្វផ្សាយពីការថែទាំសុខភាព<br>• សហការជាមួយមណ្ឌលសុខភាព<br>• បង្កើតប្រអប់សង្គ្រោះបឋមឱ្យបានគ្រប់សាលារៀន<br>• គ្រប់គ្រងលើការលក់ដូរក្នុងសាលា និងធ្វើកិច្ចសន្យាជាមួយអ្នកលក់ | • ចេញសេចក្តីណែនាំស្តីពីការគ្រប់គ្រងការលក់ដូរចំណីអាហារតាមសាលារៀន<br>• សហការជាមួយក្រសួងពាក់ព័ន្ធដើម្បីទប់ស្កាត់ការនាំចូលចំណីអាហារគ្មានគុណភាព |

| | | | |
|---|---|---|---|
| ១០.បញ្ហាអសន្តិសុខក្នុងមូលដ្ឋាន | • ពង្រឹងការអនុវត្តភូមិឃុំមានសុវត្ថិភាព | • រាយការណ៍ និងសហការជាមួយអាជ្ញាធរមូលដ្ឋាន<br>• ផ្សព្វផ្សាយណែនាំដល់សិស្សានុសិស្ស និងពង្រឹងបទបញ្ជាផ្ទៃក្នុងសាលារៀន<br>• បង្កើននិងពង្រឹងសកម្មភាពក្រុមប្រឹក្សាក្នុងសាលា<br>• សុំលេខទូរស័ព្ទអ្នកពាក់ព័ន្ធសិស្ស | • សហការជាមួយក្រសួងមហាផ្ទៃ |
| ១១.បរិយាកាសសាលារៀនមិនទាន់ជាទីមេត្រី | • កៀរគរថវិកាសប្បុរសជនក្នុងមូលដ្ឋាន និងដៃគូពាក់ព័ន្ធមកអភិវឌ្ឍសាលារៀនបន្ថែម | • ពង្រឹងការអនុវត្តតាមគោលការណ៍សាលាកុមារមេត្រី<br>• កែលម្អបរិស្ថានទាំងក្នុងនិងក្រៅសាលា<br>• ពង្រឹងគុណភាពនៃការសិក្សា<br>• កៀរគរថវិកាសប្បុរសជនក្នុងមូលដ្ឋាននិងដៃគូពាក់ព័ន្ធដើម្បីអភិវឌ្ឍសាលាបន្ថែម | • បង្កើនថវិកាទ្រទ្រង់សាលា<br>• វាយតម្លៃនិងលើកទឹកចិត្តដល់សាលាតាមបណ្តាខេត្ត |
| ១២.ឪពុកម្តាយមួយចំនួនមិនឱ្យតម្លៃលើការសិក្សា | • សហការជាមួយអាជ្ញាធរជួយអប់រំប្រជាពលរដ្ឋលើការសិក្សារបស់សិស្ស | • ផ្សព្វផ្សាយនិងជំរុញលើកទឹកចិត្តនិងទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស | • បង្កើតច្បាប់កាតព្វកិច្ចសិក្សា |

| | | | |
|---|---|---|---|
| ១៣.តវិយាបថគ្រូ និងក្រមសីលធម៌ | • រាយការណ៍ជូនថ្នាក់ដឹកនាំតាមឋានានុក្រម<br>• ណែនាំ និងអប់រំ | • ណែនាំ អប់រំគ្រូអំពីក្រមសីលធម៌វិជ្ជាជីវៈ និងធ្វើកិច្ចសន្យា<br>• ពង្រឹងការអនុវត្តអនុក្រឹត្យលេខ២៥៦ | • ផ្តល់ស្វ័យភាពអំណាចដល់នាយកសាលាក្នុងការអនុវត្តការងារ |
| ១៤.សមត្ថភាពរបស់គណៈគ្រប់គ្រងសាលានៅមានកម្រិត | • បណ្តុះបណ្តាលបន្ថែម | • ពង្រឹងអភិវឌ្ឍសមត្ថភាពបន្ថែមលើការងារគ្រប់គ្រង និងដឹកនាំ | • បើកវគ្គបំប៉ននាយកលើការងារគ្រប់គ្រង និងដឹកនាំ<br>• បង្កើនប្រាក់មុខងារសម្រាប់នាយកសាលាឱ្យបានសមស្រប |
| ១៥.សិស្សមិនបានឆ្លងកាត់មត្តេយ្យសិក្សា | • ជ្រើសរើសគ្រូក្នុងសហគមន៍ | • បង្កើតមត្តេយ្យសហគមន៍ក្នុងមូលដ្ឋាន | • បណ្តុះបណ្តាលគ្រូ |
| ១៦.បញ្ហាប្រពៃណីតាមមូលដ្ឋាន | • សហការ អប់រំ និង ផ្សព្វផ្សាយ | • អប់រំ និងផ្សព្វផ្សាយ | • សហការជាមួយក្រសួងពាក់ព័ន្ធ |
| ១៧.សិស្សចូលរៀនយឺត (លើសអាយុ) | • សហការជាមួយអាជ្ញាធរក្នុងការប្រមូលសិស្សគ្រប់អាយុចូលរៀន<br>• ស្វែងរកយន្តការទប់ស្កាត់សិស្សបោះបង់ | • ផ្សព្វផ្សាយពីច្បាប់អប់រំ | • ផ្សព្វផ្សាយ<br>• បង្កើតច្បាប់កាតព្វកិច្ចសិក្សា |